# ដំណឹងល្អដ៏ពិត

## The True Gospel

*លោក ឈាង បូរ៉ា, លោក ញ៉ាន សំអាត, លោក ម៉ៃឃើល ឡរ៉េនស៍,*
*លោក ស៊ុន សុខា, លោក ហ្វ័ររេស ម៉ាកហ្វៃល និងលោក លឹម ម៉ៅ*

ផ្លូវពិត
plovpit.com

*ដំណឹងល្អដ៏ពិត*

*The True Gospel*

រក្សាសិទ្ធិគ្រប់បែបយ៉ាង ©២០២៦

ផលិតដោយ៖ អង្គការសកម្មភាពកម្ពុជា resources@actioncambodia.org

ប្រអប់សំបុត្រលេខ ១១៧៨ រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា

បកប្រែដោយ៖ លោក ឈាង បូរ៉ា, លោក ស៊ូ ទិត្យ, និងលោក ឯក សត្យា

ពិនិត្យផ្ទៀងផ្ទាត់ដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ហុង សម្អស, លោក ឡង់ គីមឡុង, លោក ស៊ូ ទិត្យ, លោក ឯក សត្យា និងលោក ជា ពន្លឺ

សូមថ្លែងអំណរគុណចំពោះ៖ លោកស្រី ឡូញ ស្រីរ័ត្ន, និងលោកស្រី ថាវ ប៊ុនរី

យើងខ្ញុំបានរក្សាអក្ខរាវិរុទ្ធនៃសម្រង់ខគម្ពីរដែលមាននៅក្នុងព្រះគម្ពីរបកប្រែចាស់ រក្សាសិទ្ធិ©ឆ្នាំ១៩៥៤ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរសញ្ញាថ្មី កែសម្រួល រក្សាសិទ្ធិ ©ឆ្នាំ២០១៤, ២០១៦ (គកស) ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរដ៏វិសុទ្ធជាភាសាខ្មែរបច្ចុប្បន្ន រក្សាសិទ្ធិ ©ឆ្នាំ២០០៥ (គខប) ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ រក្សាសិទ្ធិ ©ឆ្នាំ២០១៤ (គគខ) ដោយព័ន្ធកិច្ចព្រះបន្ទូលនៃជីវិត,ក៏ដូចជាអសាធារណនាមមួយចំនួន ប៉ុន្តែសំណេរនៅក្នុងអត្ថបទទាំងមូលយើងខ្ញុំបានខិតខំព្យាយាមគោរពតាមអក្ខរាវិរុទ្ធនៃវចនានុក្រមខ្មែររបស់សម្ដេចសង្ឃរាជ ជួន ណាត។

អ្នករចនាអត្ថបទភាសាខ្មែរ៖ លោក វ៉េល ណាថាន និងលោក ខែម បូឡុង

For ordering information please visit:

ប្រសិនបើលោកអ្នកចង់ជាវសៀវភៅនេះ សូមចូលទៅកាន់គេហទំព័រ៖

plovpitshop.com

បោះពុម្ពលើកទី១ ចំនួន ៣.០០០ក្បាល ២០២៦ នៃគ.ស.

ISBN-978-9924-566-34-2

# មាតិកា


សេចក្តីផ្តើម . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៥

តើអ្វីទៅជាចំណុចស្នូលនៃដំណឹងល្អដ៏ពិត? . . . . . . . . . . . . . . . . . . . . . . . . . . . .៧

អ្នកបម្រើដំណឹងល្អ. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ២៧

ចូរដាស់តឿន–កុំលក់ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៤១

ការបង្កើតសិស្ស–មិនមែនការទទួលបានការសម្រេចចិត្តទេ . . . . . . . . . . . . . . . . . .៥៩

ថ្មី–មិនមែនល្អទេ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៧៥

គ្រោះថ្នាក់៖ បើក្រុមជំនុំគ្មានគោលលទ្ធិត្រឹមត្រូវ និងមិនស្គាល់ព្រះបន្ទូលពិតរបស់ព្រះ . . ៩៣

ចូរឲ្យយើងទាំងអស់គ្នាការពារដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទពី Syncretism! . . . . . ១១៥

សេចក្តីស្រឡាញ់ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .១៣១

# សេចក្តីផ្តើម

នៅក្នុងសម័យកាលដែលមានភាពច្របូកច្របល់ និងការយល់ច្រឡំជាច្រើនអំពីសារៈសំខាន់នៃជំនឿ គ្រីស្ទបរិស័ទជាច្រើនបានបង្វែរអារម្មណ៍ចេញពីខ្លឹមសារពិតនៃដំណឹងល្អ។ មនុស្សមួយចំនួនបានកាត់បន្ថយអត្ថន័យនៃដំណឹងល្អដោយផ្តោតតែលើ «ព្រះគុណនៃភាពចម្រុងចម្រើន» ការមានបាន និងជោគជ័យខាងសាច់ឈាម តែបែរជាមើលរំលងសេចក្តីបង្រៀនដ៏សំខាន់អំពីអំពើបាប ការប្រែចិត្ត ភាពបរិសុទ្ធ និងការលះបង់ទៅវិញ។ តើអ្វីទៅជាចំណុចស្នូល និងជាភាពទាក់ទាញពិតប្រាកដនៃដំណឹងល្អ?

ចំណុចស្នូលនៃដំណឹងល្អមិនមែនជាការស្វែងរកផលប្រយោជន៍លោកីយ៍នោះទេ ប៉ុន្តែគឺផ្តោតលើអង្គព្រះយេស៊ូវគ្រីស្ទផ្ទាល់។ ទ្រង់ជាព្រះដ៏ខ្ពស់បំផុតដែលបានបន្ទាបអង្គទ្រង់ យាងចុះមកកើតជាមនុស្ស រងទុក្ខ បន្ទាបខ្លួនជាបាវបម្រើ និងសុគតនៅលើឈើឆ្កាង ដើម្បីជួយសង្គ្រោះយើងឲ្យរួចផុតពីអំពើបាប និងការថ្កោលទោស។ ដូចដែលមានចែងនៅក្នុងកណ្ឌគម្ពីរ ម៉ាថាយ ១:២១ ថា៖ «បុត្រនោះនឹងជួយសង្គ្រោះរាស្ត្រទ្រង់ ឲ្យរួចពីបាប»។ ដំណឹងល្អដ៏ពិត គឺជាការប្រកាសអំពី ការសុគត ការបញ្ចុះក្នុងផ្នូរ និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ យោងតាមព្រះគម្ពីរ (១កូរិនថូស ១៥:៣-៤)។

សេចក្តីសង្គ្រោះនេះ គឺជាអំណោយទានទទេៗពីព្រះគុណនៃព្រះជាម្ចាស់ ដែលយើងទទួលបានតាមរយៈ «សេចក្តីជំនឿ» លើព្រះយេស៊ូវតែមួយអង្គគត់ ដោយមិនមែនកើតចេញពីកិច្ចការល្អ ឬសមត្ថភាពផ្ទាល់ខ្លួនរបស់យើងឡើយ។ នៅពេលដែល

ព្រះវិញ្ញាណបរិសុទ្ធធ្វើការក្នុងចិត្តរបស់យើង នាំឲ្យយើងមើលឃើញពីទម្ងន់នៃអំពើបាប ហើយប្រែចិត្តឈានទៅរកការជឿសម្លឹងមើលព្រះគ្រីស្ទ នោះព្រះជាម្ចាស់នឹងរាប់យើងជា «មនុស្សសុចរិត»។

លើសពីនេះ ដំណើរនៃសេចក្ដីសង្គ្រោះមិនបានបញ្ចប់ត្រឹមការរាប់ជាសុចរិតនោះទេ ប៉ុន្តែវាជាការចាប់ផ្ដើមនៃដំណើរជីវិតក្នុងការ «ញែកជាបរិសុទ្ធ»។ ព្រះជាម្ចាស់បានត្រាស់ហៅយើងឲ្យផ្លាស់ប្រែគំនិតជាថ្មីតាមរយៈព្រះបន្ទូលរបស់ទ្រង់ ដើម្បីរស់នៅក្នុងជីវិតដែលស្ដាប់បង្គាប់ ស្រឡាញ់ព្រះជាម្ចាស់អស់ពីចិត្ត និងស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង។ ការស្រឡាញ់នេះស្ដែងចេញតាមរយៈការធ្វើសកម្មភាព គឺការចេញទៅបង្កើតសិស្ស និងប្រកាសដំណឹងល្អដ៏ពិតនេះទៅកាន់មនុស្សជុំវិញខ្លួន។

នៅក្នុងសៀវភៅនេះ យើងនឹងសិក្សាស្រាវជ្រាវយ៉ាងស៊ីជម្រៅអំពីអត្ថន័យនៃដំណឹងល្អដ៏ពិត ដោយឆ្លើយតបទៅនឹងសំណួរគន្លឹះថា៖ «តើអ្វីទៅជាដំណឹងល្អដ៏ពិត ហើយតើអ្វីខ្លះជាចំណុចខានមិនបានដែលយើងត្រូវជឿ ដើម្បីទទួលបានសេចក្ដីសង្គ្រោះ?» សូមឲ្យការសិក្សានេះដឹកនាំចិត្តរបស់យើងឲ្យកាន់តែស្គាល់ ស្រឡាញ់ និងប្រកាសអំពីព្រះយេស៊ូវគ្រីស្ទ—ដែលជាចំណុចស្នូលនៃដំណឹងល្អដ៏ពិត—នៅក្នុងជីវិតប្រចាំថ្ងៃរបស់យើង។

*— លោក ឈាង បូរ៉ា*

*(Chheang Bora)*

# តើអ្វីទៅជាចំណុចស្នូលនៃដំណឹងល្អដ៏ពិត ?

និពន្ធដោយៈ លោក ឈាង បូរ៉ា

តើអ្វីទៅជាភាពទាក់ទាញនៃដំណឹងល្អដ៏ពិត? នេះគឺជាសំណួរដែលយើងនឹងព្យាយាមឆ្លើយនៅក្នុងជំពូកនេះ។ ចម្លើយមួយចំនួនផ្តោតទៅលើភាពចម្រុងចម្រើន ការមានបាន ភាពជោគជ័យ។ តើបងប្អូនធ្លាប់ឮគេនិយាយថា បើជឿព្រះយេស៊ូវ នោះនឹងក្លាយជាអ្នកមានដែរឬទេ? ឬក៏គេបានបន្ទាបអត្ថន័យនៃចំណុចស្នូលនៃដំណឹងល្អដ៏ពិតដល់ថ្នាក់ថា គេមិនបានបង្រៀនអំពីអំពើបាប ការថ្កោលទោស អំពីស្ថាននរក ការកែប្រែចិត្ត ភាពបរិសុទ្ធ ព្រះគម្ពីរ ឬក៏ការអធិស្ឋាន។ល។ តើនេះជាដំណឹងល្អដ៏ពិតដែលព្រះអង្គផ្ទាល់បានយាងចេញពីស្ថានសួគ៌មកយកកំណើតជាមនុស្ស បានបន្ទាបអង្គទ្រង់ផ្ទាល់ក្នុងនាមជាបាវបម្រើ ដើម្បីបំពេញនូវតម្រូវការរបស់អ្នកដទៃដែរមែនឬ? តើទ្រង់មិនបានយាងមក ដើម្បីបើកសម្តែងព័ន្ធកិច្ចរបស់ទ្រង់រហូតដល់ថ្នាក់ថា ទ្រង់ត្រូវសុគតមែនឬ? បងប្អូន ភាពទាក់ទាញគឺគួរតែត្រង់ថា ព្រះអង្គបានយាងចុះមក ហើយបានសម្រេចការទាំងអស់នោះ ដើម្បីសង្គ្រោះយើង។ នោះឯងគឺជាសេចក្តីសន្យានៃសាររបស់ព្រះជាម្ចាស់ដែលទ្រង់បានលើកឡើង ចាប់តាំងពីពេលប្រកាសថាៈ “ហើយអ្នកត្រូវថ្វាយព្រះនាមថា “យេស៊ូវ” ព្រោះបុត្រនោះនឹងជួយសង្គ្រោះរាស្ត្រទ្រង់ ឲ្យរួចពីបាប” (ម៉ាថាយ ១:២១, លោក ដេវីដ ម៉ាធីស (David

Mathis))។ ពិតណាស់ ព្រះអង្គបានយាងមក ដើម្បីសុគត បង្ហាញសេចក្តីស្រឡាញ់របស់ទ្រង់មកដល់យើង ដើម្បីបំពេញសេចក្តីទំនាយ និងបម្រើ។ល។ ប៉ុន្តែ តាមរយៈការទាំងនោះឯង គឺទ្រង់បានយាងមក ដើម្បីសម្រេចសេចក្តីសង្គ្រោះដល់យើង។

តើយើងត្រូវធ្វើដូចម្តេច ដើម្បីឲ្យទទួលបានសេចក្តីសង្គ្រោះមួយនេះ? ឬក៏ថា តើអ្វីទៅជាដំណឹងល្អដ៏ពិត? កណ្ឌគម្ពីរ យ៉ូហាន ២០:៣០-៣១ បានចែងថា “ព្រះយេស៊ូវក៏ធ្វើទីសម្គាល់ជាច្រើនទៀត នៅមុខពួកសិស្សទ្រង់ ដែលមិនបានចែងទុកក្នុងសៀវភៅនេះទេ បានចែងទុកតែប៉ុណ្ណេះ ដើម្បីឲ្យអ្នករាល់គ្នាបានជឿថា ព្រះយេស៊ូវជាព្រះគ្រីស្ទ គឺជាព្រះរាជបុត្រានៃព្រះពិត ហើយឲ្យអ្នករាល់គ្នាបានជីវិត ដោយសារព្រះនាមទ្រង់ ដោយមានសេចក្តីជំនឿ”។

បងប្អូន ចម្លើយដ៏ខ្លីលើសំណួរថា *តើអ្វីទៅជាដំណឹងល្អដ៏ពិត?* គឺថា ព្រះយេស៊ូវគ្រីស្ទផ្ទាល់គឺជាដំណឹងល្អដ៏ពិត។ នេះហើយជាអត្ថន័យនៃដំណឹងល្អដ៏ពិត៖ គឺថា ព្រះអង្គបានយាងមក ដើម្បីសង្គ្រោះយើងចេញពីអំពើបាប ខណៈពេលដែលយើងមិនចង់ឲ្យព្រះអង្គសង្គ្រោះយើង។ យើងអាចទទួលបានសេចក្តីសង្គ្រោះនោះ តាមរយៈជំនឿ ឬក៏ការជឿលើព្រះយេស៊ូវ។ ព្រះអង្គយាងចុះមករំដោះយើងចេញពីអំពើបាប និងដើម្បីស្តារយើងទៅកាន់អំណរចុងក្រោយ ដែលទ្រង់បានបង្កើតយើងមក៖ គឺដើម្បីឲ្យស្គាល់ទ្រង់ ហើយឲ្យមានអំណរក្នុងទ្រង់។ ព្រះអង្គបានយាងមក ដើម្បីផ្សះផ្សាយើង “ឲ្យជានឹងអង្គទ្រង់” (កូឡូស ១:២០)។ ព្រះអង្គមិនបានយាងមក ដើម្បីជំរុញឲ្យយើងផ្តោតទៅលើភាពចម្រុងចម្រើន ឲ្យយើងយកទ្រព្យសម្បត្តិជាគោលនោះទេ ប៉ុន្តែ “ព្រះគ្រីស្ទទ្រង់បានរងទុក្ខម្តង ដោយព្រោះបាបដែរ គឺជាព្រះដ៏សុចរិតទ្រង់រងទុក្ខជំនួសមនុស្សទុច្ចរិត ដើម្បីនឹងនាំយើងរាល់គ្នាទៅដល់ព្រះ” (១ពេត្រុស ៣:១៨, លោក ដេវីដ ម៉ាធីស (David Mathis))។

បងប្អូន! តើយើងត្រូវធ្វើដូចម្តេច ដើម្បីឲ្យអាចទទួលបានដំណឹងល្អដ៏ពិត ឬក៏សេចក្តីសង្គ្រោះនេះ ជាពិសេសខណៈពេលដែលយើងកំពុងតែរស់នៅក្នុងសម័យ

កាលដែលមានពេញទៅដោយភាពច្របូកច្របល់នៃដំណឹងល្អ? ចម្លើយគឺថា៖ «បងប្អូនគ្រាន់តែជឿលើព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ» (លោកបណ្ឌិត ចន ម៉ាកអាធើរ (John MacArthur), ១៥២) ដើម្បីឲ្យបងប្អូនអាចទទួលជឿបាន ជាដំបូងបងប្អូនត្រូវតែឮដំណឹងល្អនោះសិន។

*ដូច្នេះ សំណួរសួរថា៖ តើត្រូវឲ្យឮការប្រកាសបែបម៉េច?*

ដោយលើកឡើងនៅសម្រង់សម្ដីរបស់សាវ័ក ប៉ុល លោកបណ្ឌិត វីលៀម វ៉ានណើរ (William Varner), ដែលជាសាស្ត្រាចារ្យព្រះគម្ពីរម្នាក់នៅឯមហាវិទ្យាល័យ (The Master’s College) ហើយក៏ធ្លាប់ជាគ្រូបង្រៀនម្នាក់របស់ខ្ញុំ គាត់បានលើកឡើងថា៖ ព្រះគ្រីស្ទបានសុគតជំនួសអំពើបាបរបស់យើងយោងតាមបទគម្ពីរ ហើយថាព្រះអង្គបានទទួលការបញ្ចុះក្នុងផ្នូរ និងថាព្រះអង្គបានមានព្រះជន្មរស់ឡើងវិញនៅថ្ងៃទី៣ យោងតាមបទគម្ពីរ (១កូរិនថូស ១៥:៣-៤)។ ឃ្លាថា «តាមបទគម្ពីរ» សំដៅទៅលើព្រះគម្ពីរសញ្ញាចាស់។ ឧទាហរណ៍៖ លោកុប្បត្តិ ៣:១៥ ដែលទេវវិទូហៅខគម្ពីរនេះថា «ជាការប្រកាសដំណឹងល្អមុនគេបង្អស់»—គឺជាការប្រាប់ដំណឹងល្អជាដំបូងគេ—នៅក្នុងខគម្ពីរនេះ ព្រះ «បានសន្យាថា ទ្រង់នឹងចាត់ព្រះប្រោសលោះឲ្យមកសង្គ្រោះរាស្ត្ររបស់ទ្រង់» (Riddlebarger, ៥៣)។

ហោរា អេសាយ បានសរសេរយ៉ាងក្បោះក្បាយអំពីរបៀបដែលព្រះប្រោសលោះនេះនឹងរងទុក្ខ ហើយសុគតជំនួសអំពើបាបយើង (អេសាយ ៥៣)។ ខណៈពេលដែលគាត់កំពុងតែគេចវេះចេញពីការស្ដីបន្ទោសរបស់មិត្តភក្តិគាត់ គឺលោក យ៉ូប បានមានប្រសាសន៍ថា «ប៉ុន្តែ ឯខ្ញុំ ខ្ញុំដឹងថាអ្នកដែលលោះខ្ញុំទ្រង់មានព្រះជន្មរស់នៅ» (យ៉ូប ១៩:២៥)។ បងប្អូន ព្រះយេស៊ូវគឺជាព្រះប្រោសលោះរបស់យើង ហើយប្រាកដណាស់ ព្រះអង្គពិតជាមានព្រះជន្មរស់ឡើងវិញមែន មិនថាគេបានវាយដែកគោលលើព្រះហស្ត និងព្រះបាទរបស់ព្រះអង្គនោះទេ (ទំនុកតម្កើង ២២:១៦)។ ព្រះអង្គបានសន្យាថា ទ្រង់នឹងយាងមក ដើម្បីសង្គ្រោះយើង ជាច្រើនឆ្នាំមុនការនោះបាន

កើតឡើងទៅទៀត។ យើងត្រូវរម្លឹកអំពីការដែលព្រះអង្គបានសន្យា និងអំពីការដែលព្រះអង្គបានបំពេញសេចក្តីសន្យានោះ គ្រប់ពេលវេលា។

លោកគ្រូ ម៉ាធិន លូសើរ (Martin Luther) ដែលជាអ្នកកំណែទម្រង់ម្នាក់ បានមានប្រសាសន៍ថា «យើងត្រូវតែឮដំណឹងល្អជារៀងរាល់ថ្ងៃ ព្រោះយើងភ្លេចជារៀងរាល់ថ្ងៃ»។ ដោយសារនេះជាអ្វីដែលជាអត្ថន័យចម្បងនៃការដែលព្រះអង្គបានយាងមក ដូច្នេះសំណួរដែលខ្ញុំនឹងព្យាយាមឆ្លើយនៅពេលនេះគឺថា «តើអ្វីទៅជាដំណឹងល្អដ៏ពិត ហើយថាតើយើងចាំបាច់ត្រូវតែជឿលើអ្វី ដើម្បីឲ្យអាចទទួលបានសេចក្តីសង្គ្រោះ?»។ ចម្លើយដ៏សាមញ្ញលើសំណួរហ្នឹងគឺថា យើងត្រូវជឿលើ ការសុគត ការបញ្ចុះក្នុងផ្នូរ និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវគឺជាដំណឹងល្អដ៏ពិត។ បងប្អូនគ្រាន់តែចាំបាច់ត្រូវជឿលើព្រះអង្គតែមួយអង្គគត់ ដើម្បីឲ្យទទួលបានសេចក្តីសង្គ្រោះ។ នេះជាប្រធានបទស្នូលរបស់យើង ដែលខ្ញុំចង់ចែកចាយជាមួយនឹងបងប្អូននៅពេលនេះ។ ប្រសិនបើបងប្អូនអាចចងចាំតែប៉ុណ្ណោះក៏គ្រប់គ្រាន់ហើយ។

ប្រសិនបើព្រះយេស៊ូវមិនបានសុគតទេ នោះក៏នឹងមិនមានការបញ្ចុះក្នុងផ្នូរ ហើយប្រសិនបើមិនមានការបញ្ចុះក្នុងផ្នូរ នោះក៏នឹងមិនមានការមានព្រះជន្មរស់ឡើងវិញផងដែរ ហើយប្រសិនបើមិនមានការមានព្រះជន្មរស់ឡើងវិញទេ នោះអ្វីដែលយើងបានឮក៏ជារឿងឥតប្រយោជន៍ ហើយជំនឿរបស់យើងក៏ជាការឥតបានការផងដែរ «នោះយើងវេទនា លើសជាងមនុស្សទាំងអស់ទៅទៀត» (១កូរិនថូស ១៥:១៩)។ លោក ចាស្ទីន ឡូណាស (Justin Lonas) ដែលជាអ្នកកែសម្រួលច្បងសម្រាប់ក្រុម Pulpit Helps បានសរសេរដូចតទៅ ទាក់ទងទៅនឹងការមានព្រះជន្មរស់ឡើងវិញ «ការមានព្រះជន្មរស់ឡើងវិញគឺជាទង្វើនៃមូលដ្ឋានគ្រឹះដែលផ្តល់ឲ្យនៅអត្ថន័យដ៏ពេញ លើអ្វីៗដែលមានពីមុនហ្នឹង» (៦)។

បន្ទាប់ពីបងប្អូនបានឮការប្រកាសដំណឹងល្អ ឥឡូវនេះ បងប្អូនឈានដល់ផ្លូវបែកជាពីរ គឺការមានជម្រើសថា ទទួលជឿ ឬក៏មិនជឿ ហើយជម្រើសនោះក៏ជាការ

បង្ហាញអំពីអធិបតេយ្យភាពរបស់ព្រះលើព្រលឹងរបស់បងប្អូនផងដែរ (Stevens, ៣៨៤)។ ដាច់ខាត បងប្អូនត្រូវតែយល់ថា សេចក្តីសង្គ្រោះរបស់យើងគឺជាកម្មសិទ្ធិរបស់ព្រះគ្រីស្ទ (Berkouwer, ២៩) បងប្អូនមិនមានតួនាទីអ្វីក្នុងការទទួលបានការសង្គ្រោះខ្លួនចេញពីស្ថាននរកនោះទេ។

ព្រះអង្គបានត្រៀមទុកជាមុនក្នុងការសង្គ្រោះយើង តាំងពីមុនការចាក់គ្រឹះនៃពិភពលោកនេះទៅទៀត។ “ដោយទ្រង់បានតម្រូវយើងទុកជាមុន តាមតម្រិះសម្រេចរបស់ព្រះ ដែលទ្រង់ធ្វើគ្រប់ការទាំងអស់ តាមដែលគាប់ព្រះហឫទ័យទ្រង់” (អេភេសូរ ១:១១)។ លោកបណ្ឌិត ចន ម៉ាកអាធើរ (John MacArthur) បានសរសេរថា “ព្រះជាម្ចាស់តែងតែជាអង្គដែលផ្តើមការផ្សះផ្សាគ្នាឡើងវិញ” (១០៤)។

ឃ្លា “បងប្អូនមិនមានតួនាទីអ្វី” មិនមែនមានន័យថា បងប្អូនមិនធ្វើអ្វីសោះនោះទេ។ ពិតណាស់ ក្នុងអត្ថន័យមួយគឺថា ដើម្បីឲ្យបងប្អូនអាចឈានទៅដល់កម្រិតដែលបងប្អូនអាចមានជម្រើសទទួលជឿបាន  ទាំងអស់នោះគឺជាទង្វើដែលព្រះជាម្ចាស់សម្រេចឡើង ប៉ុន្តែទោះជាយ៉ាងណាក៏ដោយគឺយើងផ្ទាល់នេះឯងដែលត្រូវតែបើកចិត្តទទួលជឿ។

តើយើងត្រូវទទួលជឿលើអ្វី? គោលជំនឿពួកសារ៉េកបានលើកឡើងថា “ដាច់ខាតបងប្អូនត្រូវតែទទួលជឿលើព្រះវរបិតា ព្រះវិញ្ញាណបរិសុទ្ធ និងការដែលព្រះយេស៊ូវជាប់ឆ្កាង ការសុគត ការបញ្ចុះក្នុងផ្នូរ ការមានព្រះជន្មរស់ឡើងវិញ និងការដែលព្រះអង្គយាងទៅកាន់ស្ថានសួគ៌វិញ” (Reformed.org)។

បងប្អូនទំនងជាងឿងឆ្ងល់ថា “ចុះចំណែកឯកណ្ឌគម្ពីរ រ៉ូម ១០:៩-១០ ដែលមានចែងដូចតទៅថា “បើមាត់អ្នកនឹងទទួលថ្លែងប្រាប់ពីព្រះអម្ចាស់យេស៊ូវ ហើយអ្នកជឿក្នុងចិត្តថា ព្រះបានប្រោសឲ្យទ្រង់រស់ពីស្លាប់ឡើងវិញ នោះអ្នកនឹងបានសង្គ្រោះពិត ដ្បិតយើងបានសុចរិត ដោយមានចិត្តជឿ ហើយក៏បានសង្គ្រោះដោយមាត់ទទួលថ្លែង

ប្រាប់”។ តើចំណុចទាំងនេះមានអ្វីទាក់ទងជាមួយនឹងព្រះវិញ្ញាណបរិសុទ្ធ ការជាប់ឆ្នាង ឬក៏ការយាងទៅកាន់ស្ថានសួគ៌វិញ?»។

ដាច់ខាត! បងប្អូនត្រូវតែយល់ថា ការទទួលបានសេចក្តីសង្គ្រោះគឺមិនមែនជាអ្វីដែលបងប្អូនធ្វើ ហើយបន្ទាប់មកអាចទទួលបាននោះទេ គឺទាំងអស់នោះអាស្រ័យទៅលើព្រះទាំងស្រុង។ ដូចដែលព្រះអង្គប្រទានការមើលឃើញដល់ទាំងអ្នកក្រ និងអ្នកដែលជិះជាន់អ្នកក្រ (សុភាសិត ២៩:១៣) យើងទាំងអស់គ្នាសុទ្ធតែទទួលបានព្រះពរនៃព្រះគុណទូទៅរបស់ព្រះជាម្ចាស់ ប៉ុន្តែគឺយើងនេះឯងដែលមានទំនួលខុសត្រូវ ក្នុងការទទួលយកព្រះគុណដ៏វិសេសនោះ ដែលនាំឲ្យមានសេចក្តីសង្គ្រោះបាន។

លោក ប្រុសស្ពឺរ (Prosper) ពីទីក្រុងអាឃ្វីថេន Aquitaine ដែលបានជួយបិទបញ្ចប់ការប្រជុំថ្នាក់ប្រឹក្សានៅឯទីក្រុងខាធេ (Council of Carthage) នៅឆ្នាំ៤១៨ បានវែកញែកអំពីសេចក្តីសង្គ្រោះថា “គ្មានបុគ្គលណាម្នាក់អាចទទួលបានសេចក្តីសង្គ្រោះ ដោយឡែកពីព្រះគុណដ៏វិសេសរបស់ព្រះជាម្ចាស់នោះទេ” (១៧-១៦)។ គឺព្រះគុណរបស់ព្រះ។

នៅថ្ងៃបុណ្យទី៥០ នៅក្នុងកណ្ឌគម្ពីរ កិច្ចការ ២:៣៧ យើងអានអំពីអស់អ្នកដែលបានស្តាប់សេចក្តីអធិប្បាយរបស់សាវ័ក ពេត្រុស ថា៖ “នោះគេមានសេចក្តីចាក់ចុចក្នុងចិត្ត”។ នេះគឺជាឧទាហរណ៍មួយអំពីការដែលព្រះវិញ្ញាណបរិសុទ្ធធ្វើការនៅក្នុងចិត្តរបស់យើង គឺចាក់ចុចចិត្តរបស់យើង។ ព្រះអង្គបានបំពេញតួនាទីនៃការណែនាំឲ្យបងប្អូនឃើញ និងយល់អំពីអំពើបាបរបស់ខ្លួន (Berkouwer, ២៨)។ តើពេលណាជាពេលវេលាចុងក្រោយដែលលោកអ្នកបានធ្វើអំពើបាប?

ទាក់ទងទៅនឹងការប្រព្រឹត្តអំពើបាប កណ្ឌគម្ពីរ រ៉ូម ៥:១២-១៩ បានចែងដូចតទៅ៖

> ដូច្នេះ ដែលបាបបានចូលមកក្នុងលោកីយ៍ ដោយសារមនុស្សតែម្នាក់ ហើយក៏មានសេចក្តីស្លាប់ចូលមកដែរ ដោយសារអំពើបាបនោះជាយ៉ាងណា នោះសេចក្តីស្លាប់បានឆ្លងរាលដាល ដល់មនុស្សគ្រប់គ្នាយ៉ាងនោះដែរ ដ្បិតគ្រប់គ្នាបានធ្វើបាបហើយ (ព្រោះរមែងមានបាបនៅក្នុងលោកីយ៍ ដរាបដល់ក្រឹត្យវិន័យ តែកាលមិនទាន់មានក្រឹត្យវិន័យនៅឡើយ នោះមិនបានរាប់ជាទោសដល់គេទេ ប៉ុន្តែ ចាប់តាំងពីលោក អ័ដាម ដរាបដល់លោក ម៉ូសេ នោះសេចក្តីស្លាប់បានសោយរាជ្យ លើទាំងពួកអ្នកដែលធ្វើបាប មិនមែនដូចជាអំពើរំលងរបស់លោក អ័ដាម ផង ដែលលោកជាគំរូពីព្រះអង្គដែលត្រូវយាងមក ប៉ុន្តែព្រះគុណមិនមែនដូចជាអំពើរំលងនោះទេ ដ្បិតបើសិនជាមានមនុស្សជាច្រើនបានស្លាប់ ដោយព្រោះអំពើរំលងរបស់មនុស្សតែម្នាក់ នោះប្រាកដជាព្រះគុណនៃព្រះ ហើយនិងអំណោយទាននៃព្រះគុណនោះ ដែលមកដោយសារមនុស្សតែម្នាក់ គឺព្រះយេស៊ូវគ្រីស្ទនឹងបានចម្រើនលើសទៅទៀត ដល់មនុស្សជាច្រើនដែរ ហើយអំណោយទាននោះក៏មិនមែនដូចជាអំពើបាប ដែលមនុស្សតែម្នាក់បានធ្វើនោះទៀត ដ្បិតសេចក្តីជំនុំជម្រះ ដែលកើតមកដោយព្រោះម្នាក់នោះឯង នោះបានកាត់ទោសហើយ តែព្រះគុណ ដែលកើតមកដោយព្រោះការរំលងជាច្រើន នោះបានរាប់យើងទុកជាសុចរិតវិញ ដ្បិត បើសិនជាសេចក្តីស្លាប់បានសោយរាជ្យ ដោយសារមនុស្សតែម្នាក់ ដោយព្រោះម្នាក់នោះឯងបានប្រព្រឹត្តសេចក្តីរំលង ដូច្នេះ ប្រាកដជាពួកអ្នកដែលទទួលព្រះគុណដ៏បរិបូរនិងអំណោយទានជាសេចក្តីសុចរិត នោះនឹងបានសោយរាជ្យក្នុងជីវិតលើសទៅទៀត ដោយសារតែម្នាក់ដែរ គឺជាព្រះយេស៊ូវគ្រីស្ទ) ដូច្នេះ ដែលមនុស្សទាំងអស់ត្រូវទោស ដោយព្រោះអំពើរំលងតែ១ នោះមនុស្សទាំងអស់ក៏បានរាប់ជាសុចរិតឲ្យបានជីវិតវិញ ដោយសារអំពើសុចរិតតែ១បែបដូច្នោះដែរ។ ដ្បិតដូចជាមនុស្សជាច្រើន បានត្រឡប់ជាមានបាប ដោយសារមនុស្សតែម្នាក់មិនបានស្តាប់បង្គាប់ជាយ៉ាងណា នោះមនុស្សជាច្រើន ក៏បានត្រឡប់ជាសុចរិតដោយសារម្នាក់បានស្តាប់បង្គាប់វិញយ៉ាងនោះដែរ។

នៅពេលដែលលោក អ័ដាម បានធ្លាក់ក្នុងអំពើបាប នៅឯសួនច្បារអេដែន នោះមនុស្សជាតិទាំងមូលក៏បានធ្លាក់ក្នុងអំពើបាបជាមួយនឹងគាត់ដែរ ពីព្រោះយើងជាកូនចៅរបស់គាត់ ហើយគាត់ជាអ្នកតំណាងរបស់យើង។ លោកបណ្ឌិត គីម រីដលបាហ្គឺរ (Kim Riddlebarger) ដែលជាគ្រូគង្វាលច្បងនៅព្រះវិហារ Christ Reformed Church បានសរសេរថា «យើងទទួលបានអំពើបាបរបស់លោក អ័ដាម តាមរយៈធម្មជាតិនៃតំណវង្ស»។

ទាំងបងប្អូន ហើយនិងខ្ញុំ យើងមិនចាំបាច់ទៅប្រព្រឹត្តអំពើបាប ដើម្បីចុះឈ្មោះខ្លួននៅក្នុងសៀវភៅនៃអំពើបាបនោះទេ (ប្រសិនបើមានសៀវភៅបែបនោះមែន) ពីព្រោះយើងមិនគ្រាន់តែបានកើតមកនៅក្នុងអំពើបាបប៉ុណ្ណោះនោះទេ ប៉ុន្តែយើងក៏បានកើតមក ដើម្បីប្រព្រឹត្តអំពើបាបទៀតផងដែរ។ នេះហើយជាមូលហេតុដែលព្រះយេស៊ូវត្រូវតែយាងមក ដើម្បីសុគតនៅលើឈើឆ្កាង ជំនួសអំពើបាបរបស់យើង ដើម្បីឲ្យយើងអាចទទួលបានសេចក្តីសង្គ្រោះ។ នេះហើយជាអត្ថន័យពិតនៃដំណឹងល្អដ៏ពិត។ សូមប្រាកដឲ្យច្បាស់ថា នេះជាអ្វីដែលបងប្អូនបានឮ បានជឿ ក៏ដូចជាអ្វីដែលបងប្អូននឹងប្រកាសប្រាប់អ្នកនៅជុំវិញខ្លួនផងដែរ។

ដាច់ខាត បងប្អូនត្រូវតែយល់អំពីទម្ងន់នៃអំពើបាបរបស់ខ្លួន «ប្រសិនបើបងប្អូនគិតថា ខ្លួនមិនបានប្រព្រឹត្តអំពើបាប នោះបងប្អូនក៏នឹងមិនអាចទទួលបានសេចក្តីសង្គ្រោះផងដែរ...ព្រោះការលន់តួបាប និងការកែប្រែចិត្តគឺជាចំណុចដ៏សំខាន់នៅក្នុងការទទួលបានសេចក្តីសង្គ្រោះ» (MacArthur, ១៦៥)។

### *តើបងប្អូនត្រូវតែលន់តួបាប និងកែប្រែចិត្តចេញពីអ្វី?*

មុនយើងឆ្លើយលើសំណួរនេះ ជាដំបូង យើងត្រូវព្យាយាមយល់អំពីមូលហេតុដែលយើងត្រូវធ្វើបែបនោះសិន ជាពិសេស ត្រង់ចំណុចថា តើយើងបានប្រព្រឹត្តអំពើបាបទាស់នឹងនរណា? នៅពេលដែលបងប្អូនប្រព្រឹត្តអំពើបាប បងប្អូនមិនគ្រាន់តែបាន

ប្រព្រឹត្តអំពើបាបទាស់នឹងព្រះនៃព្រះគម្ពីរសញ្ញាចាស់នោះទេ ប៉ុន្តែក៏បានទាស់នឹងព្រះនៃព្រះគម្ពីរសញ្ញាថ្មីផងដែរ។

លោក ចច ស្ទីវិន (George Stevens) សរសេរថា "ព្រះដ៏ឯកអង្គ ទ្រង់ត្រូវតែឆ្លើយតបដោយអាស្រ័យទៅលើលក្ខណសម្បត្តិរបស់ទ្រង់។ [ហើយលក្ខណសម្បត្តិរបស់ទ្រង់គឺថា] ព្រះអង្គបរិសុទ្ធ (២៧៨)។ ភាពបរិសុទ្ធរបស់ព្រះអង្គសំដៅទៅលើសីលធម៌នៃភាពល្អឥតខ្ចោះរបស់ទ្រង់ ដែលនេះមានន័យថា ដាច់ខាតព្រះអង្គត្រូវតែដាក់ទោសនៅលើរាល់អំពើបាប និងអំពើអាក្រក់ (២៧៩)"។ ព្រះអង្គទាមទារពីបងប្អូន ហើយនិងខ្ញុំដូចតទៅ៖ "ចូរឲ្យឯងរាល់គ្នាបានបរិសុទ្ធ ដ្បិតអញជាបរិសុទ្ធ" (១ពេត្រុស ១:១៦)។

កណ្ឌគម្ពីរនិក្ខមនំ ជំពូក១៩ មានចែងអំពីការដែលព្រះជាម្ចាស់ត្រាស់ហៅសាសន៍អ៊ីស្រាអែលឲ្យជួបជាមួយនឹងព្រះអង្គ ប៉ុន្តែពួកគាត់មិនអាចឆ្លងផុតព្រំដែនដែលលោក ម៉ូសេ បានដាក់នោះទេ ហើយប្រសិនបើពួកគាត់ឆ្លងផុត នោះសូម្បីតែសត្វដែលមិនដឹងថាកំពុងតែមានអ្វីកើតឡើងក៏នឹងស្លាប់ផងដែរ។ ដូច្នេះ បងប្អូន ដោយសារព្រះជាម្ចាស់ទ្រង់បរិសុទ្ធ នោះព្រះអង្គក៏បានបង្គាប់ឲ្យមនុស្សទាំងអស់លន់តួបាប កែប្រែចិត្តចេញពីអំពើបាប និងស្ដាប់បង្គាប់តាមទ្រង់ផងដែរ។ មានតែតាមរយៈការធ្វើបែបនោះឯង ដែលយើងអាចចូលទៅកាន់ព្រះវត្តមានរបស់ទ្រង់វិញបាន។

ដោយសារឥឡូវយើងបានយល់អំពីមូលហេតុដែលយើងត្រូវលន់តួបាប និងកែប្រែចិត្ត ត្រង់ថាវាសំខាន់ នោះអ្វីដែលយើងនឹងធ្វើបន្ទាប់ គឺមើលអំពីរបៀបដែលយើងគួរធ្វើការនោះ។ កណ្ឌគម្ពីរ រ៉ូម ១០:៩ បានណែនាំយើងឲ្យ "...ទទួលថ្លែងប្រាប់ពីព្រះអម្ចាស់យេស៊ូវ ហើយអ្នកជឿក្នុងចិត្តថា ព្រះបានប្រោសឲ្យទ្រង់រស់ពីស្លាប់ឡើងវិញ..."។

ពាក្យថា "ព្រះអម្ចាស់" ត្រង់នេះមានន័យថា ឥឡូវនេះព្រះយេស៊ូវមានការគ្រប់

គ្រងលើជីវិតរបស់យើងទាំងស្រុង យើងមិនអាចនៅបន្តធ្វើតាមតែអំពើចិត្តខ្លួនទៀតបានឡើយ។ ប៉ុន្តែ យើងត្រូវតែធ្វើនូវអ្វីដែលព្រះអម្ចាស់នៃយើងបានបង្គាប់ឲ្យយើងធ្វើ។ កណ្ឌគម្ពីរ ១យ៉ូហាន ១:៩ បានធានាដល់យើងថា "បើយើងលន់តួបាបវិញ នោះទ្រង់មានព្រះហឫទ័យស្មោះត្រង់ ហើយសុចរិត ប្រយោជន៍នឹងអត់ទោសបាបឲ្យយើង ហើយនឹងសម្អាតយើង ពីគ្រប់អំពើទុច្ចរិតទាំងអស់ផង"។

ដោយឡែកពីការលន់តួបាប តើការកែប្រែចិត្តមានការពាក់ព័ន្ធអ្វីជាមួយនឹងការទទួលបានការអត់ទោសចេញពីអំពើបាប? ពាសពេញព្រះគម្ពីរសញ្ញាថ្មី យើងឃើញថាការកែប្រែចិត្ត និងការទទួលពិធីជ្រមុជទឹកស្ទើរតែមានការលើកឡើង ឬក៏មានការសរសេរនៅក្នុងបរិបទតែមួយ។ លោក យ៉ូហាន-បាទីស្ទ បានអធិប្បាយអំពីការកែប្រែចិត្ត និងការទទួលពិធីជ្រមុជទឹក (ម៉ាថាយ ៣:១១)។

នៅពេលដែលមានគេសួរសាវ័ក ពេត្រុស ថា ពួកគាត់គួរឆ្លើយតបយ៉ាងដូចម្តេចទាក់ទងទៅនឹងការអធិប្បាយរបស់គាត់ សាវ័ក ពេត្រុស បានឆ្លើយថា "ចូរអ្នករាល់គ្នាប្រែចិត្តចុះ ហើយទទួលបុណ្យជ្រមុជទឹកទាំងអស់គ្នា ដោយនូវព្រះនាមព្រះយេស៊ូវគ្រីស្ទ ប្រយោជន៍ឲ្យបានរួចពីបាប..." (កិច្ចការ ២:៣៨)។

ប៉ុន្តែ នេះមិនបានផ្តល់ជាចម្លើយថា តើការកែប្រែចិត្តជាអ្វីនៅឡើយនោះទេ។ បងប្អូន ដូចដែលយើងទាំងអស់គ្នាបានដឹងហើយថា ការកែប្រែចិត្តគឺជាការមើលឃើញ ឬក៏ការយល់អំពីភាពអាក្រក់នៃអំពើបាបរបស់យើង ហើយក្នុងកម្រិតណាមួយ បងប្អូនមានការស្រេកឃ្លាន ចង់ទទួលបានសេចក្តីសុចរិត (Stevens, ៣៥០)។

នៅពេលបងប្អូន ហើយនិងខ្ញុំប្រព្រឹត្តអំពើបាប ដាច់ខាតយើងត្រូវតែយល់ថា យើងកំពុងតែប្រព្រឹត្តអំពើបាបទាស់ប្រឆាំងនឹងព្រះជាម្ចាស់ផ្ទាល់ (ទំនុកតម្កើង ១១៩:១១ "ទូលបង្គំបានកំណត់ចាំព្រះបន្ទូលទ្រង់ទុកនៅក្នុងចិត្ត ប្រយោជន៍កុំឲ្យទូលបង្គំធ្វើបាបនឹងទ្រង់ឡើយ")។ ប៉ុន្តែ សំណួរសួរថា តើការទទួលពិធីជ្រមុជទឹកសំខាន់ដែរ

ឬទេ ក្នុងការទទួលបានសេចក្តីសង្គ្រោះ?

ចម្លើយដ៏សាមញ្ញលើសំណួរនេះគឺថា ទេ! ពីព្រោះយើងដឹងហើយថា ចោរដែលជាប់ឆ្កាងនៅក្បែរព្រះយេស៊ូវនៅក្នុងកណ្ឌគម្ពីរលូកា ជំពូក២៣ មិនបានទទួលពិធីជ្រមុជទឹកមុនពេលគាត់ស្លាប់នោះទេ ប៉ុន្តែព្រះយេស៊ូវបានមានបន្ទូលទៅគាត់បន្ទាប់ពីគាត់បានទូលសូមឲ្យព្រះអង្គចាំគាត់នៅក្នុងនគររបស់ទ្រង់ថា «ខ្ញុំប្រាប់អ្នកជាប្រាកដថា ថ្ងៃនេះ អ្នកនឹងនៅក្នុងស្ថានបរមសុខជាមួយនឹងខ្ញុំដែរ»។ ចំណុចគន្លឹះគឺថា «[យើង] ជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ» (កិច្ចការ ១៦:៣១)។

ពួកព្យាយុកោនៅក្នុងព្រះគម្ពីរសញ្ញាចាស់បានជឿ ហើយរំពឹងមើលអ្វីដែលយើងមានឥឡូវនេះ ដែលយើងកំពុងតែមើលត្រឡប់ក្រោយទៅវិញ—ការសុគត ការបញ្ចុះក្នុងផ្នូរ និងការមានព្រះជន្មរស់ឡើងវិញ (កាឡាទី ៣:៨ «ហើយដោយគម្ពីរបានដឹងជាមុនថា ព្រះទ្រង់នឹងរាប់ពួកសាសន៍ដទៃជាសុចរិត ដោយសេចក្តីជំនឿ បានជាមានសេចក្តីប្រកាសប្រាប់មក ដល់លោកអ័ប្រាហាំជាមុនថា "អស់ទាំងសាសន៍នឹងបានពរដោយសារឯង"»)។ ដំណឹងល្អដ៏ពិតមានតាំងពីក្នុងព្រះគម្ពីរសញ្ញាចាស់ មិនមែនគ្រាន់តែទើបតែមាននៅក្នុងព្រះគម្ពីរសញ្ញាថ្មីនោះទេ។

សំណួរដែលយើងចង់បន្តពិភាក្សាជាមួយគ្នាគឺថា តើត្រូវមានអ្វីខ្លះទាក់ទងនឹងការជឿលើការសុគត ការបញ្ចុះក្នុងផ្នូរ និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវ? ចម្លើយ៖ គឺត្រូវមានជំនឿ។ ការមានជំនឿគឺជាអ្វីដែលដំណឹងល្អទាមទារពីអ្នកពុំ។ ការមានជំនឿផ្ទាល់គឺមិនមែនជាអ្វីដែលមនុស្សមានបាបធ្វើនោះទេ។ វាគឺជាអំណោយទានពីព្រះជាម្ចាស់។ លោកគ្រូ ម៉ាធិន លូសើរ (Martin Luther) បានលើកឡើងថា «ព្រះជាម្ចាស់មិនមែនគ្រាន់តែជាអ្នកផ្តើមជំនឿនោះទេ ព្រះអង្គក៏ជាអ្នកបង្កើត និងជាអ្នករក្សាជំនឿនៅក្នុងការយល់ដឹងរបស់យើង ទាក់ទងទៅនឹងសេចក្តីសង្គ្រោះផងដែរ។ ព្រះវិញ្ញាណបរិសុទ្ធបានធ្វើឲ្យបងប្អូនមានជំនឿរហូតដល់ចំណុចដែលនាំឲ្យបងប្អូនចូលទៅកាន់ព្រះជាម្ចាស់បាន» (Trelstad)។

កណ្ឌគម្ពីរ រ៉ូម ៤:២២ បានប្រាប់យើងថា លោក អ័ប្រាហាំ បានទទួលសេចក្តីសុចរិតតាមរយៈជំនឿរបស់គាត់។ ផ្ទត់គំនិតនៃការដែលថា៖ «មនុស្សសុចរិតនឹងរស់នៅ ដោយសារសេចក្ដីជំនឿរបស់ខ្លួន» មិនមែនជាការគិតថ្មីនោះទេ តែមានតាំងពីសម័យព្រះគម្ពីរសញ្ញាចាស់មកម្ល៉េះ។ ឧទាហរណ៍៖ កណ្ឌគម្ពីរ ហាបាគុក ២:៤ ក៏បានចែងផងដែរថា «តែមនុស្សសុចរិតនឹងរស់នៅ ដោយសារសេចក្ដីជំនឿរបស់ខ្លួន» (សូមអានបន្ថែមនៅក្នុងកណ្ឌគម្ពីរ រ៉ូម ១:១៧; កាឡាទី ៣:១១; ហេព្រើរ ១០:៣៨)។ លោកបណ្ឌិត ចន ម៉ាកអាធើរ (John MacArthur) ក៏បានឯកភាពទាក់ទងទៅនឹងជំនឿថា «ជំនឿគឺជាយានយន្តដែលមនុស្សមានបាបទទួលបានការរាប់ជាសុចរិត» (១០៧)។

ដូច្នេះ តើអ្វីទៅជាការរាប់ជាសុចរិត? ដូចដែលយើងបានមើលជាមួយគ្នា «[យើង] ត្រូវមានជំនឿមុន នោះទើបយើងអាចទទួលបានការរាប់ជាសុចរិត» (Berkouwer, ១៥២)។ សូមគិតក្នុងរបៀបនេះ៖ បងប្អូនកំពុងតែជាប់ពាក្យបណ្ដឹង នៅក្នុងកន្លែងកាត់ក្ដី ទាក់ទងទៅនឹងការលួចលុយគេ ១០០ លានដុល្លារ ចៅក្រមហៀបនឹងវាយញញួរ ហើយប្រកាសថាបងប្អូនជាប់ទោស ប៉ុន្តែក្នុងរំពេចដែលគាត់រៀបនឹងវាយញញួរ ស្រាប់តែមានបុគ្គលម្នាក់ដែលបងប្អូនមិនធ្លាប់បានជួបពីមុនសោះ ចូលមកក្នុងកន្លែងកាត់ក្ដី ហើយស្នើឲ្យចៅក្រមរង់ចាំសិន។

ខណៈពេលដែលគាត់កំពុងតែនិយាយ គាត់ក៏បានមកសូម QR Code ដើម្បីបាញ់ទឹកលុយ ១០០ លានដុល្លារនោះ គឺជាចំនួនទឹកលុយដែលលោកអ្នកនឹងមិនអាចសងវិញបាន។ ក្នុងអត្ថន័យចំៗ គាត់កំពុងតែរងគ្រោះជំនួសយើង—នេះឯងគឺជាអត្ថន័យនៃការរាប់ជាសុចរិត។ សូមគិតអំពីការប្រៀបធៀបនេះ ទៅនឹងអំពើបាបរបស់បងប្អូន រាល់អំពើបាបដែលយើងបានប្រព្រឹត្ត គឺព្រះយេស៊ូវគ្រីស្ទបានបង់ថ្លៃលោះទាំងអស់។

កណ្ឌគម្ពីរ កូឡុស ២:១៣-១៥ បានចែងថា «ឯអ្នករាល់គ្នាដែលបានស្លាប់ក្នុងការ

រំលង ហើយក្នុងសណ្ឋានមិនកាត់ស្បែកខាងសាច់ឈាម នោះទ្រង់បានប្រោសឲ្យរស់ជាមួយនឹងទ្រង់ ដោយបានអត់ទោសចំពោះអស់ទាំងការរំលងរបស់អ្នករាល់គ្នា ទាំងលុបចោលសេចក្តីដែលកត់ទុកទាស់នឹងយើងក្នុងសេចក្តីបញ្ញត្តិ ដែលប្រទាំងនឹងយើង ហើយទ្រង់ក៏លើកចោល ដោយបោះភ្ជាប់នៅឈើឆ្កាង ទ្រង់បានទាំងទម្លាក់ងារពីពួកគ្រប់គ្រង និងពួកមានអំណាច ទាំងដាក់ពួកទាំងនោះនៅកណ្តាលជំនុំឲ្យគេមើល ហើយដឹកនាំគេទៅ ដោយមានជ័យជំនះ ដោយសារឈើឆ្កាងនោះឯង»។

លោកគ្រូ ម៉ធិន លូសើរ បានលើកឡើងថាយើងទទួលបាន «ការរាប់ជាសុចរិតតាមរយៈព្រះគុណដោយជំនឿ» (Trelstad)។ មានការវែកញែកគ្នាថា តើមនុស្សមានបាបអាចទទួលបានការរាប់ជាសុចរិត ក្នុងពេលដែលគាត់ទទួលជឿ ឬក៏តើគាត់ទទួលបានការរាប់ជាសុចរិតនោះ តាំងពីអស់កល្បជានិច្ចមកម្ល៉េះហើយ? បងប្អូន អ្វីដែលយើងត្រូវចងចាំនោះគឺថា ការដែលយើងទទួលបានការរាប់ជាសុចរិតនៅបច្ចុប្បន្នកាលនេះតម្រូវឲ្យព្រះអង្គបានគ្រងទុកចាប់តាំងពីអស់កល្បជានិច្ចមកក្នុងការដែលព្រះអង្គជ្រើសរើសយើង។ «ការរាប់ជាសុចរិតមិនអាចកើតឡើងបានប្រសិនបើក្នុងពេលវេលានៃការអស់កល្បជានិច្ចមិនបានបង្កើតវាមកដែរនោះទេ» (Berkouwer, ១៤៧)។ ការរាប់ជាសុចរិត គឺជាអ្វីដែលកើតឡើងម្តងជាសម្រេច គឺជាពេលដែលព្រះយេស៊ូវអត់ទោសអំពើបាបរបស់យើង។ ការញែកជាបរិសុទ្ធ គឺជាដំណើរការពេញមួយជីវិត។ ការញែកជាបរិសុទ្ធគឺជាការញែកចេញទុក។ តើញែកទុកសម្រាប់អ្វី?

បន្ទាប់ពីបងប្អូនបានទទួលជឿលើព្រះយេស៊ូវគ្រីស្ទ នោះបងប្អូននឹងទទួលបានសេចក្តីសង្គ្រោះ ដែលនេះមានន័យថា ព្រះអង្គបានអត់ទោសនូវរាល់អំពើបាបទាំងអស់របស់បងប្អូន—ដែលយើងហៅថា «ការរាប់ជាសុចរិត»—ហើយបន្ទាប់មក ព្រះវិញ្ញាណបរិសុទ្ធនឹងចាប់ផ្តើមញែកបងប្អូនជាបរិសុទ្ធ ដោយយាងមកគង់ និងបំពេញជីវិតរបស់បងប្អូន។

ដូចដែលព្រះអង្គបានជ្រើសរើសសាសន៍អ៊ីស្រាអែល បានញែកពួកគេសម្រាប់ទ្រង់នៅក្នុងព្រះគម្ពីរសញ្ញាចាស់ នោះព្រះអង្គក៏បានញែកបងប្អូនទុក នៅពេលដែលបងប្អូនបើកចិត្ត ទទួលជឿព្រះយេស៊ូវផងដែរ។ នៅក្នុងការអធិស្ឋានរបស់ព្រះយេស៊ូវ ដែលជាសម្តេចសង្ឃ ព្រះអង្គបានទូលសូមព្រះវរបិតាឲ្យញែកយើងជាបរិសុទ្ធ "សូមញែកគេចេញជាបរិសុទ្ធ ដោយសារសេចក្តីពិតរបស់ទ្រង់ ឯសេចក្តីពិត គឺជាព្រះបន្ទូលរបស់ទ្រង់" (យ៉ូហាន ១៧:១៧)។

ព្រះបន្ទូលរបស់ព្រះអង្គមានតួនាទីសំខាន់ណាស់ក្នុងការញែកយើងជាបរិសុទ្ធ ជាប្រចាំថ្ងៃ។ ក្នុងការតយុទ្ធរបស់គាត់ ដើម្បីឲ្យបានបរិសុទ្ធលោក អាឡេហ្វ (Aleph) បានសរសេរនៅក្នុងកណ្ឌគម្ពីរ ទំនុកតម្កើងជំពូក១១៩ ដែលនោះគឺជាសេចក្តីសន្និដ្ឋានរបស់គាត់ថា ជាផ្លូវតែមួយគត់ក្នុងការឲ្យបានបរិសុទ្ធ គឺតាមរយៈព្រះបន្ទូលរបស់ព្រះជាម្ចាស់ (ទំនុកតម្កើង ១១៩:៩ "មនុស្សកំឡោះនឹងសម្អាតផ្លូវដែលខ្លួនប្រព្រឹត្តដោយសារអ្វី គឺដោយប្រយ័ត្ននឹងប្រព្រឹត្តតាមព្រះបន្ទូលនៃទ្រង់")។

សាវ័ក ប៉ុល បានរម្លឹកឲ្យយើងផ្លាស់ប្រែគំនិតយើង ជាថ្មីជាប្រចាំថ្ងៃ ហើយមានផ្លូវតែមួយគត់ ដែលយើងអាចផ្លាស់ប្រែគំនិតរបស់យើងបាន គឺតាមរយៈព្រះបន្ទូលរបស់ព្រះ។ កណ្ឌគម្ពីរ រ៉ូម ១២:១-២ បានចែងថា "ដូច្នេះ បងប្អូនអើយ ខ្ញុំទូន្មានអ្នករាល់គ្នា ដោយសេចក្តីមេត្តាករុណានៃព្រះ ឲ្យបានថ្វាយរូបកាយទុកជាយញ្ញបូជារស់ ហើយបរិសុទ្ធ ដែលគាប់ព្រះហឫទ័យដល់ព្រះ ជាការគោរពនៃអ្នករាល់គ្នា ដែលមានទំនង។ កុំឲ្យត្រាប់តាមសម័យនេះឡើយ ចូរឲ្យអ្នករាល់គ្នាបានផ្លាស់ប្រែវិញ ដោយគំនិតបានកែជាថ្មីឡើង ដើម្បីនឹងអាចលមើលឲ្យបានស្គាល់បំណងព្រះហឫទ័យនៃព្រះ ដែលល្អ ស្រួលទទួល ហើយគ្រប់លក្ខណ៍ផង"។

គោលបំណងរបស់ព្រះអង្គ ក្នុងការញែកយើងគឺ ដើម្បីឲ្យយើងបម្រើទ្រង់ និងអ្នកដទៃ។ ព្រះវរបិតាបានញែកព្រះយេស៊ូវទុក ដើម្បីឲ្យយាងមកផែនដីនេះ ដើម្បីឲ្យសុគតជំនួសអំពើបាបរបស់យើង។ ដូច្នេះ គឺជាទំនួលខុសត្រូវរបស់យើងហើយ

ក្នុងការដែលព្រះអង្គបានញែកយើងទុក ដើម្បីធ្វើព័ន្ធកិច្ចសម្រាប់ទ្រង់ (Stevens, ១០១)។

*តើការបម្រើព័ន្ធកិច្ចជាអ្វី?*

សាវ័ក យ៉ាកុប បានលើកឡើងយ៉ាងច្បាស់លាស់ ក្នុងនាមជាប្រធានបទស្នូលនៅក្នុងកណ្ឌគម្ពីរដែលគាត់បាននិពន្ធថា ជំនឿដែលទទួលបានសេចក្តីសង្គ្រោះ គឺជាជំនឿដែលមានសកម្មភាព គឺជាជំនឿដែលរស់។ ព្រះយេស៊ូវក៏បានថែងនៅក្នុងកណ្ឌគម្ពីរ ចោទិយកថា ៦:៤-៥ នៅពេលដែលព្រះអង្គបានមានបន្ទូលថាៈ

“ចូរស្តាប់ចុះ “ឱអ៊ីស្រាអែលអើយ ព្រះយេហូវ៉ាជាព្រះនៃយើង គឺព្រះយេហូវ៉ាតែ១អង្គទ្រង់” ត្រូវឲ្យឯងស្រឡាញ់ព្រះយេហូវ៉ា ជាព្រះនៃឯងឲ្យអស់ពីចិត្ត អស់ពីព្រលឹង ហើយអស់ពីកម្លាំងឯង” ហើយ “ឯបញ្ញត្តិទី២ ក៏បែបដូចគ្នា គឺថា “ត្រូវឲ្យស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង” គ្មានបញ្ញត្តិណាទៀតធំជាងបទទាំង២នេះទេ” (ម៉ាកុស ១២:២៩-៣១)។

ប្រសិនបើបងប្អូនពិតជាស្រឡាញ់ព្រះអម្ចាស់មែន នោះបងប្អូនក៏នឹងចង់ធ្វើនូវអ្វីដូចដែលអ្នកជឿដំបូងបានធ្វើដែរ គឺទទួលពិធីច្រមុជទឹក បន្ទាប់ពីបានឮការប្រកាសអំពីដំណឹងល្អ ពោលគឺបន្ទាប់ពីបងប្អូនបានការប្រែចិត្ត ដោយទទួលជឿ (សូមអានបន្ថែមនៅក្នុងកណ្ឌគម្ពីរ កិច្ចការ ៨:២៦-២៨; ៩:១៨; ១០:៤៧-៤៨; ១៦:៣៣)។ ខ្ញុំសូមបញ្ជាក់ថា ការទទួលពិធីជ្រមុជទឹកមិនបាននាំឲ្យបងប្អូនទទួលបានសេចក្តីសង្គ្រោះទេ ប៉ុន្តែការទទួលពិធីជ្រមុជទឹកគឺជាការបង្ហាញថា បងប្អូនកំពុងតែស្តាប់បង្គាប់តាមទ្រង់។

វាគ្រាន់តែជាសញ្ញានៃការបង្ហាញថា បងប្អូនកំពុងតែស្តាប់បង្គាប់ព្រះយេស៊ូវ និងជាការប្រកាសទៅកាន់ពិភពលោកថា *បងប្អូនគឺជាអ្នកដើរតាមព្រះអង្គ* (ម៉ាថាយ ២៨:១៩-២០)។ យើងដឹងហើយថា ក្រុមជំនុំកូរិនថូសបានធ្វើពិធីជ្រមុជទឹក សម្រាប់

មនុស្សស្លាប់ទៅគិតថា ការធ្វើបែបនោះនឹងនាំឲ្យជីដូនជីតារបស់ពួកគាត់ ដែលបានស្លាប់ហើយ ទទួលបានសេចក្តីសង្គ្រោះផងដែរ។ ការធ្វើបែបនេះក៏មិនសូវខុសគ្នាពីជំនឿខាងពួកខុសឆ្គងមួយចំនួននោះទេ។

ប៉ុន្តែសាវ័ក ប៉ុល បានលើកឡើងយ៉ាងច្បាស់លាស់ថា ការធ្វើបែបនោះនឹងមិននាំឲ្យមានការសង្គ្រោះនោះទេ (១កូរិនថូស ១៥:២៩-៣០)។ ការទទួលពិធីជ្រមុជទឹកគឺមិនមែនជាចំណុចដែលសំខាន់បំផុត ដែលបងប្អូនត្រូវតែធ្វើ បន្ទាប់ពីបងប្អូនបានបើកចិត្តទទួលជឿនោះទេ គឺនៅមានចំណុចសំខាន់ៗផ្សេងទៀតដែលបងប្អូនត្រូវតែធ្វើ ក្នុងនាមជាអ្នកដើរតាមព្រះយេស៊ូវ។

ដូចដែលខ្ញុំបានលើកឡើង ព្រះយេស៊ូវមិនមែនគ្រាន់តែបានត្រាស់ហៅឲ្យយើងស្រឡាញ់ព្រះអង្គឲ្យអស់ពីគំនិត អស់ពីព្រលឹង អស់ពីចិត្ត និងអស់ពីកម្លាំងនោះទេ ប៉ុន្តែព្រះអង្គក៏បានត្រាស់ហៅឲ្យយើងស្រឡាញ់អ្នកជិតខាងយើងផងដែរ។ បងប្អូន ព្រះអង្គបានសង្គ្រោះយើង ដើម្បីឲ្យយើងអាចបង្ហាញសេចក្តីស្រឡាញ់នោះ។

យ៉ូហាន ៣:១៦ បានចែងថា «ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់ម៉្លេះ បានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះមិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ»។ បន្ទាប់ពីយើងទទួលបានការសង្គ្រោះ វាគឺជាទំនួលខុសត្រូវរបស់យើងក្នុងការចេញទៅបង្កើតសិស្ស ការធ្វើពិធីជ្រមុជទឹក និងការបង្រៀនអ្នកដទៃ—នេះប្រសិនបើបងប្អូនពិតជាស្រឡាញ់ព្រះជាម្ចាស់ និងអ្នកជិតខាងរបស់ខ្លួនមែន (ម៉ាថាយ ២៨:១៩-២០)។

ពិតណាស់ គឺបងប្អូននឹងមិនចង់ឃើញពួកគេវិនាសឡើយ។ ប៉ុន្តែ សូមចងចាំថា គឺមិនមែនបងប្អូនទេដែលត្រូវសម្រេចការងារទាំងអស់នេះ។ សូមចងចាំថា ការទទួលបានសេចក្តីសង្គ្រោះរបស់យើង គឺព្រះជាម្ចាស់ទេដែលបានសម្រេច គឺព្រះវិញ្ញាណបរិសុទ្ធទេដែលបានចាក់ចុចចិត្តរបស់យើង (Berkouwer, ២៨)។ ទំនួលខុសត្រូវ

របស់យើងគឺធ្វើនូវអ្វីដែលបុគ្គលដែលបាននាំបងប្អូនឲ្យជឿព្រះគ្រីស្ទបានធ្វើដែរ—គឺប្រកាសដំណឹងល្អ—ហើយថ្វាយការនោះទៅឲ្យព្រះជាម្ចាស់សម្រេច។

សរុបសេចក្តី អ្វីដែលបងប្អូនត្រូវជឿតិចបំផុត ដើម្បីឲ្យទទួលបានសេចក្តីសង្គ្រោះគឺទទួលជឿលើការសុគត ការបញ្ចុះក្នុងផ្នូរ និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ។ ព្រះជាម្ចាស់គឺជាអង្គដែលសម្រេចជំនឿរបស់បងប្អូន។ ដាច់ខាតមានតែព្រះអង្គមួយអង្គគត់ដែលត្រូវតែជាអង្គដែលជ្រើសរើសបងប្អូន តាំងពីមុនការចាក់គ្រឹះពិភពលោកនេះ ដើម្បីឲ្យបងប្អូនអាចទទួលបានសេចក្តីសង្គ្រោះនេះ។ បងប្អូន នេះឯងគឺជាអ្វីដែលយើងត្រូវប្រកាសជារៀងរាល់ថ្ងៃនៅក្នុងជីវិតរបស់យើង។

ពោលគឺ ដើម្បីឲ្យបងប្អូនអាចឈានដល់ចំណុចដែលបងប្អូនអាចមានជម្រើសទទួលជឿបាន ដែលនោះគឺជាការបង្ហាញអំពីអធិបតេយ្យភាពរបស់ព្រះជាម្ចាស់ និងជាការដែលព្រះវិញ្ញាណបរិសុទ្ធចាក់ចុចចិត្តរបស់បងប្អូន ឲ្យយល់អំពីអំពើបាបរបស់ខ្លួន នៅពេលដែលបងប្អូនឮការប្រកាសដំណឹងល្អដ៏ពិត។ តាមរយៈការជឿនោះជំនឿនឹងរាប់យើងជាសុចរិត តាមរយៈព្រះគុណ។

បន្ទាប់ពីបងប្អូនទទួលបានការរាប់ជាសុចរិត នោះដំណើរដ៏វែងឆ្ងាយនៃការញែកជាបរិសុទ្ធនឹងចាប់ផ្តើម ដែលនេះមានន័យថា ព្រះអង្គបានត្រាស់ហៅឲ្យបងប្អូនរស់នៅដោយបង្ហាញជំនឿ តាមរយៈការស្រឡាញ់ទ្រង់ និងស្រឡាញ់អ្នកដទៃ។ យើងអាចឃើញការនេះបានតាមរយៈការដែលបងប្អូនចេញទៅបង្កើតសិស្ស ធ្វើពិធីជ្រមុជទឹក និងបង្រៀនអ្វីដែលព្រះជាម្ចាស់បានបង្គាប់ឲ្យបងប្អូនធ្វើ ដោយទទួលស្គាល់ថាគឺបងប្អូនមានកាតព្វកិច្ចក្នុងការប្រកាសដំណឹងល្អ ខណៈពេលដែលព្រះជាម្ចាស់គឺជាអង្គដែលសង្គ្រោះ។

បងប្អូន នេះគឺជាចំណុចស្នូលនៃដំណឹងល្អដ៏ពិត ហើយនេះជាមូលហេតុដែលយើងជួបជុំគ្នាសម្រាប់សិក្ខាសាលាមួយនេះ។

# ឯកសារយោង

១. លោក Berkouwer, G. C. Faith and Justification, Grand Rapids: WM. B. Eerdmans Publishing, ឆ្នាំ១៩៥៤។

២. លោក David Mathis, God Came Down, Date accessed: ០៤ Dec. ២០២៤ <https://www.desiringgod.org/articles/god-came-down>

៣. លោក Lonas, Justin. “Living the Resurrection.” Pulpit Helps. ថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៩ ទំព័រ៦-៧.

៤. លោក MacArthur, John. “Having an Eternal Right Relationship with God.” Think Biblically. Eds. Hughes, John A., and Richard L. Mayhue. Illinois: Crossway Books, ឆ្នាំ២០០៣ ទំព័រ១០១-១១៤

៥. Truth Endures, Panorama City: Grace to You, ឆ្នាំ២០០៩.

៦. Reformed.org website. Apostles’ Creed. Google Search. Date accessed: ២៣ Apr. ២០០៩ <http://www.reformed.org>។

៧. លោក Riddlebarger, Kim. “Our Only Mediator.” Table Talk. ថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៩: ទំព័រ៥២-៥៣។

៨. លោក Prosper of Aquitaine. The Call of all Nations. Trans. P. De Letter. New York: Newman Press, ឆ្នាំ១៩៥២។

៩. លោក Stevens, George. The Christian Doctrine of Salvation, New York: Charles Scribner’s Son, ឆ្នាំ១៩១១។

១០. លោក Trelstad, Marit. “The Way of Salvation in Luther’s Theology:

A Feminist Evaluation." Academic Search Premier. ២០០៦. Date accessed: ២២ Apr. ២០០៩ <http://web.ebscohost.com>.

១១. លោក Varner, Will. Personal interview. ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៩។

# អ្នកបម្រើដំណឹងល្អ

និពន្ធដោយ៖ លោក ញ៉ាន សំអាត

«ដូច្នេះ ខ្ញុំផ្តាំមកអ្នកយ៉ាងអស់ពីចិត្ត នៅចំពោះព្រះ និងព្រះគ្រីស្ទយេស៊ូវ ដែលទ្រង់រៀបនឹងជំនុំជំរះ ទាំងមនុស្សរស់ និងមនុស្សស្លាប់ផង គឺផ្តាំដោយអាងដំណើរទ្រង់យាងមក និងនគរទ្រង់ថា ចូរឲ្យអ្នកផ្សាយព្រះបន្ទូលចុះ ហើយទទូចជំរុញផង ទោះត្រូវពេល ឬខុសក្តី ចូររំឭកគេឲ្យដឹងខ្លួន ព្រមទាំងបន្ទោស ហើយកំឡាចិត្តគេ ដោយចិត្តអត់ធ្មត់ និងសេចក្តីប្រៀនប្រដៅគ្រប់យ៉ាង ដ្បិតនឹងមានគ្រាមក ដែលគេមិនទ្រាំទ្រនឹងសេចក្តីបង្រៀនដ៏ត្រឹមត្រូវទេ គឺគេនឹងមានត្រចៀករមាស់ ហើយនឹងហៅគ្រូកាន់តែច្រើនឡើង មកបង្រៀនឲ្យត្រូវចិត្ត គេនឹងងាកត្រចៀកចេញពីសេចក្តីពិត បែរទៅតាមរឿងព្រេងវិញ» ១ធីម៉ូថេ ៤:១-៤។

យើងជឿថា នេះគឺជាសំបុត្រចុងក្រោយរបស់សាវ័ក ប៉ុល ដែលលោកនៅក្នុងគុកសរសេរទៅលោក ធីម៉ូថេ ដែលបានសម្តែងនៅក្នុងព្រះគម្ពីរ ២ធីម៉ូថេ ៤:៦ ដ្បិតខ្ញុំកំពុងតែត្រូវច្រួចចេញ ឯពេលវេលាដែលខ្ញុំត្រូវលាទៅ ក៏បានមកដល់ហើយ មានន័យថា លោកជិតស្លាប់ហើយ លោកជិតបញ្ចប់ជីវិតរបស់លោកហើយ។ ហើយជាអ្វីដែលសំខាន់ដែលលោកត្រូវតែនិយាយនៅពេលនេះគឺ ខ្លឹមសារសំខាន់នៅក្នុងសំបុត្រនេះគឺសាវ័ក ប៉ុល ផ្តាំឲ្យធីម៉ូថេ ប្រកាសព្រះបន្ទូល នេះគឺជាចំណុចសំខាន់របស់សាវ័ក ប៉ុល និយាយនៅក្នុង២ធីម៉ូថេ។ នៅពេលដែលសាវ័ក ប៉ុល បានប្រាប់ធីម៉ូថេឲ្យប្រកាសព្រះបន្ទូល រូបភាពនេះរំឭកឲ្យយើងនឹកចាំអំពីបណ្តាំរបស់ព្រះយេស៊ូវមុនពេលព្រះអង្គបញ្ចប់បេសកកម្មនៅលើផែនដីនេះក៏ព្រះអង្គផ្តាំឲ្យសិស្ស

របស់ទ្រង់ប្រកាសព្រះបន្ទូលដូចគ្នាហេតុនេះរូបភាពទាំងពីររវាងព្រះយេស៊ូវ និង សាវ័ក ប៉ុល មិនខុសគ្នាទេ។ ដូច្នេះហើយបានជាខ្ញុំដាក់ចំណងជើងមេរៀននេះថា "អ្នកបម្រើដំណឹងល្អ"។

ជាទូទៅយើងយល់ឃើញថាដំណឹងល្អ គឺសម្រាប់តែអ្នកដែលមិនទាន់ជឿដែលត្រូវស្ដាប់ ត្រូវឮនូវដំណឹងល្អ ចុះចំណែកអ្នកជឿហើយ តើគេត្រូវការស្ដាប់ពីអ្វី? តាមរយៈសំបុត្រនេះយើងឃើញថា ទាំងអស់គ្នាត្រូវការឮដំណឹងល្អ ទាំងអ្នកជឿ និងអ្នកមិនទាន់ជឿគឺគ្រប់គ្នាត្រូវការដំណឹងល្អដូចគ្នា។ ក្នុងនាមជាអ្នកដឹកនាំពួកជំនុំ យើងមានតួនាទីចម្បងនៅក្នុងចំណោមតួនាទីដែលព្រះអង្គប្រទានដល់យើង យើងមានតួនាទីក្នុងការស្គាល់ពួកជំនុំរបស់ព្រះអង្គ ផ្គត់ផ្គង់ចំណី ការពារ និងដឹកនាំពួកជំនុំរបស់ព្រះអង្គ។ ទាំងអស់នេះគឺជាតួនាទីរបស់អ្នកដឹកនាំពួកជំនុំ។ ប៉ុន្តែ ជាសង្ខេបមក ខ្ញុំមានទំនុកចិត្តថា រឿងដែលយើងត្រូវធ្វើចម្បងមុនគេនោះគឺ ការផ្ដល់អាហារដល់ពួកជំនុំឲ្យបានត្រឹមត្រូវ។ ប្រសិនបើ យើងមិនបានផ្ដល់អាហារដល់ពួកជំនុំឲ្យបានត្រឹមត្រូវនោះទេ យើងនឹងត្រូវទទួលខុសត្រូវនៅចំពោះមុខព្រះ។ សំណួរសួរថា តើខ្ញុំកំពុងតែជឿហើយបង្រៀនអំពីដំណឹងល្អដ៏ពិតឬទេ ពីព្រោះដំណឹងល្អដ៏ពិតគឺជាអាហាររបស់ពួកជំនុំ។ ....មិនត្រឹមតែអធិប្បាយព្រះបន្ទូលទេ គឺអធិប្បាយព្រះបន្ទូលនៃដំណឹងល្អដ៏ពិត មិនថាស្ថិតនៅក្នុងស្ថានភាពបែបណា។ នៅក្នុងខទី១ បានចែងថា៖ "ដូច្នេះ ខ្ញុំផ្ដាំមកអ្នកយ៉ាងអស់ពីចិត្ត នៅចំពោះព្រះ និងព្រះគ្រីស្ទយេស៊ូវ ដែលទ្រង់រៀបនឹងជំនុំជំរះ ទាំងមនុស្សរស់ និងមនុស្សស្លាប់ផង គឺផ្ដាំដោយអាងដំណើរទ្រង់យាងមក និងនគរទ្រង់ថា ចូរឲ្យអ្នកផ្សាយព្រះបន្ទូលឬអធិប្បាយព្រះបន្ទូល"។

យើងនឹងរៀនជាមួយគ្នាអំពីសេចក្ដី៤យ៉ាងសម្រាប់អ្នកដែលបម្រើដំណឹងល្អ៖ *១. ស្គាល់ដំណឹងល្អ ២. រស់ក្នុងដំណឹងល្អ ៣. អធិប្បាយពីដំណឹងល្អ ៤. ស្មោះត្រង់នឹងដំណឹងល្អ។*

## ១. ស្គាល់ដំណឹងល្អ

ក្នុងនាមជាអ្នកបម្រើដំណឹងល្អយើងត្រូវស្គាល់ដំណឹងល្អ។ នៅក្នុងកណ្ឌគម្ពីរ ២ធីម៉ូថេ ២:១៥ សាវ័ក ប៉ុល បង្គាប់ធីម៉ូថេឲ្យកាត់ស្រាយព្រះបន្ទូលនៃសេចក្ដីពិតយ៉ាងត្រឹមត្រូវ។ យើងឃើញពាក្យថា “កាត់ស្រាយ” ដូច្នេះមានន័យថា មិនមែនឲ្យតែយើងអធិប្បាយព្រះបន្ទូលដែលដកចេញមកពីព្រះគម្ពីរ នោះសុទ្ធតែជាដំណឹងល្អដ៏ពិតនោះទេ។ ដោយហេតុដូច្នេះហើយបានជាសាវ័ក ប៉ុល បានប្រាប់ដល់ធីម៉ូថេឲ្យកាត់ស្រាយព្រះបន្ទូលឲ្យបានត្រឹមត្រូវ ពីព្រោះមានក្រុមជាច្រើនដែលគេយកព្រះគម្ពីរមកហើយគេបង្រៀនឲ្យទៅជារឿងផ្សេង។ ហើយយើងរាប់ពួកគេទាំងនោះថាជាក្រុមខុសឆ្គងពីព្រោះគេមានព្រះគម្ពីរដូចយើងហើយក៏អធិប្បាយព្រះបន្ទូលនៅថ្ងៃអាទិត្យដូចយើងដែរ តែមិនមែនជាព្រះបន្ទូលនៃដំណឹងល្អ។ ហេតុនេះហើយបានជាសាវ័ក ប៉ុល បានប្រាប់ឲ្យធីម៉ូថេប្រយ័ត្នអំពីរបៀបក្នុងការកាត់ស្រាយអំពីព្រះបន្ទូលរបស់ព្រះ។ ដំណឹងល្អមិនមែនគ្រាន់តែជាដំបូន្មានល្អ ទ្រឹស្តីល្អ ឬទស្សនវិជ្ជាល្អទេ តែជាអ្វីដែលព្រះបានធ្វើសម្រាប់យើងទាំងអស់គ្នាជាពួកជំនុំ។

តាមរយៈដំណឹងល្អសាវ័ក ប៉ុល អធិប្បាយថា “ដ្បិតខ្ញុំដឹងថា នៅក្នុងខ្លួនខ្ញុំ គឺក្នុងសាច់ឈាមខ្ញុំ គ្មានអ្វីល្អទេ ព្រោះខ្ញុំមានចិត្តចង់ធ្វើល្អជានិច្ច ប៉ុន្តែ រកធ្វើមិនកើតសោះ” (រ៉ូម ៧:១៨)។ ប៉ុន្តែគ្រូគង្វាលសម័យនេះខ្លះអធិប្បាយថា “អ្នកជាមនុស្សអស្ចារ្យ អ្នកជាមនុស្សដែលពូកែ អ្នកមានសក្ដានុពលក្រៃលែង អ្នកអាចធ្វើបានច្រើនជាងព្រះយេស៊ូវធ្វើទៀត” តើនេះជាដំណឹងល្អទេ? នេះមិនមែនជាដំណឹងល្អទេ។ តើនេះអធិប្បាយពីព្រះបន្ទូលទេ? ហេតុនេះហើយបានជាសាវ័ក ប៉ុល ប្រាប់លោក ធីម៉ូថេថា ចូរកាត់ស្រាយព្រះបន្ទូលនៃដំណឹងល្អឲ្យបានត្រឹមត្រូវ។

សាវ័ក យ៉ូហាន អធិប្បាយនៅក្នុងដំណឹងល្អថា “បើសិនជាយើងថា យើងគ្មានបាបសោះ នោះឈ្មោះថាយើងបញ្ឆោតដល់ខ្លួន ហើយសេចក្ដីពិតមិនស្ថិតនៅក្នុងយើងទេ បើយើងលន់តួបាបវិញ នោះទ្រង់មានព្រះហឫទ័យស្មោះត្រង់ ហើយសុចរិត

ប្រយោជន៍នឹងអត់ទោសបាបឲ្យយើង ហើយនឹងសម្អាតយើង ពីគ្រប់អំពើទុច្ចរិតទាំងអស់ផង បើយើងថា យើងមិនដែលធ្វើបាបសោះ នោះឈ្មោះថាយើងធ្វើឲ្យទ្រង់ទៅជាអ្នកកុហកវិញ ហើយព្រះបន្ទូលទ្រង់មិននៅក្នុងយើងទេ» (១យ៉ូហាន ១:៨-១០)។ ប៉ុន្តែ ឥឡូវនេះ មានព្រះវិហារខ្លះគេបង្រៀនដំណឹងល្អថា «អ្នកគ្មានបាបដែលត្រូវលន់តួទៀតទេ»។

តើនេះជាដំណឹងល្អ ឬក៏ជាសត្រូវនៃដំណឹងល្អ? វាជាសត្រូវនៃដំណឹងល្អ! បើអ្នកមិនស្គាល់ដំណឹងល្អដ៏ពិត តើអ្នកការពារសេចក្ដីពិតបានតាមរបៀបណា? តួនាទីរបស់យើងមិនមែនទៅវាយប្រហារគេ តែលោកអ្នកត្រូវការពារពួកជំនុំដោយសេចក្ដីពិត។ ដំណឹងល្អដ៏ពិត មិននាំឲ្យអ្នកមានអំនួតលើខ្លួនឯង ឬអ្វីណាមួយជាងព្រះគ្រីស្ទឡើយ ប៉ុន្តែការដែលស្គាល់ដំណឹងល្អដ៏ពិតជួយឲ្យយើងដឹងថាអ្នកណាជាសត្រូវរបស់ដំណឹងល្អ ហើយអ្នកណាជាបងប្អូនដែលរងគ្រោះពីសត្រូវរបស់ដំណឹងល្អ។

ស្គាល់ដំណឹងល្អហើយ យើងត្រូវជឿ និងរស់នៅក្នុងដំណឹងល្អ បើយើងត្រឹមតែស្គាល់ដំណឹងល្អ តែមិនរស់នៅក្នុងដំណឹងល្អ នោះក៏ឥតប្រយោជន៍ដែរ។

## ២. *រស់ក្នុងដំណឹងល្អ*

ក្នុងគម្ពីរកាឡាទី សាវ័ក ប៉ុល បន្ទោសពួកជំនុំកាឡាទីថា គេបានចាប់ផ្ដើមជាមួយដំណឹងល្អ ប៉ុន្តែគេគិតថាដំណឹងល្អមិនគ្រប់គ្រាន់ដើម្បីជួយឲ្យគេពេញវ័យ មិនគ្រប់គ្រាន់ជួយឲ្យគេផ្គាប់ព្រះហឫទ័យព្រះ ដោយគេគិតថានឹងបានព្រះពរជាងនេះ បើគេអាចធ្វើតាមបញ្ញត្តិរបស់ព្រះបាន គេបានចាប់ផ្ដើមជាមួយនឹងដំណឹងល្អ តែពួកគេចង់រីកចម្រើនជាមួយនឹងបញ្ញត្តិរបស់ព្រះ។ នៅក្នុងគំនិតរបស់ពួកគេ បញ្ញត្តិរបស់ព្រះនឹងធ្វើឲ្យគេកាន់តែស្អាតឡើង កាន់តែប្រសើរឡើង មានន័យថា ពួកគេមានគំនិតខំបំពេញនូវអ្វីដែលជាចំណុចខ្វះខាតនៃដំណឹងល្អ។

នៅក្នុងកណ្ឌគម្ពីរ កាឡាទី ៣:២-៣ មានចែងថា «ខ្ញុំចង់សួរអ្នករាល់គ្នាតែប៉ុណ្ណោះ

ថា តើអ្នករាល់គ្នាបានទទួលព្រះវិញ្ញាណ ដោយប្រព្រឹត្តតាមក្រិត្យវិន័យ ឬដោយបាន ស្តាប់ ទាំងមានសេចក្តីជំនឿ តើអ្នករាល់គ្នាជាមនុស្សឥតបើគិតជាខ្លាំងដល់ម៉្លេះឬអី ដែលបានចាប់ផ្តើម ដោយព្រះវិញ្ញាណហើយ តើឥឡូវនេះបានគ្រប់លក្ខណ៍ឡើង ដោយសាច់ឈាមវិញឬ” នេះជាសត្រូវរបស់ដំណឹងល្អ។

តើលោកអ្នកមានអារម្មណ៍ថា យើងខំរស់នៅជាជីវិតគ្រីស្ទបរិស័ទឬទេ? តើលោកអ្នកគិតថាខ្លួនល្អមិនគ្រប់គ្រាន់នៅចំពោះព្រះឬទេ? តើលោកអ្នកខំព្យាយាមធ្វើល្អ ដើម្បីបំបាត់ពិរុទ្ធភាព ឬកំហុសខ្លួនឬទេ? លោកអ្នកដឹងទេថាមានគ្រីស្ទានខ្លះជិះម៉ូតូ ទៅស្ពានជ្រោយចង្វាចង់សម្លាប់ខ្លួនដូចអ្នកមិនជឿដែរ? តើលោកអ្នកដឹងទេថា មាន ជីវិតគ្រួសារគ្រីស្ទានប៉ុន្មានភាគរយដែលបាក់បែកគ្នា រួមទាំងអ្នកដឹកនាំព្រះវិហារផង ដែរ គ្រូគង្វាលដែរ? ហេតុនេះហើយបានជា ចម្លើយទៅនឹងបញ្ហាខាងលើនេះ គឺជា ដំណឹងល្អ។ យើងទាំងអស់គ្នាត្រូវការដំណឹងល្អ ពីព្រោះយើងដឹងថា យើងបានចាប់ ផ្តើមជាមួយនឹងដំណឹងល្អ ដូច្នេះយើងត្រូវបន្តរស់នៅក្នុងដំណឹងល្អ។ ដូច្នេះយើងត្រូវ ការឮព្រះបន្ទូលនៃដំណឹងល្អ ត្រូវការដំណឹងល្អគ្រប់គ្នា គ្រប់ពេលគ្រប់ទីកន្លែង គ្រប់ កាលៈទេសៈ មិនមែនតែអ្នកដែលមិនជឿទេតែយើងជាអ្នកជឿ យើងត្រូវការដំណឹង ល្អដើម្បីរស់នៅក្នុងដំណឹងល្អ។

នៅក្នុងព្រះគម្ពីរ ភីលីព ១:២៧ “ប៉ុន្តែ ចូរឲ្យអ្នករាល់គ្នាប្រព្រឹត្តបែបគួរនឹងដំណឹង ល្អរបស់ព្រះគ្រីស្ទចុះ ដើម្បីកាលណាខ្ញុំមកសួរ ឬនៅឃ្លាតពីអ្នករាល់គ្នាក្តី នោះគង់ តែនឹងបានឮនិយាយពីដំណើរអ្នករាល់គ្នាថា អ្នករាល់គ្នាបានឈរមាំមួនហើយ ព្រម ទាំងមានចិត្តមានគំនិតតែ១ ដើម្បីនឹងតតាំងជាមួយគ្នា ដោយនូវសេចក្តីជំនឿ ខាង ឯដំណឹងល្អផង»។

*តើយើងអធិប្បាយដំណឹងល្អយ៉ាងម៉េច បើខ្លួនឯងមិនស្គាល់ហើយមិនរស់នៅក្នុង ដំណឹងល្អនោះ?*

## ៣. អធិប្បាយពីដំណឹងល្អ

នៅក្នុងព្រះគម្ពីរ ២ធីម៉ូថេ ៤:២ “ចូរឲ្យអ្នកផ្សាយព្រះបន្ទូលចុះ ហើយទទូចជំរុញផង ទោះត្រូវពេល ឬខុសក្តី ចូររំឭកគេឲ្យដឹងខ្លួន ព្រមទាំងបន្ទោស ហើយកំឡាចិត្តគេ ដោយចិត្តអត់ធ្មត់ នឹងសេចក្តីប្រៀនប្រដៅគ្រប់យ៉ាង”។

នៅទីនេះបទគម្ពីរបានប្រើពាក្យថា “ចូរផ្សាយព្រះបន្ទូលទៅកាន់ពួកជំនុំ” អាច និយាយបានថា អធិប្បាយ ឬបង្រៀនព្រះបន្ទូលហ្នឹងឯង។ ខ្ញុំធ្លាប់ឮពួកជំនុំខ្លះ និយាយថា លោកគ្រូយកព្រះបន្ទូលមកវាយប្រហារខ្ញុំ អ្នកខ្លះភ័យខ្លាចក្នុងជីវិតដោយព្រោះខ្លាចខុសនឹងព្រះបន្ទូល។ មានម្នាក់និយាយថា ខ្ញុំមានព្រះបន្ទូលដែលបង្គាប់ឲ្យខ្ញុំថ្វាយបង្គំថ្ងៃសៅរ៍ ចុះអ្នកវិញបានបង្គាប់ពីណាឲ្យថ្វាយបង្គំថ្ងៃអាទិត្យ?

ដូច្នេះ នៅខទី២នេះ ពាក្យដែលសាវ័ក ប៉ុល មានប្រសាសន៍នៅត្រង់នេះគឺមានន័យថា លើសពីយើងគ្រាន់តែប្រើព្រះបន្ទូល តែព្រះបន្ទូលនោះវាអាចជាព្រះបន្ទូលដែលបង្រៀនអំពីក្រិត្យវិន័យ ដែលព្រះបន្ទូលយើងអាចបង្រៀនឲ្យពួកជំនុំភ័យខ្លាចត្រូវបណ្តាសា ជាព្រះបន្ទូលនាំឲ្យភ័យខ្លាច តែនេះមិនមែនជាព្រះបន្ទូលនៃដំណឹងល្អទេ។ យើងត្រូវការបង្រៀនព្រះបន្ទូលនៃដំណឹងល្អដល់ពួកជំនុំរបស់យើង ពីព្រោះយើងត្រូវការដំណឹងល្អ ទាំងអស់គ្នាត្រូវការដំណឹងល្អ។ បានជាសាវ័ក ប៉ុល បានប្រាប់ថា “ចូរឲ្យអ្នកប្រើព្រះបន្ទូលនៃដំណឹងល្អ” អ្នកប្រើដំណឹងល្អ ដើម្បីរំឭកពួកជំនុំឲ្យដឹងខ្លួន មិនមែនយើងមានតួនាទីគ្រាន់តែរំឭកពួកគេឲ្យខ្លាចបាបនោះទេ ហើយរបៀបដែលយើងរំឭកពួកជំនុំរបស់ផងយើង បើយើងមិនបានយកដំណឹងល្អទៅរំឭកគេទេ នោះហាក់ដូចជាយកកាំបិតទៅកាប់គេអញ្ចឹង នេះមិនមែនជាបញ្ហារបស់ពួកជំនុំទេ តែពីរបៀបដែលយើងប្រើព្រះបន្ទូលទៅកាន់ពួកគេឲ្យពួកគេឃើញដំណឹងល្អ ឬឲ្យពួកគេទាំងអស់ប្រព្រឹត្តដោយភ័យខ្លាច។ នៅទីនេះយើងត្រូវការដំណឹងល្អដើម្បីក្រើនរំឭកពួកជំនុំឲ្យដឹងខ្លួនពីរឿងជាច្រើនដើម្បីឲ្យពួកគេដឹង ត្រូវប្រើដំណឹងល្អដើម្បីបន្ទោសពួកជំនុំ បទគម្ពីរបានប្រាប់ថា “ចូរអ្នកបន្ទោសដោយដំណឹងល្អ ដោយព្រះ

បន្ទូលនៃដំណឹងល្អ» បានជាយើងត្រូវការស្គាល់ដំណឹងល្អ ត្រូវរស់នៅក្នុងដំណឹងល្អទើបយើងយកដំណឹងល្អដើម្បីបន្ទោសពួកជំនុំបាន។ យើងប្រើដំណឹងល្អដើម្បីកំឡាចិត្តពួកជំនុំ។ មិនមែនត្រឹមតែព្រះបន្ទូលដែលដកចេញពីព្រះគម្ពីរទេ ប៉ុន្តែជាព្រះបន្ទូលនៃដំណឹងល្អ។ ដំណឹងល្អគឺជាដំណឹងល្អដែលបំផ្លាស់បំប្រែជីវិត ដំណឹងល្អដែលមានអំណាចសង្គ្រោះយើងទាំងអស់គ្នា។

អំពើបាបរបស់ពួកជំនុំត្រូវតែដោះស្រាយតាមរយៈដំណឹងល្អ អំពើបាបរបស់យើងត្រូវតែដោះស្រាយជាមួយដំណឹងល្អដោយសារដំណឹងល្អ។ តើយើងបានទទួលនូវការផ្សះផ្សា តើយើងបានទទួលនូវការអត់ទោសបាបដែលយើងបានទទួលទាំងអស់នេះតាមរយៈអ្វី? គឺតាមរយៈដំណឹងល្អ។ ដូច្នេះ ពួកជំនុំក៏ត្រូវការដំណឹងល្អដើម្បីដោះស្រាយអំពើបាបរបស់គេរាល់ថ្ងៃដែរ។ អ្វីដែលខ្ញុំបានលើកឡើងនេះ មិនមែនមានន័យថា គេអាចប្រែចិត្តបានដោយព្រោះមានចែងក្នុងព្រះគម្ពីរទេ តែឲ្យពួកជំនុំមើលឃើញថា ដោយព្រោះព្រះគ្រីស្ទដែលជួយគេ គេអាចធ្វើបានដោយព្រោះព្រះគ្រីស្ទ មិនមែនដោយព្រោះគេអាចធ្វើបានឡើយ។ នេះគឺជាដំណឹងល្អសម្រាប់ពួកជំនុំនិងសម្រាប់យើងទាំងអស់គ្នា។បានជាយើងហៅថាដំណឹងល្អបំផ្លាស់បំប្រែទាំងអស់។ មិនមែនជាគ្រូគង្វាលដែលបំផ្លាស់បំប្រែគេទេ ហើយក៏មិនមែនក្រិត្យវិន័យដែលបំផ្លាស់បំប្រែគេដែរ ក៏ប៉ុន្តែដោយព្រោះដំណឹងល្អដែលបានបំផ្លាស់បំប្រែជីវិតរបស់យើងទាំងអស់គ្នាវិញ។

យើងមើលគំរូមួយដែលសាវ័ក ប៉ុល លើកទឹកចិត្តធីម៉ូថេឲ្យតស៊ូក្នុងទុក្ខលំបាក តើសាវ័ក ប៉ុល លើកទឹកចិត្តធីម៉ូថេអោយតស៊ូក្នុងទុក្ខលំបាកតាមរបៀបណា? គឺសាវ័កប៉ុល បានលើកទឹកចិត្តតាមរយៈដំណឹងល្អ។ ព្រះគម្ពីរ ២ធីម៉ូថេ ២:៨ “ចូរនឹកចាំថាព្រះយេស៊ូវគ្រីស្ទ ជាព្រះវង្សហ្លួងដាវីឌ ទ្រង់បានរស់ពីស្លាប់ឡើងវិញ តាមដំណឹងល្អដែលខ្ញុំផ្សាយប្រាប់”។ នេះគឺជាពាក្យដែលសាវ័ក ប៉ុល លើកទឹកចិត្តធីម៉ូថេឲ្យសម្លឹងមើលព្រះយេស៊ូវ និងមើលការរស់ពីសុគតឡើងវិញរបស់ព្រះយេស៊ូវ។ លោកបង្ហាញ

ធីម៉ូថេឲ្យមានសេចក្តីសង្ឃឹមនៅក្នុងព្រះគ្រីស្ទ ដោយសារដំណឹងល្អនៃព្រះគ្រីស្ទ ដើម្បីព្រះគ្រីស្ទតែមួយគត់។ តើយើងកំពុងតែរស់នៅក្នុងរូបភាពនេះដែរឬទេ? តើយើងលើកទឹកចិត្តពួកជំនុំរបស់យើងតាមរបៀបណា? បានជាសេចក្តីសង្ឃឹមរបស់យើង គុណតម្លៃរបស់យើងមិនមែនស្ថិតនៅលើអ្វីដែលយើងធ្វើសម្រាប់ព្រះនោះទេ ក៏ប៉ុន្តែអាស្រ័យទៅលើអ្វីដែលព្រះធ្វើសម្រាប់យើងវិញ។ នេះគឺជាគុណតម្លៃរបស់ផងយើង នេះគឺជាសេចក្តីសង្ឃឹមរបស់យើង ហើយបើសិនជា សេចក្តីសង្ឃឹមរបស់យើងស្ថិតនៅលើអ្វីដែលព្រះធ្វើសម្រាប់ផងយើង នោះគឺជាសេចក្តីសង្ឃឹមដ៏អស់កល្បជានិច្ចដែលមិនប្រែប្រួល។ ប្រសិនបើយើងអធិប្បាយអំពីដំណឹងល្អដ៏ពិតប្រហែលយើងមិនរំពឹងថា នឹងឮសូរនៅភាពពុះកញ្ជ្រោលនោះទេ ពីព្រោះនៅពេលដែលយើងនិយាយអំពីដំណឹងល្អគឺយើងនិយាយអំពីអំពើបាប និងការប្រែចិត្ត ពេលយើងទៅប្រកាសដំណឹងល្អគឺយើងប្រកាសអំពីអំពើបាប និងការប្រែចិត្ត តែបើយើងទៅប្រកាសអំពីភាពមានបាននោះគឺជាដំណឹងល្អផ្សេងដែលគេមិនចាំបាច់ប្រែចិត្តនោះទេ។ ហេតុនេះ ប្រសិនបើយើងទៅផ្សាយដំណឹងល្អយើងនិយាយអំពីព្រះដ៏បរិសុទ្ធ យើងជាមនុស្សអសមត្ថភាព  ហើយយើងនឹងត្រូវជំនុំជំរះ យើងត្រូវការប្រែចិត្ត ដូច្នេះដំណឹងល្អដែលយើងអធិប្បាយនៅក្នុងព្រះវិហារក៏ជាសារដដែល នេះហៅថាដំណឹងល្អនៅតែដដែល។ នេះគឺជាពេលដែលយើងប្រាប់ពួកជំនុំរបស់យើងឲ្យទុកចិត្តលើព្រះហើយមិនឲ្យមើលឃើញខ្លួនយើងអស្ចារ្យជាងព្រះនោះឡើយ។ មានអំពើបាបជាច្រើនដែលយើងត្រូវការប្រែចិត្តបានជាសេចក្តីទាំងនេះផ្ទុយពីសេចក្តីបង្រៀនបច្ចុប្បន្ន ដែលគ្រូបង្រៀនព្រះបន្ទូលមួយចំនួន បាននាំពួកជំនុំឲ្យមើលឃើញថាខ្លួនខ្លាំង ខ្លួនអស្ចារ្យខ្លួនមានសក្តានុពល។ មានព្រះវិហារខ្លះពួកជំនុំមិនដែលទាំងឮសូរពាក្យថា បាបដែលត្រូវប្រែចិត្តផងសោះនៅក្នុងពេលថ្វាយបង្គំពីមួយសប្តាហ៍ទៅមួយសប្តាហ៍។

មានលោកគ្រូម្នាក់គាត់បាននិយាយថា ពួកជំនុំរបស់គាត់នឿយហត់ពេញមួយសប្តាហ៍ហើយ ដូច្នេះគេមិនចង់ឮពាក្យថាគេមានបាប ឬត្រូវការប្រែចិត្តទៀតទេ គេ

មកព្រះវិហារដើម្បីទទួលបានការលើកទឹកចិត្ត។ មិនខុសទេ យើងទាំងអស់គ្នាត្រូវការការលើកទឹកចិត្ត ក៏ប៉ុន្តែប្រសិនបើ យើងជំរុញលើកទឹកចិត្តគាត់ដោយមិនឈរលើដំណឹងល្អ នោះមិនត្រឹមត្រូវទេ គឺយើងត្រូវជំរុញលើកទឹកចិត្តគាត់ដោយឈរលើដំណឹងល្អ តាមរយៈដំណឹងល្អពីព្រោះយើងចង់សាងសង់ក្រុមជំនុំរបស់យើងនៅលើដំណឹងល្អនៃព្រះគ្រីស្ទ ដូច្នេះយើងត្រូវអធិប្បាយអំពីដំណឹងល្អ ទើបធ្វើឲ្យពួកគាត់រីកចម្រើននៅក្នុងដំណឹងល្អ។

> ដ្បិតនឹងមានគ្រាមក ដែលគេមិនទ្រាំទ្រនឹងសេចក្ដីបង្រៀនដ៏ត្រឹមត្រូវទេ គឺគេនឹងមានត្រចៀករមាស់ ហើយនឹងហៅគ្រូកាន់តែច្រើនឡើង មកបង្រៀនឲ្យត្រូវចិត្ត ៤គេនឹងងាកត្រចៀកចេញពីសេចក្ដីពិត បែរទៅតាមរឿងព្រេងវិញ (៣)។

មិនថាតែលោកីយ៍ដែលមិនចង់ស្ដាប់សេចក្ដីពិត សូម្បីតែពួកជំនុំក៏មិនចង់ស្ដាប់សេចក្ដីពិតដែរ។ ពួកគេនឹងរត់ចេញពីសេចក្ដីពិត ព្រោះគេមិនចង់ស្ដាប់សេចក្ដីពិត។ មិនមែនតែលោកីយ៍ទេដែលបដិសេធសេចក្ដីពិត ពួកជំនុំក៏បដិសេធសេចក្ដីពិតដែរ។ នេះជាអ្វីដែលព្រះគម្ពីរបានប្រាប់យើង។ ខ្ញុំជាម្នាក់ចាប់ផ្ដើមបម្រើព្រះនៅក្រៅការិយាល័យ ក្រៅព្រះវិហារ ខ្ញុំបង្រៀនរបៀបផ្សាយដំណឹងល្អដល់មនុស្សជាច្រើន។ អ្វីដែលនៅក្នុងគំនិតរបស់ខ្ញុំគឺ “យុទ្ធសាស្ត្រ” នៅក្នុងគំនិតខ្ញុំជានិច្ច ព្រោះខ្ញុំគិតពី “ប្រសិទ្ធិភាព”។

បរិបទទីផ្សារ បើអ្នកមិនផ្លាស់ប្ដូរ អ្នកនឹងថយក្រោយហើយ។ នេះជាគ្រោះថ្នាក់របស់ពួកជំនុំព្រះគ្រីស្ទបើមិនប្រយ័ត្នទេ យើងអាចផ្លាស់ប្ដូរគ្រប់យ៉ាងបាន តែអ្វីដែលយើងមិនត្រូវផ្លាស់ប្ដូរគឺជាដំណឹងល្អ យើងមិនត្រូវផ្លាស់ប្ដូរជាដាច់ខាត។ បញ្ហាសព្វថ្ងៃដែលយើងមិនប្រយ័ត្ននោះ គឺយើងផ្លាស់ប្ដូរទាំងគោលបំណងនៃដំណឹងល្អ ដើម្បីឲ្យមានប្រសិទ្ធភាព ហើយការនោះគឺជាគ្រោះថ្នាក់។ បច្ចុប្បន្ននេះកំពុងមានភាពច្របូកច្របល់ចំពោះដំណឹងល្អ ដោយព្រោះមានសេចក្ដីមិនពិតនៅក្នុងសេចក្ដីពិត។ ខ្ញុំមិនឃើញមានអ្នកសរសេរសៀវភៅនិយាយពីដំណឹងល្អដ៏ពិតក្លាយជាមហាសេដ្ឋី

ទេ លើកលែងតែអ្នកដែលសរសេរអំពីដំណឹងល្អនៃភាពចម្រុងចម្រើន ទើបក្លាយជាមហាសេដ្ឋី។

សព្វថ្ងៃដំណឹងល្អនៃភាពចម្រុងចម្រើនកាន់តែមានប្រជាប្រិយភាព ព្រោះមើលទៅល្អ ត្រូវចិត្តចង់បាន គួរជាទីចាប់អារម្មណ៍ ងាយស្រួល កាន់តែស្រលាញ់ព្រះកាន់តែមានបាន រកអីទៀត? ក្រែងព្រះវិហារត្រូវការដង្វាយ? ក្រែងបេសកកម្មត្រូវការដង្វាយ? បើមានលុយច្រើនសម្រាប់ព្រះវិហារហើយរកអ្វីទៀត? គេហទំព័រផ្លូវពិតមានឯកសារគ្រប់គ្រាន់ទាក់ទងនឹងបញ្ហា១នេះ សូមលោកអ្នកយកទៅអានហើយពិចារណាចុះ។

គ្មានអ្នកណានៅទីនេះចង់ក្រ  គ្មានអ្នកណាចង់ឈឺ  នេះជាបំណងចិត្តយើង។ មានព្រះបន្ទូលច្រើនកន្លែងដែលមើលទៅត្រូវចិត្តយើង យើងក៏ថានេះជាបំណងព្រះហឫទ័យព្រះ ប៉ុន្តែតាមរយៈដំណឹងល្អ នោះបង្ហាញឲ្យយើងឃើញថា ចិត្តរបស់យើងអាក្រក់ណាស់ ពីព្រោះព្រះគម្ពីរបានប្រាប់ថាយើងមានបាបហើយខ្វះមិនដល់សិរីល្អនៃព្រះ យើងអាត្មានិយម ហេតុដូច្នេះហើយ យើងត្រូវការសូមព្រះអត់ទោសបាបដល់យើង កុំឲ្យតាមចិត្តយើងឡើយតែជួយយើងឲ្យធ្វើតាមព្រះហឫទ័យព្រះវិញ។ នេះជាគំរូដែលព្រះយេស៊ូវទ្រង់បានធ្វើសម្រាប់យើងនៅក្នុងសួនច្បារកេតសេម៉ានី ទ្រង់បង្ហាញពីគំរូនៃដំណឹងល្អ។ ហេតុនេះ មានឬក្រមិនមែនជារង្វាស់នៃសេចក្តីស្រលាញ់និងស្មោះត្រង់នៅចំពោះព្រះឡើយ តែបើអ្នកគិតថាអ្នកមានពរដោយព្រោះអ្នកមានជំនឿលើសគេ នោះមិនមែនជាដំណឹងល្អ បើអ្នកថា ខ្ញុំក្រ ខ្ញុំស្រលាញ់ព្រះជាងគេ នោះក៏មិនមែនដំណឹងល្អដែរ ព្រោះយើងមិនបានបង្ហាញអំពីព្រះគ្រីស្ទនៅក្នុងជីវិតរបស់យើងទេ។

នៅក្នុងព្រះគម្ពីរ ២ធីម៉ូថេ ៣:១៣-១៤ «ហើយពួកអាក្រក់ និងពួកឆបោក គេនឹងមានជំនឿនជឿនទៅខាងសេចក្តីអាក្រក់កាន់តែខ្លាំងឡើង ទាំងនាំមនុស្សឲ្យវង្វេង ហើយត្រូវវង្វេងខ្លួនឯងផង តែឯអ្នក ចូរឲ្យអ្នកនៅជាប់ក្នុងសេចក្តីដែលអ្នក

បានរៀន ហើយជឿប្រាកដវិញ ដោយដឹងថា អ្នកបានរៀនសេចក្តីនោះពីអ្នកណា»។

បទគម្ពីរនៅត្រង់នេះបានប្រាប់ថា មនុស្សអាក្រក់ និងពួកឆបោកគេនឹងរីកចម្រើន គេនឹងជឿនលឿនតែគេមិនបានរីកចម្រើននៅក្នុងដំណឹងល្អទេ។ តែអ្នករាល់គ្នាចូរឲ្យនៅជាប់ក្នុងសេចក្តីដែលអ្នកបានរៀន ហើយជឿប្រាកដ មានន័យថា យើងត្រូវរៀន យើងត្រូវស្គាល់ដំណឹងល្អហើយនៅជាប់ក្នុងដំណឹងល្អ យើងជឿដំណឹងល្អហើយរស់នៅក្នុងដំណឹងល្អ។

*ទាក់ទងនឹងការរៀន៖*

បើសិនលោកអ្នកមិនបង្រៀនពួកជំនុំទេ  នោះមានគេបង្រៀនជំនួសយើងហើយ ពីព្រោះសម័យនេះទូរស័ព្ទនៅក្នុងដៃគេ មានគ្រូច្រើនណាស់ដែលគេចូលចិត្ត ដែលអាចបំពេញបំណងគេបាន ត្រចៀករបស់គេនឹងរមាស់។ ឧទាហរណ៍៖ ក្រុមឆបោកគេចាប់ផ្តើមជាមួយនឹងសេចក្តីឆបោក ហើយរបៀបដែលគេឆបោកនោះគឺ គេបង្ហោះរូបភាពល្អ ស្អាតៗ ប្រើពាក្យពីរោះ (ព្រះពរ) ដូចជា បើអ្នកចង់ទទួលបានព្រះពរថ្ងៃនេះ សូមចុចលើរូបភាពនេះ ឬនិយាយពាក្យថា អាម៉ែនទៅ។ ចុច! ចូលក្នុងអន្ទាក់របស់គេបាត់។ តើអ្នកឃើញទេ? ដោយព្រោះគាត់ចង់បានពរទើបគាត់ចុច គាត់មិនយល់សោះថានេះជាអន្ទាក់ទេ ពីព្រោះគាត់មិនដឹងថា តើរបៀបដែលគាត់បានពរនោះយ៉ាងម៉េច។ គាត់មិនស្គាល់ដំណឹងល្អ គាត់មិនស្គាល់សេចក្តីពិត គាត់មិនស្គាល់ថាអ្នកណាជាមិត្តអ្នកណាជាសត្រូវ ពីព្រោះគាត់មិនទទួលបាននូវការការពារពីចាស់ទុំ ឬអ្នកដឹកនាំ។

ដូច្នេះ អ្វីដែលអ្នកធ្វើគឺស្មោះត្រង់ចំពោះដំណឹងល្អ កុំបន្ថែម បន្ថំ និងកាឡៃដំណឹងល្អ។ ចូរស្មោះត្រង់ហើយបន្តអធិប្បាយព្រះបន្ទូលនៃដំណឹងល្អដល់ពួកជំនុំ ហើយផ្សាយដំណឹងល្អដដែលនេះទៅផ្សាយដល់លោកីយ៍ មិនមែនតែអ្នកមិនទាន់ជឿដែលត្រូវការដំណឹងល្អទេ គឺទាំងអ្នកជឿ ទាំងគ្រូ និងគ្រួសារគ្រូដែរ។

លោក អរ.ស៊ី ស្ព្រោល (R.C Sproul) បានលើកឡើងថា៖ អ្នកតម្រូវឲ្យជឿហើយអធិប្បាយ និងបង្រៀននូវអ្វីដែលព្រះគម្ពីរនិយាយថាជាសេចក្ដីពិត មិនមែនអ្វីដែលអ្នកចង់ឲ្យព្រះគម្ពីរនិយាយថាជាសេចក្ដីពិតតាមចិត្តអ្នកទេ។ ពេលខ្លះ យើងបកស្រាយព្រះគម្ពីរតាមចិត្តយើង ធ្វើឲ្យព្រះគម្ពីរក្លាយជាចំណាប់ខ្មាំងរបស់យើង។

## ៤. ស្មោះត្រង់នឹងដំណឹងល្អ

នៅក្នុងខទី៥ «តែឯអ្នក ចូរឲ្យមានគំនិតនឹងធឹង ក្នុងគ្រប់ការទាំងអស់វិញ ចូរទ្រាំទ្រនឹងសេចក្ដីលំបាក ចូរឲ្យអ្នកធ្វើការជាគ្រូផ្សាយដំណឹងល្អចុះ ព្រមទាំងបំពេញការងាររបស់ខ្លួនគ្រប់ជំពូកផង»។

ក្នុងអត្ថបទព្រះគម្ពីរនេះ យើងឃើញថា សាវ័ក ប៉ុល បានលើកចំឈ្មោះមនុស្សខ្លះដែលបានដាច់ចេញពីដំណឹងល្អ ក្នុងនោះមាន ភីកេលុស និង ហើម៉ូគេន។ ក្នុងកណ្ឌគម្ពីរ ២ធីម៉ូថេ ១:១៥ ហើយក្នុងជំពូក ៤:១០ មាន ដេម៉ាស។ នៅទីនេះសាវ័ក ប៉ុល បានប្រាប់យើងពីមនុស្សមួយចំនួនដែលពួកគេបានតស៊ូរហូតដល់ជិតចប់ ប៉ុន្តែគេបានបោះបង់ចោលនៅពេលដែលគេជិតដល់ចុងបញ្ចប់។ មានសេចក្ដីរំខានជាច្រើនដែលធ្វើឲ្យយើងមិនអាចរត់ទៅមុខ យើងត្រូវការការលើកទឹកចិត្ត យើងត្រូវការកម្លាំងចិត្តដើម្បីរុញយើងទៅមុខ ហើយកម្លាំងចិត្តនោះគឺដំណឹងល្អ។ នៅត្រង់នេះ អ្នកខ្លះនិយាយថា វាដូចជាមិនអីទេលោកគ្រូ ឲ្យតែនាំព្រលឹងមនុស្សថ្វាយព្រះបានច្រើនមិនថារបៀបណាក៏បាន ប៉ុន្តែសាវ័ក ប៉ុល មានប្រសាសន៍ថា មិនថាជាតាមរបៀបណានោះទេ សូមអធិប្បាយដំណឹងល្អដ៏ពិតវិញ។

ព្រះវិហារគេធំៗណាស់លោកគ្រូ គេស្រឡាញ់ព្រះ គេមានដង្វាយច្រើន គេមានបេសកកម្មច្រើន គេសកម្មក្នុងការបម្រើ ចំណែកព្រះវិហារខ្ញុំមានគ្នាតិច ពួកជំនុំមិនស្រឡាញ់ព្រះ ដង្វាយតិច មិនមានអ្នកបម្រើច្រើន។ តើអ្នកទុកចិត្តលើព្រះចេស្ដាព្រះក្នុងភាពកម្សោយរបស់អ្នក ឬក៏ទុកចិត្តចំពោះសមត្ថភាពរបស់អ្នកដើម្បីទទួល

ព្រះចេស្តាទ្រង់?

សាវ័ក ប៉ុល បានមានប្រសាសន៍នៅក្នុងកណ្ឌគម្ពីរ ២កូរិនថូស ១២:៩ ថា «តែទ្រង់មានបន្ទូលមកខ្ញុំថា គុណរបស់អញល្មមដល់ឯងហើយ ដ្បិតកំឡាំងអញបានពេញខ្នាត ដោយសេចក្ដីកំសោយ ដូច្នេះ ខ្ញុំនឹងស៊ូអួតពីសេចក្ដីកំសោយរបស់ខ្ញុំដោយអំណរជាខ្លាំង ដើម្បីឲ្យព្រះចេស្តានៃព្រះគ្រីស្ទបានសណ្ឋិតនៅនឹងខ្ញុំ»។ បានជាទិសដៅរបស់ផងយើង គឺថ្វាយសិរីល្អដល់ផងព្រះជាមួយនឹងអ្វីដែលព្រះប្រទានឲ្យយើង ពួកជំនុំដ៏ពិតប្រាកដ គឺជាពួកជំនុំដែលសង់នៅលើដំណឹងល្អដ៏ពិត។

ខ្មែរខ្លះឃើញចិនមានស្តុកស្តម្ភ ក៏ខំសែនតាមចិន។ តើអ្នកត្រូវប្ដូរគោលជំនឿ និងយកសេចក្ដីបង្រៀនរបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយមកដាក់នៅពួកជំនុំរបស់អ្នក ដើម្បីឲ្យបានព្រះវិហារធំដូចពួកបរិសុទ្ធថ្ងៃចុងក្រោយទេ? អត់ទេ! ព្រោះអ្នកដឹងថានោះជាក្រុមខុសឆ្គង ពួកគេមិនបានបង្រៀនអំពីដំណឹងល្អដ៏ពិត។ ចុះហេតុអ្វីបានជាអ្នកចង់ដូច លោក Steven Furtick Jr, លោក Benny Hinn, លោក Joel Osteen, និងលោក Kenneth Copeland បើអ្នកដឹងថា ទាំងនោះមិនមែនជាដំណឹងល្អដ៏ពិតហើយ?

## សេចក្ដីបញ្ចប់

យើងបានសង្គ្រោះដោយសារដំណឹងល្អ យើងរស់នៅដោយដំណឹងល្អ យើងជាអ្នកបម្រើដំណឹងល្អ។

១. ត្រូវស្គាល់ដំណឹងល្អឲ្យកាន់តែច្បាស់ ដោយការរៀន ហើយពួកជំនុំយើងក៏ត្រូវការរៀនដែរ។

២. អនុវត្តដំណឹងល្អក្នុងជីវភាពរស់នៅ។ -រស់ក្នុងជីវិតដែលឆ្លុះបញ្ចាំងពីដំណឹងល្អនៅគ្រប់កាលៈទេសៈ - ដំណឹងល្អមិនគ្រាន់តែជាទ្រឹស្ដី ឬសារប៉ុណ្ណឹងទេ តែ

ជាអំណាចនាំមកនូវជីវិតផ្លាស់ប្រែ សម្លាប់និស្ស័យខាងសាច់ឈាមដើម្បីឲ្យរស់នៅស្របតាមបំណងព្រះហឫទ័យព្រះ។

៣. ចូរស្មោះត្រង់ក្នុងការប្រកាសដំណឹងល្អដ៏ពិតដោយសំឡឹងមើលទៅឯព្រះគ្រីស្ទ មិនមែនទៅលើសមិទ្ធផលទេ។

កុំឲ្យសមិទ្ធផលបានធ្វើឲ្យយើងពុះកញ្ជ្រោល ក៏ប៉ុន្តែសូមឲ្យយើងជាប់នៅជាមួយដំណឹងល្អវិញ។

៤. ព្រះគ្រីស្ទគឺជាម្ចាស់លើពួកជំនុំ មិនមែនគ្រូគង្វាលទេ ហើយយើងក៏មិនយកសមិទ្ធផលទៅអួតព្រះដែរ តែជាសេចក្ដីស្មោះត្រង់ក្នុងដំណឹងល្អដ៏ពិតវិញ។

# ចូរដាស់តឿន–កុំលក់

និពន្ធដោយៈ លោក ម៉ៃឃើល ឡរ៉េនស៍ (MICHAEL LAWRENCE)

(២កូរិនថូស ៤:១-៧, ៥:១៤-២១; កិច្ចការ ១៦:២៥-៣៤)

មានហាងទំនិញមួយបានបើកលក់អីវ៉ាន់ជាច្រើនឆ្នាំហើយនៅប្រទេសយើង។ ជារៀងរាល់ព្រឹក ម្ចាស់ហាងតែងតែដើរមើលជុំវិញហាងរបស់គាត់ ដើម្បីប្រាកដថា អាជីវកម្មរបស់គាត់ដំណើរការ តាមដែលវាគួរតែដំណើរការ។ នៅពេលព្រឹកមួយ ម្ចាស់ហាងគាត់បានឃើញអ្នកគ្រប់គ្រងរបស់គាត់ម្នាក់កំពុងតែដោះស្រាយជាមួយនឹងស្រ្តីជាអតិថិជនម្នាក់។ គាត់បានសួរទៅកាន់អ្នកគ្រប់គ្រងថា *«តើអ្នកកំពុងតែធ្វើអ្វីហ្នឹង...?»* អ្នកគ្រប់គ្រងឆ្លើយថា *«ខ្ញុំកំពុងតែដោះស្រាយបញ្ហាជាមួយនឹងអតិថិជន»*។ *ម្ចាស់ហាងបានតបទៅវិញថា «ទេ! អ្នកមិនត្រូវធ្វើដូច្នេះទេ ស្រ្តីនាងចង់បានអ្វី ចូររកយកមកឲ្យនាងទៅ»*។

នៅពេលដែលទីផ្សារសេរីបានចាប់ផ្តើមមានភាពរីកចម្រើនឡើង អ្នកលក់នឹងចាប់ផ្តើមយល់អំពីការដែលថាអតិថិជន គឺជាស្តេច។ កាលពីមុន យើងច្រើនតែឮគេថា «អ្នកទិញត្រូវប្រុងប្រយ័ត្ន» ដែលនោះហើយជាទំនាក់ទំនងរវាងអតិថិជន (អ្នកទិញ) នឹងអ្នកលក់។ សព្វថ្ងៃនេះវិញ មានគោលការណ៍ថ្មីមួយ ដែលធ្វើឲ្យប្រជាជនអាមេរិកបានចម្រើនឡើងនោះគឺៈ *«អតិថិជនត្រូវជានិច្ច»*។ ទីផ្សារប្រភេទនេះ តម្រូវការរបស់អតិថិជនមានសារៈសំខាន់លើសជាងអ្វីៗទាំងអស់ ហើយជាកាតព្វកិច្ចរបស់អ្នកលក់ក្នុងការបំពេញតាមតម្រូវការនោះ។ នោះមានន័យថា អ្នកលក់ត្រូវបង្កើតសេចក្តីត្រូវ

ការសម្រាប់អតិថិជន ទោះបីជាអតិថិជនមិនទាំងដឹងថា ពួកគេត្រូវការអ្វីក៏ដោយ។

នៅក្នុងបរិយាកាសនេះ ទីផ្សារមានការក្រឡាប់ចក្រយ៉ាងខ្លាំង។ អ្នកធ្វើការផ្នែកលក់ផ្ដោតតិចតួច ក្នុងការចំណាយពេលពន្យល់អតិថិជនអំពីគុណភាពរបស់ផលិតផល តែផ្ដោតច្រើនលើការបញ្ចុះបញ្ចូលអ្នកប្រើប្រាស់ដោយថា មិនថាពួកគេចង់បានបែបណានោះទេ ផលិតផលនេះនឹងធ្វើឲ្យពួកគេពេញចិត្ត។ មិនខ្វល់ថាផលិតផលជាអ្វីនោះទេ—អាចជារថយន្ត ឬថ្នាំដុសធ្មេញ ម៉ាស៊ីនបឺតក្លិន ឬម៉ាស៊ីនបោកគក់ក្ដី។ ស្ត្រីនាងចង់បានអ្វី ចូរទៅរកយកមកឲ្យនាងទៅ ចូរបំពេញតាមសេចក្ដីត្រូវការរបស់នាងទៅ នោះអ្នកនឹងលក់ដាច់ជាមិនខាន។

ទ្រឹស្ដីបែបនេះមិនត្រូវការចំណាយពេលយូរពេកទេ ក្នុងការចរចាពីទីផ្សារមុខជំនួញចូលទៅក្នុងទីផ្សារខាងជំនឿសាសនាឡើយ។ តើមានអ្វីខ្លះស៊ីគ្នារវាង «តម្រូវការ» ដែលយើងត្រូវការការអត់ទោសទៅនឹង «ផលិតផល» នៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ? បើលោកអ្នកក្រឡេកមើលទៅកាន់ឧបករណ៍បង្វឹកបង្វឹននៅដើមសតវត្សទី២០នេះ អ្វីដែលលោកអ្នកឃើញនោះ គឺជាក្បួនសម្រាប់លក់។

យ៉ាងណាមិញ ទីផ្សារមិននៅស្ងៀមមួយកន្លែងនោះទេ។ សព្វថ្ងៃនេះ មនុស្សភាគច្រើនមិនមានអារម្មណ៍ថា មានតម្រូវការ ក្នុងការទទួលបានសេចក្ដីសង្គ្រោះនោះឡើយ។ ពួកគេចង់បានអ្វីផ្សេងដូចជាៈ សុភមង្គល ការសម្រេចតាមក្ដីស្រមៃ ភាពជោគជ័យ ជីវិតគ្រួសារល្អប្រសើរ ជីវិតផ្លូវភេទដ៏ត្រេកត្រអាលជាដើម។ ហេតុនេះក្រុមជំនុំក៏បានឆ្លើយតប ដោយការផ្សាយដំណឹងល្អបែបបំពេញតាម «តម្រូវការខាងអារម្មណ៍»។ ដើម្បីអាចនាំគេឲ្យជឿព្រះជាម្ចាស់ ជំនួសឲ្យផ្សាយដំណឹងល្អនៃ «ការអត់ទោសបាប» ដែលជាដំណឹងល្អដើម យើងបែរទៅជាផ្សាយដំណឹងល្អបែបបំពេញតាមសេចក្ដីត្រូវការនៃជីវិតនេះទៅវិញ។ មានអ្នកផ្សាយដំណឹងល្អល្បីល្បាញម្នាក់ គាត់បានលើកឡើងថា *«សម្រាប់គេនោះ ការងាកចេញពីព្រះហាក់មិនមែនស្ថិតក្នុងសេចក្ដីក្រោធរបស់ព្រះ ដូចដែលមិនទទួលបានជីវិតដែលជោគជ័យឡើយ»*

(Wells, ទំព័រ៣០៣)។ ហើយបុគ្គលល្បីល្បាញដែលជាអ្នកផ្សាយដំណឹងល្អម្នាក់ផ្សេងទៀត ក៏លើកឡើងស្រដៀងគ្នាផងដែរថា *"វាគឺជាបំណងចិត្តដ៏ជ្រាលជ្រៅរបស់ខ្ញុំដែលចង់ឃើញ គ្រប់មនុស្សអាចនឹងជឿព្រះគ្រីស្ទ បើយើងអាចរកឃើញកូនសោចូលទៅកាន់ដួងចិត្តរបស់គេឃើញ...តែពេលខ្លះពិបាករកឃើញណាស់។ ប៉ុន្តែ ភាគច្រើនលោកអ្នកអាចចាប់ផ្តើមដោយរកអ្វី ដែលបុគ្គលនោះមានអារម្មណ៍ថា ត្រូវការ"* (Warren, ទំព័រ២១៩)។ វិធីសាស្ត្រនេះយើងហៅថា ការផ្សាយដំណឹងល្អបែបផលប្រយោជន៍ ឬការអធិប្បាយដែលតម្រូវតាមចិត្តអ្នកស្តាប់។ វាគឺជាគន្លឹះផ្សាយតាមបែបធ្វើទីផ្សារ ដោយផ្សាយពីព្រះយេស៊ូវទៅកាន់វប្បធម៌នៃអ្នកប្រើប្រាស់ លក់ ដើម្បីសង្គ្រោះព្រលឹង។

ហើយវាបានផលពិតមែន។ យ៉ាងហោចណាស់ នៅសហរដ្ឋអាមេរិក។ មនុស្សមកថ្វាយបង្គំពេញៗក្រុមជំនុំ មនុស្សទទួលបានការសង្គ្រោះពីជីវិតដែលគ្មានគោលដៅ ជីវិតដែលគ្មានភាពរីករាយ។ ប៉ុន្តែ តើពួកគេពិតជាទទួលបានសេចក្តីសង្គ្រោះ ហើយរួចផុតពីសេចក្តីក្រោធរបស់ព្រះជាម្ចាស់មែនឬ?

តើអ្វីទៅជាអត្ថន័យនៃគោលលទ្ធិស្តីពីការប្រែចិត្តជឿរបស់គ្រីស្ទបរិស័ទ ទាក់ទងនឹងការផ្សាយដំណឹងល្អ? គោលលទ្ធិស្តីពីការប្រែចិត្តជឿរបស់គ្រីស្ទបរិស័ទមានន័យថា ការផ្សាយដំណឹងល្អមិនមែនជាវិធីសាស្ត្រលក់ដែលយើងបិទការលក់ ដោយផ្សារភ្ជាប់ផលិតផលទៅនឹងតម្រូវការនៃអ្នកប្រើប្រាស់នោះទេ។ ការផ្សាយដំណឹងល្អ គឺជាការប្រកាសសារដែលមានសិទ្ធិអំណាចចេញមកពីព្រះជាម្ចាស់ ដោយស្មោះត្រង់។ ដំណឹងល្អ គឺជាសារដែលប្រាប់យើងអំពីតម្រូវការពិតប្រាកដរបស់យើង មិនថាយើងមានអារម្មណ៍ថា ត្រូវការ ឬក៏អត់ឡើយ។ ដំណឹងល្អ គឺជាសារដែលយើងគ្រប់គ្នាត្រូវតែឆ្លើយតប។ ដំណឹងល្អ គឺជាសារដែលបណ្តាលដោយព្រះវិញ្ញាណបរិសុទ្ធ មិនមែនជាវិធីសាស្ត្រលក់របស់យើងទេ តែជាឫទ្ធានុភាពរបស់ព្រះជាម្ចាស់សម្រាប់សេចក្តីសង្គ្រោះ និងការប្រែចិត្តជឿនៃមនុស្សបាប ដូចជាលោកអ្នក ហើយនឹងខ្ញុំ។

អ្វីដែលខ្ញុំចង់ធ្វើ ដើម្បីជាការរម្លឹកអំពីពេលវេលារបស់យើងនេះ គឺយើងនឹងធ្វើការពិចារណាអំពីរបៀបដែលយើងប្រកាសសារនៃសេចក្ដីសង្គ្រោះរបស់ព្រះជាម្ចាស់ដែលមាននៅក្នុងដំណឹងល្អ។ ដើម្បីអាចធ្វើបែបនោះបាន នោះយើងនឹងផ្ដោតទៅលើអ្វីដែលសាវ័ក ប៉ុល បានលើកឡើងស្ដីពីការប្រកាសដំណឹងល្អនៅក្នុងកណ្ឌគម្ពីរ ២កូរិនថូស ៤:១-៧៖

> «ដូច្នេះ ដែលមានការងារនេះ នោះយើងខ្ញុំមិនណាយចិត្តឡើយ តាមខ្នាតនៃសេចក្តីមេត្តាករុណា ដែលយើងខ្ញុំទទួលមក យើងខ្ញុំលះចោលអស់ទាំងការលាក់កំបាំងដែលគួរខ្មាស ឥតប្រព្រឹត្តដោយឧបាយកល ឬបំប្លែងព្រះបន្ទូលឡើយ គឺយើងខ្ញុំផ្ទុកផ្តាក់ខ្លួន នឹងបញ្ញាចិត្តរបស់មនុស្សទាំងអស់ នៅចំពោះព្រះ ដោយសម្តែងសេចក្តីពិតវិញ បើសិនណាជាដំណឹងល្អរបស់យើងខ្ញុំត្រូវគ្របបាំង នោះគឺត្រូវគ្របបាំងចំពោះតែពួកអ្នក ដែលកំពុងវិនាសទេ ជាពួកអ្នកដែលព្រះរបស់លោកីយ៍នេះ បានបង្អាប់ដល់គំនិតពួកគេដែលមិនជឿ ក្រែងរស្មីពន្លឺនៃដំណឹងល្អ ដែលសម្តែងពីសិរីល្អនៃព្រះគ្រីស្ទដ៏ជារូបអង្គព្រះ បានភ្លឺមកដល់គេ យើងខ្ញុំមិនប្រកាសប្រាប់ពីខ្លួនយើងខ្ញុំទេ គឺពីព្រះគ្រីស្ទយេស៊ូវជាព្រះអម្ចាស់វិញ ហើយក៏រាប់ខ្លួនយើងខ្ញុំ ថាជាបាវបម្រើរបស់អ្នករាល់គ្នាដោយព្រោះព្រះយេស៊ូវដែរ ដ្បិតគឺជាព្រះ ដែលមានបន្ទូលបង្គាប់ ឲ្យមានពន្លឺភ្លឺចេញពីសេចក្តីងងឹត ទ្រង់បានបំភ្លឺមកក្នុងចិត្តយើងខ្ញុំ ឲ្យយើងខ្ញុំមានរស្មីពន្លឺនៃដំណើរស្គាល់សិរីល្អរបស់ព្រះ ដែលនៅព្រះភក្ត្រនៃព្រះយេស៊ូវគ្រីស្ទ។ យើងមានទ្រព្យសម្បត្តិនេះនៅក្នុងភាជនៈដី ដើម្បីឲ្យឥទ្ធិឫទ្ធីដ៏លើសលប់បានមកពីព្រះ មិនមែនពីយើងខ្ញុំទេ»។

សូមអាន ២កូរិនថូស ៥:១១-២១៖

> «ដូច្នេះ ដែលស្គាល់សេចក្តីស្ញែងខ្លាចរបស់ព្រះអម្ចាស់ នោះយើងខ្ញុំក៏ខំបញ្ចុះបញ្ចូលមនុស្សឲ្យជឿ តែយើងខ្ញុំជាអ្នកប្រាកដច្បាស់ដល់ព្រះហើយ ខ្ញុំក៏សង្ឃឹមថា ដល់បញ្ញាចិត្តរបស់អ្នករាល់គ្នាដែរ ដ្បិតយើងខ្ញុំមិនមែនផ្ទុកផ្តាក់ខ្លួននឹងអ្នករាល់គ្នាម្តងទៀតទេ គឺយើងខ្ញុំឲ្យអ្នករាល់គ្នាមានឱកាសនឹងអួតពីយើងខ្ញុំ

> វិញ ដើម្បីឲ្យអ្នករាល់គ្នាមានពាក្យតបឆ្លើយ ដល់អស់អ្នកដែលអួតតែពីចរិតខាងក្រៅ មិនមែនពីសណ្ឋានក្នុងចិត្តនោះទេ ដ្បិតទោះបើយើងខ្ញុំវង្វេងស្មារតីក្ដី នោះគឺវង្វេងសម្រាប់ព្រះអង្គ ឬបើមានគំនិតនឹងធឹងក្ដី ក៏សម្រាប់អ្នករាល់គ្នាវិញ ដ្បិតសេចក្ដីស្រឡាញ់របស់ព្រះគ្រីស្ទបង្ខំយើងខ្ញុំ ដោយយើងខ្ញុំពិចារណាឃើញថា បើម្នាក់បានស្លាប់ជំនួសអ្នកទាំងអស់នោះទាំងអស់ឈ្មោះថាបានស្លាប់ហើយ ទ្រង់ក៏បានសុគតជំនួសមនុស្សទាំងអស់យ៉ាងនោះ គឺដើម្បីឲ្យពួកអ្នកដែលរស់នៅ មិនរស់សម្រាប់តែខ្លួនឯងទៀត គឺរស់សម្រាប់ព្រះអង្គដែលសុគតជំនួសគេ ហើយបានរស់ឡើងនោះវិញ បានជាពីនេះទៅមុខ យើងខ្ញុំមិនស្គាល់អ្នកណាខាងឯសាច់ឈាមទៀតទេ តែបើយើងខ្ញុំបានស្គាល់ព្រះគ្រីស្ទខាងសាច់ឈាមហើយ គង់តែឥឡូវនេះមិនស្គាល់ទ្រង់យ៉ាងនោះទៀតឡើយ បានជាបើអ្នកណានៅក្នុងព្រះគ្រីស្ទ នោះឈ្មោះថាបានកើតជាថ្មីហើយ អស់ទាំងសេចក្ដីចាស់បានកន្លងបាត់ទៅ។ មើល គ្រប់ទាំងអស់បានត្រឡប់ជាថ្មីវិញ គ្រប់ទាំងអស់ក៏មកពីព្រះ ដែលទ្រង់បានផ្សះផ្សាយើងនឹងព្រះអង្គទ្រង់ ដោយសារព្រះយេស៊ូវគ្រីស្ទ ហើយបានប្រទានការងារផ្សះផ្សានោះ មកយើងខ្ញុំដែរ គឺពីដំណើរដែលព្រះទ្រង់គង់ក្នុងព្រះគ្រីស្ទ កំពុងផ្សះផ្សាលោកីយ៍នឹងព្រះអង្គទ្រង់ ឥតប្រកាន់ទោសគេទៀត ហើយទ្រង់បានប្រគល់ព្រះបន្ទូលពីការផ្សះផ្សានោះមកយើងខ្ញុំ។ ដូច្នេះ យើងខ្ញុំជាទូតដំណាងព្រះគ្រីស្ទ ហាក់ដូចជាព្រះទ្រង់អង្វរដោយសារយើងខ្ញុំ គឺយើងខ្ញុំអង្វរគេជំនួសព្រះគ្រីស្ទថា ចូរឲ្យបានជាមេត្រីនឹងព្រះចុះ ដ្បិតឯព្រះអង្គ ដែលមិនបានស្គាល់បាបសោះ នោះព្រះទ្រង់បានធ្វើឲ្យត្រឡប់ជាតួបាប ជំនួសយើងរាល់គ្នាវិញ ដើម្បីឲ្យយើងរាល់គ្នាបានត្រឡប់ទៅជាសេចក្ដីសុចរិតរបស់ព្រះ ដោយនូវព្រះអង្គនោះឯង»។

ខ្ញុំចង់ផ្ដោតលើ៤ចំណុច។ *ទី១* យើងគួរតែប្រកាសដំណឹងល្អ*ដោយឥតលាក់កំបាំង*។ *ទី២* យើងគួរតែប្រកាសដំណឹងល្អ*ដោយស្មោះត្រង់*។ *ទី៣* យើងគួរតែប្រកាសដំណឹងល្អ*ដោយភាពបន្ទាន់*។ *ទី៤* ចុងក្រោយ យើងគួរតែប្រកាសដំណឹងល្អ*ដោយមានទំនុកចិត្ត*។ ខ្ញុំសង្ឃឹមថា លោកអ្នកនឹងទទួលបានការលើកទឹកចិត្ត ចេញពីការខិតខំប្រឹងប្រែងផ្សាយដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ។

*ទី១* យើងត្រូវប្រកាសដំណឹងល្អ*ដោយឥតលាក់កំបាំង*។ ក៏មានសេចក្តីបង្រៀនមួយចំនួនស្តីពីរបៀបផ្សាយដំណឹងល្អផងដែរ។ សូមមើលទៅកាន់កណ្ឌគម្ពីរ ២កូរិនថូស ៤:១-២ *«ដូច្នេះ ដែលមានការងារនេះ នោះយើងខ្ញុំមិនណាយចិត្តឡើយ តាមខ្នាតនៃសេចក្តីមេត្តាករុណា ដែលយើងខ្ញុំទទួលមក យើងខ្ញុំលះចោលអស់ទាំងការលាក់កំបាំងដែលគួរខ្មាស ឥតប្រព្រឹត្តដោយឧបាយកល ឬបំប្លែងព្រះបន្ទូលឡើយ គឺយើងខ្ញុំផ្ទុកផ្តាក់ខ្លួន និងបញ្ញាចិត្តរបស់មនុស្សទាំងអស់នៅចំពោះព្រះដោយសម្តែងសេចក្តីពិតវិញ»*។ សាវ័ក ប៉ុល បានលើកឡើងថា ព័ន្ធកិច្ចរបស់គាត់បានកើតឡើងដោយសេចក្តីបង្គាប់ និងដោយអំណាចនៃព្រះជាម្ចាស់។ ហេតុដូច្នេះហើយ គោលដៅរបស់សាវ័ក ប៉ុល គឺដើម្បីនឹងបង្ហាញដោយ *«ឥតលាក់កំបាំង…ឬបំប្លែងព្រះបន្ទូលឡើយ»*។ ចំណុចសំខាន់ដែលសាវ័ក ប៉ុល លើកឡើងនេះ ពិតជាគ្មានអ្វីដែលលាក់កំបាំងសោះឡើយ។ បើយើងវាស់វែងការផ្សាយដំណឹងល្អដែលជោគជ័យ អាស្រ័យទៅលើចំនួនមនុស្សឆ្លើយតបចំពោះដំណឹងល្អ អ្នកប្រកាសដំណឹងល្អអាចនឹងត្រូវល្បួងដូចអ្វីដែល សាវ័ក ប៉ុល បានហៅថា *«…លាក់កំបាំងដែលគួរខ្មាស ឥតប្រព្រឹត្តដោយឧបាយកល ឬបំប្លែងព្រះបន្ទូលឡើយ»* ដែលអាចនឹងមានគេប្រើការបោកបញ្ឆោត ប្រើនុយ និងកុងតាក់បញ្ជោ ដែលគេអាចនឹងបំប្លែងសម្រួលព្រះបន្ទូល ឬកែសេចក្តីអធិប្បាយរបស់គេតម្រូវទៅតាមអ្វីដែលមនុស្សចង់ឮវិញ ពួកគេធ្វើដូច្នោះដើម្បីបង្កើនឱកាសជោគជ័យ។ ប៉ុន្តែ សាវ័ក ប៉ុល បានប្រាប់ឲ្យយើង*លះចោល*ការទាំងនោះវិញ។

សាវ័ក ប៉ុល មិនបានពន្យល់អ្វីបន្ថែមលើ*សេចក្តីពិត* ដែលមាននៅបទគម្ពីរនេះឡើយ។ សាវ័ក ប៉ុល ប្រហែលជាបានរំពឹងថា ពួកគេបានយល់អំពីអ្វីដែលលោកចង់និយាយរួចហើយ ខណៈដែលខ៥ លោកបានលើកឡើងទៀតថា ពួកគេ*ប្រកាសប្រាប់ពីព្រះគ្រីស្ទយេស៊ូវជាព្រះអម្ចាស់*។ នៅក្នុងសំបុត្រទី១ លោកបានពន្យល់ក្បោះក្បាយជាងនេះ *១កូរិនថូស ១៥:១-៨៖ ព្រះគ្រីស្ទបានសុគតដោយព្រោះបាបយើង…*

*គេបានបញ្ចុះទ្រង់នៅក្នុងផ្នូរ...រួចដល់ថ្ងៃទីបី ទ្រង់មានព្រះជន្មរស់ឡើងវិញ...ហើយមានសាក្សីជាច្រើនឃើញទ្រង់បានលេចមក។*

ឱលោកអ្នកបងប្អូនជាទីស្រឡាញ់អើយ យើងត្រូវតែប្រកាសដំណឹងល្អ ដោយឥតលាក់កំបាំង ច្បាស់ៗ ដោយសេចក្តីពិតត្រង់ ពីព្រោះដំណឹងល្អ គឺជាសេចក្តីពិត ហើយជាឫទ្ធានុភាពនៃព្រះសម្រាប់សេចក្តីសង្គ្រោះ។ លោកអ្នកបងប្អូនប្រហែលជាធ្លាប់ឮពាក្យស្លោកមួយឃ្លានេះថា៖ *ប្រកាសដំណឹងល្អ បើចាំបាច់ ត្រូវប្រើព្រះបន្ទូល។* ជាក់ស្តែងណាស់ ព្រះជាម្ចាស់គាប់ព្រះទ័យឲ្យយើងចាំបាច់ប្រើព្រះបន្ទូល ហើយសាវ័ក ប៉ុល ក៏លើកទឹកចិត្តយើងដូច្នោះដែរ។ នេះមិនមែនមានន័យថា មានរបៀបជាក់លាក់តែមួយ ក្នុងការពន្យល់ព្រះបន្ទូលនោះទេ។ មានរបៀបផ្សេងៗជាច្រើនដែលលោកអ្នកអាចនឹងសង្ខេបសេចក្តីបង្រៀនស្តីពីដំណឹងល្អ។ បួនពាក្យដែលងាយស្រួល ហើយច្បាស់បំផុតសម្រាប់ការប្រកាសដំណឹងល្អ ដែលខ្ញុំស្គាល់នោះគឺ៖ «ព្រះ មនុស្ស ព្រះគ្រីស្ទ និងការឆ្លើយតប»។ ដំណឹងល្អប្រាប់យើងអំពីព្រះ...អំពីខ្លួនយើង...អំពីព្រះគ្រីស្ទ...និងអំពីរបៀបដែលយើងត្រូវឆ្លើយតប...

បងប្អូនអើយ នេះគឺជាដំណឹងដ៏ល្អស្តីពីដំណឹងល្អ។ ដំណឹងល្អមិនមែនគ្រាន់តែជាសេចក្តីបង្រៀនចេញពីគំនិតល្អរបស់មនុស្សដែលថា ព្រះជាម្ចាស់ស្រឡាញ់យើង ឬក៏ថា យើងមិនអីទេ ឬថាព្រះយេស៊ូវចង់ធ្វើជាមិត្តសម្លាញ់របស់យើង ឬក៏ថាព្រះយេស៊ូវនឹងប្រទានគោលបំណងនៃជីវិតសម្រាប់យើងនោះទេ។ ដំណឹងល្អ មិនបានសន្យាថានឹងជួយឲ្យជីវិតអាពាហ៍ពិពាហ៍របស់លោកអ្នកឲ្យល្អប្រសើរឡើង ឬក៏ថានឹងជួយឲ្យកូនៗរបស់លោកអ្នកឲ្យមានអនាគតល្អនោះដែរ។ ដំណឹងល្អក៏មិនសន្យាថា នឹងជួយជីវិតផ្លូវភេទរបស់លោកអ្នកឲ្យល្អប្រសើរឡើង ឬក៏ថាលោកអ្នកនឹងមានភាពសប្បាយរីករាយនៅកន្លែងធ្វើការច្រើនជាងមុននោះដែរ។ បើលោកអ្នកបងប្អូនជាគ្រីស្ទបរិស័ទដែលដើរតាមព្រះគ្រីស្ទដោយស្មោះត្រង់ អ្វីៗដែលលើកឡើងខាងលើនេះ អាចនឹងកើតមានដល់លោកអ្នក ប៉ុន្តែជាញយដង មិនបានកើតមានឡើងដូច្នោះ

ទេ។ ចំណុចស្នូលនៃដំណឹងល្អគឺជាព្រះជន្មរបស់ព្រះគ្រីស្ទ ការសុគត ការមានព្រះជន្មរស់ឡើងវិញ ដែលជាដង្វាយសម្រាប់លោះបាបយើង ដើម្បីរម្ងាប់សេចក្ដីក្រោធរបស់ព្រះជាម្ចាស់ និងដើម្បីឲ្យយើងបានជានាជាមួយនឹងទ្រង់វិញ។

ការបំពេញតម្រូវការខាងអារម្មណ៍ អាចនឹងមានប្រយោជន៍ក្នុងការពិនិត្យមើលដួងចិត្តរបស់ពួកគេផ្ទាល់។ ប៉ុន្តែ យើងត្រូវតែប្រុងប្រយ័ត្ន ចំពោះការបំពេញទៅតាមតម្រូវការទីផ្សារ ដែលអតិថិជនជាស្ដេច ហើយអតិថិជនត្រូវជានិច្ចនោះ។ *តើអ្វីដែលអ្នកលក់ឡាននឹងនិយាយថា រសនិយមអ្នកហាក់ដូចជាហួសហេតុបន្តិចហើយ?* (ដកស្រង់ចេញពីសៀវភៅ Wells, ទំព័រ៣០២)។ ប៉ុន្តែ បើយោងទៅតាមទស្សនៈវិស័យរបស់ព្រះគម្ពីរវិញ *"អ្នកប្រើប្រាស់នឹងមិនអាចជ្រើសរើសតាមតែចិត្តឡើយ ពីព្រោះក្នុងនាមយើងជាមនុស្សមានបាប យើងតែងតែយល់ខុសពីតម្រូវការទាំងនោះ"* ហើយតម្រូវការទាំងនោះមិនមានអព្យាក្រឹតភាពឡើយ។ (ដកស្រង់ចេញពីសៀវភៅដដែល) នោះនៅពេលយើងផ្ដល់ភាពសប្បាយរីករាយ និងជីវិតក្រុមគ្រួសារដែលល្អប្រសើរជាងមុនតាមរយៈព្រះយេស៊ូវគ្រីស្ទ គ្មានអ្វីចម្លែកនោះទេ មនុស្សភាគច្រើនឆ្លើយតបដោយវិជ្ជមាន។ ដូចដែលលោក ចហ្គ បាណា (George Barna) បានរកឃើញតាមរយៈការស្ទង់មតិស្ដីពីការទៅចូលរួមក្រុមជំនុំ និងជំនឿរបស់ពួកអ្នកដែលធំធាត់ឡើងនៅពេលដែលសេដ្ឋកិច្ចមានការរីកចម្រើន ជាក្រុមមនុស្សដែលទទួលបានដំណឹងល្អ ដែលតម្រូវតាមតម្រូវការរបស់អ្នកស្ដាប់ ជាការដោះដូរដែលចំណេញខ្លាំង រហូតដល់ថ្នាក់ពិបាកនឹងប្រកែក។ *"ដោយសារភាពពីបាបតែម្ដង នោះពួកគេមានសន្តិភាពជាមួយនឹងព្រះជារៀងរហូត។ ពួកអ្នកដែលធំធាត់ឡើងនៅពេលដែលសេដ្ឋកិច្ចមានការរីកចម្រើនរាប់លាននាក់ អធិស្ឋានលន់តួបាប ហើយបន្តរស់នៅ ដោយមិនមានការប្រែចិត្តអ្វីទាល់តែសោះ...ពួកគេយល់ថា នោះជាការដោះដូរដែលចំណេញ ពួកគេទទួលបានអ្វីដែលពួកគេចង់បាន ដោយមិនចាំបាច់បង់ថ្លៃអ្វីទាំងអស់"* (Wells, ទំព័រ៣០២)។

នៅពេលដែលយើងប្តូរអត្ថន័យស្នូលរបស់ដំណឹងល្អជាមួយនឹងអត្ថប្រយោជន៍នៃដំណឹងល្អ នោះយើងមិនបានផ្សាយដំណឹងល្អស្របតាមព្រះបន្ទូលទេ យើងកំពុងតែលក់ផលិតផលឲ្យមនុស្សវិញទេតើ។ កណ្ឌគម្ពីរ *កិច្ចការ ជំពូក១៦ មេភូគុកនៅក្រុងភីលីពសួរថា "លោកម្ចាស់អើយ តើត្រូវឲ្យខ្ញុំធ្វើដូចម្ដេចឲ្យបានសង្គ្រោះផង"* (ការបំពេញសេចក្តីត្រូវការ) សាវ័ក ប៉ុល ក៏ផ្សាយ*ព្រះបន្ទូល*ប្រាប់គាត់។ ប្រកាសដំណឹងល្អប្រាប់គេ*ដោយឥតលាក់កំបាំង*។

*ទី២* យើងត្រូវផ្សាយដំណឹងល្អ*ដោយស្មោះត្រង់*។ ដូចដែលសាវ័ក ប៉ុល បានលើកឡើងនៅ២២ ការផ្ដោតលើសេចក្ដីពិតនៃអត្ថន័យស្នូលរបស់ដំណឹងល្អមានសារៈសំខាន់ណាស់ យើងត្រូវចងចាំថា យើងមិនត្រូវលាក់បាំងពីការបង់ថ្លៃនៃដំណឹងល្អឡើយ។ សូមអានម្ដងទៀតនៅ ២កូរិនថូស ៥:១៤-១៥ "ដ្បិតសេចក្ដីស្រឡាញ់របស់ព្រះគ្រីស្ទបង្ខំយើងខ្ញុំ ដោយយើងខ្ញុំពិចារណាឃើញថា បើម្នាក់បានស្លាប់ជំនួសអ្នកទាំងអស់នោះទាំងអស់ឈ្មោះថាបានស្លាប់ហើយ ទ្រង់ក៏បានសុគតជំនួសមនុស្សទាំងអស់យ៉ាងនោះ *គឺដើម្បីឲ្យពួកអ្នកដែលរស់នៅ មិនរស់សម្រាប់តែខ្លួនឯងទៀត* គឺរស់សម្រាប់ព្រះអង្គ ដែលសុគតជំនួសគេ ហើយបានរស់ឡើងនោះវិញ"។ សាវ័ក ប៉ុល បានលើកឡើងថា គឺដើម្បីឲ្យពួកអ្នកដែលរស់នៅ មិនរស់សម្រាប់តែខ្លួនឯងទៀត គឺរស់សម្រាប់ព្រះយេស៊ូវិញ។ សាវ័ក ប៉ុល បានយកគំរូនេះតាមព្រះយេស៊ូវ។ កណ្ឌគម្ពីរ *ម៉ាថាយ ១៦:២៤ "បើអ្នកណាចង់មកតាមខ្ញុំ នោះត្រូវឲ្យលះកាត់ចិត្តខ្លួនឯងចោលចេញ ហើយផ្ទុកឈើឆ្កាងខ្លួនមកតាមខ្ញុំចុះ"*។ កណ្ឌគម្ពីរ *ម៉ាកុស ៨:៣៥ "ដ្បិតអ្នកណាដែលចង់ឲ្យរួចជីវិត នោះនឹងបាត់ជីវិតទៅ តែអ្នកណាដែលបាត់ជីវិតដោយព្រោះយល់ដល់ខ្ញុំ ហើយនិងដំណឹងល្អ នោះនឹងបានជីវិតវិញ"*។ ជាក់ស្ដែងទៅ តើព្រះយេស៊ូវបានមានព្រះបន្ទូលអ្វីខ្លះទៅកាន់សាវ័ក ប៉ុល? កណ្ឌគម្ពីរ *កិច្ចការ ៩:១៦ "ដ្បិតខ្ញុំនឹងបង្ហាញ ឲ្យគាត់ដឹងជាត្រូវរងទុក្ខលំបាកទាំងអម្បាលម៉ាន ដោយព្រោះឈ្មោះខ្ញុំ"*។

យើងមានជីវិតដែលថ្មី តាមរយៈដំណឹងល្អ។ ប៉ុន្តែ មិនមែនជាជីវិតថ្មី ដែលកែឡើងជាថ្មីចេញពីជីវិតចាស់ដដែលនោះទេ។ តើមាននរណាម្នាក់ដែលមិនចង់បានជីវិតល្អប្រសើរជាងមុននោះ? ខ្ញុំមានមិត្តភក្តិដែលជាអ្នកមិនជឿជាច្រើននាក់។ នៅពេលខ្ញុំបានស្គាល់ពួកគេកាន់តែយូរ ខ្ញុំដឹងថា ពួកគេគ្រប់ៗគ្នាចង់បានជីវិតគ្រួសារជីវិតអាពាហ៍ពិពាហ៍ ចង់ឲ្យកូនៗរបស់ពួកគេមានអនាគតល្អ ហើយមានសេចក្ដីសុខសាន្ត និងមានភាពសប្បាយរីករាយជាងសព្វថ្ងៃនេះ។ បើព្រះយេស៊ូវអាចប្រទានអ្វីៗទាំងអស់នេះឲ្យខ្ញុំ ខ្ញុំនឹងជឿព្រះយេស៊ូវ! ប៉ុន្តែ សូមចងចាំថា លោកអ្នកនាំពួកគេឲ្យជឿដោយសារអ្វី នោះឯងជាអ្វីដែលធ្វើឲ្យពួកគេនៅបន្តជឿ។ តើនឹងមានអ្វីកើតឡើងចំពោះសេចក្ដីជំនឿរបស់ពួកគេ បើអ្វីៗមិនសមតាមបំណង នៅពេលដែលជួបនឹងទុក្ខលំបាក ហើយនិងបញ្ហាផ្សេងៗក៏មកដល់នោះ នៅពេលដែលម្ដាយស្លាប់ចោលទាំងនៅវ័យក្មេង កូនៗមិនស្ដាប់បង្គាប់ បះបោរ ការងារក៏បាត់បង់? តើព្រះយេស៊ូវមិនបានមានបន្ទូលជាប្រស្នាអំពីការនេះទេឬអី? ឯពួកអ្នកដែលទទួលពូជក្នុង*កន្លែងថ្ម* ក៏ដូចគ្នាដែរ កាលណាគេឮព្រះបន្ទូល នោះគេទទួលភ្លាមដោយអំណរ។ តែគ្មានចាក់ឫសនៅក្នុងខ្លួនសោះ ហើយក៏នៅជាប់តែបន្តិចទេ បើកាលណាកើតមាន*សេចក្ដីទុក្ខលំបាក* ឬសេចក្ដីបៀតបៀន ដោយព្រោះព្រះបន្ទូល នោះគេ*វាតចិត្ត*ចេញភ្លាម (ម៉ាកុស ៤:១៦-១៧)។

ជីវិតដែលបានផ្ដល់មក ដោយដំណឹងល្អ ជាជីវិតដែលអាចស៊ូទ្រាំនឹងទុក្ខលំបាកពីព្រោះជាជីវិតដែលផ្ដល់តម្លៃចំពោះអ្វីៗដែលស្ថិតនៅក្នុងព្រះគ្រីស្ទ ហើយមិនធ្វើឲ្យផលដែលព្រះគ្រីស្ទបានប្រទានមក ត្រឡប់ទៅជាអសារឥតការនោះឡើយ។ យើងត្រូវតែពន្យល់ដោយស្មោះត្រង់ ប្រយោជន៍ឲ្យអ្នកស្ដាប់ស្គាល់ពីតម្លៃដ៏ពិតនៃដំណឹងល្អ។ តើលោក ដេវីឌ ប្រេនើដ (David Brainerd) ដែលបានចាកចេញពីជីវិតដែលល្អប្រសើរនៅទីក្រុងបូស្តុន ដើម្បីទៅប្រកាសដំណឹងល្អដល់ជនជាតិឥណ្ឌា គាត់គ្រាន់តែចង់ឆាប់ស្លាប់ទាំងវ័យក្មេង ដោយសារជម្ងឺរបេង ទាំងសោកស្ដាយពីការ

សម្រេចចិត្តនោះឬ? តើលោក អេឌូនៃរឹម ចឺឌសិន (Adoniram Judson) បានគិតថា ការរងទុក្ខដោយប្រពន្ធ និងកូនៗបានស្លាប់ចោលទាំងនៅវ័យក្មេង ក្នុងការនាំដំណឹងល្អទៅកាន់ប្រទេសភូមា គឺជាការគិតខុសឬ? តើលោក វីលៀម វិលប៊ើហ្វស (William Wilberforce) សោកស្ដាយ ដែលសុខចិត្តខកខានឱកាសអាចក្លាយជានាយករដ្ឋមន្ត្រី ដោយទៅធ្វើការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សនោះឬ? ទេ! ទីបន្ទាល់របស់ពួកគាត់ ក៏ដូចជាទីបន្ទាល់របស់លោក ជីម អែឡេដ (Jim Elliot) ដែរ *"បុគ្គលម្នាក់ដែលឲ្យអ្វីៗដែលគាត់មិនអាចរក្សាទុកបាន ដើម្បីឈោងចាប់យកអ្វីៗដែលគាត់នឹងមិនអាចបាត់បង់បាន បុគ្គលនោះមិនមែនជាមនុស្សល្ងីល្ងើទេ"*។ ខ្ញុំស៊ូលះចោលអស់ទាំងអត្ថប្រយោជន៍ សេចក្ដីសុខ និងអំណរនៃលោកីយ៍នេះចុះ ឲ្យតែបានព្រះគ្រីស្ទ នោះខ្ញុំមិនខាតបង់អ្វីសោះឡើយ។ ខ្ញុំក៏ចូលរួមប្រកាសជាមួយនឹងសាវ័ក ប៉ុល ផងដែរនៅក្នុងកណ្ឌគម្ពីរ *២កូរិនថូស ៤:១៧ "ដ្បិតសេចក្ដីទុក្ខលំបាកយ៉ាងស្រាលរបស់យើងខ្ញុំ ដែលនៅតែមួយភ្លែតនេះ នោះបង្កើតឲ្យយើងខ្ញុំមានសិរីល្អយ៉ាងធ្ងន់លើសលប់ ដ៏នៅអស់កល្បជានិច្ចវិញ"*។

ឱគ្រីស្ទបរិស័ទអើយ ហេតុអ្វីបានលោកអ្នកក្រនឹងនិយាយអំពីតម្លៃនៃភាពជាសិស្សនៅក្នុងការផ្សាយដំណឹងល្អខ្លាំងម្ល៉េះ? ខ្ញុំគិតថា ការនេះប្រាសចាកពីក្បួនលក់របស់យើងហើយ ជាភាពភ័យខ្លាចរបស់យើងដែលថា បើយើងប្រាប់អំពីការពិតទាំងស្រុងអំពីការដើរតាមព្រះគ្រីស្ទ នោះនឹងមិនមានគេចង់ជឿច្រើននោះទេ។ ហេតុនោះហើយ យើងលក់សិរីល្អតិចៗវិញ ដោយសន្យានឹងជួយនូវជំនួយតាមតម្រូវការជាក់ស្ដែងរបស់សាច់ឈាម ជាសិរីល្អ ដោយសន្យាផ្ដល់សន្តិភាពផ្លូវអារម្មណ៍ និងជាសិរីល្អដែលបំពេញដោយភាពអរសប្បាយនៃលោកីយ៍ដ៏លំបាកនេះ។ តែសេចក្ដីពិតនោះគឺថា ព្រះយេស៊ូវនឹងប្រទានជីវិតពេញបរិបូរដល់អ្នកដើរតាមទ្រង់ ហើយមិនមែនជាភាពពេញបរិបូរដែលមនុស្សមានបាបប្រាថ្នាចង់បាននោះទេ។ គឺជាជីវិតដែលពេញដោយការដឹងថា ជីវិតនេះមិនមែនជារបស់ផងយើងទៀតទេ តែជារបស់

ផងព្រះ ហើយយើងរស់នៅដើម្បីនឹងធ្វើការថ្វាយសិរីល្អដល់ទ្រង់។ ហេតុនោះហើយ យើងត្រូវតែប្រកាសដំណឹងល្អ ដោយស្មោះត្រង់។

*ទី៣* យើងត្រូវប្រកាសដំណឹងល្អ*ដោយភាពបន្ទាន់*។ មនុស្សម្នាក់ៗត្រូវតែឆ្លើយតបចំពោះដំណឹងល្អ។ សូមមើលកណ្ឌគម្ពីរ *២កូរិនថូស ៥:១៤, ២០* ម្ដងទៀត *"ដ្បិតសេចក្ដីស្រឡាញ់របស់ព្រះគ្រីស្ទបង្ខំយើងខ្ញុំ ដោយយើងខ្ញុំពិចារណាឃើញថា បើម្នាក់បានស្លាប់ជំនួសអ្នកទាំងអស់នោះទាំងអស់ឈ្មោះថាបានស្លាប់ហើយ...ដូច្នេះយើងខ្ញុំជាទូតដំណាងព្រះគ្រីស្ទ ហាក់ដូចជាព្រះទ្រង់អង្វរដោយសារយើងខ្ញុំ គឺយើងខ្ញុំអង្វរគេជំនួសព្រះគ្រីស្ទថា ចូរឲ្យបានជាមេត្រីនឹងព្រះចុះ"*។ សាវ័ក ប៉ុល យល់យ៉ាងច្បាស់ថា រស់ឬស្លាប់ជារឿងជៀសមិនរួច។ *ព្រះគ្រីស្ទបានត្រាស់ហៅឲ្យសាវ័ក ប៉ុល ឲ្យស្រឡាញ់*ក្នុងការប្រកាសដំណឹងល្អ។ គាត់អង្វរដោយអស់ពីចិត្តឲ្យមនុស្សបានជានាជាមួយនឹងព្រះជាម្ចាស់វិញ តាមរយៈព្រះយេស៊ូវគ្រីស្ទ។ ការប្រកាសដំណឹងល្អរបស់សាវ័ក ប៉ុល មិនមែនជាការប្រកាសដំណឹងល្អបែបទ្បយៗ មិនខ្វល់ពីការឆ្លើយតប បត់បែនតាមនិន្នាការសម័យកាល ដោយថាដំណឹងល្អគ្រាន់តែជាជម្រើស ហើយសួរថា *តើលោកអ្នកគិតយ៉ាងម៉េចដែរ?* នោះទេ។ សាវ័ក ប៉ុល មិនមែនជាមនុស្សឆ្មើងឆ្មៃ ឬបង្ខិតបង្ខំ ហើយបំពានលើនរណាឡើយ។ គាត់បដិសេធ*របៀបដែលមិនស្មោះត្រង់ ដែលគួរឲ្យអាម៉ាស់ផ្សេងៗ* ដូចដែលលោកអ្នកដឹងហើយថា គាត់បានផ្ដល់ជាគំនិតជាច្រើនក្នុងការចូលទៅកាន់ប្រភេទមនុស្សផ្សេងៗ។ *"ខ្ញុំបានត្រឡប់ដូចជាសាសន៍យូដា ដល់ពួកសាសន៍យូដា ដើម្បីឲ្យបានពួកយូដា..."* (១កូរិនថូស ៩:១៩-២៣)។ គាត់បានព្យាយាមមិនធ្វើជាទីជំពប់ដួលដល់នរណាម្នាក់ឡើយ ទាំងក្នុងការប្រព្រឹត្ត និងពាក្យសម្ដីរបស់គាត់ផង។ យើងមិនត្រូវមានការភាន់ច្រឡំ រវាងភាពបន្ទាន់ជាមួយនឹងការបង្ខិតបង្ខំ តាមរយៈទឹកមុខរបស់យើងនោះឡើយ។ ប៉ុន្តែយើងអាចនិយាយបានថា សាវ័ក ប៉ុល បានប្រកាសដំណឹងល្អដោយភាពម៉ឺងម៉ាត់ ដូចដែលលោក រីកឆាដ ប៉េក្សធើ (Richard Baxter) លើកឡើងថា សាវ័ក ប៉ុល

ប្រកាសដំណឹងល្អ *«ដូចជាមនុស្សហៀបនឹងស្លាប់និយាយទៅកាន់មនុស្សហៀបនឹងស្លាប់ម្នាក់ទៀត»*។

តើលក្ខណៈទាំងនេះ ខុសប្លែកពីលក្ខណៈរបស់យើងយ៉ាងដូចម្ដេចខ្លះ? យើងរស់នៅក្នុងយុគសម័យវប្បធម៌ទំនើប គ្មាននរណាចាប់អារម្មណ៍ក្នុងការដែលយើងមានភាពសប្បាយរីករាយជាមួយនឹង «សេចក្ដីជំនឿផ្ទាល់ខ្លួន» របស់យើងនោះឡើយ។ យើងហាក់មានទំនោរបន្ទាបសារនៃដំណឹងល្អរបស់យើង ឲ្យស្ថិតនៅលើខ្នង់សម្លេងទាបៗ ដោយគិតថា បើអាចមានសម្ពាធកាន់តែតិចកាន់តែល្អ។ ហើយបើយើងគ្រាន់តែនិយាយអំពីបែបផែននៃជីវិត នោះវាមិនថ្វីទេ ប៉ុន្តែការប្រកាសដំណឹងល្អមិនមែនជាការនិយាយអំពីបែបផែននៃជីវិតទេ។ នេះគឺជារឿងស្លាប់រស់។

បងប្អូនអើយ នៅពេលយើងប្រកាសដំណឹងល្អ យើងត្រូវតែអង្វរមនុស្សឲ្យប្រែចិត្ត ហើយជឿនៅថ្ងៃនេះ។ យើងទាំងអស់គ្នារស់នៅ ធ្វើហាក់ដូចជាជីវិតនៅលើផែនដីនេះមិនចេះបញ្ចប់ ទោះបីជាយើងដឹងថា ជីវិតនេះនឹងបញ្ចប់ទៅក្ដី។ ហើយពេលយើងគិតអំពីជីវិតនេះ យើងគ្រាន់តែគិតថា នឹងរស់នៅដូចជាទីបញ្ចប់នៃជីវិតនេះនឹងមកដល់នៅពេលយើងចាស់ទៅ ដោយគិតថាខ្លួននៅមានពេលច្រើនទៀត។ ប៉ុន្តែ តាមពិតជីវិតនេះ គឺប្រៀបដូចចំហាយទឹក ហើយយើងមិនដឹងថា ពេលណាវានឹងបញ្ចប់នោះទេ។ សាវ័ក ប៉ុល បានលើកឡើងថា *«ថ្ងៃនេះជាថ្ងៃនៃសេចក្ដីសង្គ្រោះហើយ» (២កូរិនថូស ៦:២)*។ *«ថ្ងៃនេះ ជាថ្ងៃដែលត្រូវស្ដាប់ព្រះសូរសៀងព្រះជាម្ចាស់ ហើយចូលក្នុងការសម្រាករបស់ទ្រង់» (ហេព្រើរ ៣-៤)*។

ទស្សនៈដែលយល់ឃើញថា យើងមានផលិតផលលក់តាមតម្រូវការរបស់អតិថិជនមានភាពចម្រូងចម្រាសណាស់។ តើអ្នកទិញទំនិញគ្រប់រូបដឹងអ្វីខ្លះ អំពីការទិញទំនិញ? ការប្រៀបធៀបទៅលើហាងទំនិញ ការតថ្លៃជាដើម។ មានតែមនុស្សឆោតទេ ដែលទិញទំនិញ ដោយគ្រាន់តែឃើញភ្លាម ក៏ទិញភ្លែតនោះ។ ឧ. សាសនាព្រះពុទ្ធប្រហែលជាអាចនឹងជួយដល់ចំណងអាពាហ៍ពិពាហ៍របស់ខ្ញុំបានច្រើនជាង

សាសនាគ្រីស្ទ។ ការចូលរួមជាមួយនឹងសហគមន៍មួយនេះ ប្រហែលជាផ្តល់ឲ្យខ្ញុំនូវគោលដៅខ្លះៗសម្រាប់ជីវិត។ ប៉ុន្តែ លក្ខណៈនៃដំណឹងល្អពិតនោះគឺថា គ្មានកិច្ចសន្យាណាមួយប្រសើរជាងដំណឹងល្អនោះទេ ពិតជាគ្មានអ្វីមួយអាចប្រៀបផ្ទឹមស្មើជាមួយនឹងអ្វីដែលដំណឹងល្អអាចផ្តល់ឲ្យបានឡើយ។ ហើយមិនមានការធានាណាមួយដែលថា វានឹងនៅតែមានសម្រាប់លោកអ្នកនៅថ្ងៃស្អែកទៀតឡើយ។

*ទី៤* ចុងក្រោយយើងគួរតែប្រកាសដំណឹងល្អ*ដោយទំនុកចិត្ត*។ ដំណឹងល្អមាននូវឫទ្ធានុភាព ដែលមិនត្រូវការជំនួយពីយើងទេ។ កណ្ឌគម្ពីរ ២កូនិនថូស ៤:៣-៧ បានចែងថា *«បើសិនណាជាដំណឹងល្អរបស់យើងខ្ញុំត្រូវគ្របបាំង នោះគឺត្រូវគ្របបាំងចំពោះតែពួកអ្នក ដែលកំពុងវិនាសទេ។ ជាពួកអ្នក ដែលព្រះរបស់លោកីយ៍នេះ បានបង្អាប់ដល់គំនិតពួកគេដែលមិនជឿ ក្រែងរស្មីពន្លឺនៃដំណឹងល្អ ដែលសម្តែងពីសិរីល្អនៃព្រះគ្រីស្ទដ៏ជារូបអង្គព្រះ បានភ្លឺមកដល់គេ យើងខ្ញុំមិនប្រកាសប្រាប់ពីខ្លួនយើងខ្ញុំទេ គឺពីព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់វិញ ហើយក៏រាប់ខ្លួនយើងខ្ញុំថាជាបាវបម្រើរបស់អ្នករាល់គ្នា ដោយព្រោះព្រះយេស៊ូវដែរ ដ្បិតគឺជាព្រះ ដែលមានបន្ទូលបង្គាប់ ឲ្យមានពន្លឺភ្លឺចេញពីសេចក្តីងងឹត ទ្រង់បានបំភ្លឺមកក្នុងចិត្តយើងខ្ញុំ ឲ្យយើងខ្ញុំមានរស្មីពន្លឺនៃដំណើរស្គាល់សិរីល្អរបស់ព្រះ ដែលនៅព្រះភក្ត្រនៃព្រះយេស៊ូវគ្រីស្ទ។ យើងមានទ្រព្យសម្បត្តិនេះនៅក្នុងភាជនៈដី ដើម្បីឲ្យឥទ្ធិឫទ្ធិដ៏លើសលប់បានមកពីព្រះ មិនមែនពីយើងខ្ញុំទេ»*។ សាវ័ក ប៉ុល ដឹងថា មិនមែនគ្រប់គ្នាដែលឮសេចក្តីបង្រៀនរបស់គាត់ហើយនឹងក្លាយជាគ្រីស្ទបរិស័ទទាំងអស់នោះទេ។ ប៉ុន្តែ តើនោះជាកំហុសនៃវិធីសាស្ត្ររបស់គាត់ឬ? តើសាររបស់គាត់នៅមិនទាន់ល្អគ្រប់គ្រាន់ឬ? ទេ! សាវ័ក ប៉ុល មានភាពច្បាស់លាស់ណាស់។ បញ្ហាស្ថិតនៅត្រង់*ចិត្តដែលមិនព្រមជឿរបស់គេវិញ*។ អំពើបាប និងដួងចិត្តដែលពេញដោយភាពពុករលួយ គ្របបាំងភ្នែកមនុស្សមិនឲ្យមើលឃើញសេចក្តីពិត។ តាមពិត ចិត្តដែលមិនព្រមជឿ មិនចង់ឃើញសេចក្តីពិតទេ។ វាគឺជាចេតនា ធ្វើជាមើលមិនឃើញ។

ដូច្នេះ តើសាវ័ក ប៉ុល ឆ្លងផុតភាពកង្វាក់នេះ បានដោយរបៀបណា? គឺមិនមែនដោយសារវិធីសាស្ត្រ ឬក៏សេចក្តីបង្រៀនដែលល្អប្រសើរជាងមុនទេ។ ព្រះជាម្ចាស់ទេតើ ដែលទ្រង់ធ្វើកិច្ចការរបស់ទ្រង់។ ព្រះទ្រង់បើកភ្នែកដែលមើលមិនឃើញនោះ ដើម្បីឲ្យគេអាចមើលឃើញសេចក្តីពិត។ ការនោះហើយ គឺពិតជាកិច្ចការព្រះជាម្ចាស់។ ព្រះអង្គដែលបានបង្កើតពន្លឺដោយព្រះបន្ទូលទ្រង់ ហើយបានធ្វើឲ្យពន្លឺនោះភ្លឺនៅក្នុងទីងងឹត គឺជាព្រះដែលធ្វើកិច្ចការទ្រង់តាមរយៈដំណឹងល្អនៃទ្រង់។ ព្រះអង្គប្រទានពន្លឺខាងឯវិញ្ញាណ ហើយធ្វើឲ្យពន្លឺភ្លឺនៅក្នុងទីងងឹតនៃចិត្តដែលមិនព្រមជឿនោះ។ ហេតុនោះហើយបានជាសាវ័ក ប៉ុល បានប្រកាសដំណឹងល្អដោយទំនុកចិត្ត ដោយសារគាត់ដឹងថា ដំណឹងល្អមិនមែនគ្រាន់តែជាពាក្យសម្តីរបស់គាត់នោះទេ។ តើសាវ័ក ប៉ុល មិនបានលើកឡើងនៅក្នុងកណ្ឌគម្ពីរ *២កូរិនថូស ៥:២០ ទេឬអី? “ដូច្នេះ យើងខ្ញុំជាទូតដំណាងព្រះគ្រីស្ទ ហាក់ដូចជាព្រះទ្រង់អង្វរដោយសារយើងខ្ញុំ!...”* ព្រះជាម្ចាស់មានបន្ទូលតាមរយៈដំណឹងល្អរបស់ទ្រង់ ដូចដែលទ្រង់តែងតែមានបន្ទូលហើយ ពេលដែលទ្រង់មានបន្ទូល នោះបង្កើតឲ្យមានជីវិត និងពន្លឺ ដ្បិតពីដំបូងឡើយមានតែសេចក្តីស្លាប់ និងសេចក្តីងងឹតប៉ុណ្ណោះ។

ឱបងប្អូនដែលជាគ្រីស្ទបរិស័ទអើយ ហេតុអ្វីយើងមិនផ្សាយដំណឹងល្អ? ហេតុអ្វីយើងមិនចែកចាយដំណឹងល្អឲ្យបានញឹកញាប់ជាងនេះ? ខ្ញុំគិតថា ភាគច្រើន គឺមកពីយើងភ័យខ្លាច និងបាក់ទឹកចិត្ត។ យើងខ្លាចគេបដិសេធ ហើយបាក់ទឹកចិត្តនៅពេលមនុស្សមិនឆ្លើយតបនឹងសារដែលយើងប្រកាស។ ម៉្យាងវិញទៀត ខ្ញុំគិតថា យើងទាំងអស់គ្នាឮពីមនុស្សដែលមានអំនួតអំពីការផ្សាយដំណឹងល្អ ដែលគេរហ័សនឹងប្រកាសអំពីតួលេខនៃអ្នកប្រែចិត្តជឿ តាមរយៈការផ្សាយដំណឹងល្អរបស់ពួកគេ។ ប៉ុន្តែ តាមពិតទៅទាំងយើង ហើយនឹងគេបានធ្វើផ្ទុយ ដោយបានភាន់ច្រឡំអំពីកិច្ចការរបស់យើងជាមួយនឹងកិច្ចការរបស់ព្រះជាម្ចាស់ ក៏ដូចជាបានយល់ខុសអំពីផលផ្លែដែលចេញពីការផ្សាយដំណឹងល្អជាមួយនឹងដំណឹងល្អផ្ទាល់នោះទៅវិញ

ទេ។ នៅពេលដែលយើងគិតថា ការផ្សាយដំណឹងល្អដែលជោគជ័យ ដែលល្អ ត្រូវតែមានមនុស្សជឿ ហើយក្លាយជាគ្រីស្ទបរិស័ទ បើមិនដូច្នោះទេយើងមុខជាឈប់ធ្វើ ឬក៏ខិតខំប្រឹងធ្វើអ្វីៗគ្រប់យ៉ាងតាមតែខ្លួនចង់ ដើម្បីទទួលបានលទ្ធផលដែលយើងប៉ងប្រាថ្នាចង់បាន។ ហើយមិនយូរប៉ុន្មាន យើងបានចូលរួមក្នុងប្រភេទនៃការលាក់កំបាំងដែលគួរខ្មាស និងឧបាយកល ឬការបំប្លែងព្រះបន្ទូលដែលសាវ័ក ប៉ុល បានប្រាប់ឲ្យយើងលះចោលនោះ។

ប៉ុន្តែ នៅពេលដែលយើងដឹងថា ការប្រែចិត្តជឿគឺជាកិច្ចការរបស់ព្រះ។ កិច្ចការចម្បងរបស់យើងនោះ គឺប្រកាសដំណឹងល្អដោយឥតលាក់កំបាំង ដោយស្មោះត្រង់ និងដោយមានភាពបន្ទាន់ បន្ទាប់មកទៀតអ្វីៗនឹងមានការផ្លាស់ប្តូរជាមិនខាន។ យើងអាចផ្សាយដំណឹងល្អដោយទំនុកចិត្ត ដ្បិតយើងដឹងថា មានតែដំណឹងល្អទេ ហើយគ្មានអ្វីផ្សេងទៀតទេ ដែលព្រះវិញ្ញាណប្រើប្រាស់ ដើម្បីបំភ្លឺដល់ភ្នែកមើលមិនឃើញទាំងនោះ។ ហើយរង្វាស់របស់ភាពជោគជ័យបានផ្លាស់ប្តូរ។ វាមិនមែនជាតួលេខទៀតទេ ប៉ុន្តែជាភាពស្មោះត្រង់វិញ។ នេះមានន័យថា ភាពភ័យខ្លាច និងពិរុទ្ធភាពទាំងឡាយដែលយើងបានជួបនៅពេលនិយាយដល់ការផ្សាយដំណឹងល្អ នោះបានរសាត់បាត់ទៅ។ នៅពេលដែលយើងមិនមែនជាអ្នកសម្រេចចំពោះលទ្ធផល នោះយើងមិនត្រូវបានកំណត់ដោយលទ្ធផលទាំងនោះទេ។ នៅពេលដែលយើងមិនមានទំនួលខុសត្រូវចំពោះលទ្ធផល នោះយើងមិនចាំបាច់ដាក់សម្ពាធលើការសម្រេចចិត្ត ឬការរៀបចំទាំងនោះដែរ។ ខ្ញុំមិនបាច់ខំប្រឹងលក់អ្វីមួយឲ្យនរណាម្នាក់ឡើយ។ ផ្ទុយទៅវិញ ខ្ញុំមានសេរីភាពក្នុងការស្រឡាញ់មនុស្ស ហើយដោយសេចក្តីស្រឡាញ់នោះហើយ ដែលជំរុញពួកគេឲ្យចង់ទទួលយកលក្ខខណ្ឌសន្តិភាពរបស់ព្រះជាម្ចាស់។

នោះហើយ ជាការផ្សាយដំណឹងល្អ។ ជាសេចក្តីដាស់តឿននៃសេចក្តីស្រឡាញ់មកពីព្រះជាម្ចាស់ ចំពោះមនុស្សមានបាបគ្រប់រូប។ យើងគ្រាន់តែជាទូត ដែលជា

អ្នកនាំពាក្យ ពាំនាំសាររបស់ព្រះប៉ុណ្ណោះ។ «ចូរឲ្យបានជាមេត្រីនឹងព្រះចុះ ដ្បិតឯព្រះអង្គ ដែលមិនបានស្គាល់បាបសោះ នោះព្រះទ្រង់បានធ្វើឲ្យត្រឡប់ជាតួបាបជំនួសយើងរាល់គ្នាវិញ ដើម្បីឲ្យយើងរាល់គ្នាបានត្រឡប់ទៅជាសេចក្តីសុចរិតរបស់ព្រះ ដោយនូវព្រះអង្គនោះឯង»។

# ការបង្កើតសិស្ស–មិនមែនការទទួលបានការសម្រេចចិត្តទេ

និពន្ធដោយ៖ លោក ម៉ៃឃើល ឡរ៉េនស៍

(១ថែស្សាឡូនីច ១:៩-១០; ១ពេត្រុស ១:២២-២៣; យ៉ូហាន ១:១០-១៣; ១យ៉ូហាន ៥:១-៥)

កាលខ្ញុំមានអាយុ១៨ឆ្នាំ ខ្ញុំបានក្លាយជាអ្នកគាំទ្រក្រុមកីឡាបាល់ទាត់ជាតិម្នាក់។ ខ្ញុំមិនមែនជាអ្នកគាំទ្រពីកំណើតនោះទេ។ ទោះគេនិយាយដូចម្ដេចក៏ដោយ ក៏ខ្ញុំត្រូវតែក្លាយជាសមាជិកនៃអ្នកគាំទ្រផ្ទាល់។ រឿងនេះមិនពិបាកយល់ទេ។ ខ្ញុំដឹងថា ខ្ញុំចូលចិត្តកីឡាបាល់ទាត់ ប៉ុន្តែ ដោយសារខ្ញុំបានចម្រើនវ័យធំឡើង ក្នុងស្រុកដែលមិនមានក្រុមជម្រើសជាតិធំៗ ខ្ញុំមិនមានចិត្តស្មោះស្ម័គ្រចំពោះក្រុមក្នុងតំបន់ទេ ហើយគ្រាន់តែតាមដានការប្រកួតជាទូទៅតែប៉ុណ្ណោះ។ ប៉ុន្តែ ខ្ញុំក៏បានដឹងថា ខ្ញុំនឹងមានចិត្តរីករាយកាន់តែខ្លាំងក្នុងការតាមដានការប្រកួត បើសិនជាខ្ញុំក្លាយជាអ្នកគាំទ្ររបស់ក្រុមណាមួយឲ្យបានជាក់លាក់។ ដូចនេះ ខ្ញុំក៏បានអង្គុយមើលកីឡា និងពិន្ទុ និងចំណាត់ថ្នាក់របស់ក្រុមនីមួយៗ ហើយក៏បានសម្រេចចិត្តក្លាយជាអ្នកគាំទ្រ

បាល់ទាត់ជាតិ។ ហើយខ្ញុំនៅតែគាំទ្ររហូតមកដល់ពេលសព្វថ្ងៃ។ វាបានក្លាយការជ្រើសរើសតាមចំណង់ចំណូលចិត្តរបស់ខ្ញុំ។ បើសិនជាខ្ញុំត្រូវក្លាយជាអ្នកគាំទ្រក្រុមកីឡាណាមួយផ្សេងទៀត ខ្ញុំក៏ត្រូវធ្វើដូចនេះផងដែរ។ តើលោកអ្នកគាំទ្រក្រុមកីឡាករបាល់ទាត់កម្ពុជាណាមួយ?

សព្វថ្ងៃនេះ មនុស្សជាច្រើន ជាពិសេសក្នុងសង្គមលោកខាងលិច យល់ឃើញថា ការផ្លាស់ប្តូរជំនឿសាសនា ទៅជាគ្រីស្ទបរិស័ទ មូស្លីម ឬពុទ្ធសាសនិក គឺមិនខុសពីការសម្រេចចិត្តរបស់ខ្ញុំ ក្លាយជាអ្នកគាំទ្របាល់ទាត់ជាតិនោះទេ។ វាបានក្លាយជាការជ្រើសរើសតាមចំណង់ចំណូលចិត្ត។ ត្រង់ចំណុចនេះ ខ្ញុំមិនចង់មានន័យថា ការផ្លាស់ប្តូរជំនឿសាសនាត្រូវមានភាពរាក់កំផែល ដូចការជ្រើសរើសក្រុមកីឡាករនោះទេ។ ខ្ញុំគ្រាន់តែបកស្រាយ តាមការសង្កេតមើល តាមបទពិសោធន៍ និងវប្បធម៌របស់យើង ដែលមានការសម្រេចចិត្តផ្ទាល់ខ្លួន ក្នុងរឿងទាំងពីរនេះ។

ពេលណាយើងចង់និយាយអំពីការផ្លាស់ប្តូរជំនឿស៊ីជម្រៅ យើងត្រូវនិយាយអំពីការកើតជាថ្មី និងការដែលព្រះអង្គបានបង្កើតយើងជាស្នាព្រះហស្តថ្មី។ បានសេចក្តីថា ព្រះទ្រង់ត្រូវតែធ្វើអន្តរាគមន៍ដោយផ្ទាល់ ហើយជួយសង្គ្រោះយើង តាមរយៈព្រះជន្ម ការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ។ ការផ្លាស់ប្តូរជំនឿទៅជាគ្រីស្ទបរិស័ទ គឺជាកិច្ចការដែលព្រះចាប់ផ្តើមជាមុន និងជាមូលដ្ឋាន។ ប៉ុន្តែ តើធ្វើដូចម្តេចឲ្យយើងដឹងថា ព្រះទ្រង់បានធ្វើឲ្យមនុស្សម្នាក់កើតជាថ្មីបាន? ព្រះគម្ពីរក៏បានចែងច្បាស់ថា ការផ្លាស់ប្តូរជំនឿក៏ជាការងាររបស់យើងផងដែរ។ យើងត្រូវតែឆ្លើយតប ហើយក្លាយជាគ្រីស្ទបរិស័ទ។ ហើយយើងឆ្លើយតប ដោយការប្រែចិត្ត និងទទួលជឿព្រះ។ តាមពិត អស់អ្នកដែលព្រះវិញ្ញាណបានធ្វើឲ្យកើតជាថ្មី ក៏ប្រែចិត្ត និងជឿព្រះ ព្រោះការប្រែចិត្ត និងជំនឿ គឺជាអំណោយ ជាព្រះគុណមកពីព្រះ ដែលចាំបាច់ត្រូវកើតមាន បន្ទាប់ពីយើងកើតជាថ្មីហើយ។ នៅពេលនេះ ខ្ញុំចង់ធ្វើការបកស្រាយអំពីភាពខុសគ្នាទាំងពីរនេះ។ យើងនឹងបានដឹងថា ការប្រែចិត្ត និង

សេចក្តីជំនឿ មិនគ្រាន់តែជាការសម្រេចចិត្តនោះទេ។ ប៉ុន្តែ ពេលណាយើងបន្ថយពួកវាមកនៅត្រឹមការសម្រេចចិត្ត គឺមានន័យថា យើងកំពុងតែកាត់បន្ថយការផ្លាស់ប្តូរជំនឿ ពីការផ្លាស់ប្រែស៊ីជម្រៅ ឲ្យមកនៅត្រឹមការជ្រើសរើសតាមចំណង់ចំណូលចិត្តបែបសាសនា។

សូមអានកណ្ឌគម្ពីរ ១ថែស្សាឡូនីច ១:៤-១០ «ឱបងប្អូន ដែលព្រះទ្រង់ស្រឡាញ់អើយ យើងខ្ញុំដឹងថា ទ្រង់បានរើសតាំងអ្នករាល់គ្នាហើយ ដ្បិតដំណឹងល្អរបស់យើងខ្ញុំ មិនបានផ្សាយមកដល់អ្នករាល់គ្នា ដោយពាក្យសំដីតែប៉ុណ្ណោះទេ គឺដោយព្រះចេស្តា នឹងព្រះវិញ្ញាណបរិសុទ្ធដែរ ហើយដោយសេចក្តីជំនឿដ៏មោះមុតជាខ្លាំងថែមទៀតផង ដូចជាអ្នករាល់គ្នាដឹងហើយ ពីដំណើរយើងខ្ញុំ ដែលនៅក្នុងពួកអ្នករាល់គ្នាជាយ៉ាងណាសំរាប់នឹងជួយដល់អ្នករាល់គ្នា អ្នករាល់គ្នាក៏បានត្រាប់តាមយើងខ្ញុំ ហើយនឹងព្រះអម្ចាស់ ដោយបានទទួលព្រះបន្ទូល ដោយសេចក្តីអំណររបស់ព្រះវិញ្ញាណបរិសុទ្ធ ក្នុងកាលដែលកំពុងតែកើតទុក្ខលំបាកជាខ្លាំងផង ដល់ម៉្លេះបានជាអ្នករាល់គ្នាបានត្រឡប់ជាគំរូ ដល់អស់អ្នកដែលជឿនៅស្រុកម៉ាសេដូន នឹងស្រុកអាខៃ ដ្បិតព្រះបន្ទូលនៃព្រះអម្ចាស់ បានផ្សាយចេញពីអ្នករាល់គ្នា មិនមែនតែក្នុងស្រុកម៉ាសេដូន នឹងស្រុកអាខៃប៉ុណ្ណោះទេ គឺរហូតដល់គ្រប់ទាំងកន្លែង ដែលឮនិយាយពីសេចក្តីជំនឿរបស់អ្នករាល់គ្នាចំពោះព្រះថែមទៀតផង បានជាមិនចាំបាច់ឲ្យយើងខ្ញុំនិយាយអ្វីទៀតទេ ដ្បិតគេថ្លែងប្រាប់ពីយើងខ្ញុំ ដែលអ្នករាល់គ្នាបានទទួលយើងជាយ៉ាងណា ទាំងបែរចេញពីរូបព្រះ មកឯព្រះដ៏ពិត ឲ្យបានគោរពប្រតិបត្តិដល់ព្រះ ដ៏មានព្រះជន្មរស់នៅនោះវិញ ហើយឲ្យបានចាំព្រះរាជបុត្រាព្រះ ទ្រង់យាងមកពីស្ថានសួគ៌ ដែលព្រះបានប្រោសឲ្យទ្រង់រស់ពីស្លាប់ឡើងវិញ គឺជាព្រះយេស៊ូវ ដែលទ្រង់ប្រោសឲ្យយើងរួចពីសេចក្តីខ្ញាល់ទៅមុខ»។

កណ្ឌគម្ពីរនេះស្ថិតក្នុងចំណោមសំបុត្រដែល សាវ័ក ប៉ុល បានសរសេរដំបូងបំផុត ហើយគាត់បានសរសេរកណ្ឌគម្ពីរសំបុត្រនេះ ផ្ញើទៅកាន់អ្នកជឿថ្មីមួយក្រុម ដែល

ជាអតីតអ្នកកាន់សាសនាយូដា និងអតីតអ្នកកាន់សាសនារបស់សាសន៍ដទៃ តែបានប្រែចិត្តជឿព្រះ តាមរយៈការចែកចាយព្រះបន្ទូលរបស់គាត់។ គាត់បានចាប់ផ្តើមសរសេរសំបុត្រនេះ ដោយក្រើនរំឭកពួកគេ អំពីរបៀបដែលពួកគេបានក្លាយជាគ្រីស្ទបរិស័ទពីដំបូង។ ការផ្លាស់ប្តូរជំនឿនេះ បានចាប់ផ្តើម ដោយព្រះជ្រើសរើសពួកគេ (ខ៤) ហើយធ្វើការ ក្នុងជីវិតរបស់ពួកគេ ដោយព្រះចេស្តា តាមរយៈព្រះវិញ្ញាណបរិសុទ្ធ និងការផ្សាយដំណឹងល្អ ដើម្បីកែប្រែចិត្តរបស់ពួកគេ (ខ៥)។ ហើយក្នុងការឆ្លើយតបចំពោះព្រះចេស្តារបស់ព្រះ អ្នកនៅទីក្រុងថែស្សាឡូនីចបានឆ្លើយតប ដោយពួកគេទទួលព្រះរាជសាររបស់ព្រះអង្គ ហើយក្លាយជាអ្នកត្រាប់តាម ជាអ្នកដើរតាមព្រះអម្ចាស់យេស៊ូវគ្រីស្ទ (ខ៦)។ សាវ័ក ប៉ុល មានប្រសាសន៍ថា ការឆ្លើយតបរបស់ពួកគេបានធ្វើជាគំរូសម្រាប់អ្នកដទៃ (ខ៧) ហើយគាត់បាននិយាយជាសង្ខេប អំពីការឆ្លើយតបនោះ ក្នុងខ៩-១០ ជាខគម្ពីរដែលខ្ញុំចង់ផ្តោតទៅលើ។ ពាក្យ «ប្រែចិត្ត និងជឿ» មិនមានប្រើក្នុងបទគម្ពីរនេះ តែគាត់កំពុងបកស្រាយអំពីអត្ថន័យនៃពាក្យទាំងពីរនេះ។

ដូចនេះ ទីមួយ ដើម្បីឲ្យបានសង្គ្រោះ លោកអ្នកត្រូវតែប្រែចិត្តចេញពីអំពើបាប។ សូមមើលខ៩ «ដ្បិតគេថ្លែងប្រាប់ពីយើងខ្ញុំ ដែលអ្នករាល់គ្នាបានទទួលយើងជាយ៉ាងណា ទាំងបែរចេញពីរូបព្រះ មកឯព្រះដ៏ពិត ឲ្យបានគោរពប្រតិបត្តិដល់ព្រះ ដ៏មានព្រះជន្មរស់នៅនោះវិញ»។ ការប្រែចិត្ត គឺជាការបែរចេញ គឺដូចដែលសាវ័ក ប៉ុល បានបកស្រាយថា ពួកជំនុំនៅទីក្រុងថែស្សាឡូនីច បែរចេញពីរូបព្រះមកឯព្រះដ៏ពិត ដើម្បីបម្រើព្រះអង្គ ជាជាងបម្រើរូបព្រះទាំងនោះ។

តើលោកអ្នកដឹងទេថា រូបព្រះគឺជាអ្វី? រូបព្រះគឺជាអ្វីដែលលោកអ្នកថ្វាយបង្គំជំនួសឲ្យការថ្វាយបង្គំព្រះដែលបង្កើតលោកអ្នក។ ក្នុងសម័យបុរាណ លោកអ្នកអាចដឹងថា នរណាម្នាក់មានរូបព្រះ ដែលជារូបចម្លាក់នៅលើធ្នើរ ក្នុងផ្ទះរបស់ពួកគេ។ ទោះយើងមិនធ្វើរូបចម្លាក់តូចៗសម្រាប់ថ្វាយបង្គំក៏ដោយ ក៏មិនមានន័យថា

យើងមិនមានរូបព្រះនោះឡើយ។ រូបព្រះគឺជាអ្វីមួយ ឬនរណាម្នាក់ ដែលលោកអ្នកមិនអាចរស់ដោយគ្មានវាបានទេ។ បើគ្មានពួកវាទេ នោះលោកអ្នកមិនអាចមានអារម្មណ៍សប្បាយ ឬពេញលេញឡើយ។ លោក ចន ខិលវិន (John Calvin) បានមានប្រសាសន៍ថា «ចិត្តរបស់មនុស្សគឺជារោងចក្រផលិតរូបព្រះ»។ ខ្ញុំយល់ឃើញថា គាត់និយាយត្រូវ។ ព្រះបានបង្កើតយើងមក សម្រាប់ថ្វាយបង្គំ ហើយបើយើងមិនថ្វាយបង្គំព្រះទេ នោះយើងនឹងថ្វាយបង្គំអ្វីផ្សេងទៀតជាមិនខាន។ យើងមិនអាចបញ្ឈប់ការថ្វាយបង្គំបានទេ។

ដូចនេះ តើលោកអ្នកថ្វាយបង្គំអ្វី? លោកអ្នកអាចដឹងថា រូបព្រះរបស់លោកអ្នកគឺជាអ្វីមួយ ដែលជំរុញលោកអ្នកឲ្យចំណាយពេល និងកម្លាំងរបស់លោកអ្នក ហើយវាកំណត់របៀបដែលលោកអ្នកប្រើប្រាស់លុយរបស់លោកអ្នក។ លោកអ្នកក៏អាចដឹងថា រូបព្រះរបស់លោកអ្នក គឺជាអ្វីមួយដែលធ្វើឲ្យលោកអ្នកខឹងខ្លាំង ព្រោះពេលណារូបព្រះរបស់យើងទទួលរងការគំរាមកំហែង យើងតែងតែចង់ការពារពួកវា។ យើងស្ទើរតែអាចបង្កើតរូបព្រះពីអ្វីក៏បាន ដែលមានដូចជា រឿងផ្លូវភេទ ប្រាក់កាស ការគិតរបស់អ្នកដទៃមកលើយើង សន្តិសុខ ការគ្រប់គ្រង និងភាពសុខស្រួល។ ប៉ុន្តែរូបព្រះដែលយើងស្រឡាញ់ខ្លាំងជាងគេ គឺខ្លួនយើង ហេតុនេះហើយ យើងក៏ចង់ឲ្យអ្នកដទៃថ្វាយបង្គំរូបព្រះរបស់យើងផងដែរ។

សាវ័ក ប៉ុល បានបង្រៀនថា មូលដ្ឋាននៃការប្រែចិត្ត គឺជាការកែតម្រង់ចិត្តរបស់យើងទាំងស្រុង ដើម្បីកុំឲ្យយើងថ្វាយបង្គំរូបព្រះរបស់យើងទៀត តែយើងទទួលព្រះអង្គធ្វើជាកម្មវត្ថុនៃការថ្វាយបង្គំរបស់យើងវិញ។

យើងច្រើនតែគិតអំពីការប្រែចិត្ត តាមរបៀបខុសពីនេះ។ ការប្រែចិត្តមិនមែនជា *ការលុបលាងកំហុស*ទេ។ ការលុបលាងកំហុសគឺជាការធ្វើអំពើល្អ ដើម្បីលុបលាងកំហុសដែលយើងបានធ្វើ។ ប៉ុន្តែ លោកអ្នកអាចលុបលាងកំហុសខ្លួនឯង ខណៈពេលដែលលោកអ្នកកំពុងតែថ្វាយបង្គំរូបព្រះដែលលោកអ្នកស្រឡាញ់ជាងគេ។

ការប្រែចិត្តក៏មិនមែនជា*ការប្ដេជ្ញាចិត្តខាងក្រមសីលធម៌*ធម្មតាៗឡើយ។ ជួនកាល យើងនិយាយអំពីការប្រែចិត្ត ធ្វើមើលតែការប្រែចិត្តគឺជាការប្ដេជ្ញាចិត្តបែបសាសនាសម្រាប់ឆ្នាំថ្មី។ ខ្ញុំនឹងព្យាយាមជៀសវាងការអនុវត្តដូចនេះទៀត។ (ឧទាហរណ៍) ប៉ុន្តែ ទោះយើងកែប្រែអាកប្បកិរិយារបស់យើងហើយក៏ដោយ ក៏ចិត្តរបស់យើងនៅតែប្ដូរផ្ដាច់ចំពោះរូបព្រះរបស់យើង។ តើព្រះយេស៊ូវបានហៅពួក ផារិស៊ី ថាអ្វី? គឺម៉ុងខ្មោចដែលលាបពណ៌ស (ម៉ាថាយ ២៣:២៧) ល្អមើលតែខាងក្រៅ តែខាងក្នុងមានពេញដោយភាពពុករលួយ។ ការប្រែចិត្តក៏មិនមែនជាការមាន*អារម្មណ៍ប្រកាន់ទោសខ្លួនឯង* ដែលបានធ្វើទង្វើអាក្រក់នោះទេ។ យើងអាចមានអារម្មណ៍ប្រកាន់ទោសខ្លួនឯង ដោយសារគេបានចាប់កំហុសយើង ពេលយើងប្រព្រឹត្តខុស ឬយើងខ្មាសគេដោយសារគេបកអាក្រាតយើង។ ជួនកាល យើងមានអារម្មណ៍ប្រកាន់ទោសខ្លួនឯង នៅពេលដែលគេមិនបានចាប់កំហុសយើង។ តែលោកអ្នកអាចមានអារម្មណ៍ប្រកាន់ទោសខ្លួនឯង ខណៈពេលដែលលោកអ្នកនៅតែស្រឡាញ់បាប ដែលធ្វើឲ្យលោកអ្នកប្រកាន់ទោសខ្លួនឯងនោះ។

ការប្រែចិត្តមិនមានអត្ថន័យដូចរៀបរាប់ខាងលើនេះទេ។ ការប្រែចិត្តពិតប្រាកដនឹងបណ្ដាលឲ្យមានជីវិតផ្លាស់ប្រែ។ ប៉ុន្តែ ជីវិតដែលផ្លាស់ប្រែនោះ កើតចេញពីការកែប្រែចិត្តក្នុងការថ្វាយបង្គំ គឺមិនមែនកើតមុនការប្រែចិត្តនោះទេ។ ការប្រែចិត្តកើតចេញពីការទទួលស្គាល់បាបរបស់ខ្លួនឯង វាជាការស្អប់អ្វីមួយដែលយើងស្រឡាញ់ និងបម្រើកាលពីមុន ហើយងាកបែរចេញពីវា ហើយផ្ទុយទៅវិញ យើងងាកទៅរកការស្រឡាញ់ព្រះ ដែលយើងធ្លាប់ស្អប់កាលពីមុន ហើយបម្រើព្រះអង្គវិញ។ ការប្រែចិត្តគឺជាការកែប្រែចិត្ត ក្នុងការថ្វាយបង្គំ ដែលនាំឲ្យមានការផ្លាស់ប្រែជីវិត ក្នុងការបម្រើព្រះ។

ហើយការប្រែចិត្តគឺជាអ្វីដែលយើងរាល់គ្នាត្រូវតែធ្វើ។ ព្រះអម្ចាស់បានបង្កើតយើងមក ឲ្យថ្វាយបង្គំព្រះអង្គ។ តែការដែលយើងសម្រេចចិត្តថ្វាយបង្គំអ្វីមួយ ឬអ្វីគ្រប់

យ៉ាង ក្រៅពីព្រះ មិនបានធ្វើឲ្យព្រះអង្គខកព្រះទ័យ ឬខូចចិត្ត ប្រៀបដូចជាគូស្នេហ៍ដែលគេបានក្បត់នោះទេ។ តែវាគឺជាការអញ្ជើញចូលមកក្នុងការជំនុំជំរះរបស់ព្រះអង្គ។ បើយើងមិនកែប្រែចិត្តក្នុងការថ្វាយបង្គំព្រះអង្គទេ នោះយើងនៅតែជាប់នៅក្រោមការថ្កោលទោសដ៏យុត្តិធម៌របស់ព្រះអង្គ។ មានផ្លូវតែមួយគត់ ដើម្បីឲ្យយើងអាចប្រែចិត្តបាន គឺទាល់តែព្រះទ្រង់ប្រទានចិត្តថ្មីដល់យើង។ ប៉ុន្តែ នៅពេលដែលព្រះអង្គប្រទានចិត្តដែលកើតជាថ្មី នោះយើងនឹងមានការប្រែចិត្ត ដោយងាកទៅរកព្រះអង្គ ដើម្បីស្រឡាញ់ និងបម្រើទ្រង់។

យើងចាំបាច់ត្រូវមានការយល់ដឹងដ៏ត្រឹមត្រូវ អំពីរឿងនេះ។ ខ្ញុំជឿជាក់ថា លោកអ្នកមានចិត្តចង់ឲ្យគេក្លាយជាគ្រីស្ទបរិស័ទ។ ហេតុនេះហើយលោកអ្នកបានមកចូលរួមសិក្ខាសាលានេះ។ យើងត្រូវប្រាកដថា ពេលណាយើងហៅគេឲ្យឆ្លើយតបចំពោះដំណឹងល្អ គឺយើងហៅពួកគេឲ្យប្រែចិត្ត។ ពេលណាយើងញែកការប្រែចិត្ត ចេញពីការទទួលជឿព្រះ ដោយសារយើងគិតថា ការប្រែចិត្តអាចកើតមានបន្ទាប់ពីយើងទទួលជឿព្រះ ឬដោយសារយើងបន្ទាបតម្លៃរបស់វា ឬកាត់បន្ថយអត្ថន័យរបស់វាមកនៅត្រឹមការប្រកាន់ទោសខ្លួនឯង ឬការប្តេជ្ញាចិត្តផ្នែកសីលធម៌ នោះយើងកំពុងតែនាំគេឲ្យវង្វេង ដោយផ្តល់ឲ្យពួកគេនូវការធានាក្លែងក្លាយថា ពួកគេគឺជាគ្រីស្ទបរិស័ទ តែតាមពិតពួកគេមិនមែនជាគ្រីស្ទបរិស័ទទេ។ ពេលណាយើងញែកការប្រែចិត្ត ចេញពីការទទួលជឿព្រះ នោះមិនខុសពីយើងកំពុងចាក់វ៉ាក់សាំង កុំឲ្យគេទទួលដំណឹងល្អអញ្ចឹង ដោយបង្រៀនពួកគេថា ពួកគេបានសង្គ្រោះហើយ ហើយមិនគួរមានការបារម្ភទៀតទេ ខណៈពេលដែលពួកគេគ្មានបានធ្វើអ្វី ក្រៅពី «ការសម្រេចចិត្តទទួលជឿព្រះ» ប៉ុណ្ណោះ។ ការធានាក្លែងក្លាយបែបនេះ មានលក្ខណៈដូចជាប្រព័ន្ធការពាររាងកាយ ដោយធ្វើឲ្យពួកគេជឿថា ពួកគេមិនចាំបាច់ត្រូវព្រួយបារម្ភទៀតទេ។

តើមនុស្សប្រភេទនោះមានលក្ខណៈដូចម្តេចខ្លះ គឺអ្នកដែលបានទទួលការបង្រៀនឲ្យសន្មតថា ពួកគេបានសង្គ្រោះហើយ តែតាមពិតពួកគេមិនទាន់បានសង្គ្រោះទេ?

គឺអ្នកដែលចង់ចូលនគរស្ថានសួគ៌ តែគ្មានពេលសម្រាប់គ្រីស្ទបរិស័ទផ្សេងទៀត ឬក្រុមជំនុំតាមតំបន់ នៅលើផែនដីទេ។ គឺអ្នកដែលចូលចិត្តព្រះយេស៊ូវ តែមិនបានប្ដេជ្ញាចិត្តធ្វើអ្វីផ្សេងទៀត ដែលមានដូចជា ការស្ដាប់បង្គាប់ សេចក្ដីបរិសុទ្ធ ការបង្កើតសិស្ស និងការលះបង់ខ្លួនឯង។ កណ្ឌគម្ពីរ ១យ៉ូហាន ៥:១-៣ បានចែងថា «អស់អ្នកណាដែលជឿថា ព្រះយេស៊ូវជាព្រះគ្រីស្ទអ្នកនោះបានកើតពីព្រះមក ហើយអស់ទាំងអ្នកណាដែលស្រឡាញ់ព្រះដ៏បង្កើតខ្លួនមក នោះក៏រមែងស្រឡាញ់ដល់អស់អ្នកឯទៀត ដែលកើតពីទ្រង់មកដែរ កាលណាយើងស្រឡាញ់ដល់ព្រះ ហើយកាន់តាមអស់ទាំងបញ្ញត្តិរបស់ទ្រង់ នោះយើងដឹងថា យើងស្រឡាញ់ដល់ពួកកូនរបស់ព្រះដែរ ដ្បិតនេះហើយជាសេចក្តីស្រឡាញ់ដល់ព្រះ គឺឲ្យយើងកាន់តាមអស់ទាំងបញ្ញត្តិរបស់ទ្រង់ ឯបញ្ញត្តិទ្រង់ នោះមិនមែនជាបន្ទុកដ៏ធ្ងន់ទេ»។

លោកគ្រូ បុនហេហ្វ័រ (Bonhoeffer) បានបកស្រាយយ៉ាងច្បាស់អំពីបញ្ហានេះដោយសរសេរថា «នៅពេលដែលព្រះយេស៊ូវហៅមនុស្សម្នាក់ឲ្យដើរតាមព្រះអង្គ គឺព្រះអង្គហៅអ្នកនោះឲ្យមកតាមព្រះអង្គ ហើយស្លាប់។ ដើម្បីក្លាយជាគ្រីស្ទបរិស័ទ យើងត្រូវលីឈើឆ្កាង ដែលជាការទទួលយកជីវិតដែលប្រែចិត្ត។ មិនមែនជាការប្ដេជ្ញាចិត្តតែមួយដង មិនមែនជាការមានអារម្មណ៍ប្រកាន់ទោសខ្លួនឯង និងសោកស្ដាយកំហុស តែមួយរយៈពេលនោះទេ។ តែជាការកែតម្រង់ចិត្តរបស់យើង ដែលចាប់ផ្ដើមនៅពេលមួយ ហើយបន្តបង្ហាញចេញមក ក្នុងជីវិតដែលបម្រើ និងស្រឡាញ់ព្រះ»។

បើលោកអ្នកចង់ក្លាយជាគ្រីស្ទាន លោកអ្នកត្រូវតែប្រែចិត្ត។ ចូរកុំខ្លាច មិនហ៊ានហៅមនុស្សឲ្យប្រែចិត្ត ត្រូវតាមព្រះគម្ពីរ។ លោកអ្នកប្រហែលជាខ្លាចពួកគេបិទចិត្ត ហើយដើរចេញដោយការភ័យខ្លាច បើលោកអ្នកហៅពួកគេឲ្យប្រែចិត្ត។ តែការទទួលជឿព្រះពិតប្រាកដតែម្នាក់ គឺប្រសើរជាងការសម្រេចចិត្តតែសម្បកក្រៅ១០នាក់ ដែលនឹងដាច់ចេញពីជំនឿវិញ ក្នុងពេលខ្លីខាងមុខ។

ទីពីរ ដើម្បីបានសង្គ្រោះ *លោកអ្នកត្រូវតែជឿដំណឹងល្អអំពីព្រះយេស៊ូវ*។ សូមមើល

ម្តងទៀត នៅក្នុងកណ្ឌគម្ពីរ ១ថែស្សាឡូនីច ១:៩-១០ “ដ្បិតគេថ្លែងប្រាប់ពីយើងខ្ញុំដែលអ្នករាល់គ្នាបានទទួលយើងជាយ៉ាងណា ទាំងបែរចេញពីរូបព្រះ មកឯព្រះដ៏ពិត ឲ្យបានគោរពប្រតិបត្តិដល់ព្រះ ដ៏មានព្រះជន្មរស់នៅនោះវិញ ហើយឲ្យបានចាំព្រះរាជបុត្រាព្រះ ទ្រង់យាងមកពីស្ថានសួគ៌ ដែលព្រះបានប្រោសឲ្យទ្រង់រស់ពីស្លាប់ឡើងវិញ គឺជាព្រះយេស៊ូវ ដែលទ្រង់ប្រោសឲ្យយើងរួចពីសេចក្តីខ្ញាល់ទៅមុខ”។ នៅក្នុងខ១០ សាវ័ក ប៉ុល បានមានប្រសាសន៍ថា គ្រីស្ទបរិស័ទនៅទីក្រុងថែស្សាឡូនីចកំពុងរង់ចាំការយាងមកវិញរបស់ព្រះយេស៊ូវ ដែលព្រះទ្រង់បានប្រោសឲ្យមានព្រះជន្មរស់ឡើងវិញ ហើយបានសង្គ្រោះយើងឲ្យរួចពីសេចក្តីក្រោធដែលត្រូវមកដល់។ ក្នុងឃ្លាទាំងនេះ សាវ័ក ប៉ុល បានសង្ខេបដំណឹងល្អ។ ព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះ បានសុគតនៅលើឈើឆ្កាង ដើម្បីសង្គ្រោះអស់អ្នកណាដែលប្រែចិត្តជឿព្រះអង្គ ឲ្យរួចពីសេចក្តីក្រោធដែលត្រូវមក ជាការជំនុំជម្រះរបស់ព្រះ មកលើការថ្វាយបង្គំរូបព្រះរបស់យើង។ តាមរយៈការលះបង់ព្រះជន្មរបស់ព្រះអង្គ ជំនួសឲ្យជីវិតយើង ធ្វើជាដង្វាយលោះបាប និងតាមរយៈការសុគតជំនួសយើង និងទទួលរងការជំនុំជម្រះរបស់ព្រះ ដោយសារបាបរបស់យើង ព្រះយេស៊ូវសម្រេចបានការសង្គ្រោះ។ ហើយដើម្បីបង្ហាញថា ព្រះទ្រង់បានទទួលយកដង្វាយលោះបាបនេះ ព្រះអង្គបានប្រោសព្រះយេស៊ូវឲ្យមានព្រះជន្មរស់ឡើងវិញ។ បើព្រះអង្គជាមនុស្សមានបាប ជាមនុស្សថ្វាយបង្គំរូបព្រះដូចយើងដែរ នោះព្រះអង្គមុខជាមិនមានព្រះជន្មរស់ឡើងវិញទេ ព្រោះវាធ្វើឲ្យព្រះអង្គសមនឹងទទួលសេចក្តីស្លាប់។ ប៉ុន្តែ សេចក្តីស្លាប់គ្មានអំណាចមកលើព្រះយេស៊ូវទេ ព្រោះបាបគ្មានអំណាចមកលើព្រះអង្គ។ ហេតុនេះហើយបានជាការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គ គឺបានបញ្ជាក់ថា ការអ្វីដែលព្រះអង្គមានបន្ទូលអំពីអង្គទ្រង់ និងការអ្វីដែលព្រះអង្គបានយាងមកធ្វើ គឺសុទ្ធតែត្រឹមត្រូវ។ ហើយសព្វថ្ងៃ ព្រះយេស៊ូវកំពុងគង់នៅខាងស្តាំព្រះវរបិតា ធ្វើជាព្រះអម្ចាស់ និងអង្គសង្គ្រោះ ហើយព្រះអង្គបានសន្យាថា ទ្រង់នឹងយាងមកវិញ នៅថ្ងៃចុងក្រោយ ដើម្បីជំនុំជម្រះលោកិយ ហើយទទួលអស់លោកអ្នកដែលជឿព្រះអង្គ

និងព្រះរាជសាររបស់ព្រះអង្គ ទៅរស់នៅជាមួយព្រះអង្គជារៀងរហូត។

នេះជាសារនៃដំណឹងល្អ ដំណឹងល្អអំពីព្រះយេស៊ូវ និងជាអ្វីដែលសាវ័ក ប៉ុល បានថា ពួកជំនុំនៅទីក្រុងថែស្សាឡូនីចបានជឿ។ ជាការពិតណាស់ ក្នុងខគម្ពីរនេះ គាត់មិនប្រើពាក្យ «ជឿ» ឬ «ជំនឿ» ទេ។ គាត់គ្រាន់តែនិយាយថា ពួកគេ «រង់ចាំព្រះរាជបុត្រានៃព្រះ ទ្រង់យាងមកពីស្ថានសួគ៌»។ ប៉ុន្តែ ខ្ញុំគិតឃើញថា នេះជាការពណ៌នាល្អបំផុត អំពីអត្ថន័យនៃការជឿព្រះយេស៊ូវ។

សេចក្តីជំនឿគឺលើសពីការទទួលយកគោលគំនិតអ្វីមួយ*នៅក្នុងចិត្ត*។ សេចក្តីជំនឿរបស់គ្រីស្ទបរិស័ទពិតជាផ្អែកទៅលើសេចក្តីពិត។ មានគោលគំនិតដែលយើងត្រូវតែទទួលយក។ ប៉ុន្តែ សាវ័ក ប៉ុល បានពណ៌នា ក្នុងបទគម្ពីរនេះថា ជំនឿពិតប្រាកដមិនគ្រាន់តែយល់ស្របថា ព្រះយេស៊ូវជាព្រះ ព្រះអង្គសុគតនៅលើឈើឆ្កាង ហើយព្រះអង្គបានមានព្រះជន្មរស់ឡើងវិញប៉ុណ្ណោះទេ។ នៅស្ថាននរកនឹងមានមនុស្សដែលយល់ស្របនឹងសេចក្តីពិតនេះ កាលពួកគេនៅរស់។ ជាងនេះទៅទៀត ជំនឿលើព្រះយេស៊ូវមិនមែនជា*រូបមន្តសម្រាប់និយាយ*ចេញមកនោះទេ។ លោកអ្នកមិនក្លាយជាគ្រីស្ទបរិស័ទទេ ដោយគ្រាន់តែនិយាយ ឬអធិស្ឋានចេញជាពាក្យសម្តីថា «ឱព្រះយេស៊ូវគ្រីស្ទអើយ! ទូលបង្គំជាមនុស្សមានបាប សូមព្រះអង្គអត់ទោសបាបឲ្យទូលបង្គំ» ឬនិយាយថា «ព្រះយេស៊ូវគឺជាព្រះអម្ចាស់»។ មានគ្រីស្ទបរិស័ទច្រើនពេកហើយដែលមានចេតនាល្អ តែបានប្រើខគម្ពីរ រ៉ូម ១០:៩ ដោយកាត់បន្ថយមកនៅត្រឹមរូបមន្តមួយសម្រាប់និយាយ ដោយជឿថា ដរាបណាលោកអ្នកនិយាយចេញមកយ៉ាងដូចនេះ ដោយចិត្តស្មោះត្រង់ នោះលោកអ្នកបានក្លាយជាគ្រីស្ទបរិស័ទហើយ។ ឱមិត្តអ្នកអានអើយ! នោះមិនមែនជាជំនឿទេ តែជាវេទមន្ត។ គឺធ្វើមើលតែពាក្យសម្តីទាំងនោះ មានអំណាចដោយខ្លួនឯង។ ហើយវាមិនខុសពីរបៀបដែលលោកអ្នកក្លាយជាសាសនិកអ៊ីស្លាមនោះទេ។

ជំនឿមិនមែនជាការយល់ស្រប ចំពោះសេចក្តីពិតណាមួយ ឬនិយាយចេញនូវពាក្យសម្តីណាមួយនោះឡើយ។ ជាងនេះទៅទៀត ជំនឿមិនមែនជាការអនុវត្តន៍ខាងវិញ្ញាណ ឬជាផ្នែកមួយនៃសហគមន៍នៃសេចក្តីជំនឿ ឬជាការស្វែងរកទិសដៅខាងឯវិញ្ញាណនោះទេ។ សេចក្តីជំនឿគឺជាការទុកចិត្ត និងពឹងផ្អែកទាំងស្រុងទៅលើព្រះ គឺជឿថា ព្រះអង្គនឹងធ្វើតាមព្រះបន្ទូលសន្យាក្នុងដំណឹងល្អ។ ***ពួកជំនុំនៅទីក្រុងថែស្សាឡូនីច*** បានធ្វើលើសពីការសរសេរនៅក្រដាសថា ពួកគេជាអ្នកជឿព្រះយេស៊ូវ ឬលើសពីការអធិស្ឋានតាមលំនាំណាមួយ។ ពួកគេបានចាប់ផ្តើម***វង់ចាំព្រះយេស៊ូវ***យាងមកវិញ ហើយពឹងផ្អែកលើសេចក្តីសង្គ្រោះរបស់ព្រះអង្គ។ សេចក្តីជំនឿរបស់ពួកគេបានបង្ហាញចេញមក តាមរយៈជីវិតដែលបានផ្លាស់ប្រែ។ ពួកគេឈប់ពឹងផ្អែកលើអំពើល្អ ពួកគេឈប់ពឹងផ្អែកលើរូបព្រះរបស់ពួកគេ ពួកគេឈប់ពឹងផ្អែកលើទ្រព្យសម្បត្តិ។ ពួកគេបានចាប់ផ្តើមពឹងផ្អែកលើព្រះបន្ទូលសន្យា ក្នុងដំណឹងល្អ។ ពួកគេចាប់ផ្តើមទុកចិត្តលើព្រះបន្ទូលរបស់ព្រះដែលថា បើពួកគេងាកបែរចេញពីអំពើបាប ហើយពឹងផ្អែកលើព្រះគ្រីស្ទ និងព្រះរាជកិច្ចដែលព្រះអង្គបានសម្រេចនៅលើឈើឆ្កាង ជំនួសពួកគេ ដោយពួកគេមិនបន្ថែមអ្វីទៀត នោះពួកគេគ្មានអ្វីដែលត្រូវភ័យខ្លាចនៅចំពោះព្រះ នៅពេលអនាគត គឺគ្មានការជំនុំជំរះ គ្មានការថ្កោលទោស តែផ្ទុយទៅវិញ មានជីវិតអស់កល្បជានិច្ច។ សេចក្តីជំនឿលើសពីការសូត្រព្រះបន្ទូលសន្យារបស់ព្រះ ទៅកាន់ព្រះអង្គ ក្នុងការអធិស្ឋាន តែជាការពឹងផ្អែក ទទួល និងទុកចិត្តព្រះបន្ទូលសន្យាទាំងនោះ។ ហើយការអនុវត្តន៍ដូចនេះធ្វើឲ្យជីវិតលោកអ្នកផ្លាស់ប្រែ។ គឺដូចដែលកណ្ឌគម្ពីរយ៉ាកុបបានចែងថា “***ជំនឿដែលគ្មានការប្រព្រឹត្ត*** ជំនឿដែលគ្មានការផ្លាស់ប្រែ គឺជា***ជំនឿស្លាប់*** គឺគ្មានជំនឿទាល់តែសោះ” (យ៉ាកុប ២:១៧)។

តើយើងកំពុងបង្រៀនគេឲ្យពឹងផ្អែកទៅលើអ្វី? កុំពឹងផ្អែកលើខ្លួនឯង កុំពឹងផ្អែកលើអំពើល្អ ភាពស្មោះត្រង់ ការអនុវត្តន៍ខាងឯវិញ្ញាណឡើយ។ ហើយកុំពឹងផ្អែក

លើការសម្រេចចិត្តដែលលោកអ្នកបានធ្វើ ឬការអធិស្ឋានរបស់លោកអ្នកកាលនៅក្មេង ឬមួយការសម្រេចចិត្តរបស់លោកអ្នកនៅកន្លែងបោះជំរុំយុវជន ឬក៏ពាក្យសម្ដីដែលលោកអ្នកនិយាយក្នុងបន្ទប់គេង កាលមួយឆ្នាំ ឬមួយទសវត្សរ៍មុន។ សាវ័កប៉ុល បានមានប្រសាសន៍ ក្នុងកណ្ឌគម្ពីរ ២កូរិនថូស ១៣:៥ ដោយបង្គាប់យើងថា «ចូរអ្នករាល់គ្នាពិចារណាខ្លួនឯងមើល តើស្ថិតនៅក្នុងសេចក្តីជំនឿឬទេ»។ ចូរពឹងផ្អែកលើព្រះគ្រីស្ទ ដូចដែលព្រះអង្គបានសន្យាចំពោះលោកអ្នក ក្នុងដំណឹងល្អ។ សេចក្តីជំនឿដែលបានសង្គ្រោះ គឺជាការពឹងផ្អែក ដែលឈោងទៅរក និងតោងឲ្យជាប់ព្រះគ្រីស្ទ ដោយមិនប្រលែងដៃ។ ហើយបន្ទាប់មក ចូរស្វែងរកភស្តុតាងនៃព្រះគុណរបស់ព្រះ ក្នុងជីវិតលោកអ្នកចុះ។ ក្នុងនាមយើងជាពួកជំនុំ ចូរយើងជួយគ្នាឲ្យមើលឃើញភស្តុតាងនៃព្រះគុណរបស់ព្រះ ក្នុងជីវិតយើងម្នាក់ៗ។ បើលោកអ្នកនៅជាប់ក្នុងព្រះគ្រីស្ទ លោកអ្នកមិនចាំបាច់ត្រូវក្រឡេកមកក្រោយ មើលទៅការសម្រេចចិត្តកាលពីមុនក៏បាន។ ការសម្រេចចិត្តនោះនឹងបង្ហាញលទ្ធផលឲ្យឃើញច្បាស់ ក្នុងពេលសព្វថ្ងៃ។

ដូចដែលយើងចាំបាច់ត្រូវចែកចាយឲ្យបានត្រឹមត្រូវអំពីការប្រែចិត្តក្នុងការផ្សាយដំណឹងល្អរបស់យើងជាយ៉ាងណា នោះយើងក៏ចាំបាច់ត្រូវចែកចាយឲ្យគេមានសេចក្តីជំនឿត្រឹមត្រូវផងដែរ។ គ្រោះថ្នាក់អាចកើតមាន នៅពេលដែលយើងបង្រៀនគេឲ្យអាចពន្យល់ដំណឹងល្អ អធិស្ឋាន យល់ស្របចំពោះសេចក្តីពិត ហើយថែមទាំងប៉ះពាល់ចិត្តដោយសេចក្តីពិតទាំងនោះ តែគេមិនស្គាល់ព្រះយេស៊ូវ ហើយមិនពឹងផ្អែកលើព្រះអង្គ។ គឺដូចសាវ័ក យ៉ូហាន បានមានប្រសាសន៍ក្នុងបទគម្ពីរ ១យ៉ូហាន ៤ ថា «*បើអ្នកណាថា ខ្លួនស្រឡាញ់ព្រះ តែស្អប់ដល់បងប្អូនវិញ អ្នកនោះជាអ្នកកុហក*»។ សេចក្តីជំនឿដែលបានសង្គ្រោះនឹងបង្ហាញខ្លួនចេញមក ក្នុងជីវិតដែលផ្លាស់ប្រែ។

តាំងពីយូរមកហើយ ចាប់តាំងពីយុគសម័យភ្ញាក់រឭកដ៏ធំជំនាន់ទីពីរ ព្រះវិហារដំណឹងល្អជាច្រើនបាននិយាយអំពីការទទួលជឿព្រះថា គ្រាន់តែជាការសម្រេចចិត្តដែលគេត្រូវតែធ្វើ និងបន្ទាប់មកបង្ហាញការសម្រេចចិត្តនោះដោយលើកដៃឡើង ហើយដើរទៅរកតុអាសនា។ «ការហៅឲ្យដើរទៅរកអាសនា» គឺជាការលើកទឹកចិត្តគេឲ្យធ្វើការសម្រេចចិត្ត ហើយបន្ទាប់មកបង្ហាញចេញការសម្រេចចិត្តនោះ តាមរយៈសកម្មភាពជាសាធារណៈ។ ប៉ុន្តែ តើការទទួលជឿព្រះដែលប្រែក្លាយជាការសម្រេចចិត្តដូចនេះ បានបង្កើតផលផ្លែអ្វីខ្លះ? គឺបង្កើតឲ្យមានព្រះវិហារដែលមានពេញទៅដោយមនុស្សដែលប្រកាសថា ខ្លួនជាគ្រីស្ទបរិស័ទ តែមានការរស់នៅមិនខុសពីលោកីយ៍ប៉ុន្មានទេ។ អត្រានៃការលែងលះគ្នាក្នុងក្រុមជំនុំយើង មិនមានអ្វីល្អជាងសហគមន៍ដែលយើងកំពុងរស់នៅទេ។ ការស្រឡាញ់សម្ភារៈនិយមហាក់ដូចជាកំពុងតែកើនឡើង ដោយគ្មានការទប់ស្កាត់។ ការមើលរូបអាសអាភាស ក្នុងចំណោមមនុស្សប្រុសបានក្លាយជារឿងធម្មតាទៅហើយ ហើយក៏កំពុងកើនឡើងនៅក្នុងចំណោមមនុស្សស្រី ក្នុងពួកជំនុំរបស់យើងដែរ។ បញ្ជីសមាជិកភាពនៃពួកជំនុំមានពេញទៅដោយមនុស្សដែលកម្រមកព្រះវិហារ ឬឈប់មកព្រះវិហារ។ តើហេតុអ្វី? គឺមិនគ្រាន់តែដោយសារគ្រីស្ទបរិស័ទធ្វើអំពើបាបប៉ុណ្ណោះទេ។ តែដោយសារពួកជំនុំ និងសមាជិកភាពរបស់យើង មានពេញទៅដោយមនុស្សដែលមិនមែនជាគ្រីស្ទបរិស័ទ ដែលមិនបានកើតជាថ្មី ប៉ុន្តែ បានទទួលការធានាថា ពួកគេបានសង្គ្រោះ ដោយសារពួកគេបានធ្វើការសម្រេចចិត្តដើរតាមព្រះយេស៊ូវ។

ហើយអ្វីដែលគួរឲ្យអៀនខ្មាសនោះគឺ យើងមានចិត្តអន្ទះសាចង់ផ្លុំត្រែអបអរ «ការសម្រេចចិត្ត» ទាំងនោះ ហើយចាត់ទុកការផ្សាយដំណឹងល្អរបស់យើងថាជាការងារដែលជោគជ័យ ហើយប្រញាប់អបអរខ្លួនឯង ប៉ុន្តែ តាមពិត ទោះក្នុងចំណោមអ្នកទាំងនោះ មានតែ១០ភាគរយ ដែលនៅតែដើរតាមព្រះគ្រីស្ទ ក្នុងរយៈពេល១ឆ្នាំទៀតក៏ដោយ ក៏ក្រុមដូចសមាគមន៍ ប៊ីលី ក្រាហាំ (Billy Graham Association) នឹង

ប្រាប់លោកអ្នកថា លោកអ្នកកំពុងតែធ្វើបានល្អជាងពួកជំនុំភាគច្រើន។ តែការសម្រេចចិត្តទាំងនោះមានអ្វីខ្លះ? ហើយហេតុអ្វីយើងមានចិត្តរំភើបរីករាយ ចំពោះពួកវាខ្លាំងយ៉ាងនេះ? ព្រោះការសម្រេចចិត្តទាំងនោះ គឺជាចំនួនមនុស្សទទួលជឿព្រះដែលយើងសម្រេចបាន។ ប៉ុន្តែ តើការអះអាងដូចនេះបានប្រយោជន៍អ្វី? ខ្ញុំបាននឹកចាំ អំពីរឿងរបស់លោកគ្រូ ស្ពើជិន (Spurgeon) ដែលបានចែកចាយអំពីគ្រូគង្វាលម្នាក់ជាមិត្តភក្តិរបស់គាត់ ដែលត្រូវមនុស្សស្រវឹងស្រាម្នាក់មកឈរពាំងផ្លូវគាត់ នៅថ្ងៃមួយបានប្រាប់គាត់ថា «អេ លោក ហ៊ីល (Hill) ខ្ញុំជាមនុស្សដែលលោកគ្រូបាននាំឲ្យជឿព្រះ»។ លោកគ្រូ ហ៊ីល ក៏បានឆ្លើយតបថា «លោកប្រាកដជាមនុស្សដែលខ្ញុំបាននាំឲ្យជឿព្រះមែនហើយ តែអ្នកមិនបានជឿព្រះអង្គទេ»។

ការសម្រេចចិត្តរបស់មនុស្សគឺជាអ្វីដែលយើងអាចប្រមូលផល ប្រើប្រាស់ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន ងាយនឹងប្រមូលឲ្យបានច្រើន និងបង្កើតឲ្យមាន ដោយចិត្តមិនស្មោះត្រង់។ ប៉ុន្តែ ការបង្កើតសិស្សមិនដូចនេះទេ។ ឱមិត្តភក្តិទាំងឡាយអើយ! ការបង្កើតសិស្សគឺជាអ្វីដែលព្រះយេស៊ូវបានប្រាប់យើងឲ្យចេញទៅ ហើយបង្កើតថ្វាយព្រះអង្គ។ យើងមិនគ្រាន់តែត្រូវឲ្យគេសម្រេចចិត្តទេ តែយើងក៏ត្រូវនាំឲ្យពួកគេក្លាយជាសិស្ស ជាអ្នកដើរតាមយូរអង្វែង ដែលស៊ូទ្រាំទុក្ខលំបាក លីឈើឆ្កាង និងដើរតាមព្រះយេស៊ូវ។

ពិតណាស់ យើងមិនគួរកំណត់ស្តង់ដារនៃការធ្វើជាសិស្ស ខ្ពស់ជាងការកំណត់របស់ព្រះយេស៊ូវ ប៉ុន្តែ យើងក៏មិនគួរកំណត់ស្តង់ដារឲ្យទាបជាងដែរ។ ដូចនេះ តើព្រះអង្គបានត្រាស់ហៅមនុស្ស ឲ្យឆ្លើយតបចំពោះដំណឹងល្អដូចម្តេចខ្លះ? កណ្ឌគម្ពីរ *ម៉ាកុស ១:១៤-១៥ «គ្រាក្រោយដែលគេបញ្ជូនយ៉ូហានទៅឃុំហើយ នោះព្រះយេស៊ូវទ្រង់យាងមកក្នុងស្រុកកាលីឡេវិញ ព្រមទាំងប្រកាសប្រាប់ដំណឹងល្អពីនគរព្រះថា ពេលវេលាបានសម្រេចហើយ នគរព្រះជិតមកដល់ ដូច្នេះ ចូរប្រែចិត្ត ហើយជឿដំណឹងល្អចុះ»*។ នេះជាអ្វីដែលពួកសិស្សដំបូងរបស់ព្រះយេស៊ូវធ្វើ ខណៈ

ពេលដែលពួកគេចាកចេញពីជីវិតចាស់ ហើយដើរតាមព្រះយេស៊ូវ ដោយការប្រែចិត្ត ចេញពីបាប និងមានសេចក្ដីជំនឿ។

ដើម្បីក្លាយជាគ្រីស្ទាន យើងត្រូវក្លាយជាសិស្សរបស់ព្រះគ្រីស្ទ គឺលោកអ្នកត្រូវតែ ចាប់ផ្ដើមរស់នៅ ក្នុងជីវិតដែលមានការប្រែចិត្ត និងសេចក្ដីជំនឿ ក្នុងពេលបច្ចុប្បន្ន ហើយបង្ហាញថា ខ្លួនបានកើតជាថ្មី ខណៈពេលដែលពួកគេរង់ចាំ ដោយសង្ឃឹម ថា ព្រះយេស៊ូវនឹងយាងមកពីស្ថានសួគ៌វិញ គឺព្រះយេស៊ូវដែលបានរំដោះយើងឲ្យ រួចពីសេចក្ដីក្រោធដែលត្រូវមក។

# ថ្មី–មិនមែនល្អទេ

និពន្ធដោយ៖ លោក ម៉ែឃើល ឡរ៉េនស៍

(អេសេគាល ៣៦:២៤-២៨ និងយ៉ូហាន ៣:១-១០)

ទង្វើនៃការក្លាយជាគ្រីស្ទបរិស័ទ  គឺជាការហៅថាការប្រែចិត្ត ប៉ុន្តែតើបុគ្គលណាម្នាក់អាចប្រែចិត្តបានដោយរបៀបណា? យើងចង់ឃើញមនុស្សម្នាក្លាយជាគ្រីស្ទបរិស័ទ ហេតុដូច្នេះហើយបានជាយើងគិតអំពីរបៀប និងសាររបស់យើង។ យើងគិតអំពីរនាំង ដែលយើងមិនត្រូវការមួយចំនួន ដែលយើងអាចនឹងដាក់ ដើម្បីឃាំងផ្លូវ។ យើងគិតអំពីរបៀបបញ្ចុះបញ្ចូល និងអំពីជំនាញកាត់ស្រាយរបស់យើង។ ពិតណាស់ ទាំងអស់នោះល្អ និងត្រឹមត្រូវ។ ប៉ុន្តែ ប្រសិនបើយើងមិនមានការយល់ដឹងត្រឹមត្រូវអំពីគោលលទ្ធិ តាមព្រះគម្ពីរ ទាក់ទងទៅនឹងការប្រែចិត្ត របៀបដែលយើងបានគិតយ៉ាងនោះនឹងនាំឲ្យយើងវង្វេងផ្លូវជាមិនខាន។ ពីព្រោះចំណុចដំបូងដែលយើងត្រូវតែយល់ គឺជាអ្វីដែលខ្ញុំនឹងព្យាយាមវែកញែកនៅក្នុងជំពូកមួយនេះ។ ការប្រែចិត្តគឺជាព័ន្ធកិច្ចរបស់ព្រះជាម្ចាស់ មុនវាក្លាយជាទង្វើរបស់យើង។ ការកើតជាថ្មីត្រូវតែកើតមុនការប្រែចិត្ត ហើយការកើតជាថ្មីក៏ជាព័ន្ធកិច្ចរបស់ព្រះជាម្ចាស់ មិនមែនទង្វើរបស់យើងនោះទេ។

ស្តាប់ទៅ ចំណុចនេះទំនងជាដំណឹងអាក្រក់សម្រាប់មនុស្សមួយចំនួន។ ប៉ុន្តែតាមពិតទៅវាគឺជាដំណឹងដ៏ល្អបំផុត ពីព្រោះយោងតាមព្រះគម្ពីរ យើងមិនអាចផ្លាស់ប្រែខ្លួនឯងបានទេ តែយើងត្រូវតែផ្លាស់ប្រែ ហេតុដូច្នេះហើយ បានដំណឹងនេះជាដំណឹងដ៏ល្អណាស់ ដោយសារព្រះជាម្ចាស់បានប្តេជ្ញាព្រះអង្គទ្រង់ផ្ទាល់ ដើម្បីនាំ

ឲ្យមានការផ្លាស់ប្រែនេះអាចកើតឡើងបាន។ ព្រះអង្គត្រូវតែបង្កើតយើងជាថ្មី មិនមែនបង្កើតឲ្យយើងក្លាយជាមនុស្សល្អនោះទេ។ កណ្ឌគម្ពីរ យ៉ូហាន ៣:១-១០៖

> «រីឯនៅក្នុងពួកផារិស៊ី  មានចៅហ្វាយសាសន៍យូដាម្នាក់ឈ្មោះ នីកូដេម លោកក៏មកឯព្រះយេស៊ូវទាំងយប់ទូលថា លោកគ្រូ យើងខ្ញុំដឹងថា លោកជាគ្រូមកពីព្រះពិត ដ្បិតគ្មានអ្នកណាអាចនឹងធ្វើទីសម្គាល់ ដែលលោកធ្វើទាំងនេះបានទេ លើកតែព្រះគង់នៅជាមួយប៉ុណ្ណោះ ព្រះយេស៊ូវមានបន្ទូលឆ្លើយថា ប្រាកដមែន ខ្ញុំប្រាប់អ្នកជាប្រាកដថា បើមិនបានកើតជាថ្មី នោះគ្មានអ្នកណាអាចនឹងឃើញនគរព្រះបានទេ លោក នីកូដេម ទូលសួរថា ធ្វើដូចម្តេចនឹងកើតឡើងបាន ក្នុងកាលដែលចាស់ហើយ តើអាចនឹងចូលទៅក្នុងពោះម្តាយម្តងទៀត ហើយកើតឡើងវិញបានឬ ព្រះយេស៊ូវមានបន្ទូលឆ្លើយថា ប្រាកដមែនខ្ញុំប្រាប់អ្នកជាប្រាកដថា បើមិនបានកើតអំពីទឹក ហើយអំពីព្រះវិញ្ញាណ នោះគ្មានអ្នកណាអាចនឹងចូលទៅក្នុងនគរព្រះបានទេ របស់អ្វីដែលកើតពីសាច់ នោះជាសាច់ទេ ហើយដែលកើតពីព្រះវិញ្ញាណ នោះជាវិញ្ញាណវិញ កុំឲ្យឆ្ងល់ ពីពាក្យដែលខ្ញុំប្រាប់ថា ត្រូវតែកើតជាថ្មីនោះឡើយ ឯខ្យល់ ចង់បក់ទៅឯណា ក៏ចេះតែបាន ហើយអ្នកឮសូរសព្ទ តែមិនដឹងជាមកពីណា ឬទៅឯណាទេ អស់អ្នកណាដែលកើតមកពីព្រះវិញ្ញាណ នោះក៏ដូច្នោះដែរ លោក នីកូដេម ទូលសួរថា ធ្វើដូចម្តេចឲ្យការទាំងនេះកើតបាន ព្រះយេស៊ូវទ្រង់ឆ្លើយថា អ្នកជាគ្រូនៃសាសន៍អ៊ីស្រាអែល តែមិនដឹងការទាំងនេះទេឬ»។

ទាក់ទងទៅនឹងគោលលទ្ធិនៃការប្រែចិត្ត នេះគឺជាខគម្ពីរដែលយើងត្រូវតែចាប់ផ្តើមជាមួយ ពីព្រោះគឺត្រង់នេះឯងដែលព្រះយេស៊ូវបានប្រើប្រាស់ជាដំបូងនូវភាសាអំពី “ការកើតជាថ្មី”។ ខ្ញុំនឹងមិនចំណាយពេល ដើម្បីពន្យល់នូវរាល់គ្រប់ចំណុចនៅត្រង់នេះទេ ដូចដែលខ្ញុំតែងតែធ្វើ ប្រសិនបើយើងមានពេលវេលាជាច្រើន ដើម្បីសិក្សាកណ្ឌគម្ពីរយ៉ូហាន។ ខ្ញុំគ្រាន់តែចង់ឲ្យបងប្អូនសម្គាល់មើលជម្រើសពីរយ៉ាងទាក់ទងទៅនឹងជីវិត។ ជាដំបូង ខ្ញុំចង់ឲ្យបងប្អូនឲ្យតម្លៃលើ *ការអំពាវនាវឲ្យធ្វើជាមនុស្សល្អ* ដែលនោះគឺជាអ្វីដែលលោក នីកូដេម កំពុងតែដេញតាម។ ទីពីរ ខ្ញុំចង់

ឲ្យបងប្អូនយល់អំពី *សារៈសំខាន់នៃការកើតជាថ្មី* ដែលនោះគឺជាអ្វីដែលព្រះយេស៊ូវកំពុងតែទទូចចង់បាន។ ជម្រើសពីរយ៉ាង៖ *ការអំពាវនាវឲ្យធ្វើជាមនុស្សល្អ និងសារៈសំខាន់នៃការកើតជាថ្មី*។

ជាដំបូង *ការអំពាវនាវឲ្យធ្វើជាមនុស្សល្អ*៖ លោក នីកូដេម បានទៅរកព្រះយេស៊ូវ ដោយមានការសរសើរជាច្រើន ក៏ដូចជាសំណួរដែលមិនបានលើកសួរជាច្រើនផងដែរ។ បើយើងសង្ខេបសំណួររបស់គាត់ទៅ៖ *«ហេតុអ្វីបានជាយើងត្រូវស្តាប់លោកគ្រូ?»*។ ព្រះយេស៊ូវបានយាងមក ហើយមានបន្ទូលអំពីរបៀបចូលទៅកាន់នគរព្រះ។ ប៉ុន្តែ នោះគឺជាអ្វីដែលពួកផារិស៊ីមានជំនាញលើ។ ពួកគេដឹងអំពីរបៀបដែលលោកអ្នកអាចចូលទៅកាន់នគរព្រះបាន។ គឺលោកអ្នកអាចចូលបានតាមរយៈការធ្វើល្អ។ គឺការធ្វើល្អ។

ចំពោះលោក នីកូដេម និងពួកផារិស៊ីឯទៀតៗដូចគាត់ដែរ នោះមានន័យថា ពួកគាត់ត្រូវតែធ្វើជាសាសន៍យូដាដែលមានសភាពល្អ៖ គឺត្រូវធ្វើតាមច្បាប់ និងក្រឹត្យវិន័យ គឺត្រូវទៅសាលាប្រជុំ គឺត្រូវធ្វើទានដល់អ្នកក្រ គឺមិនត្រូវចំណាយពេលជាមួយនឹងសាសន៍ដទៃ។ តាមពិតទៅ ពួកគាត់ស្ទើរតែមាននិម្មិតជាក់លាក់មែនទែនអំពីរបៀបធ្វើជាសាសន៍យូដាដែលមានសភាពល្អ។ លោក នីកូដេម មិនបានគិតថា គាត់ជាមនុស្សល្អឥតខ្ចោះទេ។ តាមពិតទៅ គាត់ទំនងជាដឹងថា គាត់គួរតែធ្វើជាមនុស្សឲ្យបានកាន់តែល្អប្រសើរជាងមុន។ ទំនងនោះគឺជាមូលហេតុចម្បងដែលគាត់បានទៅរកព្រះយេស៊ូវ។ ប៉ុន្តែ នៅចុងបញ្ចប់ គាត់អាចបានត្រឹមតែក្លាយជាមនុស្សល្អប៉ុណ្ណោះ។

ចំពោះយើងជាច្រើននាក់ អត្ថន័យនៃការធ្វើល្អបានមានការផ្លាស់ប្រែជាច្រើន។ បច្ចុប្បន្ននេះ មានប្រភេទនៃអត្ថន័យជាច្រើនខុសៗគ្នា ទាក់ទងទៅនឹងការធ្វើជាមនុស្សល្អ។ អត្ថន័យមានតាំងពីការដកខ្លួនចេញពីការរស់នៅ ហើយអនុញ្ញាតឲ្យមានការរស់នៅ រហូតទៅដល់ការមានសម្បជញ្ញៈ និងការចូលរួមផ្ទាល់ទាក់ទងទៅ

នឹងសង្គម។ និយាយទៅគឺថែមទាំងមានការធ្វើល្អបែបសាសនា បែបខាងឯវិញ្ញាណ ហើយសូម្បីតែការធ្វើល្អនៅកន្លែងខ្ញុំរស់នៅផងដែរ គឺថាយើងមិនចង់មានការឈ្លោះប្រកែកគ្នា គឺយើងបែរជាផ្តោតទៅលើការមិនធ្វើឲ្យនរណាម្នាក់មានអារម្មណ៍ថា *មិនស្រួលចិត្ត*។ ប៉ុន្តែ មិនថាយើងមានប្រភេទនៃការធ្វើល្អច្រើន ខុសៗគ្នា ប៉ុណ្ណាក៏ដោយ ក៏ការអំពាវនាវឲ្យធ្វើជាមនុស្សល្អមិនបានផ្លាស់ប្រែដែរ។ ការធ្វើជាមនុស្សល្អ (មនុស្សដែលមានការរីករាយ ឬក៏មនុស្សដែលកំពុងតែក្លាយជាមនុស្សដែលកាន់តែល្អប្រសើរជាមុន) មិនថាលោកអ្នកផ្តល់អត្ថន័យយ៉ាងដូចម្តេចក៏ដោយ គឺទាំងនោះដើម្បីធ្វើឲ្យលោកអ្នកមានអារម្មណ៍ល្អពីខ្លួនឯង។ គឺដើម្បីឲ្យខ្លួនឯងមានមោទនភាពទាក់ទងទៅនឹងបុគ្គលដែលលោកអ្នកបានក្លាយជា។ គឺដើម្បីសរសើរខ្លួនឯងទៅកាន់អ្នកដទៃ ឬក៏ថាដើម្បីសរសើរខ្លួនឯងទៅកាន់ព្រះទៀតផង។ បើនិយាយម្យ៉ាងវិញទៀត ការអំពាវនាវឲ្យធ្វើជាមនុស្សល្អ គឺដើម្បីអនុញ្ញាតឲ្យលោកអ្នកអាចបង្ហាញថា *ខ្លួនគ្មានទោស* ទៅកាន់អ្នកដែលកំពុងសួរនាំអំពីជីវិតរបស់លោកអ្នក ចេញពីសតិសម្បជញ្ញៈរបស់ខ្លួន គឺរហូតទៅដល់ព្រះទៀតផង។

ប៉ុន្តែ មិនថាលោកអ្នកបានផ្តល់អត្ថន័យយ៉ាងដូចម្តេចទៅលើការធ្វើជាមនុស្សល្អ មនុស្សដែលមានចិត្តរីករាយ ក៏ការអំពាវនាវឲ្យធ្វើជាមនុស្សល្អតែងតែមានមូលដ្ឋានលើគំនិត៣យ៉ាង។ ទស្សនៈសុទិដ្ឋិនិយម (optimistic view) លើមនុស្សលោក។ *ទស្សនៈនៃការឲ្យតម្លៃតូចទាប* (domesticated view) ទៅលើព្រះជាម្ចាស់ និងទស្សនៈលើសាសនាថាជារបៀបនៃ*ការកែទម្រង់ខ្លួនឯង ផ្នែកសីលធម៌* (moral self-reform)។ ពិតណាស់លោក នីកូដេម មិនបានលើកឡើងនូវរាល់ចំណុចទាំងអស់នេះនោះទេ។ ប៉ុន្តែ យើងឃើញចំណុចទាំងអស់នេះយ៉ាងច្បាស់លាស់នៅក្នុងចម្លើយរបស់គាត់ទៅកាន់ព្រះយេស៊ូវ។ សូមអានម្តងទៀតនៅក្នុងកណ្ឌគម្ពីរ យ៉ូហាន ៣:៣-៩ “ព្រះយេស៊ូវមានបន្ទូលឆ្លើយថា “ប្រាកដមែន ខ្ញុំប្រាប់អ្នកជាប្រាកដថា បើមិនបានកើតជាថ្មី នោះគ្មានអ្នកណាអាចនឹងឃើញនគរព្រះបានទេ”។ លោក នីកូ

ដេម ទូលសួរថា "ធ្វើដូចម្ដេចនឹងកើតឡើងបាន ក្នុងកាលដែលចាស់ហើយ តើអាចនឹងចូលទៅក្នុងពោះម្ដាយម្ដងទៀត ហើយកើតឡើងវិញបានឬ?" ព្រះយេស៊ូវមានបន្ទូលឆ្លើយថា "ប្រាកដមែនខ្ញុំប្រាប់អ្នកជាប្រាកដថា 'បើមិនបានកើតអំពីទឹក ហើយអំពីព្រះវិញ្ញាណ នោះគ្មានអ្នកណាអាចនឹងចូលទៅក្នុងនគរព្រះបានទេ។ របស់អ្វីដែលកើតពីសាច់ នោះជាសាច់ទេ ហើយដែលកើតពីព្រះវិញ្ញាណ នោះជាវិញ្ញាណវិញ។ កុំឲ្យឆ្ងល់ ពីពាក្យដែលខ្ញុំប្រាប់ថា ត្រូវតែកើតជាថ្មីនោះឡើយ ឯខ្យល់ ចង់បក់ទៅឯណា ក៏ចេះតែបាន ហើយអ្នកឮសូរសព្ទ តែមិនដឹងជាមកពីណា ឬទៅឯណាទេ អស់អ្នកណាដែលកើតមកពីព្រះវិញ្ញាណ នោះក៏ដូច្នោះដែរ'"។ លោក នីកូដេម ទូលសួរថា "ធ្វើដូចម្ដេចឲ្យការទាំងនេះកើតបាន?" ព្រះយេស៊ូវទ្រង់ឆ្លើយថា "អ្នកជាគ្រូនៃសាសន៍អ៊ីស្រាអែល តែមិនដឹងការទាំងនេះទេឬ?"»។ ព្រះយេស៊ូវបានប្រាប់លោក នីកូដេម ថាប្រសិនបើគាត់ចង់ចូលនគរព្រះ គឺគាត់ត្រូវតែធ្វើនូវអ្វីដែលមិនអាចធ្វើបាន—គឺគាត់ត្រូវតែកើតជាថ្មី។ យើងអាចសង្ខេបការឆ្លើយតបរបស់លោក នីកូដេម ថា «ឆ្កួតហើយ! យើងមិនអាចធ្វើដូច្នោះបានទេ។ ព្រះមិនតម្រូវឲ្យយើងធ្វើអ្វីដែលយើងមិនអាចធ្វើបានឡើយ។ នេះមិនមែនជារបៀបដែលខ្ញុំបានគិតថាវាត្រូវតែដំណើរការយ៉ាងដូច្នោះទេ»។ ជាមូលដ្ឋាន លោក នីកូដេម បានសន្មតថាគាត់អាចធ្វើនូវអ្វីដែលគាត់ត្រូវធ្វើ ដើម្បីបង្ហាញថាខ្លួនគ្មានទោសនៅចំពោះព្រះ។ គាត់បានសន្មតថា ព្រះគឺជាព្រះដែលនឹងពេញចិត្តចំពោះការខិតខំប្រឹងប្រែងដែលអស់ពីសមត្ថភាពរបស់គាត់។ ហើយគាត់បានសន្មតថា ចំណុចស្នូលនៃសាសនាគឺ ដើម្បីឲ្យគាត់អាចក្លាយជាបុគ្គលដែលល្អប្រសើរជាងមុន ដែលគាត់មិនអាចធ្វើបានដោយខ្លួនឯង គឺដើម្បីឲ្យព្រះអាចនឹងទទួលយកគាត់បាន។

តើលោកអ្នកធ្លាប់មានទស្សនៈដូចលោក នីកូដេម ដែរឬទេ? ខ្ញុំធ្លាប់មាន។ កាលខ្ញុំជាសិស្សវ័យក្មេងម្នាក់នៅឯមហាវិទ្យាល័យ ខ្ញុំមិនមែនជាបុគ្គលដែលគួរតែមានលក្ខណៈដូចដែលខ្ញុំគួរតែមាននោះទេ ហើយខ្ញុំក៏បានបារម្ភថា ព្រះជាម្ចាស់ក៏នឹងមិន

ទទួលយកខ្ញុំដែរ។ ដូច្នេះ ខ្ញុំក៏បានចាប់ផ្ដើមការសន្ទនាមួយជាមួយនឹងព្រះជាម្ចាស់។ ខ្ញុំបានចាប់ផ្ដើមចរចាជាមួយនឹងព្រះអង្គ៖ *«ខ្ញុំនឹងឈប់ផឹកស្រា ខ្ញុំនឹងលែងរញ៉េរញ៉ៃជាមួយនឹងសង្សារខ្ញុំ។ ហើយខ្ញុំនឹងចាប់ផ្ដើមអានព្រះគម្ពីររបស់ខ្ញុំឲ្យបានកាន់តែច្រើនជាងមុន។ តើព្រះអង្គយល់ឃើញយ៉ាងម៉េចដែរ?»* ខ្ញុំបានគិតថា ខ្លួនអាចធ្វើនូវអ្វីដែលខ្ញុំត្រូវតែធ្វើបាន។ ហើយព្រះអង្គនឹងមានការស្ងប់ស្ងៀង។ ហើយសាសនាក៏នឹងជួយខ្ញុំផងដែរ។

ប្រមាណឆ្នាំមុន មិត្តភក្តិម្នាក់របស់ខ្ញុំបានប្រាប់ខ្ញុំអំពីមូលនិធិឈាម (The Blood Foundation)។ គឺជាក្រុមមួយនៅឯប្រទេសថៃ ដែលបានប្ដេជ្ញាចិត្តលើគំនិតនៃការរួបរួមខាងឯព្រលឹងវិញ្ញាណ ទាក់ទងទៅនឹងគ្រួសារមនុស្ស។ គឺដើម្បីឲ្យតម្លៃលើការអត់ទ្រាំ និងការយល់ចិត្តគ្នា៖ ពួកគាត់បាននាំក្រុមតូចឲ្យមានបទពិសោធន៍ក្នុងជំនឿនិងវប្បធម៌ខុសៗគ្នា ក្នុងលក្ខណៈបែបជាត្រាំ ឬក៏ជ្រលក់ពួកគាត់ឲ្យស្គាល់រសជាតិជំនឿស៊ុប។ ពួកគាត់ទៅធ្វើជាលោកសង្ឃមួយខែ ឬក៏កាន់តាមសាសនាឥស្លាមមួយខែ។ ពួកគាត់បានសន្មតថា សាសនាគឺគ្រាន់តែជាអ្វីដែលខ្លួនធ្វើតែប៉ុណ្ណោះ ដូច្នេះលោកអ្នកគ្រាន់តែអាចសាកល្បងវាចុះ។ មិនចាំបាច់កែប្រែចិត្តទេ។ មិនចាំបាច់មានអំណះអំណាងនៃកំណែទម្រង់ពិត ពីខាងក្នុងនោះទេ។ គឺលោកអ្នកគ្រាន់តែទទួលស្គាល់ថា សាសនាគឺដើម្បីជួយឲ្យលោកអ្នកកាន់តែបានល្អប្រសើរជាងមុន កាន់តែអាចក្លាយជាមនុស្សល្អ នោះលោកអ្នកនឹងទំនងជាឃើញថា សាសនារបស់បុគ្គលណាម្នាក់អាចនាំឲ្យគាត់ឈានដល់ជំហាននោះបាន ដូចដែលសាសនារបស់លោកអ្នកបានធ្វើដល់លោកអ្នកផងដែរ។

នេះជាមូលហេតុដែលមនុស្សជាច្រើននៅលោកខាងលិចបានបោះបង់សាសនាចោល។ ប្រសិនបើចំណុចស្នូលនៃសាសនាគឺ ដើម្បីឲ្យខ្ញុំអាចក្លាយជាបុគ្គលដែលល្អប្រសើរជាងមុននៅថ្ងៃនេះ បើប្រៀបធៀបទៅនឹងម្សិលមិញ ដូច្នេះហេតុអ្វីបានជាខ្ញុំគ្រាន់តែត្រូវការសាសនាតែមួយ ឬក៏ថាហេតុអ្វីបានជាខ្ញុំចាំបាច់ត្រូវកាន់តាម

សាសនាណាមួយ។ តាមពិតទៅ សំណួរដ៏ពិត មិនថាមាន ឬក៏មិនមានសាសនា ប្រសិនបើគោលបំណងរបស់លោកអ្នកគឺគ្រាន់តែឲ្យបានក្លាយជាមនុស្សល្អប្រសើរជាងមុន តើលោកអ្នកកំពុងតែជោគជ័យ ឬក៏អត់? ហើយថា តើយោងតាមស្តង់ដាររបស់អ្នកណា? ចុះបើស្តង់ដារដែលលោកអ្នកកំពុងតែឈោងចាប់មិនមែនជាស្តង់ដារដែលលោកអ្នកត្រូវតែបំពេញតាម?

ប្រសិនបើលោកអ្នកជាគ្រីស្ទបរិស័ទ នោះលោកអ្នកនឹងដឹងថា ការធ្វើជាមនុស្សល្អនឹងមិនអាចបំពេញតម្រូវការបានទេ។ ព្រះអង្គបានរចនាយើងឡើងជាថ្មី តាមរយៈព្រះគុណនៃដំណឹងល្អ។ ប៉ុន្តែ យើងងាយក្នុងការលង់ចូលក្នុងផ្នត់គំនិតចាស់នៃការធ្វើជាមនុស្សល្អ។ គឺការរាប់ថា ខ្លួនឯងគ្មានទោសដោយពឹងលើសីលធម៌នៃការប្រព្រឹត្តរបស់ខ្លួន ជាជាងពឹងលើព្រះគុណ។ គឺការសង់ក្រុមជំនុំរបស់យើងលើសីលធម៌ ជាជាងលើឈើឆ្កាង។ តើលោកអ្នកអាចដឹងថា ការនេះកំពុងតែកើតឡើងបានដោយរបៀបណា? គឺមានរបៀបច្រើន។ តើពេលវេលាបានកន្លងផុតច្រើនជាងមួយអាទិត្យ បន្ទាប់ពីលោកអ្នកបានសូមឲ្យនរណាម្នាក់អត់ទោសលោកអ្នក សម្រាប់អំពើបាបដែលលោកអ្នកបានប្រព្រឹត្តហើយឬនៅ? តើលោកអ្នកមានមិត្តភក្តិដែលមិនឯកភាពជាមួយនឹងលោកអ្នក ទាក់ទងទៅនឹងអត្ថន័យរបស់លោកអ្នកនៃពាក្យថា ធ្វើជាមនុស្សល្អ ឬក៏សីលធម៌ដែរឬទេ? តើលោកអ្នកគិតថា មានមនុស្សណាល្អប្រសើរជាងខ្លួនដែរឬទេ ហើយហេតុអ្វីបានជាលោកអ្នកគិតដូច្នោះ? តើពេលណាជាពេលវេលាចុងក្រោយដែលលោកអ្នកបានលួងលោមខ្លួនឯង ទាក់ទងទៅនឹងអំពើបាបណាមួយ ពីព្រោះយ៉ាងហោចណាស់វាក៏មិនមែនជាអំពើបាបដែលធ្ងន់ធ្ងរផងដែរ? បងប្អូន នេះគឺជាផ្នត់គំនិតនៃការគិតទាក់ទងទៅនឹងការធ្វើល្អ។

នៅក្នុងក្រុមជំនុំរបស់ពួកយើង យើងនឹងដឹងថា យើងបានចាប់ផ្តើមឲ្យតម្លៃលើសីលធម៌ជាជាងលើឈើឆ្កាង នៅពេលដែលយើងអត់ធន់នឹងអំពើបាបមួយចំនួន ហើយមិនបានអត់ធន់លើអំពើបាបមួយចំនួនទៀត។ នៅពេលដែលយើងឲ្យតម្លៃ

ស្មើគ្នាលើនយោបាយ និងជំនឿរបស់យើង។ នៅពេលដែលមនុស្សមួយប្រភេទ មិនទទួលបានការស្វាគមន៍ពីយើង។ នៅពេលដែលយើងបែកគ្នាដោយអាស្រ័យ លើការរៀបចំសណ្តាប់ធ្នាប់ ឬក៏ទម្រង់ការងាររបស់យើង ជាជាងមានការរួបរួមគ្នា ដោយពឹងលើដំណឹងល្អ។ ប៉ុន្តែ ច្បាស់ជាងនេះទៅទៀត គឺយើងនឹងឃើញអំពីរបៀប នោះនៅពេលដែលយើងសរសើរជំនឿគ្រីស្ទបរិស័ទទៅកាន់លោកីយ៍។ គឺនៅពេល ដែលយើងនិយាយថា ជីវិតរបស់លោកអ្នកនឹងកាន់តែល្អប្រសើរជាងមុន ប្រសិនបើ លោកអ្នកក្លាយជាគ្រីស្ទបរិស័ទ! សូមមើល (ចង្អុលមកកាន់ខ្លួនឯង)។ នៅពេល ដែលយើងបង្រៀនកូនយើងថា ការធ្វើជាមនុស្សល្អគឺជាអត្ថន័យនៃការធ្វើជាគ្រីស្ទ បរិស័ទ។ ខ្ញុំមិនដែលអធិប្បាយដោយមានចំណងជើងថា «គន្លឹះ១០យ៉ាងនៃការ មានជីវិតអាពាហ៍ពិពាហ៍ដែលល្អប្រសើរជាងមុន» ទេ។ នេះមិនមែនមកពីខ្ញុំមិន គិតថា ព្រះគ្រីស្ទនឹងនាំឲ្យមានចំណុចផ្លាស់ប្រែនៅក្នុងជីវិតអាពាហ៍ពិពាហ៍របស់ លោកអ្នកនោះទេ។ មូលហេតុខ្ញុំមិនធ្វើដូច្នោះ គឺដោយសារខ្ញុំដឹងថា លោកីយ៍នេះ កំពុងតែសួរមកខ្ញុំ ក៏ដូចជាកំពុងតែសួរមកកាន់យើងដែលជាក្រុមជំនុំថា៖ ហេតុអ្វី បានជាយើងត្រូវតែស្តាប់លោកអ្នក? ហើយប្រសិនបើយើងឆ្លើយតបទៅវិញថា៖ «គឺ ដោយសារខ្ញុំនឹងជួយឲ្យលោកអ្នកក្លាយជាមនុស្សដែលល្អប្រសើរជាងមុន ក្លាយជា មនុស្សដែលសប្បាយចិត្តជាងមុន ឬក៏ក្លាយជាមនុស្សដែលល្អជាងមុន» ព្រោះនៅ ពេលដែលពួកគេឃើញក្រុមជំនុំ និងជីវិតរស់នៅរបស់យើង នោះពួកគេនឹងមិនជឿ ទេ។ ពួកគេនឹងមិនឈប់ទទួលយកផ្នត់គំនិតនៃការធ្វើជាមនុស្សល្អ ពីព្រោះវាមិន ដែលបាត់បង់ការអំពាវនាវនោះទេ។ គឺពួកគាត់នឹងឃើញថា ពួកគាត់មិនចាំបាច់ នៅបន្តមានផ្នត់គំនិតនោះនៅក្នុងក្រុមជំនុំទេ។

ពិតណាស់ ការអំពាវនាវឲ្យធ្វើជាមនុស្សល្អគឺពិតជាខ្លាំងមែន។ វាប៉ះទង្គិចនឹង តុច្ឆភាព និងមោទនភាពរបស់យើង។ វាជះឥទ្ធិពលទៅលើបំណងប្រាថ្នានៃការ ដែលយើងចង់សរសើរខ្លួនឯងទៅកាន់ព្រះជាម្ចាស់ និងទៅកាន់គ្នាទៅវិញទៅមក។

វាសម្អាតយើងបានយ៉ាងល្អពីខាងក្រៅ។ ប៉ុន្តែ នោះមិនមែនជាការផ្លាស់ប្តូរដែលយើងត្រូវការនោះទេ។

យើងមិនចាំបាច់ក្លាយជាមនុស្សល្អនោះទេ។ អ្វីដែលយើងត្រូវការនោះ គឺក្លាយជាមនុស្សដែលបានកើតជាថ្មី។ នោះគឺជាអ្វីដែលព្រះយេស៊ូវបានប្រឆាំងជាមួយនឹងលោក នីកូដេម និងយើង។ តម្រូវការនៃការកើតជាថ្មី។ ព្រះយេស៊ូវបានលើកឡើងយ៉ាងច្បាស់លាស់នៅក្នុងខគម្ពីរនេះបីដងថា គឺមិនមែនគ្រាន់តែជាជម្រើសនោះទេ ប៉ុន្តែគឺជាផ្នត់គំនិតដែលចាំបាច់ត្រូវមាន។ ដាច់ខាត គឺយើងត្រូវតែកើតជាថ្មី ប្រសិនបើយើងចង់ចូលនគរព្រះ។ សូមមើលម្តងទៀតនៅក្នុងខ៣ «ព្រះយេស៊ូវមានបន្ទូលឆ្លើយថា “ប្រាកដមែន ខ្ញុំប្រាប់អ្នកជាប្រាកដថា បើមិនបានកើតជាថ្មី នោះគ្មានអ្នកណាអាចនឹងឃើញនគរព្រះបានទេ”»។ នៅក្នុងខ៥ «ព្រះយេស៊ូវមានបន្ទូលឆ្លើយថា “ប្រាកដមែនខ្ញុំប្រាប់អ្នកជាប្រាកដថា បើមិនបានកើតអំពីទឹក ហើយអំពីព្រះវិញ្ញាណ នោះគ្មានអ្នកណាអាចនឹងចូលទៅក្នុងនគរព្រះបានទេ”»។ នៅក្នុងខ៧ «កុំឲ្យឆ្ងល់ពីពាក្យដែលខ្ញុំប្រាប់ថា ត្រូវតែកើតជាថ្មីនោះឡើយ»។ ការបង្រៀននៅក្នុងព្រះគម្ពីរនេះគឺច្បាស់លាស់ណាស់។ ប្រសិនបើយើងចង់ជានាជាមួយនឹងព្រះ គឺយើងមិនចាំបាច់គ្រាន់តែធ្វើឲ្យខ្លួនឯងល្អប្រសើរជាងមុននោះទេ។ តែយើងត្រូវការការចាប់ផ្តើមជាថ្មី។ ព្រះអង្គត្រូវតែបង្កើតយើងជាថ្មី យើងត្រូវតែកើតជាថ្មីម្តងទៀត (ប្រសិនបើយើងចង់ប្រើព្រះបន្ទូលរបស់ព្រះយេស៊ូវផ្ទាល់)។ តាមពិតទៅ ព្រះគម្ពីរបានប្រើប្រាស់ពាក្យពេចន៍ខុសៗគ្នាមួយចំនួន ដើម្បីពណ៌នាអំពីអ្វីដែលព្រះយេស៊ូវកំពុងតែមានបន្ទូលនៅត្រង់នេះ។ «បានជាបើអ្នកណានៅក្នុងព្រះគ្រីស្ទ នោះឈ្មោះថាបានកើតជាថ្មីហើយ អស់ទាំងសេចក្តីចាស់បានកន្លងបាត់ទៅ មើល គ្រប់ទាំងអស់បាន*ត្រឡប់ជាថ្មីវិញ*» (២កូរិនថូស ៥:១៧)។ «ចូរប្រដាប់ខ្លួនដោយមនុស្សថ្មីវិញ ដែលកំពុងតែកែឡើងខាងឯសេចក្តីចេះដឹង ឲ្យបានត្រូវនឹងរូបអង្គព្រះ ដែលបង្កើត*មនុស្សថ្មី*នោះមក» (កូឡូស ៣:១០)។ ប៉ុន្តែ ពាក្យមួយដែលព្រះគម្ពីរមិនដែលប្រើប្រាស់

ដើម្បីពណ៌នាអំពីអ្វីដែលព្រះយេស៊ូវកំពុងតែមានបន្ទូលគឺពាក្យ «កំណែទម្រង់ ឬក៏កែទម្រង់»។ ការកែទម្រង់អ្វីមួយគឺជាការស្តារនូវអ្វីដែលធ្លាប់បានបែកបាក់ គឺជាការកែអ្វីមួយដែលមានការឆ្គង។ ប៉ុន្តែ ភាសាព្រះគម្ពីរទាក់ទងទៅនឹងការផ្លាស់ប្តូរ ដែលព្រះយេស៊ូវកំពុងតែមានបន្ទូល មានអត្ថន័យជ្រៅជ្រះជាងនេះទៅទៀត—គឺលើសពីការជួសជុលយើងឡើងវិញ គឺរហូតដល់ថ្នាក់ថា មានការផ្លាស់ប្តូរយ៉ាងខ្លាំងទាក់ទងទៅនឹងលក្ខណៈដើមរបស់យើងផ្ទាល់។

យោងតាមព្រះគម្ពីរ ព្រះបានបង្កើតយើងនៅក្នុងរូបអង្គទ្រង់។ ព្រះអង្គបានបង្កើតយើងមក ដើម្បីឲ្យថ្វាយបង្គំទ្រង់ ដើម្បីឲ្យស្រឡាញ់ទ្រង់ និងដើម្បីឲ្យយើងអាចទទួលបានការស្កប់ចិត្តយ៉ាងជ្រាលជ្រៅនៅក្នុងអង្គទ្រង់ផ្ទាល់។ នោះហើយគឺជាលក្ខណៈដើមរបស់យើង។ ប៉ុន្តែ នៅពេលដែលឪពុកម្តាយដំបូងរបស់យើងបានសម្រេចចិត្តបះបោរទាស់ប្រឆាំងនឹងព្រះអង្គ ដោយស្វែងរកការស្កប់ចិត្តនៅកន្លែងផ្សេងទៀត គឺពួកគាត់មិនគ្រាន់តែមិនបានស្តាប់តាមច្បាប់ណាមួយនោះទេ ប៉ុន្តែពួកគាត់បាននាំឲ្យមានភាពពុករលួយដល់លក្ខណៈដើមរបស់ខ្លួនផងដែរ។ ទេវវិទូបានហៅការនេះថាជា «អំពើបាបមរតក» ហើយយើងទាំងអស់គ្នាសុទ្ធតែទទួលបានមរតកនេះ។ ព្រះអង្គបានបង្កើតយើងឲ្យមានលក្ខណៈ ដើម្បីស្រឡាញ់ទ្រង់ ប៉ុន្តែឥឡូវនេះយើងបែរជាមានលក្ខណៈដែលមានទំនោរមកកាន់ខ្លួនឯង គឺទំនោរនៃការស្រឡាញ់ខ្លួនឯងជាជាងស្រឡាញ់ព្រះ។ ហើយយើងក៏បានបង្ហាញអំពីលក្ខណៈដើមនេះជាប្រចាំថ្ងៃ ក្នុងការដែលយើងសម្រេចចិត្តប្រព្រឹត្តអំពើបាបជាប្រចាំ។ សាវ័ក ប៉ុល បានមានប្រសាសន៍ដូចតទៅនៅក្នុងកណ្ឌគម្ពីរ អេភេសូរ ២:១-៣ ថា «ពីដើម អ្នករាល់គ្នាក៏ស្លាប់ក្នុងការរំលង ហើយក្នុងអំពើបាបដែរ។ ជាការដែលអ្នករាល់គ្នាបានប្រព្រឹត្ត តាមរបៀបលោកីយ៍នេះ គឺតាមមេគ្រប់គ្រងរាជ្យលើអាកាស ជាវិញ្ញាណ ដែលសព្វថ្ងៃនេះបណ្តាលមកក្នុងពួកមនុស្សរឹងចចេស។ យើងរាល់គ្នាទាំងអស់ក៏បានប្រព្រឹត្តក្នុងពួកនោះពីដើមដែរ ដោយសេចក្តីប៉ងប្រាថ្នារបស់សាច់ឈាមយើង ទាំងប្រព្រឹត្តសេចក្តី

ដែលសាច់ឈាម និងគំនិតយើងចង់បានផង ហើយតាមកំណើតយើង នោះយើងជាមនុស្សជាប់ក្នុងសេចក្ដីខ្វាល់ ដូចជាមនុស្សឯទៀតដែរ»។ នេះជាមូលហេតុដែលការគ្រាន់តែធ្វើជាមនុស្សល្អនឹងមិនអាចបំពេញតម្រូវការបាន ហើយជាមូលហេតុដែលព្រះយេស៊ូវបានមានបន្ទូលថា ដាច់ខាតយើងត្រូវកើតជាថ្មីម្ដងទៀត។

សារៈសំខាន់នៃសភាពថ្មី ឬក៏ការកើតជាថ្មីម្ដងទៀត គឺជាសេចក្ដីពិត៣យ៉ាងដែលយើងឃើញមាននៅក្នុងព្រះគម្ពីរ។ *ភាពបរិសុទ្ធ*របស់ព្រះជាម្ចាស់ *អសមត្ថភាព*របស់មនុស្ស និង*ព្រះគុណ*នៃដំណឹងល្អ។ នេះគឺជាការសង្ខេបនៃអ្វីដែលព្រះយេស៊ូវបានមានបន្ទូលទៅកាន់លោក នីកូដេម។ សូមមើលនៅក្នុង៥-៦ «ព្រះយេស៊ូវមានបន្ទូលឆ្លើយថា ប្រាកដមែនខ្ញុំប្រាប់អ្នកជាប្រាកដថា បើមិនបានកើតអំពីទឹក ហើយអំពីព្រះវិញ្ញាណ នោះគ្មានអ្នកណាអាចនឹងចូលទៅក្នុងនគរព្រះបានទេ។ របស់អ្វីដែលកើតពីសាច់ នោះជាសាច់ទេ ហើយដែលកើតពីព្រះវិញ្ញាណ នោះជាវិញ្ញាណវិញ»។ ត្រង់នេះ ព្រះយេស៊ូវបានញែកញែកយ៉ាងច្បាស់លាស់រវាងសាច់ឈាម និងវិញ្ញាណ ដែលនេះសំដៅទៅលើការញែកញែករវាងយើង និងព្រះអង្គផ្ទាល់។ មិនថាសាច់ឈាមយើងល្អប៉ុណ្ណាក៏ដោយក៏ព្រះយេស៊ូវបានមានបន្ទូលថា វាមិនអាចបង្កើតនូវជីវិតខាងឯវិញ្ញាណ ដែលយើងត្រូវតែមាន ដើម្បីឲ្យយើងអាចបានជានាជាមួយនឹងព្រះជាម្ចាស់បានដែរ។ លើសពីនេះទៅទៀត ព្រះអង្គក៏មិនដូចយើងដែរ។ ព្រះអង្គទ្រង់បរិសុទ្ធ និងមានពេញទៅដោយសិរីល្អ។ ព្រះអង្គមិនស្ញប់ស្ញែងត្រង់ថា យើងល្អ ឬក៏ជាមនុស្សល្អប៉ុណ្ណានោះទេ។ តាមពិតទៅ សភាពល្អ ឬក៏ភាពជាមនុស្សល្អរបស់យើង គឺគ្រាន់តែជាការរម្លឹកម្ដងហើយម្ដងទៀតថា យើងជាកូនចៅរបស់លោកអ័ដាម និងនាង អេវ៉ា តែប៉ុណ្ណោះ។ ដូចនឹងពួកគាត់ យើងក៏កំពុងតែរស់នៅសម្រាប់សិរីល្អរបស់ខ្លួន ជាជាងរបស់ព្រះជាម្ចាស់ ខណៈពេលដែលយើងព្យាយាមរាប់ខ្លួនឯងថា គ្មានទោសនៅចំពោះព្រះអង្គដោយរំពឹងលើជីវិតល្អរបស់ខ្លួន។

មិនថា យើងបានកែតម្រង់ខ្លាំងប៉ុណ្ណានៅខាងក្រៅក៏ដោយក៏យើងនៅមិនអាច

ផ្លាស់ប្តូរសណ្ឋាននៃលក្ខណៈដើមនៅខាងក្នុងរបស់យើងបាន។ ហេតុដូច្នេះហើយ បានជាព្រះគម្ពីរបានពណ៌នាថា យើងជាមនុស្សស្លាប់ មិនមែនគ្រាន់តែថាយើងជាអ្នកឈឺនោះទេ (អេភេសូរ ២)។ ជាប់ជាទាសករ មិនមែនគ្រាន់តែវង្វេងទេ (រ៉ូម ៦)។ ជាមនុស្សដែលស្មោកគ្រោក មិនមែនគ្រាន់តែជាមនុស្សដែលមិនល្អឥតខ្ចោះប៉ុណ្ណោះនោះទេ (ទីតុស)។ ហើយមនុស្សស្លាប់មិនអាចធ្វើឲ្យខ្លួនឯងរស់ឡើងវិញបាននោះដែរ។ ទាសករមិនអាចគ្រាន់តែសម្រេចចិត្តថា ខ្លួនទទួលបានសេរីភាពបានដែរ។ យើងទាំងអស់គ្នាសុទ្ធតែកំពុងតែឈរក្រោមការជំនុំជំរះរបស់ព្រះជាម្ចាស់ ដែលជាការជំនុំជំរះដែលយើងស័ក្តិសមនឹងទទួល ហើយប្រសិនបើយើងនៅតែឯង នោះក៏យើងនឹងមិនអាចធ្វើអ្វីបានដែរ។ សាច់ឈាមអាចបង្កើតបានតែសាច់ឈាមប៉ុណ្ណោះ ប៉ុន្តែអ្វីដែលយើងត្រូវការនោះ គឺជីវិតដែលកើតចេញពីព្រះវិញ្ញាណ។ តើយើងអាចទទួលបានការនេះដោយរបៀបណា?

ដែលនេះនាំយើងមកដល់សេចក្តីពិតទីបី—មិនមែនការខិតខំប្រឹងប្រែងរបស់យើងទាក់ទងទៅនឹងការកែទម្រង់ផ្នែកសីលធម៌ទេ—ប៉ុន្តែគឺការចាប់ផ្តើមដោយព្រះគុណរបស់ព្រះជាម្ចាស់នៅក្នុងដំណឹងល្អវិញ។ មានតែព្រះអង្គទេដែលអាចធ្វើឲ្យយើងអាចទទួលបានការផ្លាស់ប្តូរ និងការកើតជាថ្មីបែបនេះបាន។ សូមអាននៅក្នុងខ៨ជាមួយខ្ញុំ «ឯខ្យល់ ចង់បក់ទៅឯណា ក៏ចេះតែបាន ហើយអ្នកឮសូរសព្ទ តែមិនដឹងជាមកពីណា ឬទៅឯណាទេ អស់អ្នកណាដែលកើតមកពីព្រះវិញ្ញាណ នោះក៏ដូច្នោះដែរ»។ ព្រះយេស៊ូវបានប្រៀបធៀបព័ន្ធកិច្ចរបស់ព្រះវិញ្ញាណនៃព្រះទៅនឹងខ្យល់។ គ្មានអ្នកណាអាចគ្រប់គ្រងលើខ្យល់បានទេ។ ខ្យល់បក់ទៅណា តាមតែទំនោរចិត្តរបស់វា។ ដូចគ្នានេះដែរ នេះគឺជាអ្វីដែលព្រះយេស៊ូវកំពុងតែមានបន្ទូលអំពីព្រះវិញ្ញាណ។ បើអ្នកណាចង់ចូលនគរព្រះ ដាច់ខាតគាត់ត្រូវតែកើតជាថ្មីម្តងទៀត។ ប៉ុន្តែ ដើម្បីឲ្យបុគ្គលណាម្នាក់អាចកើតជាថ្មីបាន ដាច់ខាតព្រះជាម្ចាស់ផ្ទាល់ត្រូវតែជាអង្គដែលធ្វើការចាប់ផ្តើម ព្រះអង្គត្រូវតែធ្វើការនោះ នោះទើបវាអាចកើតឡើងបាន។ ហើយ

នោះឯងគឺជាអ្វីដែលព្រះអង្គបានធ្វើ តាមរយៈព្រះយេស៊ូវគ្រីស្ទ។ ដោយមិនបានរង់ចាំទាល់តែយើងទូលសូម តាមពិតទៅខណៈពេលដែលយើងកំពុងតែជាខ្មាំងសត្រូវជាមួយនឹងព្រះអង្គនៅឡើយ គឺព្រះអង្គបានចាត់ព្រះរាជបុត្រារបស់ទ្រង់ ជាបុគ្គលទី២នៃព្រះត្រៃឯក ដើម្បីឲ្យទ្រង់យាងមកក្នុងលក្ខណៈជាសាច់ឈាម ឲ្យរស់នៅនូវជីវិតដែលព្រះអង្គបានបង្កើតយើងឲ្យរស់នៅ។ នេះគឺជាអ្វីដែលព្រះយេស៊ូវបានប្រព្រឹត្ត។ ព្រះអង្គបានមានព្រះជន្ម មិនមែនក្នុងលក្ខណៈជាព្រះជន្មដ៏ល្អ ឬរីករាយនោះទេ ប៉ុន្តែក្នុងលក្ខណៈជាព្រះជន្មដែលល្អឥតខ្ចោះ គឺព្រះជន្មដែលគ្មានអំពើបាប ពោលគឺព្រះជន្មដែលមានភក្តីភាពក្នុងការថ្វាយសិរីល្អទាំងអស់ទៅកាន់ព្រះជាម្ចាស់។ ហើយបន្ទាប់មក ព្រះយេស៊ូវបានថ្វាយព្រះជន្មរបស់ទ្រង់នៅលើឈើឆ្កាង ក្នុងនាមជាយញ្ញបូជា។ ព្រះអង្គមិនស័ក្តិសមនឹងទទួលសេចក្តីក្រោធរបស់ព្រះជាម្ចាស់ទេ។ ប៉ុន្តែ ព្រះអង្គបានទទួលយកសេចក្តីក្រោធនោះ ក្នុងនាមជាអ្នកជំនួស សម្រាប់អស់អ្នកដែលនឹងបែរចេញពីអំពើបាបរបស់ខ្លួន ហើយទទួលជឿទ្រង់។ ដើម្បីបង្ហាញជាភស្តុតាងឲ្យគ្រប់គ្នាឃើញ គឺព្រះបានប្រោសព្រះយេស៊ូវពីការសុគតឡើងវិញ។

ប៉ុន្តែ នេះគ្រាន់តែជាដើមចមនៃការចាប់ផ្តើមរបស់ព្រះជាម្ចាស់ចំពោះយើង តែប៉ុណ្ណោះ។ ព្រះយេស៊ូវកំពុងតែមានបន្ទូលអំពីព្រះវិញ្ញាណ និងអំពីព័ន្ធកិច្ចរបស់ទ្រង់នៅក្នុងខ៨។ ពីព្រោះគឺព្រះវិញ្ញាណនៃព្រះនេះហើយ ដែលទទួលយកគ្រប់ប្រយោជន៍នៃអ្វីដែលព្រះគ្រីស្ទបានសម្រេច (ព្រះជន្ម សេចក្តីសុចរិត ព្រះគុណ) ហើយយកការនោះមកដាក់លើយើង មកបំផ្លាស់បំប្រែលក្ខណៈដើមរបស់យើង មកធ្វើឲ្យយើងអាចមានជីវិតឡើងវិញ (កើតជាថ្មី) ដើម្បីឲ្យយើងអាចបែរទៅរកព្រះគ្រីស្ទក្នុងជំនឿ និងស្រឡាញ់ទ្រង់ ទុកចិត្តលើទ្រង់ និងដើរតាមទ្រង់បាន។

រាប់រយឆ្នាំមុននោះ ហោរា អេសេគាល បានថ្លែងទំនាយថា នេះគឺជាអ្វីដែលព្រះអង្គនឹងធ្វើសម្រាប់រាស្រ្តបះបោរ និងរាស្រ្តមានបាបរបស់ទ្រង់។ នៅក្នុងកណ្ឌគម្ពីរអេសេគាល ជំពូក៣៦ គាត់បានធ្វើបទបង្ហាញដោយលើកឡើងអំពីរូបភាព ដោយ

ពណ៌នាអំពីការផ្លាស់ប្ដូរដ៏អស្ចារ្យនេះ ដែលព្រះជាម្ចាស់នឹងសម្រេចឡើង។ ព្រះអង្គនឹងនាំពួកគេចេញពីភាពជាឈ្លើយ។ ព្រះអង្គនឹងសម្អាតពួកគេចេញពីទម្រង់នៃភាពមិនបរិសុទ្ធ។ ប៉ុន្តែ សំខាន់ជាងនោះទៅទៀត ព្រះអង្គនឹងផ្លាស់ប្ដូរលក្ខណៈដើមរបស់ពួកគេ ហើយតាមរយៈការផ្លាស់ប្ដូរលក្ខណៈដើមរបស់ពួកគេនោះ គឺព្រះអង្គនឹងផ្សះផ្សាពួកគេជាមួយនឹងទ្រង់វិញ។ កណ្ឌគម្ពីរ  អេសេគាល ៣៦:២៦-២៨ បានចែងថា "អញនឹងឲ្យឯងមានចិត្តថ្មី ហើយនឹងដាក់វិញ្ញាណថ្មីនៅក្នុងឯងដែរ អញនឹងដកចិត្តដែលរឹងដូចថ្ម ពីរូបសាច់ឯងចេញ រួចនឹងឲ្យមានចិត្តជាសាច់វិញ។ អញនឹងដាក់វិញ្ញាណរបស់អញនៅក្នុងឯងរាល់គ្នា ហើយបណ្ដាលឲ្យឯងរាល់គ្នាដើរតាមក្រិត្យក្រម ហើយរក្សាបញ្ញត្តិច្បាប់របស់អញ ព្រមទាំងប្រព្រឹត្តតាមផង។ នោះឯងរាល់គ្នានឹងអាស្រ័យនៅក្នុងស្រុក ដែលអញបានឲ្យដល់ពួកឰយុកោឯង ឯងរាល់គ្នានឹងធ្វើជារាស្ត្ររបស់អញ ហើយអញនឹងបានជាព្រះដល់ឯង"។ តាមរយៈព័ន្ធកិច្ចរបស់ព្រះគ្រីស្ទ នោះព្រះជាម្ចាស់បានរក្សាសេចក្ដីសន្យារបស់ទ្រង់ ហើយតាមរយៈអំណាចនៃព្រះវិញ្ញាណ គឺព្រះអង្គបានអនុវត្តកិច្ចការនោះដោយមានពេញទៅដោយអធិបតេយ្យភាព និងព្រះគុណ។ ព្រះអង្គបានបង្កើតយើងជាស្នាព្រះហស្តថ្មី។ ព្រះអង្គបានផ្លុំខ្យល់ដង្ហើមនៃជីវិតថ្មីមកក្នុងយើង។ គឺយើងបានកើតជាថ្មីម្ដងទៀត មិនមែនតាមរយៈកិច្ចការរបស់ខ្លួន ប៉ុន្តែតាមរយៈព្រះគុណរបស់ទ្រង់។

ប្រសិនបើបងប្អូននៅក្នុងព្រះគ្រីស្ទ នោះបងប្អូនមានលក្ខណៈថ្មី ជាលក្ខណៈដែលមានទំនោរទៅកាន់ព្រះ គឺមិនមែនចេញពីព្រះអង្គទេ។ នេះមិនមែនមានន័យថា បងប្អូនលែងប្រព្រឹត្តអំពើបាបទៀតឡើយ។ ពិតណាស់ លក្ខណៈដើមចាស់របស់យើងត្រូវបានសម្លាប់ចោល ប៉ុន្តែអំពើបាបនៅបន្តមាន គឺយើងនឹងនៅបន្តមានរហូតដល់ថ្ងៃយើងស្លាប់។ ប៉ុន្តែ លក្ខណៈដើមនោះលែងជាអ្នកគ្រប់គ្រងលើយើងទៀតហើយ។ គឺព្រះគ្រីស្ទទេ ដែលកំពុងគ្រប់គ្រងលើយើង។ ហើយតាមរយៈព្រះគុណរបស់ទ្រង់នោះលោកអ្នកអាចបដិសេធអំពើបាប និងសេចក្ដីល្បួងបាន។ ជាជាងសងសឹក គឺ

លោកអ្នកអាចអត់ទោសដល់អ្នកដទៃបាន នៅពេលដែលគេបានធ្វើខុសលើលោកអ្នក។ លោកអ្នកអាចលះបង់ចំណាប់អារម្មណ៍របស់ខ្លួន ដើម្បីជាប្រយោជន៍ដល់អ្នកដទៃ។ ប៉ុន្តែ សំខាន់ជាងនេះទៅទៀត លោកអ្នកអាចទទួលបានការសម្រាកនៅក្នុងការធានាថា ព្រះអង្គស្រឡាញ់ និងទទួលយកលោកអ្នក នេះមិនមែនដោយសារអ្វីដែលលោកអ្នកបានប្រព្រឹត្ត ឬក៏នឹងធ្វើនោះទេ ប៉ុន្តែដោយសារអ្វីដែលព្រះយេស៊ូវបានសម្រេច។ ដូច្នេះ នៅពេលដែលលោកអ្នកប្រព្រឹត្តអំពើបាប នោះលោកអ្នកអាចរត់ទៅរកទ្រង់បាន លោកអ្នកអាចលន់តួបាប ហើយលោកអ្នកក៏អាចស្គាល់អំពីសេចក្តីពិតនៃការអត់ទោសរបស់ព្រះជាម្ចាស់ តាមរយៈសេចក្តីស្រឡាញ់ដែលបានប្រោសលោះផងដែរ។

នេះមិនមែនគ្រាន់តែផ្តោតទៅលើលោកអ្នកបែបជាបុគ្គលនោះទេ ប៉ុន្តែក៏ផ្តោតទៅលើលោកអ្នក បែបជាក្រុមជំនុំទាំងមូលផងដែរ។ យើងគឺជាសង្គមនៃស្នាព្រះហស្តថ្មីរបស់ព្រះអង្គ។ យើងមិនមែនជាសង្គមនៃមនុស្សល្អ ដូចដែលលោកីយ៍នេះវាស់វែងនោះទេ ហើយក៏មិនមែនជាក្រុមមនុស្សដែលចូលចិត្តអ្វីៗដូចគ្នាផងដែរ ប៉ុន្តែយើងគឺជាក្រុមមនុស្សមានបាប ដែលទទួលបានការកើតជាថ្មី ដែលមកប្រជុំគ្នា។ នៅពេលដែលចំណុចនេះមានការបង្ហាញជាភស្តុតាង នោះមានន័យថា យើងកំពុងតែបង្ហាញអំពីទីបន្ទាល់ដ៏មានពេញទៅដោយអំណាច ទាក់ទងទៅនឹងសេចក្តីពិតដ៏អស្ចារ្យនៃដំណឹងល្អ។ ដូច្នេះ តើមានអ្វីទៅដែលយើងអាចធ្វើបាន ដើម្បីប្រាកដថា សង្គមដែលបានកើតជាថ្មីនេះរបស់យើងអាចក្លាយជាសង្គមដែលបង្ហាញយ៉ាងមានប្រសិទ្ធភាពនូវអំណាចព្រះចេស្តានៃដំណឹងល្អ? នេះគឺជាហេតុផលមួយដែលថា ការមានសមាជិកភាពនៃក្រុមជំនុំសំខាន់ណាស់។ យើងមិនអាច ហើយក៏មិនចង់កត់ចុះនូវឈ្មោះនៃមនុស្សដែលបានកើតជាថ្មីដែរ។ ប៉ុន្តែ យើងចង់ព្យាយាមរក្សាទុកនូវសមាជិកភាពនៃក្រុមជំនុំដែលបានកើតជាថ្មី ពីព្រោះសមាជិកនៃក្រុមជំនុំយើងធ្វើការអះអាងជាផ្លូវការ សម្រាប់យើងទៅកាន់លោកីយ៍នេះ។ ពិតណាស់

យើងមិនអាចធ្វើការនេះបានយ៉ាងល្អឥតខ្ចោះឡើយ ប៉ុន្តែយើងអាចព្យាយាមធ្វើវាដោយស្មោះត្រង់ នៅពេលដែលយើងព្យាយាមរកមើលព្រះគុណនៃការផ្លាស់ប្រែចិត្ត គឺមិនមែនការធ្វើពុត ផ្នែកសីលធម៌ទេ។ នេះជាមូលហេតុដែលពួកចាស់ទុំធ្វើការសម្ភាសន៍សមាជិកភាព។ នេះជាមូលហេតុដែលយើងអនុវត្តការដាក់ពិន័យក្នុងក្រុមជំនុំ។ នេះជាមូលហេតុដែលគ្រីស្ទបរិស័ទធ្វើពិធីជ្រមុជទឹក សមាជិកភាព និងពិធីលាងព្រះអម្ចាស់។ លក្ខណៈវិនិច្ឆ័យបីនេះគឺដូចគ្នា—មិនមែនថាការធ្វើជាមនុស្សល្អទេ។ គឺមានតែចិត្តទន់ភ្លន់ និងចិត្តដែលកែប្រែ ហើយមានជំនឿលើព្រះគ្រីស្ទតែមួយអង្គប៉ុណ្ណោះ ដែលអ្នកជឿត្រូវតែប្រកាស និងរក្សាទុក។ មិនមានអ្វីផ្សេងទៀតលើស ឬក៏តិចជាងនេះនោះទេ។

នៅក្នុងការផ្សាយដំណឹងល្អរបស់យើង គឺយើងមិនគួរសង្ឃាតចង់បានតែការសម្រេចចិត្តជឿនោះទេ ពីព្រោះយើងដឹងហើយថា ក្នុងអត្ថន័យមួយ គឺបេះដូងយើងមានពេញទៅដោយការបោកបញ្ឆោត ហើយក្នុងអត្ថន័យមួយទៀតយើងក៏អាចប្រើប្រាស់ការប៉ិនប្រសព្វរបស់យើង ដើម្បីនាំឲ្យមានការសម្រេចចិត្តជឿផងដែរ។ ទេ! យើងចង់ប្រកាសដំណឹងល្អដោយមានការស្មោះត្រង់ ដែលមានពេញទៅដោយភាពបន្ទាន់ និងដោយទទួលស្គាល់ថា មានតែព្រះអង្គមួយអង្គប៉ុណ្ណោះដែលអាចសង្គ្រោះបាន តាមរយៈការដែលព្រះអង្គនាំមនុស្សម្នាមកកាន់ព្រះគ្រីស្ទ។ យើងត្រូវតែអធិស្ឋានសូមឲ្យព្រះអង្គបំពេញព័ន្ធកិច្ចនៃព្រះគុណរបស់ទ្រង់។

គ្មានបុគ្គលណាកើតមកជាគ្រីស្ទបរិស័ទនោះទេ។ ហើយក៏មិនមែនថា គ្រប់គ្នានឹងក្លាយជាគ្រីស្ទបរិស័ទដែរ។ ប៉ុន្តែ ប្រសិនបើបងប្អូននឹងក្លាយជាគ្រីស្ទបរិស័ទ ដោយដឹងអំពីការផ្លាស់ប្តូរដ៏ពិតប្រាកដ និងជីវិតថ្មីដែលព្រះគ្រីស្ទប្រទានដល់បងប្អូនមែន គឺបងប្អូនត្រូវតែក្លាយជាមនុស្សដែលលើសពីមនុស្សល្អទៅទៀត។ បងប្អូនត្រូវតែទទួលការកើតជាថ្មី។ បងប្អូនត្រូវតែកើតជាថ្មី។ ហើយទោះបើបងប្អូនមិនអាចធ្វើការនេះបានដោយខ្លួនឯងមែន តែព្រះជាម្ចាស់អាច ហើយក៏នឹងធ្វើការនោះ ក៏ដូច

ជាបានធ្វើការនោះរួចហើយផងដែរ ប្រសិនបើបងប្អូនជាអ្នកជឿលើព្រះគ្រីស្ទ។

# គ្រោះថ្នាក់៖ បើក្រុមជំនុំគ្មានគោលលទ្ធិត្រឹមត្រូវ និងមិនស្គាល់ព្រះបន្ទូលពិតរបស់ព្រះ

និពន្ធដោយលោកគ្រូ៖ ស៊ុន សុខា

នៅពេលដែលយើងនិយាយអំពីគោលលទ្ធិនៅក្នុងក្រុមជំនុំ មានមនុស្សជាច្រើននាក់ណាស់មិនចូលចិត្តអំពីគោលលទ្ធិទេ ដោយភាគច្រើនលើកឡើងថា ការនិយាយអំពីគោលលទ្ធិគឺជារឿងដ៏ធុញទ្រាំណាស់ ហើយខ្លះទៀតថា ការលើកឡើងអំពីគោលលទ្ធិគឺធ្វើឲ្យមនុស្សបាក់បែកគ្នា។ ជាទូទៅពួកគេនិយាយតែផ្នែកសេចក្ដីស្រឡាញ់តែមួយប៉ុណ្ណោះ ប៉ុន្តែជាមួយគ្នាប្រសិនបើយើងនិយាយតែផ្នែកសេចក្ដីស្រឡាញ់តែពុំមានសេចក្ដីពិតនៅក្នុងសេចក្ដីស្រឡាញ់ តើនោះជាសេចក្ដីស្រឡាញ់បែបយ៉ាងដូចម្ដេច? តែផ្ទុយទៅវិញ ព្រះអង្គសព្វព្រះហឫទ័យឲ្យយើងមានសេចក្ដីស្រឡាញ់ទៅកាន់គ្នាទៅវិញទៅមកនៅក្នុងសេចក្ដីពិតរបស់ព្រះអង្គផងដែរ។

*គ្រោះថ្នាក់ចំពោះក្រុមជំនុំបើគ្មានគោលលទ្ធិត្រឹមត្រូវ*

តើក្រុមជំនុំចង់សំដៅទៅលើអ្វី? ចម្លើយគឺក្រុមជំនុំជាសហគមន៍ខាងឯវិញ្ញាណនៃអ្នកជឿដែលរួបរួមគ្នានៅក្នុងព្រះគ្រីស្ទ ជាជាងសំណង់អគារ ឬក៏ជាស្ថាប័នណាមួយ។

ក្រុមជំនុំគឺជារូបកាយរបស់ព្រះគ្រីស្ទ ដែលព្រះគ្រីស្ទគឺជាសិរសាហើយជាប្រធាននៅប្រមុខនៃយើងទាំងអស់គ្នា (១កូរិនថូស ១២:២៧, កូឡូស ១:១៨, អេភេសូរ ៤:១៥-១៦)។ ក្រុមជំនុំយើងបែងចែកចេញជាក្រុមជំនុំសាកល និងក្រុមជំនុំនៅក្នុងស្រុក «ជាទូទៅគ្រីស្ទបរិស័ទបម្រើព្រះនៅក្នុងតំបន់នីមួយៗគឺនោះហើយជាក្រុមជំនុំតាមតំបន់»។ យើងបានដឹងថា មានគ្រីស្ទបរិស័ទជាច្រើននៅក្នុងក្រុមជំនុំសកល ហើយពួកគេក៏មានចំណែកជាមួយនឹងយើងផងដែរ យើងដែលកំពុងតែបម្រើព្រះនៅក្នុងក្រុមជំនុំតាមតំបន់យើងមិនមែនកំពុងតែបម្រើព្រះតែម្នាក់ឯងឯកកោរនោះទេ ទោះបីពេលខ្លះយើងមានអារម្មណ៍ឯកោក៏ដោយ។ ប៉ុន្តែសូមចងចាំថា មានគ្រីស្ទបរិស័ទជាច្រើនកំពុងតែអធិស្ឋានសម្រាប់លោកអ្នក បងប្អូនហើយនិងខ្ញុំអាចឈរនៅសព្វថ្ងៃនេះ មិនមែនមកពីយើងខ្លួនឯងពូកែនោះទេ។ ពួកគេបានអធិស្ឋានទាំងសម្រក់ទឹកភ្នែក ទាំងតមសម្រាប់ពួកយើងដែលជាក្រុមជំនុំតាមតំបន់ផងដែរ ប៉ុន្តែយើងមិនបានឃើញការទាំងនោះដោយផ្ទាល់ភ្នែកយើងទេ ដោយសារពួកគេជាក្រុមជំនុំសាកល។ កណ្ឌគម្ពីរម៉ាថាយ ១៦:១៨ *«ខ្ញុំប្រាប់អ្នកថា អ្នកឈ្មោះពេត្រុស ខ្ញុំនឹងតាំងពួកជំនុំខ្ញុំនៅលើថ្មដានេះ ហើយទ្វារស្ថានឃុំព្រលឹងមនុស្សស្លាប់នឹងមិនដែលឈ្នះពួកជំនុំឡើយ»*។ នេះគឺជាសារៈសំខាន់នៃពួកជំនុំរបស់ព្រះ។ ព្រះអង្គបានរាប់ពួកជំនុំរបស់ទ្រង់គឺសំខាន់លើអ្វីៗទាំងអស់។ យើងទាំងអស់គ្នាត្រូវបានព្រះត្រាស់ហៅនៅក្នុងការបម្រើក្នុងបេសកកម្មរបស់ព្រះដែលមានដូចជា៖ ជាបេសកជនក្តី ជាគ្រូគង្វាលក្តី ឬជាប្រធានស្ថាប័នអង្គការក្តី គឺថា យើងទាំងអស់គ្នាគឺមានភារកិច្ចតួនាទីយ៉ាងសំខាន់នោះគឺជា *«ការមើលថែ ការពារហ្វូងចៀមរបស់ព្រះ»*។

សំណួរមួយខ្ញុំសួរថា តើលោកអ្នកធ្វើជាគ្រូគង្វាលដ៏ល្អ ឬគ្រាន់តែធ្វើជាអ្នកស៊ីឈ្នួលតែប៉ុណ្ណោះ? ក្នុងរយៈពេលជាង១០០ឆ្នាំដែលដំណឹងល្អបានមកដល់ក្នុងប្រទេសកម្ពុជា តើយើងបានមានចំណែកធ្វើអ្វីខ្លះថ្វាយដល់ព្រះ ដែលទ្រង់បានស្រឡាញ់ដល់លោកអ្នក? មានគ្រីស្ទបរិស័ទខ្លះបានលើកឡើងថា នៅពេលណា

ដែលក្រុមជំនុំរបស់ពួកគេលែងមានជនបរទេសដែលជាអ្នកផ្គត់ផ្គង់ពីលើក្រុមជំនុំរបស់ពួកគេទៅ នោះព្រះវិហាររបស់ពួកគេផ្ទាល់ក៏នឹងលែងមានការប្រជុំថ្វាយបង្គំទៀតដែរ។ ប៉ុន្តែជាមួយគ្នា លោកអ្នកហើយនិងខ្ញុំ យើងទាំងអស់គ្នាគឺមិនដូច្នោះឡើយ។ ប៉ុន្តែ ជាការពិតយើងត្រូវការបេសកជនដែលជាជនបរទេសដែលស្មោះត្រង់នឹងព្រះ គឺជាដៃគូដំណើងល្អសម្រាប់យើងទាំងអស់គ្នា តែមិនមែនជាចៅហ្វាយនាយរបស់ក្រុមជំនុំរបស់យើងនោះទេ។ នៅក្នុងព្រះគ្រីស្ទយើងជាអវយវៈរបស់ព្រះ។ ឧទាហរណ៍៖ ម្រាមដៃមិនសូវសំខាន់ដូចជាភ្នែក ប៉ុន្តែប្រសិនបើយើងអត់មានម្រាមដៃនោះទេ យើងក៏មើលឃើញថា មិនមានសោភ័ណភាពល្អមើលនោះដែរ។ ជាមួយគ្នា យើងទាំងអស់គ្នាត្រូវការគ្នាទៅវិញទៅមក។ នៅកណ្ឌគម្ពីរ ១កូរិនថូស ១:២ *«ផ្ញើមកពួកជំនុំនៃព្រះ នៅក្រុងកូរិនថូស ជាពួកអ្នកដែលបានញែកចេញជាបរិសុទ្ធ ក្នុងព្រះគ្រីស្ទយេស៊ូវ បានទាំងហៅមកធ្វើជាពួកបរិសុទ្ធ ជាមួយនឹងអស់អ្នក នៅគ្រប់ទីកន្លែង ដែលអំពាវនាវដល់ព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា គឺនៃគេ និងយើងផង»*។

នៅត្រង់ខគម្ពីរនេះគឺលើកឡើងអំពីក្រុមជំនុំបែបជាសកល និងក្រុមជំនុំនៅក្នុងតំបន់។ តើបេសកកម្មរបស់ក្រុមជំនុំគឺជាអ្វី? គឺបានន័យថា ក្រុមជំនុំគឺជាអ្នកជឿសុទ្ធសាធ។ ហើយតើតួនាទីរបស់អ្នកជឿម្នាក់គឺជាអ្វី? ជាការពិតណាស់ ក្រុមជំនុំរបស់ព្រះទាំងអស់គ្នាគឺជាអ្នកដែលនឹងចេញបង្កើតសិស្ស។ នៅពេលបច្ចុប្បន្ននេះមានក្រុមគ្រីស្ទបរិស័ទខ្លះ មិនសូវផ្តោតទៅលើការបង្កើតសិស្សនោះទេ ប៉ុន្តែផ្តោតទៅលើតែចំនួនតួលេខអ្នកជឿច្រើនប៉ុណ្ណោះ។ ពេលខ្លះ ពួកគេបានថតរូប ឬថតវីដេអូអំពីចំនួនមនុស្សដើម្បីជាការបង្ហាញថា ពួកគេបានធ្វើការអស្ចារ្យយ៉ាងសម្បើមដោយយើងបានផ្តល់ដល់មនុស្សទាំងនោះ នូវដង្វាយបន្តិចបន្តួច ជំនួយផ្សេងៗបែបបណ្តោះអាសន្នដល់ពួកគេប៉ុណ្ណោះ បន្ទាប់មកយើងប្រើប្រាស់ចំនួនវត្តមាននៃមនុស្សទាំងនោះដើម្បីជាប្រយោជន៍ឲ្យបានជំនួយពីខាងស្រុកក្រៅមក។ល។ តែការពិតទៅ

ការធ្វើបែបនេះ យើងកំពុងតែបំផ្លាញព្រលឹងមនុស្សវិញហើយ ផ្ទុយទៅវិញ ពួកគេគឺត្រូវការព្រះយេស៊ូវយ៉ាងពិតប្រាកដវិញទេតើ។ ព្រះអង្គសព្វព្រះហឫទ័យដល់លោកអ្នកហើយនិងខ្ញុំគឺចេញទៅបង្កើតសិស្ស (ម៉ាថាយ ២៨:១៩-២០; ម៉ាកុស ១៦:១៥; កិច្ចការ ១:៨)។

តាមរយៈបទគម្ពីរទាំងនេះគឺជាសេចក្ដីបង្គាប់ដូចគ្នាដល់យើងក្នុងការធ្វើបេសកកម្ម *“ចូរទៅបញ្ចុះបញ្ចូលឲ្យមានសិស្សនៅគ្រប់ទាំងសាសន៍ ព្រមទាំងធ្វើបុណ្យជ្រមុជទឹកឲ្យ ដោយនូវព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធចុះ ហើយបង្រៀន ឲ្យគេកាន់តាមគ្រប់ទាំងសេចក្ដី ដែលខ្ញុំបានបង្គាប់មកអ្នករាល់គ្នាផង...”*។ ការបង្កើតសិស្សមិនមែនជារឿងងាយស្រួលនោះឡើយ ហើយយើងទាំងអស់គ្នាក៏មិនមែនជាមនុស្សដែលរស់នៅរហូតនោះដែរ។ ដំណើរជីវិតរបស់យើងគឺកាន់តែទៅមុខ ហើយសុខភាពរបស់យើងក៏កាន់តែខ្សោយទៅៗផងដែរ នៅពេលខ្លះយើងបានភ្លេចគិតខ្លួនឯងថា ខ្លួនរបស់យើងនឹងមិនចេះស្លាប់ទេ ប៉ុន្តែផ្ទុយទៅវិញ វាមិនដូច្នោះឡើយ ជីវិតរបស់យើងទាំងអស់គ្នាក៏កាន់តែកៀកទៅមុខ ដែលរៀបនឹងហៀបទៅជួបជាមួយព្រះអម្ចាស់យេស៊ូវហើយ។ សំណួរគឺសួរថា តើនរណាដែលជាអ្នកដែលបន្តវេនក្នុងការធ្វើបេសកកម្មរបស់យើងទាំងអស់គ្នា? ប្រហែលមានបងប្អូនខ្លះគាត់មានគំនិតគិតថា អ្នកដទៃផ្សេងទៀតចេះជាងខ្លួន ឬមានសមត្ថភាពល្អជាងខ្លួន គឺចង់ចេះតែម្នាក់ឯង ដូច្នេះគាត់មិនចង់បង្កើតសិស្សដ៏ពិតរបស់ព្រះយេស៊ូវដទៃៗទៀតនោះទេ។

ដូច្នេះ សូមឲ្យយើងមានការប្រុងប្រយ័ត្នអំពីចំណុចនៃគំនិតបែបនេះ។ មហាបេសកកម្មរបស់ព្រះយេស៊ូវដែលបានបង្គាប់ដល់យើងគឺពិតជាសំខាន់ណាស់។ ប្រហែលលោកអ្នកបងប្អូនខ្លះធ្លាប់មានបទពិសោធន៍ជាមួយអស់អ្នកហៀបនឹងស្លាប់ទៅ បន្ទាប់មកគាត់មានពាក្យពេចន៍ផ្ដែផ្ដាំចុងក្រោយមកកាន់យើង ហើយការផ្ដែផ្ដាំដែលសារនោះឯងគឺមានតម្លៃណាស់។ ចំណែកឯព្រះអម្ចាស់យេស៊ូវគ្រីស្ទនៃយើងទ្រង់បានមានការផ្ដែផ្ដាំចុងក្រោយមុនពេលដែល ព្រះអង្គយាងត្រឡប់ទៅនគរស្ថាន

សួគ៌វិញដល់យើងផងដែរ ព្រះអង្គក៏ឲ្យសិស្សរបស់ព្រះអង្គត្រូវតែចងចាំនូវបណ្ដាំដែលទ្រង់បានប្រាប់នោះគឺថា ឲ្យពួកគេចេញទៅបង្កើតសិស្សនៅគ្រប់ទីកន្លែង ដែលនេះគឺហៅថា ការធ្វើបេសកកម្មដែលហុចបន្ត។

សរុបសេចក្តីមក លោកអ្នកហើយនិងខ្ញុំគឺមានកាតព្វកិច្ចសំខាន់ណាស់ក្នុងជីវិតគឺត្រូវតែបង្កើតសិស្ស។ បង្កើតសិស្សគឺមានន័យថា គឺនាំឲ្យអ្នកដទៃផ្សេងទៀតឲ្យក្លាយទៅជាម្នាក់ដូចនឹងយើងខ្លួនឯង (អ្នកជឿព្រះដែលមានភាពពេញវ័យយ៉ាងពិតប្រាកដ) ផងដែរ។ ក្រុមជំនុំគឺជារូបកាយរបស់ព្រះគ្រីស្ទខាងវិញ្ញាណផងដែរ។ ក្រុមជំនុំគួរតែរួបរួមគ្នា ទោះបីជាមានផ្នែកខ្លះ មានលក្ខណៈខុសប្លែកគ្នារវាងគោលជំនឿតូចៗ (ដែលមិនទាក់ទងនឹងសេចក្តីសង្គ្រោះ) ជាការពិតណាស់ យើងត្រូវតែផ្តោតទៅលើសេចក្តីពិតធំៗនៃគោលលទ្ធិដែលត្រូវឲ្យក្រុមជំនុំមានការប្រុងប្រយ័ត្នមុននឹងមានការរួបរួមគ្នា ប៉ុន្តែសម្រាប់ក្រុមជំនុំណាដែលមានការខុសប្លែកគ្នាបន្តិចបន្តួច ប៉ុន្តែសេចក្តីពិតធំៗគឺមានការដូចគ្នានោះវាការមួយដែលយើងអាចរួបរួមគ្នាបានដែរ។ ឧទាហរណ៍៖ ខ្ញុំផ្ទាល់មកនិកាយប្រេសប៊ីធារាន ហើយប្រហែលមានបងប្អូនខ្លះគាត់មកពីខាងនិកាយបាប់ទីស្ទ។ ដូច្នេះយើងមានលក្ខណៈខុសប្លែកគ្នាអំពីការជ្រមុជទឹកគឺត្រូវចុះទៅក្នុងទឹក រីឯខាងប្រេសប៊ីធារាន គឺក្បង់ទឹកដាក់លើក្បាល ឬប្រោសទឹកដាក់ យើងមិនអាចអះអាងថា អ្នកជឿព្រះយេស៊ូវទាំងអស់ត្រូវតែស្ថិតនៅក្នុងនិកាយបាប់ទីស្ទទាំងស្រុងទើបបានត្រឹមត្រូវ ឬបានការសង្គ្រោះ ការនោះមិនមែនជាអ្វីត្រឹមត្រូវនោះទេ។

សេចក្តីសង្គ្រោះពិតមិនកើតឡើងទាល់តែបានជ្រមុជទឹកចូលក្នុងទឹក ឬប្រោសទឹកលើក្បាលទើបបានសង្គ្រោះនោះទេ ប៉ុន្តែគឺកើតឡើងអំពីការប្រែចិត្តចេញពីអំពើបាប និងការទទួលជឿលើព្រះយេស៊ូវ នោះទើបបានទទួលនូវសេចក្តីសង្គ្រោះ។

កណ្ឌគម្ពីរយ៉ូហាន ២១:១៥-១៧ *«កាលគេបានបរិភោគរួចហើយ នោះព្រះយេស៊ូវមានព្រះបន្ទូលនឹងស៊ីម៉ូន-ពេត្រុសថា ស៊ីម៉ូនកូនយ៉ូណាសអើយ តើអ្នកស្រឡាញ់*

*ខ្ញុំជាជាងរបស់ទាំងនេះឬអី គាត់ទូលឆ្លើយថា ព្រះករុណាវិសេសព្រះអម្ចាស់ ទ្រង់ជ្រាបថាទូលបង្គំពេញចិត្តនឹងទ្រង់ហើយ ទ្រង់មានព្រះបន្ទូលថា ចូរឲ្យចំណីដល់កូនចៀមខ្ញុំស៊ីផង រួចទ្រង់មានព្រះបន្ទូលទៅគាត់ម្តងទៀតថា ស៊ីម៉ូន កូនយ៉ូណាសអើយ តើស្រឡាញ់ខ្ញុំឬអី គាត់ទូលឆ្លើយថា ព្រះករុណាវិសេសព្រះអម្ចាស់ ទ្រង់ជ្រាបថា ទូលបង្គំពេញចិត្តនឹងទ្រង់ហើយ ទ្រង់មានព្រះបន្ទូលទៅគាត់ថា ចូរឃ្វាលហ្វូងចៀមរបស់ខ្ញុំចុះ រួចទ្រង់មានព្រះបន្ទូលជាគំរប៣ដងថា ស៊ីម៉ូន កូនយ៉ូណាសអើយ តើពេញចិត្តនឹងខ្ញុំមែនឬអី ពេត្រុសមានចិត្តព្រួយ ដោយទ្រង់មានព្រះបន្ទូលជាគំរប់៣ដងថា តើពេញចិត្តនឹងខ្ញុំឬអីដូច្នេះ បានជាគាត់ទូលឆ្លើយថា ព្រះអម្ចាស់អើយ ទ្រង់ជ្រាបគ្រប់ការទាំងអស់ គឺទ្រង់ជ្រាបថា ទូលបង្គំពេញចិត្តនឹងទ្រង់ហើយ ព្រះយេស៊ូវមានព្រះបន្ទូលទៅគាត់ថា ចូរឲ្យចំណីដល់ហ្វូងចៀមខ្ញុំស៊ីផង»*។ ពាក្យពេចន៍របស់ព្រះយេស៊ូវម្តងហើយម្តងទៀតដែលថា *«ចូរឲ្យចំណីដល់កូនចៀមខ្ញុំស៊ីផង»*។

ដូច្នេះ ការទាំងអស់នេះគឺជាកាតព្វកិច្ចរបស់អ្នកគង្វាលម្នាក់ៗគឺជាការ «ឲ្យចំណីដល់ហ្វូងចៀម ហើយនិងការពារហ្វូងចៀមរបស់ព្រះ។ ការឲ្យចំណីដល់ហ្វូងចៀមគឺបានន័យថា ការថែបំប៉ន ការថែរក្សា ចិញ្ចឹមដល់ពួកគេ រីឯចំណីវិញ គឺជាចំណីខាងឯព្រលឹងវិញ្ញាណ។ ជាការសោកស្តាយណាស់ នៅពេលអ្នកគង្វាលផ្ទាល់បានលើកឡើងថា តើឲ្យខ្ញុំឲ្យចំណីដល់កូនចៀមបានយ៉ាងដូចម្តេចទៅ ព្រោះមានពេលខ្លះអ្នកគង្វាលផ្ទាល់មិនទាន់បានហូបចំណីផង គឺដោយព្រោះមានពេលខ្លះ អ្នកគង្វាលគាត់មិនចង់ហូបដោយខ្លួនរបស់គាត់ផ្ទាល់ទេ។ មានគ្រូគង្វាលខ្លះ ព្រះគម្ពីររបស់គាត់ផ្ទាល់រក្សាទុកយ៉ាងស្អាតបំផុតនៅលើហឹង ដោយសារតែគាត់គិតថា មិនអីទេ! ឥឡូវនេះ មានកម្មវិធីនៅក្នុងទូរស័ព្ទដៃ ដូច្នេះហើយប្រើប្រាស់ព្រះគម្ពីរនៅក្នុងទូរស័ព្ទក៏បានដែរ ប៉ុន្តែជាក់ស្តែងវាមិនដូច្នោះឡើយគឺមិនដែលអានព្រះគម្ពីរទាល់តែសោះ។

មានពេលខ្លះ កម្មវិធីព្រះគម្ពីរមានទាំងព្រះគម្ពីរសម្លេងទៀត ក៏នៅតែមានលេសក្នុងលើកឡើងថា គ្មានពេលស្តាប់ទេ។ល។ ដូច្នេះ វាពិតជាមានការសោកស្តាយ និង

ឈឺចិត្តត្រង់ថា តើមានវិធីសាស្ត្របែបណាទៀតដែលអាចជួយបាន? ត្រឡប់មកវិញការដែលអ្នកគង្វាលរបស់ព្រះផ្តល់ចំណីដល់កូនចៀមរបស់ព្រះ នោះអ្នកគង្វាលខ្លួនពួកគាត់ផ្ទាល់ក៏ត្រូវតែហូបចំណីអាហារដោយខ្លួនពួកគាត់ផ្ទាល់ដែរ។ នៅពេលដែលព្រះបានត្រាស់ហៅបងប្អូនឲ្យបម្រើព្រះនៅក្នុងផ្នែកណាមួយក៏ដោយ សូមលោកអ្នកបម្រើដល់ព្រះអង្គដោយអស់ពីចិត្តរបស់យើង។ យើងដែលជាអ្នកគង្វាលគឺត្រូវតែហ៊ានការពារដល់ហ្វូងចៀមរបស់ព្រះ។ ការពារគឺបានន័យថា គឺត្រូវហ៊ានលះបង់ជីវិតដើម្បីហ្វូងចៀមរបស់ខ្លួនដូចដែលព្រះយេស៊ូវបានសុគតជំនួសយើងរាល់គ្នាដែរ។

សំណួរសួរថា តើលោកអ្នកហ៊ានប្តូរជីវិតដើម្បីការពារហ្វូងចៀមរបស់លោកអ្នកទេ? នៅពេលដែលមានបញ្ហាអ្វីមួយដែលកំពុងតែជះឥទ្ធិពលដល់កូនចៀមក្នុងក្រុមជំនុំរបស់លោកអ្នកតើលោកអ្នកនឹងចេញមកការពារហ្វូងចៀមរបស់ព្រះដែរឬទេ? តើលោកអ្នកហ៊ានប្រឆាំងនឹងខ្មាំងសត្រូវនៃឈើឆ្កាងរបស់ព្រះដែរឬទេ? ឬក៏យើងបណ្តោយឲ្យពួកឆ្កែចចកស៊ីចៀមរបស់យើង? ទាំងនេះគឺជាព្រះបន្ទូលរបស់ព្រះយេស៊ូវផ្ទាល់បាននិយាយទៅកាន់លោក ពេត្រុស ហើយទ្រង់ក៏មានបន្ទូលមកលើយើងរាល់គ្នាផងដែរ ដាច់ខាតត្រូវតែឲ្យចំណីដល់ហ្វូងចៀមរបស់យើង។ កូនចៀមរបស់លោកអ្នកគឺជាពួកជំនុំដែលសំខាន់ជាទីបំផុត។ កណ្ឌគម្ពីរ ១ពេត្រុស ៥:២ *«ចូរឃ្វាលហ្វូងចៀមរបស់ព្រះ ដែលនៅជាមួយនឹងអ្នករាល់គ្នាចុះ ទាំងគ្រប់គ្រងដោយស្ម័គ្រពីចិត្ត មិនមែនដោយបង្ខំទេ ក៏មិនមែនដោយចង់បានកំរៃដែរ គឺដោយគាប់ចិត្តវិញ»*។ ខគម្ពីរនេះ ក៏បានលើកឡើងស្រដៀងគ្នា ជាមួយនឹងព្រះយេស៊ូវដែលទ្រង់បានបន្ទូលនៅក្នុងកណ្ឌគម្ពីរ យ៉ូហាន ២១:១៥-១៧។ សាវ័ក ពេត្រុស បានទទួលនៅសារពីព្រះយេស៊ូវដោយផ្ទាល់ ហើយបានជួបព្រះអង្គដោយផ្ទាល់ ដូច្នេះហើយព្រះយេស៊ូវក៏បានបង្រៀនការនេះដល់គាត់ មូលហេតុនេះហើយបានជាគាត់យកការនេះទៅបង្រៀនដល់អ្នកដឹកនាំផ្សេងទៀតផងដែរដូចមានចែងនៅក្នុងសំបុត្ររបស់លោក ១ពេត្រុស ៥:២។ ហើយចុះតើលោកអ្នកបងប្អូនបានចំណាយពេលជាមួយ

ហ្វូងចៀមរបស់លោកអ្នកបងប្អូនយ៉ាងដូចម្ដេចដែរ?

**គោលបំណង៖** ដើម្បីស្វែងយល់ពីផលវិបាកដែលក្រុមជំនុំជួបប្រទះ នៅពេលដែលខ្វះការយល់ដឹងត្រឹមត្រូវអំពីព្រះបន្ទូលរបស់ព្រះ និងគោលលទ្ធិត្រឹមត្រូវ។

កណ្ឌគម្ពីរ ហូសេ ៤:៦ *«រាស្ត្រអញ គេត្រូវបំផ្លាញទៅ ដោយខ្វះខាតដំរិះដូច្នេះ ដោយព្រោះឯងមិនព្រមទទួលដំរិះ បានជាអញក៏នឹងបោះបង់ចោលឯង មិនឲ្យធ្វើជាសង្ឃដល់អញទៀតដែរ ហើយដោយហេតុ ដែលឯងបានភ្លេចច្បាប់របស់ព្រះនៃឯងនោះអញក៏នឹងភ្លេចកូនចៅរបស់ឯងដូចគ្នា»*។

បើនិយាយឲ្យខ្លីទៅ ពួកជំនុំរបស់ព្រះគឺត្រូវបានបំផ្លាញដោយសារខ្វះដំរិះ។ ខ្វះដំរិះនេះគឺមានន័យថា ពួកជំនុំខ្វះនូវចំណេះដឹងនៃព្រះបន្ទូលរបស់ព្រះ ឬគោលលទ្ធិនៃសេចក្តីបង្រៀនដ៏ត្រឹមត្រូវរបស់ព្រះ។ ពួកជំនុំបច្ចុប្បន្ននេះ មិនបានក្លាយជាពួកជំនុំដែលមានភាពពេញវ័យ ប៉ុន្តែគឺបានក្លាយទៅជាពួកជំនុំយ៉ិនស៊ិន។ អ្នកជឿខ្លះ ជឿព្រះយេស៊ូវយូរហើយ ប៉ុន្តែជំនឿរបស់ពួកគឺជាជំនឿរបៀបទារកនៅតូចនៅឡើយ។ ពួកគេមិនអាចបរិភោគអាហាររឹងៗបានទេ តែទទួលបានតែអាហារទន់ៗ។ នេះមិនមែនជាកំហុសរបស់ពួកគេទាំងស្រុងទេ វាគឺជាកំហុសរបស់អ្នកគង្វាលផ្ទាល់នោះឯង។

ពួកជំនុំមិនរីកចម្រើនគឺដោយសារតែកំហុសរបស់អ្នកគង្វាល។ មានគ្រូគង្វាលខ្លះពួកគាត់មានការរវល់ខ្លាំងពេក ជាមួយពិភពខាងក្រៅ និងរឿងអាជីវកម្មផ្ទាល់ខ្លួន ដូច្នេះគាត់មិនមានពេលវេលាណាមួយក្នុងការផ្ដល់អាហារយ៉ាងត្រឹមត្រូវ និងទៀងទាត់សម្រាប់សមាជិករបស់ខ្លួននោះទេ។ ដូច្នេះនេះគឺជាការរលឹកដាស់តឿនដល់លោកអ្នកត្រង់ថា តើព្រះបានត្រាស់ហៅលោកអ្នកឲ្យមកធ្វើអ្វី? នេះគឺជាសំណួរមួយដ៏សំខាន់ដែលលោកអ្នកត្រូវសួរខ្លួនឯង!

## *សារៈសំខាន់នៃការស្គាល់ព្រះបន្ទូលពិតរបស់ព្រះ*

មូលដ្ឋានគ្រឹះខាងវិញ្ញាណសម្រាប់ពួកជំនុំគ្រប់រូបគឺត្រូវការសេចក្តីពិតមកពីព្រះ។ កណ្ឌគម្ពីរ ម៉ាថាយ ៧:២៤-២៧ *«ដូច្នេះ អស់អ្នកណាដែលឮពាក្យរបស់ខ្ញុំទាំងនេះ ហើយប្រព្រឹត្តតាម ខ្ញុំនឹងធៀបអ្នកនោះដូចជាមនុស្សប៉ិនប្រយ័ត្ន ដែលសង់ផ្ទះខ្លួននៅលើថ្ម រួចភ្លៀងធ្លាក់មក ទឹកក៏ជន់ឡើង ហើយខ្យល់បក់ប៉ះនឹងផ្ទះនោះ តែមិនបានរលំទេ ពីព្រោះបានសង់នៅលើថ្ម ឯអស់អ្នកណាដែលឮពាក្យរបស់ខ្ញុំទាំងនេះ តែមិនប្រព្រឹត្តតាម អ្នកនោះត្រូវធៀបដូចជាមនុស្សល្ងង់ ដែលសង់ផ្ទះខ្លួននៅលើខ្សាច់វិញ រួចភ្លៀងធ្លាក់មក ទឹកក៏ជន់ឡើង ហើយខ្យល់បក់ប៉ះនឹងផ្ទះនោះ ផ្ទះនោះក៏រលំទៅ ហើយមានការខូចខាតជាធំ»*។ តាមរយៈបទគម្ពីរនេះ ព្រះយេស៊ូវកំពុងតែប្រដូចអំពីក្រុមជំនុំដែលគ្មានគ្រឹះ ហើយនិងក្រុមជំនុំដែលមានគ្រឹះរឹងមាំ។ គ្រឹះនៅអត្ថន័យនេះគឺអាចជាសេចក្តីបង្រៀន ហើយក៏ជាគោលលទ្ធិដែលត្រឹមត្រូវផងដែរ។ យើងទាំងអស់មិនគួរមានការធុញទ្រាន់និងគោលលទ្ធិដ៏ត្រឹមត្រូវនោះទេ។ គ្រូគង្វាលមិនគួរធុញទ្រាន់ និងការបង្រៀនគោលលទ្ធិដ៏ត្រឹមត្រូវដល់សមាជិកនៅក្នុងក្រុមជំនុំរបស់លោកអ្នកឡើយ។ កុំសាងសង់ក្រុមជំនុំរបស់លោកអ្នកឲ្យដូចទៅនឹងកន្លែងដែលមានភាពទាក់ទាញភ្ញៀវទេសចរឡើយ។ ក្រុមជំនុំដែលមានភាពទាក់ទាញទេសចរគឺបានន័យថា ការតុបតែក្នុងក្រុមជំនុំ ការថ្វាយបង្គំច្រៀង របៀបរបបកម្មវិធី គឺមានសភាពដូចទៅហ្នឹងក្លឹបរាត្រី។ល។

ការតុបតែងតែក្រុមជំនុំ ដើម្បីឲ្យមានភាពទាក់ទាញបានសមាជិកច្រើន ចូលរួមក្នុងវេនថ្វាយបង្គំ ដោយមិនខ្វល់ពីគោលលទ្ធិនៃសេចក្តីពិតនោះមិនខុសគ្នាពីរបៀបលោកីយ៍ធ្វើនោះទេ។ ក្រុមជំនុំគឺកន្លែងនៃការជួបជុំថ្វាយបង្គំសិក្សាព្រះបន្ទូល ហើយក៏ជាកន្លែងដែលគ្រីស្ទបរិស័ទជុំគ្នាអធិស្ឋានទៅកាន់ព្រះអង្គផងដែរ។ ដូច្នេះ គ្រឹះដ៏មាំបំផុតសម្រាប់សមាជិកក្នុងក្រុមជំនុំគឺជាការបង្រៀនគោលលទ្ធិដ៏ត្រឹមត្រូវក្នុងព្រះបន្ទូលទៅកាន់ពួកគេ។ ជាការពិតណាស់ ការបង្រៀនគោលលទ្ធិដ៏ត្រឹមត្រូវតាមព្រះ

បន្ទូលព្រះ ទំនងជាមនុស្សមួយចំនួនមិនសូវចូលចិត្ត ហើយក៏មិនពេញចិត្តនឹងស្ដាប់នោះដែរ ប៉ុន្ដែការបង្រៀនគោលលទ្ធិតាមសេចក្ដីពិតគឺមានប្រសិទ្ធភាពណាស់។

សមាជិកម្នាក់ៗរបស់លោកអ្នកបងប្អូនអាចតយុទ្ធប្រឆាំង និងការបង្រៀនក្លែងក្លាយបានគឺដោយសារតែពួកគេមានគ្រឹះនៃគោលលទ្ធិដ៏ត្រឹមត្រូវនោះឯង។ មានសមាជិកនៃក្រុមជំនុំខ្លះ គ្រូគង្វាលមិនចាំបាច់ចង្អុលបង្ហាញដល់សមាជិករបស់ខ្លួនអំពីក្រុមគ្រីស្ទបរិស័ទខុសឆ្គងនានាដែលកើតមានឡើងនៅសព្វថ្ងៃនេះទេ គឺពួកគេម្នាក់ៗបានដឹង ហើយតយុទ្ធប្រឆាំងដោយខ្លួនពួកគេរួចរាល់ហើយ។ ទោះបីជាមានក្រុមខុសឆ្គងផ្សេងៗទៀតដែលកំពុងតែកើតឡើងថ្មីៗ ឧទាហរណ៍៖ ក្រុមខុសឆ្គងដែលមកពីប្រទេសចិនជាដើម (ដែលបង្រៀនថា ព្រះយេស៊ូវបានយាងមកវិញហើយ ដែលព្រះយេស៊ូវរបស់ក្រុមពួកគេគឺជាភេទស្រី) ក៏ពួកជំនុំដែលបានចាក់គ្រឹះយ៉ាងរឹងមាំលើគោលលទ្ធិដ៏ត្រឹមត្រូវពួកគេនឹងសម្គាល់ឃើញភ្លាមអំពីការបង្រៀនខុសឆ្គង។

តែផ្ទុយទៅវិញ ជាការសោកស្ដាយ មានគ្រូគង្វាលខ្លះ បែរជាមិនដឹងអ្វីទាល់តែសោះអំពីការបង្រៀនខុសឆ្គងពីក្រុមខុសឆ្គងនានាដែលកើតមានឡើងសព្វថ្ងៃនេះ សូម្បីតែចំណុចដែលត្រូវវែកញែក ឬមានគ្រឹះនៃគោលលទ្ធិដ៏ត្រឹមត្រូវ។ ប្រសិនគ្រូគង្វាលមិនដឹងថា ក្រុមខុសឆ្គងនានា តើពួកគេបង្រៀនខុសអ្វី នោះតើធ្វើដូចម្ដេចឲ្យសមាជិកម្នាក់ៗក្នុងពួកជំនុំដឹងបានដោយរបៀបណាទៅ? ប៉ុន្ដែ សម្រាប់ខ្ញុំផ្ទាល់ប្រសិនបើសមាជិកណាម្នាក់ក្នុងក្រុមជំនុំដឹងអំពីគោលលទ្ធិដ៏ត្រឹមត្រូវបានដឹងថាក្រុមខុសឆ្គងបង្រៀនអ្វីដែលខុសយ៉ាងច្បាស់ តាមការលើកទឹកចិត្តរបស់ខ្ញុំ គ្រូគង្វាលគួរតែត្រឡប់ទៅជាសមាជិកធម្មតាវិញ ហើយសមាជិកណាដែលមានគ្រឹះនៃគោលលទ្ធិដ៏ត្រឹមត្រូវ ដែលមើលទៅមានលក្ខណៈដែលអាចក្លាយជាគ្រូគង្វាលបាន នោះក្រុមជំនុំគួរតែពិចារណាចំនុចត្រង់នេះ។

កណ្ឌគម្ពីរ ២ធីម៉ូថេ ២:១៥ បានចែងថា *“ចូរខំប្រឹងនឹងថ្វាយខ្លួនដល់ព្រះ ទុកជាមនុស្សដែលបានល្បងលជាប់ហើយ ជាអ្នកធ្វើការ ដែលមិនត្រូវខ្មាសឡើយ ដោយ*

*កាត់ស្រាយព្រះបន្ទូលនៃសេចក្ដីពិតយ៉ាងត្រឹមត្រូវ*»។ ត្រង់ឃ្លា « *...ដែលមិនត្រូវខ្មាសឡើយ...*» តើលោកអ្នកផ្ទាល់មានការខ្មាសអៀនទេ នៅពេលដែលលោកអ្នកប្រកាសសេចក្ដីពិតនៃព្រះបន្ទូលព្រះ? តើការពារសេចក្ដីពិតនៃព្រះបន្ទូលព្រះមានការខ្មាសអៀនអត់? យើងមិនគួរខ្មាសអៀនក្នុងការប្រកាសសេចក្ដីពិតនៃព្រះបន្ទូលព្រះនោះទេ ព្រោះការប្រកាសសេចក្ដីពិតនៃព្រះបន្ទូលគឺនាំមកនូវការផ្លាស់ប្តូរ ហើយមានសោភ័ណភាពក្នុងការដើរត្រឹមត្រូវក្នុងជំនឿជាមួយព្រះអង្គសង្គ្រោះ។ នៅក្នុងកណ្ឌគម្ពីរកិច្ចការ ១៧:១១ *«រីឯពួកអ្នកស្រុកនោះ មានចិត្តល្អជាងពួកអ្នកនៅថែស្សាឡូនីច គេប្រុងប្រៀបសព្វគ្រប់នឹងទទួលព្រះបន្ទូល ក៏ពិចារណាមើលគម្ពីររាល់តែថ្ងៃ ឲ្យបានដឹងជាសេចក្ដីទាំងនោះត្រូវឬមិនត្រូវ*»។

នៅខគម្ពីរបានបង្ហាញថា ពួកអ្នកនៅក្រុងបេរា គឺពួកគេ«មានចិត្តល្អជាង» ពួកអ្នកនៅថែស្សាឡូនីច។ តើហេតុអ្វីបានជាពួកអ្នកជឿនៅក្រុងបេរាមានចិត្តល្អជាងអ្នកនៅថែស្សាឡូនីច ពួកគេសុទ្ធតែជាអ្នកជឿដូចគ្នា? ពីព្រោះថា ពួកក្រុងបេរាជាអ្នករក្សាព្រះបន្ទូលព្រះរាល់តែថ្ងៃ ដើម្បីឲ្យពួកគេដឹងថា *«សេចក្ដីទាំងនោះត្រូវឬមិនត្រូវ*»។ នេះគឺជាសារៈសំខាន់នៃព្រះបន្ទូលព្រះ។ កណ្ឌគម្ពីរអេភេសូរ ៤:១៤ *«ដើម្បីកុំឲ្យយើងនៅជាកូនតូចទៀត ទាំងត្រូវគ្រប់អស់ទាំងខ្យល់នៃសេចក្ដីបង្រៀនបោក ហើយផាត់យើងចុះឡើង ដោយសេចក្ដីឆបោករបស់ផងមនុស្ស ហើយដោយឧបាយកល ដែលគេប្រើនឹងនាំឲ្យវង្វេងទៀតឡើយ*»។ ហេតុដូច្នេះ សមាជិកនៃក្រុមជំនុំរបស់ព្រះ នៅពេលដែលទទួលបានការហ្វឹកហ្វឺនត្រឹមត្រូវ នោះពួកគេម្នាក់ៗគឺចេះការពារខ្លួនរបស់ពួកគេផ្ទាល់ពី *«សេចក្ដីបង្រៀនបោក...»* ហើយពួកគេក៏ចេះបដិសេធនូវអ្វីដែលជាសេចក្ដីបង្រៀនក្លែងក្លាយ។ ការនេះ ទាមទារឲ្យលោកអ្នកផ្តល់ចំណីអាហារដែលជាព្រះបន្ទូលដល់សមាជិករបស់លោកអ្នកយ៉ាងត្រឹមត្រូវ ហើយរាល់តែថ្ងៃ។

*គ្រោះថ្នាក់នៅពេលក្រុមជំនុំមិនអើពើនឹងគោលលទ្ធិពិត*

ការបោកបញ្ឆោតខាងវិញ្ញាណ និងការបង្រៀនក្លែងក្លាយ។ កណ្ឌគម្ពីរ ១ធីម៉ូថេ

៤:១ *"តែព្រះវិញ្ញាណ ទ្រង់មានព្រះបន្ទូលយ៉ាងជាក់ច្បាស់ថា នៅគ្រាជាន់ក្រោយបង្អស់ អ្នកខ្លះនឹងលាកចាកចេញពីសេចក្តីជំនឿ ដោយស្តាប់តាមវិញ្ញាណបញ្ឆោត និងសេចក្តីបង្រៀនរបស់ពួកអារក្ស"*។ តាមរយៈបទគម្ពីរនេះ សាវ័ក ប៉ុល ហាក់បីដូចជាប្រើប្រាស់នូវពាក្យធ្ងន់ៗ នៅត្រង់ឃ្លាថា *"សេចក្តីបង្រៀនរបស់ពួកអារក្ស"*។ យើងឃើញថា ការនេះគឺជាគ្រាចុងក្រោយដែលនឹងមានការនេះកើតឡើង គឺជាគ្រាចុងក្រោយនៅសម័យកាលសាវ័ក ប៉ុល ដែលបង្រៀនដល់លោក ធីម៉ូថេ រយៈពេលជាង២០០០ឆ្នាំហើយ។

ប៉ុន្តែ ព្រឹត្តិការណ៍នៃការបង្រៀនក្លែងក្លាយនេះ ក៏កើតមានឡើងនៅក្នុងគ្រាចុងក្រោយក្នុងសម័យកាលឥឡូវនេះផងដែរ ហើយពួកគ្រូក្លែងក្លាយទាំងនោះ ពួកគេមកបង្រៀន និងមិនដែលប្រាប់យើងថា ពួកគេមិនមែនជាអ្នកបង្រៀនក្លែងក្លាយទេ។ ឧទាហរណ៍៖ នៅក្នុងប្រទេសកូរ៉េមានព្រះវិហារដ៏ធំមួយ។ បន្ទាប់មកមានក្រុមនិកាយខុសឆ្គងដែលពួកគេបំផ្លាញក្រុមជំនុំនោះ។

ជាដំបូង ពួកគេចូលមកធ្វើជាសមាជិកធម្មតាដែលសកម្មមែនទែន នៅក្នុងក្រុមជំនុំនោះ ពួកគេបម្រើយ៉ាងសកម្ម ហើយពួកគេពូកែណាស់។ល។ ហេតុដូច្នេះហើយ គ្រូគង្វាល គណៈកម្មការ និងអ្នកដឹកនាំនៅព្រះវិហារនោះបានឃើញថា ពួកគេសកម្មណាស់ ឆេះឆួលណាស់ បន្ទាប់មកអ្នកដឹកនាំក៏បានផ្តល់នូវតួនាទី និងមុខតំណែងណាមួយដល់ពួកគេ។

ហើយបន្ទាប់មកនៅពេលដែលក្រុមពួកគេបានកើនចំនួនឡើងក្នុងក្រុមជំនុំ ពួកគេក៏ចាប់ផ្តើមបង្កើតបក្សពួកនិយម  ហើយចាប់ផ្តើមមើលឃើញកំហុសរបស់គ្រូគង្វាលនៅទីនោះ ដោយចោទប្រកាន់ថា  គ្រូគង្វាលសព្វថ្ងៃចាស់ពេកហើយ គ្រូគង្វាលរបស់យើងបង្រៀនយូរៗទៅមិនសូវល្អទេ ថាចេះ! ថាចុះ!។ល។ បន្ទាប់មកពួកគេក៏លើកឡើងថា ឥឡូវនេះ ពួកគេស្គាល់គ្រូគង្វាលម្នាក់ដែលល្បីល្បាញ ដែលទទួលបាន Ph.D មកពី UK ដែលពូកែរៅហារស័ព្ទណាស់ ដូច្នេះ ចូរយើងអញ្ជើញ

គាត់ឲ្យមកដឹកនាំ និងបង្រៀននៅក្នុងក្រុមជំនុំ។ បន្ទាប់មកបានដឹងថា គ្រូគង្វាលនោះគឺជាមេដឹកនាំរបស់ក្រុមខុសឆ្គងពួកគេសោះ ហើយក្រុមជំនុំក៏ចាប់ផ្ដើមបាក់បែកគ្នាអស់ទៅ។ ពួកគេមិនចាំបាច់ប្រើអាវុធបំផ្លាញនោះទេ ដូច្នេះ នេះគឺជាគំរូមួយដល់យើងទាំងអស់គ្នា។ ចូរឲ្យលោកអ្នកទាំងអស់មានការប្រុងប្រយ័ត្នគ្រប់ពេលវេលាទាំងអស់ សូម្បីតែនៅក្នុងបណ្ដាញសង្គមណាមួយ នៅពេលដែលយើងឃើញសមាជិក ឬក៏បងប្អូនរួមជំនឿរបស់យើងកំពុងតែចូលរួមនៅក្រុមណាមួយដែលមិនត្រឹមត្រូវ នោះចូរឲ្យយើងប្រាប់ដល់ពួកគាត់ភ្លាមៗ ការពារគាត់ ហ៊ានប្រាប់គាត់ កុំខ្លាចគាត់អន់ចិត្តចំពោះយើងឡើយ។

កណ្ឌគម្ពីរ ២ថែស្សាឡូនីច ២:៣ *«កុំឲ្យអ្នកណាបញ្ឆោតអ្នករាល់គ្នាជាយ៉ាងណាដែរ ដ្បិតថ្ងៃនោះមិនមកឡើយ ទាល់តែមានសេចក្ដីក្បត់សាសនាមកជាមុន ហើយមនុស្សដែលជាតួបាបនោះបានលេចមក គឺជាមនុស្សដែលត្រូវហិនវិនាស»*។ ជាការពិតណាស់ វិញ្ញាណបោកបញ្ឆោត ហើយនិងសេចក្ដីបង្រៀនក្លែងក្លាយគឺនឹងមកដល់យើងមិនអាចទប់ស្កាត់វាបាននោះឡើយ។ ប្រហែលមានបងប្អូនរួមជំនឿបានសួរថា ហេតុអ្វីបានជារាជរដ្ឋាភិបាលក្នុងប្រទេសយើងអនុញ្ញាតឲ្យក្រុមខុសឆ្គងនានាចូលមកក្នុងប្រទេសយើង? ចម្លើយនោះគឺជាសេរីភាពនៃសាសនា ដូច្នេះនរណាៗក៏អាចធ្វើការនោះបានដែរ។ល។ ត្រឡប់មកវិញ អ្វីដែលសំខាន់គឺលោកអ្នកហើយនឹងខ្ញុំត្រូវបង្រៀនអ្វីដែលត្រឹមត្រូវតាមព្រះបន្ទូលនៅកាន់ពួកជំនុំរបស់យើងម្នាក់ៗ។

## *ការសម្របសម្រួលខាងសីលធម៌*

ប្រសិនបើយើងមើលទៅអ្នកមិនជឿព្រះ នៅពេលខ្លះ ពួកគេមានសីលធម៌ល្អណាស់ សីលធម៌របស់យើងបែបជាមនុស្សជាតិមានដូចជា៖ ការគោរព ការឲ្យតម្លៃ និងការនិយាយគឺល្អប្រពៃផ្អែមជាទីបំផុត ប៉ុន្ដែជាមួយគ្នា សេចក្ដីពិតវាមិនមែនទាក់ទងនឹងសីលធម៌របស់មនុស្សជាតិនោះទេ ព្រោះថាសីលធម៌គ្រាន់តែជាការសម្ដែងអំពីអ្វីដែលនៅសម្បកខាងក្រៅ ប៉ុន្ដែអំពើបាប និងការពុករលួយទាំងស្រុង

របស់មនុស្សគឺមាននៅក្នុងដួងចិត្តរបស់មនុស្សរួចហើយ ពោលគឺអំពើបាបដើម។ ឧទាហរណ៍៖ លោកអ្នកដែលមានកូនតូចៗ តើលោកអ្នកដែលជាឪពុកម្តាយធ្លាប់បង្រៀនកូនៗឲ្យចេះជេរ ចេះវាយគ្នា ចេះដណ្តើមរបស់គ្នាទេ?

ចម្លើយគឺថា មិនដែលបង្រៀនកូនយើងចេះធ្វើយ៉ាងដូច្នោះទេ ប៉ុន្តែពួកគេចេះការនេះរួចហើយ ព្រោះវាជាអំពើបាបដើមរបស់គាត់។ កណ្ឌគម្ពីរ រ៉ូម ១:២១-២៥ *«ព្រោះកាលគេបានស្គាល់ព្រះ នោះគេមិនបានដំកើងទ្រង់ ទុកជាព្រះទេ ក៏មិនដឹងគុណទ្រង់ដែរ គេកើតមានគំនិតឥតប្រយោជន៍វិញ ហើយចិត្តគេ ដែលឥតយោបល់ ក៏បានត្រឡប់ជាងងឹតទៅ គេអួតខ្លួនថា មានប្រាជ្ញា បានជាគេត្រឡប់ទៅជាល្ងង់ល្ងើវិញ គឺគេបំផ្លាស់សិរីល្អនៃព្រះដែលមិនចេះខូច ឲ្យទៅជារូប មើលទៅដូចជាមនុស្សដែលតែងតែខូចវិញ ហើយដូចជាសត្វស្លាប សត្វជើង៤ និងសត្វលូនវារដែរ ហេតុនោះបានជាព្រះទ្រង់ប្រគល់គេទៅឯសេចក្ដីស្មោកគ្រោក តាមចិត្តគេប្រាថ្នាចង់បានឲ្យបានបង្អាប់ដល់រូបកាយគេទៅវិញទៅមក គេបានផ្លាស់សេចក្ដីពិតនៃព្រះ ឲ្យទៅជាសេចក្ដីភូតភរវិញ ក៏កោតខ្លាច ហើយគោរពបូជាដល់របស់ដែលកើតមក ជាជាងដល់ព្រះ ដែលបង្កើតរបស់ទាំងនោះមក ជាព្រះដែលមានព្រះពរអស់កល្បជានិច្ច អាម៉ែន»*។ តាមរយៈបទគម្ពីរនេះ យើងឃើញថា មនុស្សជាតិសុខចិត្តធ្វើរូបព្រះ ដើម្បីគោរពថ្វាយបង្គំជាជាងថ្វាយបង្គំដល់ព្រះដែលបង្កើតអ្វីៗទាំងអស់។

ប្រសិនបើយើងពិតជាចង់គោរពដល់រូបព្រះបដិមាករពិតមែន នោះយើងគួរតែគោរពដល់ជាងៗដែលបានដាប់ធ្វើរូបបដិមាករនោះឲ្យកើតឡើង យើងគួរតែស្ញើចសរសើរដល់អ្នកដែលបង្កើតរូបនោះមក។

### *ព្រះវិហារបាត់បង់ជាតិប្រៃ ហើយក្លាយជាមនុស្សមិនអាចបែងចែកគ្នាបានជាមួយមនុស្សនៅក្នុងលោកីយ*

ប្រសិនបើក្រុមជំនុំលែងមានជាតិប្រៃ ហើយប្រសិនបើលែងមានគោលជំនឿដ៏ត្រឹមត្រូវ

ទេ នោះក្រុមជំនុំនឹងមិនអាចបែងចែកសូម្បីតែក្រុមជំនុំខ្លួនឯងផ្ទាល់រវាងមនុស្សក្នុងលោកីយ៍បាននោះឡើយ។ អ្នកជឿម្នាក់ៗគួរតែមានបង្ហាញចេញនូវគំរូសីលធម៌ដែលបង្ហាញចេញជាភស្តុតាងថា ខ្លួនពិតបានជាកើតជាថ្មីហើយ។

## *ការបែងចែក និងភាពច្របូកច្របល់*

កណ្ឌគម្ពីរ ១កូរិនថូស ១:១០-១៣ *«ឥឡូវនេះ បងប្អូនអើយ ខ្ញុំទូន្មានដល់អ្នករាល់គ្នា ដោយនូវព្រះនាមព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងថា ចូរនិយាយសេចក្ដីដដែលទាំងអស់គ្នា កុំឲ្យមានសេចក្ដីបាក់បែកក្នុងពួកអ្នករាល់គ្នាឡើយ ត្រូវឲ្យបានរួបរួមគ្នា ដោយមានចិត្តមានគំនិតតែ១វិញ ឱបងប្អូនអើយ ពីព្រោះមានពួកអ្នកផ្ទះនាងខ្លូអេបានប្រាប់ខ្ញុំ ពីដំណើរអ្នករាល់គ្នាថា តែងតែមានសេចក្ដីឈ្លោះប្រកែក ក្នុងពួកអ្នករាល់គ្នា គឺថា អ្នករាល់គ្នានិមួយៗ ប្រកាន់ថា ខ្លួនជាសិស្សរបស់ប៉ុល ជារបស់អ័ប៉ុឡូស ជារបស់កេផាស ឬជារបស់ព្រះគ្រីស្ទ ដូច្នេះ តើព្រះគ្រីស្ទបានបាក់បែកឬអី តើប៉ុលត្រូវឆ្កាងជំនួសអ្នករាល់គ្នាឬអី តើអ្នករាល់គ្នាបានទទួលបុណ្យជ្រមុជដោយនូវឈ្មោះប៉ុលឬអី»។* នៅក្នុងបទគម្ពីរ ពួកជំនុំកូរិនថូសគឺថា ពួកគេមានការច្របូកច្របល់ ហើយបានចាប់ផ្ដើមបែកចែកអំពីបក្សពួក ឬប្រកាន់នៅក្នុងក្រុមជំនុំរបស់ខ្លួន នៅត្រង់ឃ្លាថា *«ខ្លួនជាសិស្សរបស់ប៉ុល ជារបស់អ័ប៉ុឡូស ជារបស់កេផាស ឬជារបស់ព្រះគ្រីស្ទ...»*

ប៉ុន្តែ ជាមួយគ្នាសាវ័ក ប៉ុល បានបង្រៀនដល់ពួកជំនុំកូរិនថូសថា តើព្រះគ្រីស្ទអង្គទ្រង់ផ្ទាល់មានការបែងចែកទេ? ខណៈពេលទាំងអស់អះអាងពីបក្សពួករៀងៗខ្លួន? ជាការពិត លោក អ័ប៉ុឡូស គាត់គឺជាម្នាក់ដែលពូកែវោហារស័ព្ទ ហើយចំណែកលោកសាវ័ក ប៉ុល គឺជាបេសកជន។ សាវ័ក ប៉ុល បានបង្រៀនយ៉ាងត្រឹមត្រូវថា កុំឲ្យមានការបែងចែករវាងក្រុមជំនុំរបស់ព្រះ ឬក៏មានបង្កើតបក្សពួកក្នុងជំនុំដោយប្រកាន់ម្នាក់រៀងៗខ្លួនឡើយ ប៉ុន្តែផ្ទុយទៅវិញគឺត្រូវមានគ្រឹះមាំ។ កណ្ឌគម្ពីរ ទីតុស ៣:៩-១១ *«ប៉ុន្តែ ចូរចៀសវាងពីសេចក្ដីដេញដោលយ៉ាងល្ងីល្ងើ និងពីរឿងពង្សាវតារ*

*ហើយពីសេចក្ដីឈ្លោះប្រកែក និងសេចក្ដីជជែកពីក្រឹត្យវិន័យចេញទៅ ដ្បិតសេចក្ដីទាំងនោះសុទ្ធតែឥតប្រយោជន៍ ហើយឥតអំពើទាំងអស់ ឯមនុស្សណាដែលបង្កើតបក្សពួក នោះត្រូវកាត់គេចោលចេញ ក្នុងពេលក្រោយដែលទូន្មានប្រដៅគេម្ដងពីរហើយ ដោយដឹងថា មនុស្សយ៉ាងនោះខូចអស់ហើយ ក៏ចេះតែធ្វើបាបព្រមទាំងកាត់ទោសខ្លួនគេផង»។*

ខគម្ពីរនេះ បានលើកឡើងអំពីជម្លោះដ៏ល្ងង់ខ្លៅ និងការខុសឆ្គងបានបែងចែករូបកាយពីជំនុំរបស់ព្រះ។ ដូច្នេះ ភាពល្ងង់ខ្លៅខាងគោលលទ្ធិបង្កាត់គំនិតលើសេចក្ដីពិត បណ្ដាលឲ្យមានជម្លោះ។ ប្រសិនបើនៅក្នុងក្រុមជំនុំរបស់លោកអ្នកផ្ទាល់កំពុងតែមានជម្លោះកើតឡើង នោះចូលលោកអ្នកត្រូវនាំយកបញ្ហាទាំងនោះមកដាក់នៅលើតុ ហើយបន្ទាប់មកជជែកជាមួយគ្នា វាមិនមែនជាការវាយប្រហារទៅកាន់គ្នាទៅវិញទៅមកឡើយ។

## *ការបាត់បង់ទីបន្ទាល់ និងអំណាច*

នៅពេលដែលយើងមិនបានលើកឡើងអំពីគោលលទ្ធិឲ្យបានត្រឹមត្រូវទេ នោះនឹងធ្វើឲ្យបាត់បង់ទីបន្ទាល់ និងអំណាចនៃព្រះបន្ទូលរបស់ព្រះ។ កណ្ឌគម្ពីរម៉ាថាយ ៥:១៣-១៦ *«អ្នករាល់គ្នាជាអំបិលនៃផែនដី បើអំបិលបាត់ជាតិប្រៃហើយ នោះតើនឹងយកអ្វី ដើម្បីធ្វើឲ្យប្រៃឡើងវិញបាន ជារបស់គ្មានប្រយោជន៍ទៀតសោះ មានតែបោះបង់ចោលទៅក្រៅ ឲ្យមនុស្សដើរជាន់ប៉ុណ្ណោះ អ្នករាល់គ្នាជាពន្លឺនៃលោកីយ៍ ឯទីក្រុងណាដែលនៅលើភ្នំ នោះលាក់មិនកំបាំងទេ ក៏គ្មានអ្នកណាអុជចង្កៀង យកទៅដាក់ក្រោមថាំងដែរ គេតែងដាក់លើជើងចង្កៀងវិញ នោះទើបភ្លឺដល់អ្នកដែលនៅក្នុងផ្ទះទាំងអស់គ្នា ដូច្នេះ ចូរឲ្យពន្លឺរបស់អ្នករាល់គ្នា បានភ្លឺនៅមុខមនុស្សលោកយ៉ាងនោះដែរ ដើម្បីឲ្យគេឃើញការល្អ ដែលអ្នករាល់គ្នាប្រព្រឹត្ត រួចសរសើរដំកើងដល់ព្រះវរបិតានៃអ្នករាល់គ្នាដែលគង់នៅស្ថានសួគ៌»*។ ដូច្នេះ បទគម្ពីរបានប្រាប់យើងថា លោកអ្នកគឺអំបិល និងពន្លឺដើម្បីបំភ្លឺទៅកាន់លោកីយ៍។

នៅពេលខ្លះ យើងទាំងអស់គ្នាបានភ្លេចតម្លៃនៃការត្រាស់ហៅរបស់ព្រះ លោកអ្នកគឺមានតម្លៃស្មើនឹងព្រះជន្មនៃអង្គព្រះយេស៊ូវគ្រីស្ទ។ ដូច្នេះ យើងមានសេរីភាព។ សេរីភាពចេញអំពីអំពើបាប! សេរីភាពពីអារក្ស! សេរីភាពពីសេចក្តីស្លាប់!។ ទ្រនិចចុងក្រោយនៃសេចក្តីស្លាប់ក៏គ្មានអំណាចមកលើទៀត គឺដោយព្រោះព្រះយេស៊ូវគ្រីស្ទ។ ហេតុដូចនេះហើយ លោកអ្នកត្រូវតែឲ្យតម្លៃមកខ្លួនលោកអ្នក។ តម្លៃក្នុងជីវិតលោកអ្នកគឺថា លោកអ្នកត្រូវតែបំប្រែ ឬនាំពន្លឺទៅ កាន់លោកីយ៍ និងនាំនូវឥទ្ធិពលផងដែរ។

ត្រឡប់មកវិញ ចុះប្រសិនបើយើងបាត់បង់នូវគោលលទ្ធិ និងការបង្រៀនត្រឹមត្រូវនោះយើងនឹងចាប់ផ្តើមបាត់បង់នូវទីបន្ទាល់ហើយគ្មានឥទ្ធិពលអ្វី ហើយលែងមានជាតិដើម្បីបំប្រែទៀតហើយ។ នៅកណ្ឌគម្ពីរ វិវរណៈ ៣:១៥-១៧ *“អញស្គាល់ការដែលឯងធ្វើ ហើយថា ឯងមិនត្រជាក់ ក៏មិនក្តៅផង អញចូលចិត្តឲ្យឯងបាន ទោះត្រជាក់ឬក្តៅក្តី ដូច្នេះ ដោយព្រោះឯងគ្រាន់តែស្ទើរៗ ប៉ុណ្ណោះ គឺមិនមែនត្រជាក់ ក៏មិនក្តៅផង នោះអញនឹងខ្ជាក់ឯងចេញពីមាត់អញទៅ ដោយព្រោះឯងអួតថា ឯងជាអ្នកមាន បានកាន់តែស្តុកស្តម្ភឡើងហើយ ក៏មិនត្រូវការនឹងអ្វីសោះ តែឯងមិនដឹងថា ឯងវេទនា លំបាក ទ័លក្រ ខ្វាក់ភ្នែក ហើយអាក្រាតវិញនោះទេ”*។ ក្រុមជំនុំឡៅឌីសេគឺជាក្រុមជំនុំដែលបានបាត់បង់អំពីឱជារស ក្តៅមិនក្តៅ ត្រជាក់មិនត្រជាក់។

ដូច្នេះ ក្រុមជំនុំមិនត្រូវបាត់បង់នៅភាពឆេះឆួលពីការបម្រើព្រះនោះទេ។ ពួកជំនុំរបស់ព្រះមិនត្រូវដេកលក់ដោយបើកភ្នែកនោះទេ។ សរុបសេចក្តីទៅពួកជំនុំរបស់ព្រះមិនត្រូវដូចក្រុមជំនុំឡៅឌីសេនោះឡើយ ពោលគឺត្រូវតែឆេះឆួល។

*គំរូព្រះគម្ពីរក្រុមជំនុំនៅក្នុងគ្រោះថ្នាក់ដោយសារតែភាពល្ងង់ខ្លៅខាងគោលលទ្ធិ*

នៅក្នុងក្រុមជំនុំកាឡាទី ពួកគេចាប់ផ្តើមមើលទៅកាន់ដំណឹងល្អផ្សេងទៀត សាវ័កប៉ុល បានព្រមានដល់ពួកគេ។ កណ្ឌគម្ពីរកាឡាទី ១:៦-៩ *“ខ្ញុំឆ្ងល់ណាស់ ពីដំណើរ*

*ដែលអ្នករាល់គ្នាបានផ្លាស់ប្រែចេញពីព្រះ ដែលទ្រង់បានហៅអ្នករាល់គ្នាមក ក្នុងព្រះគុណ នៃព្រះគ្រីស្ទ ជាឆាប់ម្ល៉េះ និងទៅតាមដំណឹងល្អផ្សេងទៀតនោះ ដែលមិនមែនជាដំណឹងល្អ១ទៀតទេ គឺមានមនុស្សខ្លះបំភាន់អ្នករាល់គ្នាវិញ ហើយចង់បង្ខូចដំណឹងល្អព្រះគ្រីស្ទផង ប៉ុន្តែ បើយើងខ្ញុំ ឬទេវតាពីស្ថានសួគ៌ នឹងប្រាប់ដំណឹងណាមកអ្នករាល់គ្នា ខុសពីដំណឹងល្អ ដែលយើងខ្ញុំបានប្រាប់ហើយ នោះឲ្យគេត្រូវបណ្ដាសាចុះ ឯសេចក្ដីដែលខ្ញុំទើបនឹងនិយាយអម្បាញ់មិញនេះ នោះខ្ញុំនិយាយម្ដងទៀតថា បើអ្នកណាប្រាប់ដំណឹងណា ខុសអំពីដំណឹងល្អ ដែលអ្នករាល់គ្នាបានទទួលហើយ នោះឲ្យគេត្រូវបណ្ដាសាចុះ»*។ ក្រុមជំនុំកាឡាទីគឺថា ពួកគេកំពុងតែវង្វេង បានជាសាវ័ក ប៉ុល បានប្រាប់ថា *«បើអ្នកណាប្រាប់ដំណឹងណា ខុសអំពីដំណឹងល្អ ដែលអ្នករាល់គ្នាបានទទួលហើយ នោះឲ្យគេត្រូវបណ្ដាសាចុះ»*។

### *ក្រុមជំនុំកូរិនថូស*

រីឯនៅក្នុងក្រុមជំនុំកូរិនថូសគឺថា មានការយល់ច្រឡំអំពីការរស់ឡើងវិញរបស់ព្រះយេស៊ូវ ហើយពួកគេកំពុងតែទទួលនូវសេចក្ដីបង្រៀនថ្មី ដោយមានអ្នកផ្សេងបានបង្រៀន និងអះអាងថាព្រះយេស៊ូវបានយាងមកជាលើកទី២រួចហើយ យើងមិនចាំបាច់រង់ចាំព្រះយេស៊ូវទៀតទេ។ ដូច្នេះហើយបានជាពួកជំនុំចាប់ផ្ដើមវល់ៗ ហើយមានមន្ទិលថា តើយើងគួររង់ចាំ ឬក៏មិនគួររង់ចាំ? ដូច្នេះហើយ ពួកគេមិនយល់ទាល់តែសោះ! នេះហើយគឺលទ្ធផលនៃការដែលមិនស្គាល់គោលលទ្ធិដ៏ត្រឹមត្រូវ។ ករណីនេះនៅក្នុងក្រុមជំនុំខ្លះ ពេលខ្លះមិនចាំបាច់ទាល់តែក្រុមខុសឆ្គង ឬនិកាយខុសឆ្គងមកបង្រៀនខុសឆ្គងឲ្យវង្វេងនោះទេ គឺថា ក្រុមជំនុំវង្វេងដោយខ្លួនឯងទៅហើយ ដោយសារតែមិនស្គាល់អំពីគោលលទ្ធិដ៏ត្រឹមត្រូវ។

### *ក្រុមជំនុំទាំង៧នៃវិវរណៈ*

នៅកណ្ឌគម្ពីរវិវរណៈ២ និងជំពូក៣ បានបង្ហាញប្រាប់ថា ក្រុមជំនុំជាច្រើនបានបរាជ័យក្នុងគោលលទ្ធិ សេចក្ដីស្រឡាញ់ និងភាពបរិសុទ្ធ ដោយទទួលបានការព្រមានយ៉ាងម៉ឺងម៉ាត់ពីព្រះគ្រីស្ទ។

### *ឥទ្ធិពលនៃសម័យទំនើប*

ការកើនឡើងនៃគ្រូក្លែងក្លាយ! ក្រុមក្លែងក្លាយមានច្រើនប្រភេទដូចជា៖ គ្រូក្លែងក្លាយ ហោរាក្លែងក្លាយ ព្រះគ្រីស្ទក្លែងក្លាយ គឺថាមានច្រើនប្រភេទ ដែលយើងទាំងអស់គ្នាមិនអាចយល់បាន។ កណ្ឌគម្ពីរ ២ពេត្រុស ២:១-៣ *«តែកាលពីដើម មានហោរាក្លែងក្លាយ នៅក្នុងពួកជន ដូចជានឹងមានគ្រូក្លែងក្លាយក្នុងពួកអ្នករាល់គ្នាដែរ គេនឹងលួចនាំបញ្ចូលបក្សពួកដែលបង្ខូចបំផ្លាញ គេមិនព្រមស្គាល់ព្រះដ៏ជាម្ចាស់ ដែលបានលោះគេនោះឡើយ ក៏នាំសេចក្ដីវិនាសដ៏ឆាប់រហ័សឲ្យមកលើខ្លួនផង នឹងមានមនុស្សជាច្រើនទៅតាមផ្លូវវិនាសរបស់គេ នោះផ្លូវពិតនឹងត្រូវសេចក្ដីប្រមាថមើលងាយ ដោយព្រោះគេដែរ ហើយដោយគេមានចិត្តលោភ នោះគេនឹងប្រើអ្នករាល់គ្នាឲ្យបានចំណេញ ដោយពោលពាក្យបញ្ឆោតបំពោត តែតាំងពីយូរមកហើយ សេចក្ដីជំនុំជំរះគេមិននៅស្ងៀមស្ងាត់ទេ ហើយសេចក្ដីហិនវិនាសរបស់គេក៏មិនងុយងោកដែរ»*។ ដូច្នេះ ហោរាក្លែងក្លាយគេបានកើតឡើង មានតាំងពីជំនាន់សាវ័ក ពេត្រុសបាននិយាយ ហើយរហូតមកដល់គ្រាសព្វថ្ងៃនេះ គឺថា បានមានវត្តមាននៃហោរាក្លែងក្លាយជាច្រើនបានមកហើយដែរ។ មានបុគ្គលខ្លះ បានអះអាងថា ខ្លួនគេផ្ទាល់គឺជាព្រះ ហើយបានបោកបញ្ឆោតដល់មនុស្ស។ នេះហើយជាមូលហេតុដែលលោកអ្នកហើយខ្ញុំត្រូវតែប្រដាប់កាយ និងត្រូវខ្ជាប់ខ្ជួនជានិច្ចជាមួយនឹងព្រះបន្ទូលព្រះនោះឯង។

## អក្ខរកម្ម/ខ្វះដំរិះ ខាងគោលលទ្ធិនៅក្នុងក្រុមជំនុំ

កណ្ឌគម្ពីរហូសេ ៤:៦ *«រាស្ត្រអញ គេត្រូវបំផ្លាញទៅ ដោយខ្វះខាតដំរិះដូច្នេះ ដោយព្រោះឯងមិនព្រមទទួលដំរិះ បានជាអញក៏នឹងបោះបង់ចោលឯង មិនឲ្យធ្វើជាសង្ឃដល់អញទៀតដែរ ហើយដោយហេតុ ដែលឯងបានភ្លេចច្បាប់របស់ព្រះនៃឯងនោះ អញក៏នឹងភ្លេចកូនចៅរបស់ឯងដូចគ្នា»*។ នៅពេលបច្ចុប្បន្ននេះ មានឧបករណ៍ជាច្រើនណាស់ ក្នុងការអាន ហើយស្រាវជ្រាវបន្ថែមទៀតបានមានដូចជាគេហទំព័រផ្លូវពិត ដែលមានមេរៀនជាច្រើនជាប្រចាំថ្ងៃ ហើយនិងសៀវភៅជាឯកសារ PDF ទាញយកដោយឥតគិតថ្លៃ ហើយក៏មានវេបសាយសៀវភៅអនឡាញក្នុងការកុម្ម៉ង់ទិញអានជាភាសាខ្មែរនៅក្នុង Plovpitshop.com។ល។

## សម្របសម្រួលជាមួយវប្បធម៌

កណ្ឌគម្ពីររ៉ូម ១២:២ *«កុំឲ្យត្រាប់តាមសម័យនេះឡើយ ចូរឲ្យអ្នករាល់គ្នាបានផ្លាស់ប្រែវិញ ដោយគំនិតបានកែជាថ្មីឡើង ដើម្បីនឹងអាចលមើលឲ្យបានស្គាល់បំណងព្រះហឫទ័យនៃព្រះ ដែលល្អ ស្រួលទទួល ហើយគ្រប់លក្ខណ៍ផង»*។ សម័យកាលសព្វថ្ងៃនេះអាក្រក់ណាស់។ ព្រះគម្ពីរបានប្រាប់ថា *«កុំត្រាប់តាមសម័យនេះឡើយ...»*។

## មធ្យោបាយដោះស្រាយ៖ ការត្រឡប់ទៅរកព្រះបន្ទូល និងគោលលទ្ធិ

តើមានមធ្យោបាយអ្វី ដើម្បីអាចបង្រៀនគោលលទ្ធិដ៏ត្រឹមត្រូវដល់ក្រុមជំនុំ? តើត្រូវធ្វើយ៉ាងណាដើម្បីនឹងនាំពួកគេឲ្យវិលត្រឡប់មកកាន់ព្រះបន្ទូល ហើយនិងគោលលទ្ធិដ៏ត្រឹមត្រូវវិញ? ចម្លើយនោះគឺថា ៖ គ្រូគង្វាលត្រូវតែអធិប្បាយអំពីគោលលទ្ធិដ៏ត្រឹមត្រូវនោះឯង។ គ្រូគង្វាល ឬអ្នកដឹកនាំ បេសកជន គ្រូផ្សាយដំណឹងល្អគឺត្រូវតែបង្រៀនអំពីគោលលទ្ធិដ៏ត្រឹមត្រូវមុនគេ។ កណ្ឌគម្ពីរ ២ធីម៉ូថេ ៤:២ *«ចូរឲ្យអ្នកផ្សាយព្រះបន្ទូលចុះ ហើយទទូចជំរុញផង ទោះត្រូវពេល ឬខុសក្តី ចូររំឭកគេឲ្យដឹងខ្លួន ព្រមទាំងបន្ទោស ហើយកំឡាចិត្តគេ ដោយចិត្តអត់ធ្មត់ និងសេចក្តីប្រៀនប្រដៅ*

*គ្រប់យ៉ាង»*។

យើងត្រូវតែប្រកាស ឬបង្រៀនសេចក្តីពិតនៃព្រះបន្ទូលព្រះទោះបីត្រូវពេល ឬខុសក្តី នៅទីកន្លែងណាក៏ដោយ ក៏សារនៃការប្រកាសនោះ ដាច់ខាតគឺត្រូវតែដូចគ្នាដដែល។ សារនៃការបង្រៀនសេចក្តីពិតដ៏ត្រឹមត្រូវគឺត្រូវតែដូចគ្នា មិនថា មនុស្សជាអ្នកមាន ឬជាអ្នកក្រីក្រក្តី ពោលគឺដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទគឺនៅតែដដែលជានិច្ច។

កណ្ឌគម្ពីរ ទីតុស ២:១ *«ចូរឲ្យអ្នកនិយាយតែសេចក្តីណា ដែលសំណាំនឹងសេចក្តីបង្រៀនដ៏ត្រឹមត្រូវ»*។ ខគម្ពីរនេះបានប្រាប់ដល់យើងថា *«ត្រូវតែបង្រៀនសេចក្តីបង្រៀនដ៏ត្រឹមត្រូវ»* ហើយក្នុងក្រុមជំនុំក៏ត្រូវតែបង្កើតសិស្សផងដែរ។ ក្រុមជំនុំមិនមែនគ្រាន់តែបង្កើតចំនួនបរិមាណនៃអ្នកចូលរួម តែគ្មានគុណភាពនោះឡើយ។ ដូច្នេះយើងត្រូវតែបង្កើតសិស្សវិញ (គឺជាអ្នកជឿលើព្រះយេស៊ូវគ្រីស្ទយ៉ាងពិតប្រាកដ)។

*ព្រះវិហារត្រូវតែបង្កើតសិស្ស*

កណ្ឌគម្ពីរ អេភេសូរ ៤:១១-១៤ *«គ្រូបង្រៀនត្រូវបានផ្តល់ឲ្យដើម្បីជួយពួកបរិសុទ្ធឲ្យរីកចម្រើនតាមសេចក្តីពិត»*។ កណ្ឌគម្ពីរ កិច្ចការ ២០: ២៧ *«សាវ័ក ប៉ុលបានប្រកាសអំពី«ឱវាទទាំងស្រុងរបស់ព្រះ»*។ សោកស្តាយមានក្រុមជំនុំខ្លះ មិនអធិប្បាយអំពីអំពើបាបទាល់តែសោះ។ ឧទាហរណ៍៖ អំពីក្រុមជំនុំធំមួយនៅក្រៅប្រទេសដែលអ្នកដឹកនាំរបស់ពួកគេគឺលោក ចូអែល អូស្ទីន (Joel Osteen)។ លោក ចូអែល អូស្ទីន (Joel Osteen) គាត់មិនដែលនិយាយអំពីអំពើបាបដែលត្រូវការកែប្រែចិត្តនោះទេ គាត់ថាបញ្ហារឿងអំពើបាបគឺមិនត្រូវនិយាយជាដាច់ខាត។ គាត់មិននិយាយអំពីស្ថាននរកបឹងភ្លើងទាល់តែសោះ។

ដូច្នេះ យើងឃើញថា មានព្រះវិហារដែលមានមនុស្សច្រើនចូលរួម នោះក៏មិនប្រាកដមានគ្រប់ទាំងសេចក្តីពិតតាមព្រះបន្ទូលព្រះទាំងស្រុងនោះទេ ហើយពេល

ខ្លះក៏មានក្រុមជំនុំដែលតូចមានសមាជិកតិច ប៉ុន្តែពួកគេបម្រើព្រះដោយស្មោះត្រង់ និងត្រឹមត្រូវនៅចំពោះព្រះវិញ។

*អ្នកជឿត្រូវតែរីកចម្រើនក្នុងចំណេះដឹង*

អ្នកជឿគ្រប់គ្នាត្រូវតែស្គាល់សេចក្តីពិតជាមុនសិន ហើយអ្វីដែលជាការក្លែងក្លាយ យើងមិនចាំបាច់ត្រូវស្គាល់ច្រើន ឬស្រាវជ្រាវនោះឡើយ។ កុំចាំបាច់ត្រូវទទួលបទពិសោធន៍ពីភាពក្លែងក្លាយ។ ឧទាហរណ៍៖ យើងត្រូវស្គាល់លុយពិតប្រាកដ អ្វីដែលខុសពីលុយពិតគឺសុទ្ធតែលុយក្លែងក្លាយទាំងអស់។

ក្រុមជំនុំដែលមិនស្គាល់ព្រះបន្ទូលរបស់ព្រះ និងគោលលទ្ធិដ៏ត្រឹមត្រូវ គឺដូចជាផ្ទះដែលគ្មានគ្រឹះ។ ខ្មាំងសត្រូវកំណត់គោលដៅក្រុមជំនុំដែលមិនមានព័ត៌មានដោយមានកំហុស ការបែកបាក់ និងការស្លាប់ខាងវិញ្ញាណ។ ខ្មាំងសត្រូវរបស់យើងតែងតែក្រវែលមើលដល់អស់អ្នកណាដែលខ្សោយ ហើយវាចាំលេបត្របាក់ដល់អស់អ្នកណាដែលនៅម្នាក់ឯង ហើយជាពិសេសគឺអស់អ្នកណាដែលគ្មានគ្រឹះនៃព្រះបន្ទូលរបស់ព្រះនោះឯង។

# ចូរឲ្យយើងទាំងអស់គ្នាការពារដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ពី Syncretism!

និពន្ធដោយៈ លោក ហ្វ័ររេស ម៉ាកហ្វែល (FORREST MCPHAIL)

ខ្ញុំចង់បង្រៀនពាក្យភាសាអង់គ្លេសមួយ ដោយសារតែភាសាខ្មែរមិនទាន់មានពាក្យណាមួយដែលបកប្រែចំនឹងពាក្យក្នុងភាសាអង់គ្លេសគឺពាក្យថា «ស៊្សិងក្រេទីស៊ិម» (“Syncretism”)។ ជាមួយគ្នាប្រសិនបើលោកអ្នកមិនចងចាំពាក្យភាសាអង់គ្លេសទេ ប៉ុន្តែសំខាន់ខ្ញុំឲ្យលោកអ្នកចងចាំនូវអត្ថន័យនៃពាក្យនេះ។ ពាក្យថា «ស៊្សិងក្រេទីស៊ិម» គឺបានន័យថា «ការលាយសាសនា ឬក៏បញ្ចូលសាសនាជាមួយគ្នា» ឬក៏ «ផ្សំគំនិតសាសនា» ឬក៏ «សំយោគគំនិតពីទស្សនវិជ្ជា និងសាសនាផ្សេងៗ ជំនួសការទទួលជឿដំណឹងល្អតាមព្រះគម្ពីរ»។ មនុស្សជាច្រើនប្តូរអត្ថន័យនៃដំណឹងល្អឲ្យសមនឹងបំណងប្រាថ្នា និងគំនិតរបស់ពួកគេជំនួសវិញ។ ការកែឆ្នៃដំណឹងល្អនេះ គឺជាការលាយសាសនា ឬក៏បញ្ចូលសាសនាជាមួយគ្នានោះឯង។ គឺបានន័យថា យើងលាយគំនិតរបស់សាសនាទៅតាមគំនិតរបស់ខ្លួនឯង។

*គ្រោះថ្នាក់នៃការលាយសាសនា ឬក៏បញ្ចូលសាសនាជាមួយគ្នា*

ពាក្យ "ការលាយសាសនា ឬក៏បញ្ចូលសាសនាជាមួយគ្នា" មិនមែនជាការបដិសេធសាសនាមួយសម្រាប់សាសនាមួយផ្សេងទៀតទេ ប៉ុន្តែជាការទទួលយកផ្នែកផ្សេងៗនៃសាសនាទាំងពីរហើយបង្កើតជំនឿសាសនាថ្មីវិញ។ ដូច្នេះ សម្រាប់គ្រីស្ទបរិស័ទណាដែលកំពុងតែធ្វើបែបនេះ គឺកំពុងតែលាយឡំជំនឿ និងសាសនាហើយ (ការលាយសាសនា ឬក៏បញ្ចូលសាសនាជាមួយគ្នា)។ ពួកគេមិនមែនបដិសេធសេចក្តីបង្រៀនក្នុងព្រះគម្ពីរទាំងស្រុងនោះទេ គឺបានន័យថា ពួកគេទទួលយកការបង្រៀនខ្លះ បដិសេធខ្លះ។ ហើយពួកគេបន្ថែមខ្លះ ហើយដកចេញខ្លះ នោះហើយគឺជាការលាយឡំសាសនា និងជំនឿដែលយើងហៅថា (ការលាយសាសនា ឬក៏បញ្ចូលសាសនាជាមួយគ្នា)។

សាតាំងមានជំនាញក្នុងការល្បួងដល់មនុស្ស ដើម្បីជ្រើសរើសផ្នែកនៃព្រះបន្ទូលរបស់ព្រះដើម្បីជឿ ឬបដិសេធ។ ការលាយឡំសេចក្តីពិតរបស់ព្រះជាមួយនឹងសេចក្តីមិនពិត តែងតែជាយុទ្ធសាស្ត្ររបស់អារក្សជានិច្ច។ បងប្អូនអើយ យើងទាំងអស់គ្នាកំពុងតែរស់នៅក្នុងសង្គ្រាមខាងវិញ្ញាណ។ សង្គ្រាមនេះគឺសំដៅទៅសេចក្តីពិតរបស់ព្រះ ដែលបានមានចែងនៅក្នុងព្រះគម្ពីរ។ ការដែលយើងទទួលយកទាំងស្រុង ឬមិនទទួលយកទាំងស្រុងនោះ ត្រង់ចំណុចដែលយើងជឿទាំងស្រុង ឬមិនជឿទាំងស្រុងនោះឯងគឺជាចម្បាំងខាងវិញ្ញាណដែលមាននៅក្នុងជីវិតរស់នៅរាល់ថ្ងៃនេះ។ យើងទាំងអស់គ្នាដាច់ខាត ត្រូវជឿលើព្រះបន្ទូលរបស់ព្រះទាំងស្រុង ហើយយើងមិនត្រូវទុកចិត្តលើគំនិតរបស់មនុស្ស ហើយក៏មិនត្រូវទុកចិត្តលើគំនិតរបស់ខ្លួនឯងផង។ ជាមួយគ្នា យើងទាំងអស់គ្នាត្រូវទុកចិត្តលើព្រះបន្ទូលរបស់ព្រះវិញ។

*គ្រប់ទីកន្លែងដែលអ្នកជឿលើព្រះយេស៊ូវ ប្រកាសដំណឹងល្អ* មានគ្រោះថ្នាក់នៃ *«ការលាយសាសនា ឬក៏បញ្ចូលសាសនាជាមួយគ្នា»* នេះ។

គឺនៅគ្រប់កន្លែង ដំណឹងល្អរបស់ព្រះយេស៊ូវទៅដល់ទីណាក៏ដោយក៏នៅតែមាន

*«ការលាយសាសនា ឬក៏បញ្ចូលសាសនាជាមួយគ្នា»នេះ។ មិនមានកន្លែងណាមួយដែលមិនមានបញ្ហានេះនោះទេ។* ពីព្រោះ មនុស្សជាតិយើងមិនស្វែងរកបំណងព្រះហឫទ័យព្រះ ហើយក៏មិនចង់បានសេចក្តីសង្គ្រោះដែលមកពីព្រះផងដែរ។ ប៉ុន្តែផ្ទុយទៅវិញ ពួកគេចង់បានគំនិត និងប្រាជ្ញារបស់ខ្លួនពួកគេវិញ។ នេះគឺជាអ្វីដែលមនុស្សយើងចង់កែច្នៃដំណឹងល្អ ជាពិសេស រាល់ថ្ងៃនៅប្រទេសកម្ពុជាយើងក៏មានក្រុមគ្រីស្ទានខ្លះ  ចង់ច្នៃដំណឹងល្អ និងសេចក្តីបង្រៀនរបស់ព្រះយេស៊ូវឲ្យស្របគ្នាដូចគ្នានឹងជំនឿលើសាសនារបស់ពួកគេចង់បានទៅវិញ។ ពួកគេព្យាយាមសម្របសម្រួលរវាងជំនឿលើព្រះយេស៊ូវ លាយគ្នាជាមួយនឹងជំនឿលើសាសនាព្រះពុទ្ធ។ ពួកគេចង់យកសាសនាដែលពួកគេធ្លាប់ជឿពីមុនៗមកច្នៃខ្លះ បន្ទាប់មកលាយជាមួយគ្នាហ្នឹងជំនឿលើព្រះយេស៊ូវគ្រីស្ទហើយអះអាងថា ពួកគេក៏ជឿលើព្រះយេស៊ូវដែរ នេះហៅថា «ការលាយសាសនា ឬក៏បញ្ចូលសាសនាជាមួយគ្នា»។

*ការលើកឡើងក្នុងព្រះគម្ពីរសញ្ញាចាស់អំពី «ការលាយសាសនា ឬក៏បញ្ចូលសាសនាជាមួយគ្នា»*

នៅព្រះគម្ពីរសញ្ញាចាស់មានបញ្ហានៃ *«ការលាយសាសនា ឬក៏បញ្ចូលសាសនាជាមួយគ្នា»* មាននៅច្រើនកន្លែងមែនទែនបញ្ហានេះ។ ជនរងគ្រោះដំបូង ដែលអារក្សសាតាំងនាំឲ្យមានការបោកបញ្ឆោតនៅក្នុងព្រះគម្ពីរគឺនាង អេវ៉ា៖ តើអារក្សសាតាំងបាននិយាយយ៉ាងដូចម្តេចទៅកាន់នាង អេវ៉ា នៅក្នុងសួនច្បារអេដែន?  នៅក្នុងកណ្ឌគម្ពីរ លោកុប្បត្តិ ៣:១ *«ឯពស់ជាសត្វចេះឧបាយកលលើសជាងអស់ទាំងសត្វព្រៃ ដែលព្រះយេហូវ៉ាដ៏ជាព្រះទ្រង់បានបង្កើត វានិយាយទៅកាន់ស្ត្រីថា តើព្រះមានព្រះបន្ទូលហាមមិនឲ្យអ្នកបរិភោគផ្លែឈើណានៅក្នុងសួនច្បារមែនឬ»*។ អារក្សសាតាំងចាប់ផ្តើមនាំឲ្យការមានសង្ស័យទៅលើព្រះបន្ទូលរបស់ព្រះ។ អារក្សសាតាំងចាប់ផ្តើមបញ្ចូលនូវគំនិតផ្សេងៗដែលខុសពីព្រះហឫទ័យរបស់ព្រះ ហើយជាទីបំផុត នាង អេវ៉ា បានជ្រើសរើសស្តាប់តាមអារក្សសាតាំង។

ចំណែកឯសាសន៍អ៊ីស្រាអែលវិញ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ យើងបានឃើញថា នៅពេលដែលលោក ម៉ូសេ បានឡើងទៅលើកំពូលភ្នំស៊ីណាយ ដើម្បីទទួលក្រឹត្យវិន័យរបស់ព្រះ១០ប្រការ ប៉ុន្តែនៅក្បែរជើងភ្នំស៊ីណាយ ពួកបណ្តាជនបានចាប់ផ្តើមសូនរូបកូនគោមាសមួយ ហើយពួកបណ្តាជន *"...ដោយប្រកាសថា នែពួកអ៊ីស្រាអែលអើយ នេះហើយជាព្រះនៃឯងដែលបាននាំឯងចេញពីស្រុកអេស៊ីព្ទមក"* (និក្ខមនំ ៣២:៨)។ មិនតែប៉ុណ្ណោះនោះទេ ការថ្វាយបង្គំរបស់ពួកសាសន៍អ៊ីស្រាអែល គឺទាំងការស៊ីផឹក និងសហាយស្មន់នៅចំពោះមុខរូបកូនគោនោះទេ ប៉ុន្តែនៅចំពោះមុខព្រះយេហូវ៉ាទៀតផង។ យើងបានឃើញថា ពួកសាសន៍អ៊ីស្រាអែលមិនបានបដិសេធព្រះយេហូវ៉ាទាំងស្រុងទេ ប៉ុន្តែពួកគេបានបំផ្លាស់អត្ថន័យជំនឿទៅលើព្រះយេហូវ៉ា។

បន្ទាប់មកទៀត  យើងឃើញថា ពួកសាសន៍អ៊ីស្រាអែលនៅក្នុងទីរហោស្ថានអស់ជាង៤០ឆ្នាំ ពួកគេនៅតែមិនព្រមទទួលជឿលើព្រះបន្ទូលព្រះទាំងស្រុង។ ប៉ុន្តែមុនពេលដែលពួកសាសន៍អ៊ីស្រាអែលបានចូលទៅក្នុងទឹកដីស្រុកកាណាននៅក្នុងកណ្ឌគម្ពីរចោទិយកថា មានពេលជាច្រើនដងដែលព្រះបានព្រមានដល់ពួកសាសន៍អ៊ីស្រាអែលអំពីៈ កុំថ្វាយបង្គំរូបព្រះ កុំឆ្លាក់រូបព្រះ កុំយកអ្នកមិនជឿធ្វើជាប្តីឬប្រពន្ធ។ល។ ព្រះបានមានបន្ទូលច្រើនដងដល់សាសន៍អ៊ីស្រាអែលក្នុងកណ្ឌគម្ពីរចោទិយកថាថា ពីព្រោះមនុស្សតែងតែភ្លេចខ្លួនជានិច្ច។

*បើគ្មានភាពប្រុងប្រយ័ត្ន នោះនឹងពិតជាមានការចាប់ផ្តើមវង្វេងជាមិនខាន*

យើងបានឃើញថា ពួកសាសន៍អ៊ីស្រាអែលនោះហើយគឺជាគំរូសម្រាប់យើងនៅក្នុងចំណុចនេះ នេះហើយគឺជាប្រវត្តិរបស់សាសន៍អ៊ីស្រាអែលហើយនៅក្នុងព្រះគម្ពីរសញ្ញាចាស់ដោយពួកគេមិនប្រុងប្រយ័ត្ន។ ហើយយើងបានឃើញថា ទោះបីជាក្នុងតំណណា ទោះបីជាមានស្តេចសោយរាជ្យលើពួកគេយ៉ាងណា ពួកគេមិនដែលបោះបង់ចោលព្រះយេហូវ៉ាទេ ប៉ុន្តែពួកគេចង់ជឿលើព្រះយេហូវ៉ាផង ហើយនិងជឿលើព្រះ

ក្លែងក្លាយផ្សេងៗទៀតដែរ ដើម្បីថ្វាយបង្គំ។

យើងបានឃើញថា ហោរានៃព្រះ តែងតែនិយាយច្រើនដងអំពីការប្រុងប្រយ័ត្ន នៃ « ការលាយសាសនា ឬក៏បញ្ចូលសាសនាជាមួយគ្នា» (មិនមានពាក្យនេះទេនៅក្នុងព្រះគម្ពីរ) កុំឲ្យពួកសាសន៍អ៊ីស្រាអែលលាយឡំ ការថ្វាយបង្គំព្រះយេហូវ៉ាផង និងគំនិតនៃការថ្វាយបង្គំរូបព្រះ ឬបន្ថែម និងរបៀបនៃសាសនាផ្សេងទៀតចូលក្នុងព្រះបន្ទូលរបស់ព្រះនោះទេ ប៉ុន្តែពួកគេត្រូវតែប្រុងប្រយ័ត្ន។ នៅក្នុងកណ្ឌគម្ពីរចោទិយកថា ១២:៣២ បានចែងថា *«អស់ទាំងសេចក្តីណាដែលអញបង្គាប់ដល់ឯងរាល់គ្នា នោះត្រូវប្រយ័ត្ន និងប្រព្រឹត្តតាមចុះ មិនត្រូវបន្ថែមបញ្ចូលអ្វី ឬកាត់ចោលអ្វីឡើយ»*។ ដូច្នេះ នៅក្នុងព្រះគម្ពីរសញ្ញាចាស់មានបញ្ហានេះច្រើន។ ហើយចុះចំណែកព្រះគម្ពីរសញ្ញាថ្មីវិញ?

*ការលាយសាសនា ឬក៏បញ្ចូលសាសនាជាមួយគ្នានៅក្នុងគម្ពីរសញ្ញាថ្មី*

នៅក្នុងព្រះគម្ពីរសញ្ញាថ្មីក៏មានបញ្ហានេះផងដែរនៅគ្រប់ទីកន្លែង។ នៅពេលដែលព្រះយេស៊ូវបានយាងមកទ្រង់បានចុះទៅតាមតំបន់ភូមិ ឃុំ ស្រុក និងតាមតំបន់នានា ហើយបានបង្រៀនដល់ហ្វូងមនុស្សគឺព្រះអង្គតែងតែប្រឆាំង ពួកផារិស៊ី និងសាឌូស៊ី ដោយព្រោះពួកគេទាំងនោះតែងតែ «ការលាយសាសនា ឬក៏បញ្ចូលសាសនាជាមួយគ្នា»។ ពួកគេទាំងនោះ បានយកក្រិត្យវិន័យក្នុងព្រះគម្ពីរសញ្ញាចាស់ មកបំផ្លាស់អត្ថន័យដើមរបស់វា។ យកក្រឹត្យវិន័យក្នុងព្រះគម្ពីរសញ្ញាចាស់របស់ព្រះ មកបង្រៀនឲ្យខុសពីព្រះហឫទ័យដើមរបស់ព្រះ ហើយបានបន្ថែមទម្លាប់ជាច្រើនមកលើព្រះគម្ពីរថែមទៀត បន្ទាប់មកបង្ខំដល់ហ្វូងមនុស្សឲ្យគ្រាប់តាម ស្តាប់តាម ចំណែកឯព្រះយេស៊ូវវិញ តែងតែប្រឆាំងនឹងពួកគេទាំងនោះ។ នោះហើយជាហេតុដែលព្រះបានអនុញ្ញាតឲ្យពួកគេទាំងនោះឆ្កាងព្រះអង្គ ដោយព្រោះពួកគេបានបដិសេធព្រះបន្ទូលរបស់ព្រះយេស៊ូវ។

*ការស្តីបន្ទោសយ៉ាងខ្លាំងរបស់សាវ័ក ប៉ុល ទៅកាន់ក្រុមជំនុំនៅស្រុកកាឡាទី*
ចំណែករាល់ពួកសាវ័កព្រះយេស៊ូវ នៅគ្រប់កន្លែងក៏បានព្រមានដល់យើងអំពីចំណុចនេះដដែល ដោយឲ្យយើងការពារដំណឹងល្អរបស់ព្រះ យើងត្រូវរក្សាដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទទាំងនេះគឺតួនាទីដ៏ធំរបស់ក្រុមជំនុំ។ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី តើមានកណ្ឌ/សំបុត្រណាមួយដែលមិនបង្រៀនអំពីបញ្ហាគ្រូខុសឆ្គង? ចម្លើយគឺថា ក្នុងព្រះគម្ពីរសញ្ញាថ្មីទាំងអស់សុទ្ធតែលើកឡើងអំពីបញ្ហានេះ ដូច្នេះ បញ្ហានេះគឺធំណាស់។

*ការស្តីបន្ទោសយ៉ាងខ្លាំងរបស់សាវ័ក ប៉ុល ទៅកាន់ក្រុមជំនុំនៅស្រុកកាឡាទី*
សាវ័ក ប៉ុល បានស្តីបន្ទោសយ៉ាងខ្លាំងទៅកាន់ក្រុមជំនុំនៅស្រុកកាឡាទីនៅក្នុងកណ្ឌគម្ពីរកាឡាទី ១:៦-១០៖

> «ខ្ញុំឆ្ងល់ណាស់ ពីដំណើរដែលអ្នករាល់គ្នាបានផ្លាស់ប្រែចេញពីព្រះ ដែលទ្រង់បានហៅអ្នករាល់គ្នាមក ក្នុងព្រះគុណ នៃព្រះគ្រីស្ទ ជាឆាប់ម៉្លេះ និងទៅតាមដំណឹងល្អផ្សេងទៀតនោះ ដែលមិនមែនជាដំណឹងល្អ១ទៀតទេ គឺមានមនុស្សខ្លះបំភាន់អ្នករាល់គ្នាវិញ ហើយចង់បង្ខូចដំណឹងល្អព្រះគ្រីស្ទផង ប៉ុន្តែបើយើងខ្ញុំ ឬទេវតាពីស្ថានសួគ៌ នឹងប្រាប់ដំណឹងណាមកអ្នករាល់គ្នា ខុសពីដំណឹងល្អ ដែលយើងខ្ញុំបានប្រាប់ហើយ នោះឲ្យគេត្រូវបណ្តាសាចុះ ឯសេចក្តីដែលខ្ញុំទើបនឹងនិយាយអម្បាញ់មិញនេះ នោះខ្ញុំនិយាយម្តងទៀតថា បើអ្នកណាប្រាប់ដំណឹងណា ខុសអំពីដំណឹងល្អ ដែលអ្នករាល់គ្នាបានទទួលហើយ នោះឲ្យគេត្រូវបណ្តាសាចុះ ដ្បិតតើខ្ញុំរកបញ្ចុះបញ្ចូលអ្នកណា តើជាមនុស្ស ឬព្រះ ឬចង់បំពេញចិត្តមនុស្សឬអី បើសិនជាខ្ញុំចង់បំពេញចិត្តមនុស្ស នោះខ្ញុំមិនមែនជាបាវបំរើរបស់ព្រះគ្រីស្ទទេ»។

នេះគឺជាខគម្ពីរដែលប្រើប្រាស់ពាក្យធ្ងន់ៗដែលយើងទាំងអស់គ្នាគួរតែយកចិត្តទុកដាក់ហើយញាប់ញ័រផង ពីសារៈសំខាន់ដែលយើងទាំងអស់គ្នាត្រូវការពារដំណឹងល្អរបស់ព្រះយេស៊ូវ។ ប្រសិនបើមាននរណាម្នាក់មកឯយើង ហើយបានប្រកាស

ពីដំណឹងល្អដែលខុសឆ្គង នោះមិនមែនត្រឹមតែយើងគ្រាន់តែបដិសេធពួកគេ ឬក៏មិនស្ដាប់ពួកគេនោះទេ ប៉ុន្តែគឺថាសាវ័ក ប៉ុល បានប្រាប់ថា *«ឲ្យគេត្រូវបណ្ដាសាដោយប្រើប្រាស់ពាក្យធ្ងន់ៗបែបនេះពីរដង»*។ យើងទាំងអស់គ្នាគួរតែញាប់ញ័រ ហើយចេញពីគ្រូក្លែងក្លាយដែលពួកគេមានការផ្សាយដំណឹងដែលខុសប្លែកចេញពីសេចក្ដីបង្រៀនដ៏ត្រឹមត្រូវនៅក្នុងព្រះគម្ពីរ។ ដើម្បីយើងស្គាល់ពួកគ្រូខុសឆ្គងទាំងនោះបាន គឺខ្លួនយើងម្នាក់ៗត្រូវច្បាស់លាស់អំពីដំណឹងល្អដ៏ពិត និងគោលលទ្ធិត្រឹមត្រូវដែលមានចែងក្នុងព្រះគម្ពីរ។

យើងទាំងអស់គ្នាត្រូវតែ ជឿ ចាំ ស្គាល់ ដើម្បីនៅពេលណាដែលយើងជួបប្រទះនឹងក្រុមខុសឆ្គង ឬក៏ឃើញពួកគេបានបង្ហោះ ផ្សព្វផ្សាយ ការបង្រៀនខុសឆ្គងនៅក្នុងបណ្ដាញសង្គមនោះយើងនឹងបដិសេធដោយឆ្លើយថា អត់ទេៗ ទោះបីជាពួកគេសូមឲ្យលោកអ្នកធ្វើជាមិត្តភក្ដិលើបណ្ដាញសង្គម ឬនៅក្រៅបណ្ដាញសង្គមក្ដី។ល។ ដូច្នេះ យើងស្គាល់ច្បាស់អំពីគ្រូៗក្លែងក្លាយ ដោយសារយើងយល់ច្បាស់អំពីដំណឹងល្អរបស់ព្រះយេស៊ូវដោយខ្លួនយើងផ្ទាល់ម្នាក់ៗ។

នៅខគម្ពីរនេះ ហេតុអ្វីបានសាវ័ក ប៉ុល ស្ដីបន្ទោសដល់ក្រុមជំនុំកាឡាទីយ៉ាងខ្លាំងម្ល៉េះ? ពីព្រោះថា មានអ្នកជឿលើព្រះមួយចំនួននៅក្នុងស្រុកនោះ គឺពួកគេកំពុងតែទទួលការបង្រៀនមកពីគ្រូខុសឆ្គងហើយ ដោយចង់ឲ្យពួកគេបែរមកជឿលើដំណឹងល្អបែបមិនពិតវិញ។ ដូច្នេះ សាវ័ក ប៉ុល បានពន្យល់យ៉ាងច្បាស់ថា នេះគឺជាគ្រោះថ្នាក់យ៉ាងខ្លាំងណាស់សម្រាប់ពួកគេ ហេតុនេះហើយ បានជាសាវ័ក ប៉ុល បានសរសេរទៅកាន់ពួកគេដើម្បីឲ្យពួកគេបែរមករកសេចក្ដីពិតនៃដំណឹងល្អឡើងវិញ។ ដូច្នេះហើយបានជានៅកណ្ឌគម្ពីរកាឡាទី ១:១១ រហូតដល់កាឡាទី ២:១០ សាវ័ក ប៉ុល បានរម្លឹកពួកគេថា ព្រះបានចាត់សាវ័ក ប៉ុល ឲ្យមកដើម្បីផ្សាយដំណឹងល្អជាយ៉ាងណា ដើម្បីបង្ហាញថាលោក ប៉ុល គឺជាសាវ័ករបស់ព្រះយេស៊ូវយ៉ាងពិតប្រាកដមិនមែនជាម្នាក់ដែលបានតាំងខ្លួនឡើងជាសាវ័កនោះទេ ប៉ុន្តែគឺព្រះអង្គទេតើ ដែល

ទ្រង់បានជ្រើសរើសសាវ័ក ប៉ុល គឺជាសាវ័ក។

ព្របន្ទាប់មកសាវ័ក ប៉ុល ចង់ឲ្យពួកគេបានដឹងថា ដំណឹងល្អដ៏ខុសឆ្គងនេះគឺគ្រោះថ្នាក់ខ្លាំងណាស់ ដោយត្រង់ថា តើនរណាខ្លះដែលអាចនឹងជំពប់ជើងដួលចំពោះដំណឹងល្អដ៏ខុសឆ្គងនេះបាន? បន្ទាប់មកសាវ័ក ប៉ុល ក៏បានលើកឡើងអំពីសាវ័ក ពេត្រុស និងលោក បាណាបាស ដែលពួកគេបានជំពប់នៅចំពោះគ្រូក្លែងក្លាយ។ សូម្បីតែសាវ័ក និងគ្រូគង្វាល ក៏អាចទទួលឥទ្ធិពលមកពីគ្រូក្លែងក្លាយដែរ ដូច្នេះយើងទាំងអស់គ្នាត្រូវប្រុងប្រយ័ត្ន។ ដូច្នេះ នៅក្នុងកណ្ឌគម្ពីរ កាឡាទី ២:១១ បានចែងថា *“ប៉ុន្តែ កាលលោកពេត្រុសបានមកដល់អាន់ទីយ៉ូក នោះខ្ញុំបានទាស់ទទឹងនឹងលោកនៅប្រទល់មុខ ពីព្រោះលោកគួរឲ្យបន្ទោសបាន”*។ នៅក្នុងខគម្ពីរនេះ សាវ័ក ប៉ុល កំពុងតែលើកឡើងអំពីសាវ័ក ពេត្រុស។ នៅខ១២-១៤ *“ឯពួកសាសន៍យូដាឯទៀត ក៏ធ្វើជាពើជាមួយនឹងលោកដែរ ដល់ម៉្លេះបានជាបាណាបាសត្រូវបណ្ដោយតាមអំពើកំពុតរបស់គេទៀត កាលខ្ញុំឃើញថា គេមិនដើរត្រង់តាមសេចក្ដីពិតនៃដំណឹងល្អទេ នោះខ្ញុំក៏សួរលោកពេត្រុស នៅមុខមនុស្សទាំងអស់ថា បើលោក ដែលជាសាសន៍យូដា មិនប្រព្រឹត្តតាមទំនៀមទម្លាប់របស់សាសន៍យូដាទេ គឺប្រព្រឹត្តតាមទំនៀមទម្លាប់សាសន៍ដទៃវិញ នោះហេតុអ្វីបានជាបង្ខំឲ្យសាសន៍ដទៃ ប្រព្រឹត្តដូចជាសាសន៍យូដាដូច្នេះ”*។

ប្រហែលលោកអ្នកមានចម្ងល់ថា តើខគម្ពីរនេះមានន័យយ៉ាងដូចម្ដេច? តើសាវ័កពេត្រុស កំពុងតែមានបញ្ហាអ្វីទៅ? បានសាវ័ក ប៉ុល បន្ទោសលោកយ៉ាងដូច្នេះ? គឺថាសាវ័ក ពេត្រុស និងលោក បាណាបាស បានច្នៃដំណឹងល្អដ៏ពិតនៅក្នុងការប្រព្រឹត្តរបស់ពួកគេ ពីព្រោះថា លោកទាំងពីរហ្នឹង (លោកពេត្រុស និងលោក បាណាបាស) បានយល់ច្បាស់លាស់ថា អស់អ្នកដែលបានជឿព្រះយេស៊ូវមិនចាំបាច់ចុះចូលក្នុងក្រឹត្យវិន័យនៅគ្រាសញ្ញាចាស់ទៀតទេ គឺអស់អ្នកដែលជឿលើព្រះយេស៊ូវនៅក្នុងគ្រាព្រះគុណដែលមាននៅសព្វថ្ងៃនេះ មិនចាំបាច់ត្រូវចុះចូលតាមទម្លាប់របស់សាសន៍

យូដាទៀតទេ។

ជាមួយគ្នាដែរ មានអ្នកជឿព្រះមួយចំនួននៅទីក្រុងយេរូសាឡឹមជាដើម ពួកគេចង់ឲ្យសាសន៍ដទៃដែលបានទទួលជឿលើព្រះយេស៊ូវឲ្យកាត់ស្បែកប្រសិនបើគេកើតមកជាភេទប្រុស ហើយពួកគេចុះចូលចំពោះក្រឹត្យវិន័យ ហើយបណ្តាលឲ្យពួកគេធ្វើតាមទម្លាប់របស់សាសន៍យូដា ដើម្បីអាចក្លាយជាគ្រីស្ទបរិស័ទបាន ដូច្នេះ ការធ្វើទាំងនេះ មិនមែនជាដំណឹងល្អរបស់ព្រះយេស៊ូវនោះឡើយ។ ដំណឹងល្អរបស់ព្រះយេស៊ូវដ៏ពិតគឺថាព្រះយេស៊ូវបានបំពេញក្រឹត្យវិន័យរបស់ព្រះរួចរាល់អស់ហើយ ដើម្បីអស់អ្នកណាដែលជឿលើព្រះយេស៊ូវមិនចាំបាច់ចុះចូលចំពោះក្រឹត្យវិន័យទៀតទេ ពីព្រោះថា ដំណឹងល្អនេះគឺជាសម័យនៃសេចក្តីសញ្ញាថ្មី ជាសម័យនៃព្រះគុណរបស់ព្រះហើយ។ ទោះបីជាមានអ្នកជឿព្រះយេស៊ូវមកពីសាសន៍ណាក៏ដោយ ក៏មិនចាំបាច់ត្រូវកាត់ស្បែក ក៏មិនចាំបាច់ចុះចូលក្រឹត្យវិន័យ ហើយក៏មិនចាំបាច់ធ្វើដំណើរទៅព្រះវិហារនៅក្រុងយេរូសាឡឹមដោយផ្ទាល់ដើម្បីថ្វាយបង្គំព្រះ ពោលគឺមិនចាំធ្វើការទាំងអស់នេះនោះទេ។

ប៉ុន្តែ យើងឃើញថា គួរតែសាវ័ក ពេត្រុស និងលោក បាណាបាស ពួកគាត់ទាំងពីរបានយល់ច្បាស់អំពីការនេះហើយ ផ្ទុយទៅវិញគឺនៅពេលដែលគ្រូក្លែងក្លាយបានចុះមកពីទីក្រុងយេរូសាឡឹម ដែលមើលទៅដូចជាមានឥទ្ធិពលខ្លាំង ទំនងមើលទៅដូចជាអ្នកធំ ខណៈពេលពួកគេបានមកដល់ អាន់ទីយ៉ូក ហើយសាវ័ក ពេត្រុស ដែលធ្លាប់បរិភោគអាហារជាមួយសាសន៍ដទៃ ក៏បានឃើញពួកសាសន៍យូដាមិនពេញចិត្តនឹងលោក គាត់ក៏បានត្រឡប់មករាប់ខ្លួនមកជាសាសន៍យូដាវិញ។ គឺមានន័យថា ពួកគាត់ចាប់ផ្តើមច្រឡំអំពីអត្ថន័យនៃដំណឹងល្អ ពីព្រោះថាអស់អ្នកជឿលើព្រះយេស៊ូវមិនចាំបាច់ត្រូវចុះចូលចំពោះសាសន៍យូដាទៀតនោះទេ។ ដូច្នេះ នៅពេលដែលសាវ័ក ប៉ុល បានឃើញ *«...គេមិនដើរតាមសេចក្តីពិតនៃដំណឹងល្អទេ...»* នោះសាវ័ក ប៉ុល ក៏បានស្តីបន្ទោសសាវ័ក ពេត្រុស និងលោក បាណាបាស នៅចំពោះ

មុខពួកគេភ្លាម ហើយអរគុណព្រះអង្គដែលសាវ័ក ពេត្រុស និងលោក បាណាបាស បានសារភាពហើយបែរត្រឡប់មកឯដំណឹងល្អវិញ។

ម៉្យាងវិញទៀត អរគុណព្រះ ដែលសាវ័ក ប៉ុល មានចិត្តក្លាហាន ដើម្បីស្តីបន្ទោសដល់ពួកគេទាំងពីរនាក់នោះ ទោះបីជាលោក ពេត្រុស មានឋានៈដូចគ្នាជាសាវ័កដូចសាវ័ក ប៉ុលក៏ដោយ។ តើលោកអ្នកបងប្អូនផ្ទាល់ហ៊ានស្តីបន្ទោសដល់សាវ័កពេត្រុស ទេ ប្រសិនបើ លោកអ្នកឃើញទង្វើរបស់សាវ័ក ពេត្រុស ខុសឆ្គងយ៉ាងដូច្នោះ? ដូច្នេះ សាវ័ក ប៉ុល បានស្តីបន្ទោសដល់សាវ័ក ពេត្រុស។ ព្រះវិញ្ញាណបរិសុទ្ធបានជួយយើងឲ្យច្បាស់អំពីសារៈសំខាន់នៃការស្តីបន្ទោសគ្នាទៅវិញទៅមក ប្រសិនបើវង្វេងដើរចេញពីសេចក្តីជំនឿ ឬសូម្បីតែយើងវង្វេងដើរចេញបន្តិចក៏ដោយ។

## *យើងត្រូវតែផ្សាយតែដំណឹងល្អដ៏ពិតរបស់ព្រះយេស៊ូវគ្រីស្ទប៉ុណ្ណោះ*

នៅក្នុងកណ្ឌគម្ពីរ កាឡាទី ២:១៦-២១ សាវ័ក ប៉ុល បានពន្យល់ប្រាប់អំពីសារៈសំខាន់ដែលសាវ័ក ពេត្រុស និងលោក បាណាបាស ត្រូវកែខ្លួនឡើងវិញ ពីព្រោះបើមិនដូច្នោះទេ នឹងអាចនាំអ្នកជទៃដែលជឿព្រះយេស៊ូវមានការយល់ច្រឡំអំពីដំណឹងល្អរបស់ព្រះយេស៊ូវ។ នៅក្នុងកណ្ឌគម្ពីរកាឡាទី ២:១៦ បានចែងថា *«យើងដឹងថាមនុស្សមិនបានរាប់ជាសុចរិត ដោយប្រព្រឹត្តតាមក្រឹត្យវិន័យនោះឡើយ គឺដោយសេចក្តីជំនឿ ជឿដល់ព្រះយេស៊ូវគ្រីស្ទវិញ ហេតុនោះបានជាយើងជឿដល់ព្រះគ្រីស្ទយេស៊ូវ ដើម្បីឲ្យបានរាប់ជាសុចរិត ដោយសារសេចក្តីជំនឿ ជឿដល់ព្រះគ្រីស្ទនោះ មិនមែនដោយប្រព្រឹត្តតាមក្រឹត្យវិន័យទេ ពីព្រោះគ្មានមនុស្សណាបានរាប់ជាសុចរិតដោយប្រព្រឹត្តតាមក្រឹត្យវិន័យឡើយ»*។

សូមបន្តអាននៅក្នុងកាឡាទី ២:២០-២១ *«ខ្ញុំបានជាប់ឆ្កាងជាមួយនឹងព្រះគ្រីស្ទ ប៉ុន្តែខ្ញុំរស់នៅ មិនមែនជាខ្ញុំទៀត គឺជាព្រះគ្រីស្ទទ្រង់រស់ក្នុងខ្ញុំវិញ ហើយដែលខ្ញុំរស់ក្នុងសាច់ឈាមឥឡូវនេះ នោះគឺរស់ដោយសេចក្តីជំនឿ ជឿដល់ព្រះរាជបុត្រានៃព្រះ*

*ដែលទ្រង់ស្រឡាញ់ខ្ញុំ ក៏បានប្រគល់ព្រះអង្គទ្រង់ជំនួសខ្ញុំហើយ ខ្ញុំមិនលើកព្រះគុណនៃព្រះចោលទេ ដ្បិតបើសិនជាសេចក្ដីសុចរិតមកដោយសារក្រឹត្យវិន័យ នោះព្រះគ្រីស្ទបានសុគតជាឥតប្រយោជន៍សោះ»*។

ដូច្នេះ ប្រសិនបើទាំងអស់គ្នាផ្ទៃដំណឹងល្អរបស់ព្រះយេស៊ូវទៅជាការដែលថា យើងជឿព្រះយេស៊ូវផង ហើយយើងត្រូវខំប្រព្រឹត្តតាមរបៀបសាសនាផង ដើម្បីឲ្យបានសង្គ្រោះ នោះបានន័យថា ការសុគតរបស់ព្រះយេស៊ូវនៅលើឈើឆ្កាងទៅជាឥតប្រយោជន៍សោះ ពីព្រោះព្រះយេស៊ូវបានសងថ្លៃលោះបាបរបស់យើងនៅលើឈើឆ្កាងនៅជាប់នឹងរូបអង្គទ្រង់នោះ។ ដូច្នេះ ប្រសិនបើយើងជឿព្រះយេស៊ូវហើយ បន្ទាប់មកយើងមានចេតនាបន្ថែមការផ្សេងៗ ឲ្យប្រកាន់ការនេះ ឬក៏ការនោះ ត្រូវធ្វើនេះត្រូវធ្វើនោះ ត្រូវជឿលើនេះលើនោះ ដើម្បីអាចក្លាយជាអ្នកជឿព្រះយេស៊ូវយ៉ាងពិតប្រាកដ នោះមិនមែនជាដំណឹងល្អដែលមកពីព្រះនោះទេ។ គឺអត់ទេ!។

ដូច្នេះ បើមាននរណាម្នាក់ដែលវង្វេងបែរចេញពីដំណឹងល្អដ៏ពិត នោះយើងត្រូវតែកែប្រែចិត្តហើយវិលត្រឡប់ទៅឯដំណឹងល្អដ៏ពិតវិញ យើងត្រូវនាំគាត់អធិស្ឋានលន់តួបាបទៅចំពោះព្រះ។ មួយទៀត ប្រសិនបើ លោកអ្នកបានឃើញបងប្អូនរួមជំនឿណាម្នាក់នៅក្នុងព្រះគ្រីស្ទ ដែលពួកគេកំពុងតែជឿលើដំណឹងល្អដ៏ខុសឆ្គង នោះយើងក៏ត្រូវបន្ទោសពួកគេដោយដំណឹងល្អ ហើយជំរុញឲ្យពួកគេបែរត្រឡប់មកឯដំណឹងល្អដ៏ពិតរបស់ព្រះវិញផងដែរ។

ម្យ៉ាងវិញទៀត យើងត្រូវតែបន្ទាបខ្លួនជានិច្ច ដោយដឹងខ្លួនជាមុនថា យើងផ្ទាល់ម្នាក់ៗក៏វង្វេងចេញពីដំណឹងល្អដ៏ពិតបានដែរ។ នៅក្នុងកណ្ឌគម្ពីរ ១ធីម៉ូថេ ៤:១៦ *«ចូរប្រុងប្រយ័ត្ននឹងខ្លួនអ្នក ហើយនិងសេចក្ដីបង្រៀន ចូរកាន់ខ្ជាប់តាមសេចក្ដីទាំងនេះ ដ្បិតដែលធ្វើដូច្នោះ នោះអ្នកនឹងសង្គ្រោះខ្លួនអ្នកបាន ព្រមទាំងពួកអ្នកដែលស្ដាប់អ្នកផង»*។ នេះគឺខគម្ពីរដែលសាវ័ក ប៉ុល បាននិយាយទៅកាន់លោក ធីម៉ូថេ ដែលគ្រូគង្វាល ឬជាបេសកជន។ ប្រសិនបើសាវ័ក ពេត្រុស និងលោក បាណាបាស

បាស អាចដួល នោះយើងក៏អាចធ្វើបានដែរ។ កុំស្មានថា អ្នកហួសពីការបរាជ័យនេះទេ។ ប្រសិនបើយើងបរាជ័យ យើងអាចស្វែងរកការអភ័យទោសបាន។ យើងត្រូវប្រយ័ត្នគ្នាទៅវិញទៅមក។

*តើអ្នកណាក្នុងចំណោមអ្នកដែលអះអាងថា ជឿលើព្រះយេស៊ូវគ្រីស្ទសព្វថ្ងៃនេះ បង្រៀនដំណឹងល្អមួយដ៏ខុសឆ្គង (ការលាយសាសនា ឬក៏បញ្ចូលសាសនាជាមួយគ្នា) នៅស្រុកខ្មែរយើងនេះ?*

- មានគ្រូខុសឆ្គងដែលមកពីៈ អាមេរិក (សាសនាមរមន ឬព្រះយេស៊ូវអាណាចក្រព្រះយេស៊ូវពួកបរិសុទ្ធចុងក្រោយ និងសាសនាស្មរបន្ទាល់ព្រះយេហូវ៉ា) គ្រូខុសឆ្គងសន្យាភាពចម្រុងចម្រើន ដូចជា អ្នកស្រី ចយ ម៉ាយើរ (Joyce Meyer) និងក្រុមជំនុំសាវ័កថ្មី។

- មានក្រុមខុសឆ្គងមកពីប្រទេសកូរ៉េៈ ក្រុមខុសឆ្គង អាន់ សាំង ហុង និងផ្សេងៗទៀត។

- មានក្រុមខុសឆ្គងមកពី ប្រទេស ហ្វីលីពីនៈ អាប៉ូឡូ គីបូឡូយ ដែលអះអាងថា ខ្លួនជាព្រះរាជបុត្រានៃព្រះ។

- មានក្រុមខុសឆ្គងមកពីប្រទេសចិនៈ ពួកជំនុំនៃព្រះដ៏មានអំណាចចេស្តា ឬដំណឹងល្អនៃស្ថានសួគ៌។

ប្រហែលនៅថ្ងៃអនាគតនៅស្រុកខ្មែរ និងមានក្រុមខុសឆ្គងលេចឡើងនៅក្នុងប្រទេសកម្ពុជាផងដែរ។ យើងកុំមានគំនិតស្តីបន្ទោសដល់ប្រទេសដទៃដែលនាំឲ្យគ្រូខុសឆ្គងនាំចូលមកក្នុងប្រទេសកម្ពុជា ប៉ុន្តែប្រហែលនឹងមានគ្រូខុសឆ្គងចេញពីស្រុកខ្មែរផ្ទាល់ផងដែរ។ ដូច្នេះ យើងទាំងអស់គួរតែមានការប្រុងប្រយ័ត្នជានិច្ច។

ខ្ញុំគឺជាបេសកជននៅក្នុងប្រទេសកម្ពុជា នៅពេលណាដែលខ្ញុំត្រឡប់ទៅលេងនៅ

សហរដ្ឋអាមេរិកវិញ មានគេតែងតែសួរខ្ញុំថា តើនៅស្រុកខ្មែរ តើបញ្ហាដែលលំបាកជាងគេក្នុងការធ្វើបេសកកម្មបម្រើព្រះមានអ្វីខ្លះ? ខ្ញុំចម្លើយថា បញ្ហាលំបាកមិនមែនមកពីសាសនាព្រះពុទ្ធទេ ហើយក៏មិនមែនដោយសារពួកគេថ្វាយបង្គំអារក្សអ្នកតានោះដែរ តែអ្វីដែលពិបាកជាងគេនៅបច្ចុប្បន្ននោះគឺថា គ្រូខុសឆ្គងជាច្រើនបានមកក្នុងប្រទេសកម្ពុជា ហើយបាននាំប្រជាជនកម្ពុជាឲ្យច្រឡំហើយវង្វេង។ ចំណុចនេះហើយ ដែលពិបាកបំផុតក្នុងការផ្សាយដំណឹងល្អ។

សូមមើលកណ្ឌគម្ពីរ វិវរណៈ ២២:១៨-១៩ *«ខ្ញុំធ្វើបន្ទាល់ ដល់អស់អ្នកណា ដែលឮសេចក្ដីទំនាយ ក្នុងគម្ពីរនេះថា បើអ្នកណាបញ្ចូលអ្វីក្នុងសេចក្ដីទាំងនេះ នោះព្រះទ្រង់នឹងបន្ថែមអស់ទាំងសេចក្ដីវេទនា ដែលកត់ទុកក្នុងគម្ពីរនេះ ដល់អ្នកនោះផង ហើយបើអ្នកណាដកអ្វី ពីព្រះបន្ទូលក្នុងគម្ពីរនៃសេចក្ដីទំនាយនេះចេញ នោះព្រះទ្រង់នឹងដកចំណែក ដែលអ្នកនោះមានដល់ដើមជីវិត និងទីក្រុងបរិសុទ្ធ ហើយនិងសេចក្ដីទាំងប៉ុន្មាន ដែលកត់ទុកក្នុងគម្ពីរនេះចេញដែរ»*។ ដូច្នេះ ព្រះបន្ទូលរបស់ព្រះដែលមានការព្រមាននេះគឺជាព្រះបន្ទូលដែលធ្ងន់ធ្ងរណាស់ ដូចគ្នានឹងព្រះបន្ទូលរបស់លោក ម៉ូសេ ដែលមានចែងនៅក្នុងកណ្ឌគម្ពីរចោទិយកថាផងដែរ។

សូមបងប្អូនអានកណ្ឌគម្ពីរកាឡាទី ១:៦-១០ ម្តងទៀត *«ខ្ញុំឆ្ងល់ណាស់ ពីដំណើរដែលអ្នករាល់គ្នាបានផ្លាស់ប្រែចេញពីព្រះ ដែលទ្រង់បានហៅអ្នករាល់គ្នាមក ក្នុងព្រះគុណនៃព្រះគ្រីស្ទជាឆាប់ម្ល៉េះ និងទៅតាមដំណឹងល្អផ្សេងទៀតនោះ ដែលមិនមែនជាដំណឹងល្អ១ទៀតទេ គឺមានមនុស្សខ្លះបំភាន់អ្នករាល់គ្នាវិញ ហើយចង់បង្ខូចដំណឹងល្អព្រះគ្រីស្ទផង  ប៉ុន្តែ បើយើងខ្ញុំ ឬទេវតាពីស្ថានសួគ៌ នឹងប្រាប់ដំណឹងណាមកអ្នករាល់គ្នា ខុសពីដំណឹងល្អ ដែលយើងខ្ញុំបានប្រាប់ហើយ នោះឲ្យគេត្រូវបណ្តាសាចុះ ឯសេចក្ដីដែលខ្ញុំទើបនឹងនិយាយអម្បាញ់មិញនេះ នោះខ្ញុំនិយាយម្តងទៀតថា បើអ្នកណាប្រាប់ដំណឹងណា ខុសអំពីដំណឹងល្អ ដែលអ្នករាល់គ្នាបានទទួលហើយ នោះឲ្យគេត្រូវបណ្តាសាចុះ ដ្បិតតើខ្ញុំរកបញ្ចុះបញ្ចូលអ្នកណា តើជាមនុស្ស ឬព្រះ*

*ឬចង់បំពេញចិត្តមនុស្សឬអី បើសិនជាខ្ញុំចង់បំពេញចិត្តមនុស្ស នោះខ្ញុំមិនមែនជាបាវបម្រើរបស់ព្រះគ្រីស្ទទេ»។*

*ការការពារដំណឹងល្អគឺធ្ងន់ធ្ងរណាស់ ដំណឹងល្អមិនពិត ថ្កោលទោសមនុស្សទៅនរក!*

បងប្អូនអើយ! ប្រសិនបើយើងជឿលើដំណឹងល្អមិនពិតគឺយើងនឹងធ្លាក់ស្ថាននរកហើយ។ តើលោកអ្នកនឹងមានអារម្មណ៍យ៉ាងដូចម្ដេចចំពោះដំណឹងល្អមិនពិត? យើងត្រូវមានចិត្តអាណិតអាសូរដល់អស់អ្នកដែលត្រូវបានគេបោកបញ្ឆោតដែរ យើងត្រូវព្យាយាមជួយពួកគេឲ្យយល់ពីដំណឹងល្អដ៏ពិត ដើម្បីសង្គ្រោះពួកគេពីសេចក្ដីស្លាប់អស់កល្បជានិច្ច។ ជាការពិតណាស់ យើងក៏ត្រូវតែផ្សាយដំណឹងល្អទៅដល់អស់អ្នកដែលបានធ្លាប់ចូលរួមជាមួយក្រុមខុសឆ្គងនានា ដូច្នេះហើយយើងទាំងអស់គ្នាក៏ត្រូវការប្រាប់ និងពន្យល់ ឬបង្រៀនពួកគេអំពីសេចក្ដីពិតនៃព្រះគម្ពីរជាច្រើនផងដែរ ពីព្រោះក៏បានទទួលយកការបង្រៀនមិនត្រឹមត្រូវជាច្រើន។ ការនេះមិនមែនជារឿងស្រួលនោះទេ ប៉ុន្តែយើងទាំងអស់គ្នាត្រូវក្លាហាន ហើយមានចិត្តអាណិតអាសូរដល់ពួកគេផងដែរ។

តាមរយៈព្រះវិញ្ញាណបរិសុទ្ធក្នុងកណ្ឌគម្ពីរយ៉ាកុប ព្រះអង្គសព្វព្រះហឫទ័យដល់កូនៗរបស់ព្រះអង្គដែលចង់ការពារដំណឹងល្អរបស់ព្រះគ្រីស្ទឲ្យបន្តស្មោះត្រង់ក្នុងដំណឹងល្អរបស់ព្រះគ្រីស្ទជានិច្ច។ ព្រះអង្គសព្វព្រះហឫទ័យដល់យើងទាំងអស់គ្នាឲ្យមានចិត្តអាណិតអាសូរ ឲ្យក្លាហាន និងឧស្សាហ៍ដាស់តឿនដល់អស់អ្នកណាដែលជឿតាម ឬលង់តាមគ្រូខុសឆ្គង សេចក្ដីបង្រៀនខុសឆ្គងនានា ដើម្បីឲ្យពួកគេឲ្យបែរត្រឡប់មករកឯដំណឹងល្អដ៏ពិត និងសេចក្ដីបង្រៀនដ៏ត្រឹមត្រូវរបស់ព្រះវិញ ដើម្បីបានការសង្គ្រោះ។

កណ្ឌគម្ពីរ យ៉ាកុប ៥:១៩-២០ បានចែងថា *«បងប្អូនអើយ បើមានអ្នកណាក្នុងពួកអ្នករាល់គ្នា គេវង្វេងចេញពីសេចក្តីពិត ហើយមានអ្នកណានាំអ្នកនោះត្រឡប់មកវិញ នោះត្រូវដឹងថា អ្នកណាដែលនាំមនុស្សបាប ឲ្យត្រឡប់ពីផ្លូវវង្វេងមកវិញ នោះឈ្មោះថា បានជួយសង្គ្រោះព្រលឹង១ ឲ្យរួចពីសេចក្តីស្លាប់ ហើយក៏គ្របបាំងអំពើបាបជាអនេកអនន្តផង»*។

# សេចក្តីស្រឡាញ់

និពន្ធដោយ៖ លោកគ្រូ លឹម ម៉ៅ

«ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម្ល៉េះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ ពីព្រោះព្រះទ្រង់មិនបានចាត់ព្រះរាជបុត្រាទ្រង់ ឲ្យមកក្នុងលោកីយ៍ ដើម្បីនឹងជំនុំជំរះលោកីយ៍នោះទេ គឺឲ្យលោកីយ៍បានសង្គ្រោះ ដោយសារទ្រង់វិញ ឯអ្នកណាដែលជឿដល់ទ្រង់ នោះមិនជាប់មានទោសទេ តែអ្នកណាដែលមិនជឿវិញ នោះត្រូវមានទោសហើយ ពីព្រោះមិនបានជឿដល់ព្រះនាមនៃព្រះរាជបុត្រាតែ១របស់ព្រះ ហើយទោសនេះ គឺថាពន្លឺបានមកក្នុងលោកីយ៍ តែមនុស្សលោកចូលចិត្តនឹងសេចក្តីងងឹតជាជាងពន្លឺ ពីព្រោះអំពើដែលគេធ្វើទាំងប៉ុន្មាន សុទ្ធតែអាក្រក់ ដ្បិតអ្នកណាដែលប្រព្រឹត្តអាក្រក់ នោះតែងស្អប់ដល់ពន្លឺ ហើយមិនមកឯពន្លឺទេ ក្រែងអំពើដែលខ្លួនប្រព្រឹត្តទាំងប៉ុន្មាន បានបើកឲ្យឃើញ តែអ្នកណាដែលប្រព្រឹត្តតាមសេចក្តីពិតវិញ នោះតែងមកឯពន្លឺ ដើម្បីឲ្យអំពើដែលខ្លួនប្រព្រឹត្ត បានសម្តែងមកឲ្យដឹងថា បានធ្វើដោយនូវព្រះ» (យ៉ូហាន ៣:១៦-២១)។

ក្នុងជំពូកនេះ ខ្ញុំចង់ចែករំលែកជាមួយបងប្អូនអំពីដំណឹងល្អ ហើយគឺសម្រាប់ទាំងអស់គ្នា និងរូបខ្ញុំផ្ទាល់ផងដែរ។ ហើយមានតែដំណឹងល្អរបស់អង្គព្រះយេស៊ូវគ្រីស្ទតែមួយគត់ ទើបអាចរំដោះមនុស្សទាំងអស់ឲ្យមានសេរីភាពចេញពីអំណាចនៃអំពើបាបបាន។ ឥឡូវនេះ សូមយើងមើលនៅក្នុងខ.១៦ នៃកណ្ឌគម្ពីរដំណឹងល្អយ៉ូហាន តាមរយៈខគម្ពីរនេះ ខ្ញុំជឿថាសូម្បីតែអ្នកជឿថ្មីក៏ចងចាំខនេះមុនគេដែរ រួមទាំងអស់លោកអ្នកបងប្អូន និងខ្ញុំដែលចងចាំហើយស្រឡាញ់បំផុត ជាព្រះបន្ទូលរបស់ព្រះ

ដែលយើងព្វមុនគេហើយចាប់ចិត្តមុនគេផងដែរ។

ទីមួយ ខ្ញុំចង់ឲ្យបងប្អូនទាំងអស់ពិចារណាជាមួយគ្នា អំពីសេចក្តីស្រឡាញ់នៅក្នុងព្រះបន្ទូលព្រះអង្គដែលចែងថា "ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក..." នៅពេលដែលយើងនិយាយដល់សេចក្តីស្រឡាញ់ តើយើងគិតអំពីអ្វីមុនគេ? តើយើងគិតថាខ្ញុំជាអ្នកទទួលឬចែកសេចក្តីស្រឡាញ់ ឬក៏យើងមើលអ្វីៗទាំងអស់នៅក្នុងសេចក្តីស្រឡាញ់? នៅពេលដែលយើងមើលអំពីសេចក្តីស្រឡាញ់ យើងអាចឲ្យនិយមន័យទៅតាមបរិបទជាក់ស្តែង ក៏ប៉ុន្តែ នៅពេលដែលយើងនិយាយថា អ្វីទៅជាសេចក្តីស្រឡាញ់? ទីមួយ សេចក្តីស្រឡាញ់ដ៏ពិត ហើយជាតួនៃសេចក្តីស្រឡាញ់នោះ គឺជាព្រះ។ ប្រហែលជាយើងងាយនឹងទទួលយកតួនៃសេចក្តីស្រឡាញ់ ហើយនិងអង្គនៃសេចក្តីស្រឡាញ់ពិតមែន ពីព្រោះគ្មានសេចក្តីស្រឡាញ់ណាដែលធំ ហើយគ្មានសេចក្តីស្រឡាញ់ណាមួយអាចប្រៀបប្រដូចនឹងព្រះបានទេ ប្រសិនបើយើងយកអ្វីមួយដែលយើងយល់នៅលើផែនដី យកគំនិតដែលយើងគិតនេះទៅផ្ទឹមនឹងសេចក្តីស្រឡាញ់របស់ព្រះ នោះគឺមិនអាចប្រៀបផ្ទឹមបានឡើយ ពីព្រោះក្តីស្រឡាញ់របស់ព្រះគឺបរិបូរ គ្រប់លក្ខណ៍ ហើយគ្មានសេចក្តីបោកបញ្ឆោត ឬពុតមាយាណាមួយនៅក្នុងព្រះដែលជាតួនៃសេចក្តីស្រឡាញ់នោះឡើយ។ នៅពេលដែលយើងនិយាយអំពីក្តីស្រឡាញ់ដ៏បរិបូរ និងគ្រប់លក្ខណ៍របស់ព្រះ ព្រះអង្គមិនត្រូវការទទួលយកសេចក្តីស្រឡាញ់ពីអ្វីមួយដែលនៅខាងក្រៅ ប្រហែលជាយើងត្រូវការសេចក្តីស្រឡាញ់អំពីអ្នកដែលនៅជុំវិញខ្លួនយើង។ ប្រហែលជាយើងត្រូវការ ការលើកទឹកចិត្ត ជំនួយ ឬការគាំទ្រពីអ្នកដែលនៅជុំវិញខ្លួនយើង មិនថាជាអ្នកដែលនៅជិតខ្លួនយើងបំផុត ឬនៅឆ្ងាយពីយើងនោះទេ គឺយើងត្រូវការអ្នកទាំងអស់នោះ។

ប៉ុន្តែ ព្រះអង្គស្កប់ស្កល់ និងបរិបូរនៅក្នុងសិរីល្អនៃសេចក្តីស្រឡាញ់របស់ព្រះអង្គហើយ ទ្រង់មិនត្រូវការយើងទេ។ ទ្រង់មិនត្រូវការនរណាម្នាក់ឲ្យជួយបន្ថែមសេចក្តីស្រឡាញ់ដល់ព្រះអង្គទេ ទ្រង់មានគ្រប់គ្រាន់ហើយ ពោលគឺព្រះអង្គក៏មិនត្រូវការ

ឲ្យនរណាម្នាក់ស្រឡាញ់ព្រះអង្គ ដើម្បីឲ្យសេចក្តីស្រឡាញ់របស់ព្រះអង្គបានបរិបូរច្រើនជាងមុននោះដែរ។ ហេតុអ្វី? ព្រះអង្គមិនត្រូវការអ្នកដទៃឲ្យសេចក្ដីស្រឡាញ់អង្គទ្រង់ ដូចជាព្រះអង្គទ្រង់ស្រឡាញ់ដោយអង្គទ្រង់ទេ ហើយនេះគឺអាថ៌កំបាំងមួយដែលទ្រង់បានបង្រៀនដល់យើងទាំងអស់គ្នាថា «ឲ្យស្រឡាញ់ព្រះឲ្យអស់ពីចិត្ត ហើយស្រឡាញ់អ្នកដទៃឲ្យដូចជាខ្លួនឯង» នេះគឺជាអាថ៌កំបាំងមួយដែលព្រះអង្គប្រាប់ថា ទ្រង់គឺជាព្រះ ទ្រង់ស្រឡាញ់ព្រះអង្គទ្រង់ផ្ទាល់។ នេះគឺជាអាថ៌កំបាំងមួយដែលព្រះអង្គប្រាប់ថា សេចក្ដីស្រឡាញ់ដ៏បរិបូរ គឺសេចក្ដីស្រឡាញ់ដ៏បរិសុទ្ធឥតពុតមាយា ជាសេចក្ដីស្រឡាញ់ដែលឥតមានអាថ៌កំបាំងអ្វីមួយដែលបង្កប់អត្ថន័យអាក្រក់នៅទីនោះ តែជាសេចក្ដីស្រឡាញ់ដ៏បរិបូរហើយគ្រប់លក្ខណ៍។

ជាមួយគ្នានេះដែរ ព្រះបន្ទូលទ្រង់បានប្រាប់ថា «ព្រះទ្រង់ស្រឡាញ់ដល់មនុស្សលោក» តើសេចក្ដីស្រឡាញ់ដែលព្រះអង្គមានបន្ទូលនេះ មានកម្រិត ឬដែនកំណត់នៅត្រឹមជាតិសាសន៍ណាមួយឬទេ? ឧទាហរណ៍៖ នៅក្នុងការសន្ទនារវាងព្រះយេស៊ូវ និងលោក នីកូដេម នៅក្នុងកណ្ឌគម្ពីរយ៉ូហានជំពូក៣នេះ តើព្រះយេស៊ូវកំពុងមានបន្ទូលទៅកាន់ នីកូដេម ថាព្រះអង្គស្រឡាញ់មនុស្សលោកនេះ គឺសំដៅទៅលើជនជាតិមួយដែលជាពូជខាងសាច់ឈាមរបស់លោកអ័ប្រាហាំឬយ៉ាងណា? ព្រះបន្ទូលព្រះអង្គបានប្រាប់យើងថា ព្រះអង្គស្រឡាញ់មនុស្សលោកដោយឥតលំអៀង ជាក្តីស្រឡាញ់ដល់មនុស្សគ្រប់គ្នា ពីព្រោះមនុស្សគ្រប់គ្នាមិនថាជាតិសាសន៍អ្វី។ គ្រប់គ្នាជាស្នាព្រះហស្តដែលព្រះអង្គបានបង្កើតមកនៅក្នុងសេចក្ដីស្រឡាញ់របស់ទ្រង់ ហើយព្រះអង្គផ្សាយសេចក្ដីស្រឡាញ់របស់ទ្រង់ទៅកាន់មនុស្សគ្រប់ជាតិសាសន៍។ ប៉ុន្តែ ព្រះអង្គផ្សាយសេចក្ដីស្រឡាញ់របស់ទ្រង់ដល់មនុស្សគ្រប់គ្នា តើមានមនុស្សប៉ុន្មាននាក់ដែលអាចនឹងទទួលបាននូវសេចក្ដីស្រឡាញ់ដ៏គ្រប់លក្ខណ៍របស់ព្រះបាន តើប៉ុន្មាននាក់ដែលយល់អំពីសេចក្ដីស្រឡាញ់ដែលព្រះបានមានបន្ទូលប្រាប់ថា «ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់ម្ល៉េះ...»។ អស់អ្នកដែលបាន

ពុំដំណឹងល្អដែលប្រកាសថាព្រះទ្រង់ស្រឡាញ់អ្នក នៅពេលអ្នក ឬនរណាម្នាក់ផ្សាយដំណឹងល្អទៅកាន់គេ តើមានប៉ុន្មាននាក់ដែលនឹងឆ្លើយតប ហើយទទួលយកសេចក្តីស្រឡាញ់ដែលប្រាប់ថាទ្រង់ស្រឡាញ់អ្នកបាន? នៅពេលដែលយើងនិយាយពីសេចក្តីស្រឡាញ់របស់ព្រះ គឺព្រះអង្គស្រឡាញ់ដល់មនុស្សគ្រប់គ្នា ប៉ុន្តែបើសិនជាយើងនិយាយពីការឆ្លើយតបទៅនឹងសេចក្តីស្រឡាញ់វិញ គឺមិនមែនគ្រប់គ្នាសុទ្ធតែឆ្លើយតបទៅនឹងសេចក្តីស្រឡាញ់របស់ផងព្រះបានទេ។

នៅក្នុងការជីកកកាយអាថ៌កំបាំងយើងស្វែងយល់នៅក្នុងសេចក្តីជំនឿដ៏បរិសុទ្ធរបស់យើងដែលជាជំនឿទៅតាមបទគម្ពីរ។ ត្រឡប់មកវិញនៅពេលដែលយើងនិយាយអំពីសេចក្តីស្រឡាញ់របស់ព្រះ គឺព្រះទ្រង់ស្រឡាញ់មនុស្សលោក។ យើងអាចឃើញសេចក្តីសុចរិតរបស់ព្រះ សេចក្តីស្រឡាញ់របស់ព្រះដែលទ្រង់បានប្រទានឲ្យ៖ «ដើម្បីឲ្យបានធ្វើជាកូនរបស់ព្រះវរបិតានៃអ្នករាល់គ្នា ដែលគង់នៅស្ថានសួគ៌ ព្រោះទ្រង់ធ្វើឲ្យថ្ងៃរបស់ទ្រង់រះឡើង បំភ្លឺទាំងមនុស្សអាក្រក់នឹងមនុស្សល្អ ហើយទ្រង់បង្អុរឲ្យភ្លៀងធ្លាក់មក លើទាំងមនុស្សសុចរិត នឹងមនុស្សទុច្ចរិតផង» (ម៉ាថាយ ៥:៤៥)។ យើងឃើញថា មនុស្សទាំងអស់សុទ្ធតែទទួលបាននូវសេចក្តីស្រឡាញ់ព្រះគុណរបស់ព្រះ។

ប៉ុន្តែ នៅពេលដែលយើងនិយាយថា តើមានប៉ុន្មាននាក់ដែលទទួលបានទាំងអស់នោះដូចជា ការការពារពីព្រះ ទទួលបានព្រះគុណពីព្រះ សេចក្តីមេត្តាករុណាពីព្រះ ដូចដែលយើងបានឃើញនៅក្នុងព្រះគម្ពីរកិច្ចការ ១៧:២៨ នៅពេលដែលសាវ័ក ប៉ុល បានប្រកាសដំណឹងល្អ «ដ្បិតគឺដោយសារទ្រង់ហើយ ដែលយើងរាល់គ្នាបានរស់ កំរើក ហើយមាននៅផង ដូចជាពួកអ្នកលើកកំណាព្យខ្លះរបស់អ្នករាល់គ្នា បាននិយាយដែរថា "មនុស្សយើងជាពូជព្រះដែរ" (កិច្ចការ ១៧:២៨)។ ដោយនូវសេចក្តីស្រឡាញ់របស់ផងទ្រង់ ព្រះអង្គបានអនុញ្ញាតឲ្យកើតឡើង ហើយព្រះអង្គបានប្រទាន ដោយផ្សាយព្រះគុណ សេចក្តីមេត្តាករុណា សេចក្តីស្រឡាញ់របស់

ផងព្រះអង្គដែលមនុស្សយើងមិនអាចនឹងពណ៌នាបាន។

យើងអាចយល់បានមួយផ្នែកទៅតាមកម្រិតនៃការយល់ដឹងរបស់យើង តែយើងមិនអាចយល់ពីសេចក្តីស្រឡាញ់ដ៏បរិបូររបស់ព្រះបានទេ។ តើនរណាដែលអាចឆ្លើយតប យល់អំពីសេចក្តីស្រឡាញ់របស់ផងព្រះអង្គហើយជឿជាក់ ទទួលស្គាល់ថា ព្រះទ្រង់ជាតួនៃសេចក្តីស្រឡាញ់នោះ ហើយព្រះអង្គកំពុងតែស្រឡាញ់ខ្ញុំជាខ្លាំង។ នេះជាចំណុចមួយដែលយើងរៀនបាន ហើយមិនមែនទើបតែឥឡូវនេះទេ ក៏ប៉ុន្តែសំណួរដដែលនេះកើតឡើងដដែលៗដែលសួរអំពីសេចក្តីស្រឡាញ់ដ៏សុចរិតរបស់ព្រះ។ នៅពេលខ្លះមនុស្សយើងអាចយល់ថា យើងល្អវិសេសជាងព្រះហើយចោទប្រកាន់បើសិនជា ព្រះទ្រង់ស្រឡាញ់តែអ្នកនេះហើយស្អប់អ្នកនោះ ព្រះមិនសុចរិត។

ហេតុនេះហើយបានជារហូតមកដល់ពេលនេះ យើងមើលពីសេចក្តីបង្រៀនដែលយើងហៅថា «ដំណឹងល្អដ៏ពិត»។ ពេលខ្លះយើងអាចមានការយល់ច្រឡំថា យើងល្អវិសេសជាងព្រះ ឆ្លាត ហើយចោទប្រកាន់ព្រះ ហើយយើងបានថ្កោលទោសព្រះថាទ្រង់ធ្វើនេះមិនត្រឹមត្រូវទេ ព្រះអង្គលំអៀង។ ប៉ុន្តែសូមឲ្យយើងមើលពីអ្វីដែលព្រះទ្រង់បានប្រទាន ព្រះទ្រង់ជាតួនៃសេចក្តីស្រឡាញ់ ហើយព្រះអង្គបានផ្សាយសេចក្តីស្រឡាញ់ហើយព្រះអង្គបង្ហាញគ្រប់ទាំងសេចក្តីមេត្តាករុណារបស់ផងព្រះអង្គដោយឥតលំអៀង។ បញ្ហាគឺថា តើនរណាក្រោយពេលដែលទទួលបានពន្លឺថ្ងៃតែមួយ រស់នៅលើផែនដីតែមួយដូចមនុស្សដទៃទៀតដែរ តើនរណាខ្លះដែលឆ្លើយតបទៅនឹងសេចក្តីស្រឡាញ់របស់ផងព្រះអង្គហើយឆ្លើយថា អាម៉ែន! ព្រះគឺជាព្រះពិត ឥតមានព្រះឯណាទៀតដែលមានពេញដោយក្តីស្រឡាញ់ គ្មានព្រះណាទៀតដែលស័ក្តិសមឲ្យយើងគោរពថ្វាយបង្គំក្រៅពីព្រះអង្គសង្គ្រោះមួយអង្គឡើយ។

យើងមើលបន្តនៅក្នុងព្រះបន្ទូលបានចែងនៅក្នុងខ១៦នេះដដែល ដែលបានប្រាប់ថា «ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់ម៉្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១...» មកដល់ត្រឹមនេះយើងដឹងយ៉ាងច្បាស់ថា ព្រះរាជបុត្រាទ្រង់តែមួយរបស់

ព្រះអង្គនោះគឺមានព្រះនាមព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះតែមួយ ដែលគង់នៅជាមួយព្រះវរបិតាតាំងពីអស់កល្បរៀងមក។ ទីមួយ ដែលខ្ញុំបានចែករំលែកជាមួយបងប្អូនគឺថាព្រះជាតួនៃសេចក្តីស្រឡាញ់ ហើយព្រះអង្គមិនត្រូវការអ្វីខាងក្រៅឲ្យស្រឡាញ់អង្គទ្រង់ ឬមកបំពេញនូវសេចក្តីស្រឡាញ់របស់ផងព្រះអង្គនោះទេ។

ទ្រង់គឺជាព្រះដែលគង់នៅតាំងពីអស់កល្ប ជាព្រះរាជបុត្រាដែលគង់នៅជាមួយព្រះវរបិតាតាំងពីអស់កល្បរហូតមក។ ព្រះអង្គគឺជាព្រះដែលគ្មានការចាប់ផ្តើម ហើយជាព្រះដែលមិនមានបង្កើតព្រះណាផ្សេងទៀតឡើយ។ ប៉ុន្តែនៅក្នុងព្រះគម្ពីរដែលជាព្រះបន្ទូលនៃសេចក្តីពិតបានប្រាប់យើងថា ព្រះអង្គដ៏ជាព្រះរាជបុត្រានៃព្រះទ្រង់មានព្រះវត្តមានតាំងពីបំផុតកល្បមក ដែលគង់នៅជាមួយនឹងព្រះវរបិតា ដែលព្រះគម្ពីរម៉ាថាយបានប្រាប់យើងថា ព្រះរាជបុត្រាបានគង់ក្នុងឱរានៃព្រះរាជបុត្រា ព្រះអង្គបានយាងមកពីព្រះវរបិតាហើយព្រះរាជបុត្រាដែលគង់ក្នុងឱរានៃព្រះរាជបុត្រានេះគឺមានព្រះនាមថា ព្រះយេស៊ូវ។ ហើយនេះព្រះអង្គបានបង្ហាញប្រាប់យើងនៅក្នុងរូបភាពមួយកាន់តែច្បាស់ថែមទៀតថា ព្រះអង្គគឺជាតួនៃសេចក្តីស្រឡាញ់ហើយព្រះអង្គកំពុងតែផ្សាយនូវសេចក្តីស្រឡាញ់ដល់មនុស្សគ្រប់ជាតិសាសន៍តាមរយៈដំណឹងល្អតែមួយដែលនាំឲ្យមនុស្សគ្រប់ជាតិសាសន៍ទទួលបាននូវសេចក្តីសង្គ្រោះដ៏ពិតប្រាកដ ហើយព្រះនាមព្រះរាជបុត្រាដែលនាំឲ្យមនុស្សគ្រប់ជាតិសាសន៍ទទួលបាននូវសេចក្តីសង្គ្រោះដ៏ពិតប្រាកដនោះគឺមានព្រះនាមថា ព្រះយេស៊ូវគ្រីស្ទ។

ព្រះអង្គជាព្រះរាជបុត្រាតែមួយនៃព្រះតាំងពីអស់កល្បមក។ ប្រហែលជាមានដំណឹងល្អមួយផ្សេងទៀតបានប្រាប់ថាព្រះយេស៊ូវគ្រីស្ទបានចាប់ផ្តើមព្រះវត្តមានក្លាយជាព្រះពីពេលណាមួយ  ឬបើសិនជាយើងមើលត្រឡប់ក្រោយទៅសតវត្សទី៤ អំពីជម្លោះរវាងលោក អេរៀន (Arius) ហើយនិងលោក និងអ័ធាណាសីស៍ (Athanasius) យើងឃើញមានទាក់ទងអំពីព្រះវត្តមានអង្គព្រះយេស៊ូវគ្រីស្ទ ព្រះវត្តមាននៃព្រះរាជបុត្រា លោក អេរៀន បង្រៀនថាព្រះរាជបុត្រា ព្រះយេស៊ូវគ្រីស្ទគឺត្រូវ

បានបង្កើត។ នេះជាដំណឹងល្អមួយផ្សេងទៀត បើកាលណាព្រះយេស៊ូវគ្រីស្ទត្រូវបានបង្កើតពីពេលណាមួយ ព្រះយេស៊ូវមិនមែនជាព្រះទេពីព្រោះព្រះនោះត្រូវបានបង្កើត។ ប្រសិនបើព្រះត្រូវបានបង្កើតដោយព្រះណាមួយផ្សេងទៀតនោះមិនមែនជាដំណឹងល្អពិតទេ ហើយព្រះយេស៊ូវគ្រីស្ទដែលបានបង្កើតនោះក៏មិនមែនជាព្រះដែរ។ ហេតុដូច្នេះហើយ បានជាយើងជាអ្នកបម្រើព្រះអង្គ យើងជាអ្នកស្គាល់សេចក្តីពិត យើងជាអ្នកដែលរស់នៅក្នុងសេចក្តីពិត ត្រូវឲ្យយើងបានកាន់តាមកាន់តែស៊ីជម្រៅក្នុងសេចក្តីពិតហើយបានក្រោកឈរឡើងក្នុងដំណឹងល្អ ប្រកាសដំណឹងល្អ។

ហេតុអ្វីបានជាយើងត្រូវការការពារដំណឹងល្អ? ពីព្រោះមានតែដំណឹងល្អដ៏ពិតតែមួយគត់ក្នុងអង្គព្រះយេស៊ូវគ្រីស្ទ ហើយជាព្រះយេស៊ូវគ្រីស្ទដែលមិនមែនត្រូវបានបង្កើត ក៏ប៉ុន្តែព្រះអង្គគឺជាព្រះដែលគង់នៅតាំងពីអស់កល្បរៀងមក ព្រះអង្គជាព្រះរាជបុត្រាតាំងពីបំផុតអស់កល្បមក គ្មានព្រះមួយណាបង្កើតឲ្យមានព្រះវត្តមានអង្គព្រះយេស៊ូវគ្រីស្ទទេ គឺទ្រង់ជាព្រះតាំងពីអស់កល្ប។ កណ្ឌគម្ពីរ រ៉ូម ៥:៨ បានប្រាប់ថា «តែឯព្រះ ទ្រង់សម្តែងសេចក្តីស្រឡាញ់របស់ទ្រង់ ដល់យើងរាល់គ្នាឲ្យឃើញច្បាស់ ដោយព្រះគ្រីស្ទបានសុគតជំនួសយើងរាល់គ្នា នោះគឺក្នុងកាលដែលយើងនៅមានបាបនៅឡើយផង»។ ព្រះអង្គបានបង្ហាញ បានផ្សាយសេចក្តីស្រឡាញ់របស់ផងទ្រង់ហើយព្រះអង្គកំពុងតែប្រទាននូវសេចក្តីស្រឡាញ់របស់ផងទ្រង់ដល់យើងទាំងអស់គ្នាតាមរយៈការសុគតជំនួសបាបរបស់យើងរាល់គ្នា។

នៅពេលដែលយើងឮដំណឹងល្អហើយយើងឃើញថាដំណឹងល្អអាចជួយខ្ញុំបាន យើងត្រូវតែកែប្រែចិត្តទទួលយកដំណឹងល្អ  តើព្រះអង្គចាប់ផ្តើមទតមើលហើយស្រឡាញ់យើងនៅពេលនេះឬនៅពេលណា? គឺព្រះអង្គស្រឡាញ់យើងទាំងអស់គ្នាតាំងពីមិនទាន់មានវត្តមានយើងនៅលើផែនដីមកម៉្លេះ គឺព្រះអង្គបានស្រឡាញ់យើងជាមុនដោយគ្មានលក្ខខណ្ឌ។ ទ្រង់ស្រឡាញ់តាំងពីយើងនៅជាមនុស្សមានបាបនៅឡើយ មិនមែនចាំរហូតដល់យើងធ្វើឲ្យស័ក្តិសមឲ្យទ្រង់ស្រឡាញ់នោះទេ

បើសិនដូច្នេះ នោះមិនមែនជាសេចក្តីស្រឡាញ់ដ៏ពិតនោះទេ។ មានព្រះវិហារជាច្រើន បានចាប់ផ្តើមបង្វែរដំណឹងល្អចេញពីព្រះគុណរបស់ផងព្រះ ឲ្យមនុស្សរស់នៅបែបជាសាសនា គឺព្យាយាមធ្វើល្អរស់នៅសម្រាប់តែខ្លួនឯង ព្យាយាមធ្វើល្អដើម្បីទទួលបានអ្វីមួយដែលកើតចេញពីទង្វើ (ធ្វើល្អបានល្អ) នេះគឺមានន័យថាគេកំពុងតែបង្វែរសេចក្តីបង្រៀនឲ្យចេញពីគ្រឹះនៃដំណឹងល្អ។ សេចក្តីស្រឡាញ់ដែលព្រះបានប្រទានដល់យើង ប្រហែលជាយើងគិតថា យើងជាមនុស្សដែលធ្វើល្អហើយស័ក្តិសមឲ្យព្រះទ្រង់ស្រឡាញ់យើងនោះទេ។

អ្វីដែលព្រះទតមើលឃើញក្នុងយើងមានតែម៉្យាងគត់គឺអំពើបាបហើយដោយសារតែអំពើបាបនៅក្នុងខ្លួនយើងរាល់គ្នា ហើយនៅពេលព្រះអង្គទតទ្រង់ក្រោធដោយសារគ្រប់ទាំងទង្វើរបស់មនុស្ស ហើយគ្រប់គ្នាបានបែរចេញពីសេចក្តីពិត បែរចេញទៅតាមផ្លូវរបស់ខ្លួន។ ព្រះគម្ពីរសុភាសិតបានចែងថា “មនុស្សនឹងបានស្កប់ចិត្តនឹងសេចក្តីល្អ ដោយសារផលដែលកើតពីមាត់ខ្លួន ហើយកិច្ចការដែលដៃមនុស្សធ្វើ នោះនឹងបានសងដល់អ្នកនោះវិញ (សុភាសិត ១២:១៤)។ ក៏ប៉ុន្តែកណ្ឌគម្ពីរ សុភាសិត ១៤:១២ បានចែងថា “មានផ្លូវមួយដែលមើលទៅដូចជាត្រឹមត្រូវល្អ ដល់មនុស្ស តែចុងបំផុតនៃផ្លូវនោះ គឺជាសេចក្តីស្លាប់វិញ”។ ប៉ុន្តែ មនុស្សទាំងអស់គេមិនចូលចិត្តស្តាប់នូវអ្វីដែលជាសេចក្តីពិត អ្វីដែលជាដំណឹងល្អនៃសេចក្តីពិត ពីព្រោះសេចក្តីពិតធ្វើឲ្យគេពិបាកស្តាប់។

ហេតុអ្វីបានជាមនុស្សទៅប្រព្រឹត្តនូវការមិនល្អដែលយើងរាប់ថាជាផលផ្លែនៃអំពើបាប គឺដោយសារតែខាងក្នុងបានខូចទៅហើយគឺខូចតាំងពីអ័ដាមដែលជាឪពុករបស់យើងគាត់បានប្រព្រឹត្តរំលងនឹងព្រះ ហើយបាននាំសេចក្តីខូចអាក្រក់នោះមកឲ្យយើងរាល់គ្នា ហើយយើងរាល់គ្នាបានកើតនៅក្នុងអំពើរំលងរបស់គាត់។ ដោយសារតែអំពើរំលងរបស់មនុស្សដំបូងតែមួយគត់បាននាំឲ្យយើងមានសមត្ថភាពបង្កើតនូវអំពើបាប ការរំលងជាច្រើន ហើយអំពើបាបនោះបាននាំមកនូវសេចក្តីស្លាប់ ហើយ

សេចក្តីស្លាប់បានគ្រប់គ្រងលើមនុស្សទាំងអស់ហើយមនុស្សទាំងអស់កើតមកក្នុង សេចក្តីស្លាប់។

គ្មានអំណាចណាមួយអាចរួចចេញពីសេចក្តីស្លាប់បានទេ ហើយយើងក៏មិនអាចធ្វើអ្វីមួយដែលកើតចេញពីខ្លួនឯងឲ្យរួចចេញពីសេចក្តីស្លាប់បានដែរ។ គឺស្លាប់ហើយ យើងអសមត្ថភាពហើយ យើងមិនអាចទៅចាប់យកព្រះ យើងមិនអាចបែរទៅរកជីវិតឯណាដោយខ្លួនឯង ហើយយើងមិនអាចសង់ស្ពានណាមួយដើម្បីឆ្លងទៅឯព្រះ និងដើម្បីឲ្យទទួលបានជីវិតដោយខ្លួនឯងបានឡើយ គឺយើងបានជាប់នៅក្នុងអំណាចនៃសេចក្តីស្លាប់ គឺយើងស្លាប់ហើយ នៅក្នុងកណ្ឌគម្ពីរ យ៉ូហាន ៣:១៦ ពាក្យគន្លឹះដែលយើងត្រូវពិចារណានៅកន្លែងនេះគឺ ព្រះអង្គបានប្រទានព្រះរាជបុត្រាតែមួយមកសុគតជំនួសអំពើបាបយើងរាល់គ្នា ការបញ្ជូលព្រះរាជបុត្រានោះហើយគឺបញ្ជាក់ពីសេចក្តីស្រឡាញ់របស់ទ្រង់។ ព្រះអង្គស្រឡាញ់យើងមិនមែនដោយការខិតខំប្រឹងប្រែងរបស់យើងនោះទេ។ តែទ្រង់បានស្រឡាញ់យើងទាំងយើងនៅមានបាបនៅឡើយផង។ ព្រះអង្គបានប្រាប់ពីសេចក្តីស្រឡាញ់នោះដល់អស់អ្នកណាដែលជឿដល់ព្រះរាជបុត្រានោះមិនត្រូវវិនាសឡើយ មិនមែនដោយការខិតខំប្រឹងប្រែងរបស់ខ្លួននោះឡើយ។

យើងត្រូវបានគ្រប់គ្រងដោយអំពើបាប ហើយអំពើបាបនោះឯងបាននាំឲ្យមានសេចក្តីស្លាប់ បើទោះជាយ៉ាងណាយើងនៅតែមានសេចក្តីសង្ឃឹមពីព្រះដែលបង្កើតយើងរាល់គ្នា ទ្រង់មិនបានអនុញ្ញាតឲ្យយើងត្រូវវិនាសនោះទេ។ ក៏ប៉ុន្តែព្រះអង្គបានប្រទានសេចក្តីសង្ឃឹមមួយ ហើយទ្រង់បានបង្ហាញយ៉ាងច្បាស់ សេចក្តីសង្ឃឹមនោះនៅក្នុងព្រះរាជបុត្រា គឺអង្គព្រះយេស៊ូវគ្រីស្ទ ព្រះអង្គថា អស់អ្នកណាដែលជឿដល់ព្រះរាជបុត្រានោះមិនត្រូវវិនាសឡើយ តែឲ្យមានជីវិតអស់កល្បជានិច្ចវិញ ជឿ និងមិនត្រូវវិនាសឡើយ។

ប្រហែលជាអស់លោកអ្នកបងប្អូនសួរថា ចុះបើមិនជឿវិញ? ចម្លើយនោះគឺ

សាមញ្ញ នឹងត្រូវវិនាស។ នៅក្នុងកណ្ឌគម្ពីររ៉ូម ក៏បានពណ៌នាថា មនុស្សសុចរិតគឺរស់នៅដោយសារជំនឿ។ ជំនឿគឺជាគន្លឹះមួយដែលផ្ដល់នូវសេចក្ដីសង្ឃឹមដល់មនុស្សគ្រប់គ្នា ហើយព្រះបង្ហាញនូវសេចក្ដីសុចរិតរបស់ព្រះអង្គដល់មនុស្សគ្រប់គ្នាដោយប្រើនូវអ្វីដែលទ្រង់បានឲ្យ (សេចក្ដីជំនឿ) ឆ្លើយទៅកាន់ព្រះដោយប្រើសេចក្ដីជំនឿនេះថា ដល់អស់អ្នកណាដែលជឿដល់ព្រះរាជបុត្រានោះមិនត្រូវវិនាសឡើយ តែឲ្យមានជីវិតអស់កល្បជានិច្ចវិញ។ តើមានប៉ុន្មាននាក់ដែលនឹងឆ្លើយតបទៅកាន់ព្រះដោយជំនឿ ជឿលើព្រះរាជបុត្រាព្រះអង្គ? ទ្រង់បានបង្ហាញសេចក្ដីស្រឡាញ់របស់ព្រះអង្គដោយប្រទានព្រះរាជបុត្រាផងព្រះអង្គមកសុគតជំនួសយើងរាល់គ្នាក្នុងកាលដែលយើងនៅមានបាបនៅឡើយ។

តើនរណាគេអាចឆ្លើយតបទៅកាន់ព្រះដោយការជឿបាន? មានបុគ្គលពីរនាក់ដែលយើងអាចស្គាល់ពួកគាត់ យ៉ាកុប អាមីនាស ហើយមានមនុស្សម្នាក់ទៀតនោះគឺលោក ចន ខិលវិន។ នៅពេលដែលយើងនិយាយពីព្រះវត្តមានព្រះយើងតែងចងចាំអំពីពួកគាត់។ នៅពេលដែលយើងនិយាយពីការជ្រើសរើសរបស់ព្រះយើងនិយាយពីទំនួលខុសត្រូវមនុស្សយើង ឬនិយាយពីអធិបតេយ្យភាពរបស់ព្រះគឺយើងឃើញពីបុគ្គលពីរនាក់នេះ គឺអំពីលោក យ៉ាកុប អាមីនាស និងលោក ចន ខិលវិន។ ខ្ញុំមិនចង់វែកញែកថានរណាខុស ឬត្រូវនោះទេ ក៏ប៉ុន្តែខ្ញុំចង់ឲ្យបងប្អូនពិចារណាពីសេចក្ដីពិត។

សេចក្ដីពិតទីមួយ មនុស្សយើងនៅចំពោះព្រះ នោះគឺបានស្លាប់ គ្រប់គ្នាគឺបានស្លាប់ក្នុងអំពើបាប និងអំពើរំលងរបស់ខ្លួន។ ក្នុងកណ្ឌគម្ពីរ យ៉ូហាន ៣:១៦ «...ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ តែឲ្យមានជីវិតអស់កល្បជានិច្ចវិញ»។ យើងឃើញថា ព្រះបានបង្ហាញសេចក្ដីស្រឡាញ់របស់ផងទ្រង់ដោយបានប្រទានព្រះរាជបុត្រាទ្រង់តែមួយឲ្យមកសុគត ដើម្បីឲ្យយើងទទួលបាននូវជីវិតចេញពីសេចក្ដីស្លាប់ដ៏អស់កល្បជានិច្ច។ នៅក្នុងសេចក្ដីពិតទី១នេះឯង គឺ

មនុស្សយើងនៅក្នុងអំពើបាប ពេញទៅដោយសេចក្ដីពុករលួយយើងអសមត្ថភាព។ តើយើងអាចមានសមត្ថភាពទទួលជឿលើព្រះដោយខ្លួនឯងដោយគ្មានជំនួយមកពីព្រះដែរឬទេ? នេះគឺជាការពិតដែលយើងកើតមកក្នុងជីវិតមួយដែលអសមត្ថភាព យើងមិនអាចទៅបង្កើតការល្អណាមួយដែលធ្វើឲ្យព្រះអង្គសព្វព្រះទ័យដោយខ្លួនឯងបានទេ។ ព្រះអង្គបានស្រឡាញ់យើងដោយសារតែបំណងព្រះហឫទ័យរបស់ផងទ្រង់ ព្រះអង្គជ្រើសរើសយើងគឺទៅតាមបំណងព្រះហឫទ័យទ្រង់ហើយព្រះអង្គបានសព្វព្រះទ័យប្រទានជីវិតដល់យើងទាំងអស់គ្នាគឺទៅតាមបំណងព្រះហឫទ័យទ្រង់ មិនមែនដោយសារយើងបានបំពេញលក្ខខណ្ឌណាមួយឲ្យគ្រប់គ្រាន់ដើម្បីឲ្យយើងមានជំនឿនោះទេ។

ដូច្នេះ យើងមើល ជំនឿគឺត្រូវតែមកអំពីព្រះ មិនមែនជាជំនឿដែលកើតចេញពីយើងផ្ទាល់នោះទេ តែជាជំនឿដែលយើងឆ្លើយតបទៅកាន់ព្រះវិញ។ “ដ្បិតគឺដោយព្រះគុណ  ដែលអ្នករាល់គ្នាបានសង្គ្រោះ ដោយសារសេចក្ដីជំនឿ ហើយសេចក្ដីនោះក៏មិនមែនកើតពីអ្នករាល់គ្នាដែរ គឺជាអំណោយទានរបស់ព្រះវិញ ក៏មិនមែនដោយការប្រព្រឹត្តដែរ ក្រែងអ្នកណាអួតខ្លួន” (អេភេសូរ ២:៨-៩)។ សេចក្ដីជំនឿគឺជាអំណោយដែលព្រះអង្គបានប្រទានមកឲ្យយើងបានឆ្លើយតបទៅកាន់ព្រះអង្គដោយទទួលស្គាល់អង្គព្រះយេស៊ូវគ្រីស្ទដោយយល់ច្បាស់ខាងឯវិញ្ញាណ ហើយយើងប្រើអំណោយដែលព្រះអង្គបានប្រទានមក ដើម្បីឆ្លើយតបទៅកាន់ព្រះអង្គគឺមិនមែនជារបស់យើង។ មិនមានមនុស្សណាម្នាក់ដែលអាចប្រើជំនឿ និងការតាំងចិត្តរបស់ខ្លួនឯងដើម្បីជឿព្រះបានទេ ក៏ប៉ុន្តែជំនឿដែលប្រទាននូវជីវិតអស់កល្បជានិច្ចគឺជាជំនឿតែមួយគត់ដែលជាអំណោយរបស់ព្រះ ហើយសេចក្ដីជំនឿនោះឯងដែលប្រកាសឆ្លើយតបទៅនឹងសេចក្ដីស្រឡាញ់ដែលព្រះអង្គបានបង្ហាញ។ ជំនឿដែលយើងឈរគឺជាជំនឿដែលមកអំពីព្រះជាអំណោយទានរបស់ព្រះដែលទ្រង់បានប្រទានឲ្យយើង។

ចូរឲ្យយើងបានប្រើសេចក្ដីជំនឿនោះ ជឿលើព្រះរាជបុត្រារបស់ផងទ្រង់គឺ ព្រះ

យេស៊ូវគ្រីស្ទដែលជាព្រះតែមួយអង្គគត់ដែលអាចប្រទាននូវជីវិតអស់កល្បជានិច្ចដល់យើងទាំងអស់គ្នា។ នេះគឺជាជំនឿដែលនាំមកនូវសេចក្តីសង្គ្រោះ។ សព្វថ្ងៃនេះយើងឃើញមានព្រះនាមព្រះយេស៊ូវច្រើន តើយើងគួរជឿមួយណា? «បងប្អូនអើយ ខ្ញុំចង់ប្រាប់ឲ្យអ្នករាល់គ្នាដឹងពីដំណឹងល្អ ដែលខ្ញុំបានផ្សាយរួចមកហើយ ជាដំណឹងដែលអ្នករាល់គ្នាបានទទួល ក៏ឈរជាប់ក្នុងនោះផង អ្នករាល់គ្នាកំពុងតែបានសង្គ្រោះដោយសារដំណឹងល្អនោះផង គឺបើសិនជាកាន់ខ្ជាប់តាមព្រះបន្ទូល ដែលខ្ញុំបានថ្លែងប្រាប់មក លើកតែអ្នករាល់គ្នាបានជឿ ដោយឥតបើគិត ដ្បិតមុនដំបូង ខ្ញុំបានប្រាប់មកអ្នករាល់គ្នា តាមសេចក្តីដែលខ្ញុំបានទទួលដែរ គឺថាព្រះគ្រីស្ទបានសុគត ដោយព្រោះបាបរបស់យើងរាល់គ្នា តាមបទគម្ពីរ ហើយថា ទ្រង់ត្រូវគេបញ្ចុះក្នុងផ្នូរ រួចដល់ថ្ងៃទី៣ នោះទ្រង់មានព្រះជន្មរស់ឡើងវិញ ក៏តាមបទគម្ពីរ» (១កូរិនថូស ១៥:១-៤)។

ចម្លើយគឺថា យើងជឿព្រះយេស៊ូវគ្រីស្ទដែលប្រសូត សុគតហើយមានព្រះជន្មរស់ឡើងវិញតាមបទគម្ពីរ។ ប្រសិនបើ មានព្រះយេស៊ូវណាមួយទៀតដែលខុសពីបទគម្ពីរយើងដឹងថានោះមិនមែនជាព្រះយេស៊ូវពិតនោះទេ មិនមែនជាព្រះសង្គ្រោះទេ ប៉ុន្តែជាអ្នកដែលនាំឲ្យពួកជំនុំវង្វេងវិញ។ ដូច្នេះ ព្រះយេស៊ូវគ្រីស្ទដែលជាម្ចាស់នៃជីវិតហើយនាំឲ្យយើងទទួលបានជីវិតអស់កល្បគឺជាព្រះយេស៊ូវគ្រីស្ទដែល ប្រសូត្រ សុគតហើយមានព្រះជន្មរស់ឡើងវិញស្របតាមបទគម្ពីរ។

# លិបិក្រមតាមព្រះគម្ពីរ

## សញ្ញាចាស់


### លោកុប្បត្តិ

៣:១ ១១៧
៣:១៥ ៩

### និក្ខមនំ

៣២:៨ ១១៨

### ចោទិយកថា

៦:៤-៥ ២១
១២:៣២ ១១៩

### យ៉ូប

១៩:២៥ ៩

### ទំនុកតម្កើង

២២:១៦ ៩
១១៩:៩ ២០
១១៩:១១ ១៦

### សុភាសិត

១២:១៤ ១៣៨
១៤:១២ ១៣៨
២៩:១៣ ១២

### អេសាយ

៥៣ ៩

### អេសេគាល

៣៦:២៤-២៨ ៧៥
៣៦:២៦-២៨ ៨៨

### ហូសេ

៤:៦ ១០០, ១១២

### ហាបាគុក

២:៤ ១៨


## សញ្ញាថ្មី


### ម៉ាថាយ

១:២១ ៥, ៧
៣:១១ ១៦
៥:១៣-១៦ ១០៨
៥:៤៥ ១៣៤
៧:២៤-២៧ ១០១
១៦:១៨ ៩៤
១៦:២៤ ៤៩
២៣:២៧ ៦៤
២៨:១៩-២០ ២១, ២២, ៩៦

### ម៉ាកុស

១:១៤-១៥ ៧២

៤:១៦-១៧ ៥០
៨:៣៥ ៤៩
១២:២៩-៣១ ២១
១៦:១៥ ៩៦

**យ៉ូហាន**

១:៨-១០ ៣០
១:៩ ១៦
១:១០-១៣ ៥៩
៣:១-១០ ៧៥, ៧៦
៣:៣-៩ ៧៨
៣:១៦ ២២, ១៣៩, ១៤០
៣:១៦-២១ ១៣១
៤ ៧០
៥:១-៥ ៥៩
៥:១-៣ ៦៦
១៧:១៧ ២០
២០:៣០-៣១ ៨
២១:១៥-១៧ ៩៧, ៩៩

**កិច្ចការ**

១:៨ ៩៦
២:៣៧ ១២
២:៣៨ ១៦
៨:២៦-២៨ ២១
៩:១៦ ៤៩
១៦:២៥-៣៤ ៤១
១៦:៣១ ១៧
១៧:១១ ១០៣
១៧:២៨ ១៣៤, ១៣៤
២០ ១១៣

**រ៉ូម**

១:១៧ ១៨
១:២១-២៥ ១០៦
៤:២២ ១៨
៥:៨ ១៣៧
៥:១២-១៩ ១៣
៦ ៨៦
៧:១៨ ២៩
១០:៩ ១៥, ៦៨
១០:៩-១០ ១១
១២:១-២ ២០
១២:២ ១១២

**១កូរិនថូស**

១:២ ៩៥
១:១០-១៣ ១០៧
៩ ៥២
១២:២៧ ៩៤
១៥:១-៨ ៤៦
១៥:១-៤ ១៤២
១៥:៣-៤ ៥, ៩
១៥:១៩ ១០
១៥:២៩-៣០ ២២

**២កូរិនថូស**

៤:១-៧ ៤១, ៤៤
៤:១-២ ៤៦
៤:១៧ ៥១
៥:១១-២១ ៤៤
៥:១៤-១៥ ៤៩
៥:១៤ ៥២
៥:១៧ ៨៣
៥:២០ ៥៥
៦:២ ៥៣
១២:៩ ៣៩
១៣:៥ ៧០

## កាឡាទី

១:៦-១០ ១២០, ១២៧
១:៦-៩ ១០៩
១:១១ ១២១
២:១០ ១២១
២:១១ ១២២
២:១៦ ១២៤
២:១៦-២១ ១២៤
២:២០-២១ ១២៤
៣:២-៣ ៣០
៣:៨ ១៧
៣:១១ ១៨

## អេភេសូរ

១:១១ ១១
២ ៨៦
២:១-៣ ៨៤
២:៨-៩ ១៤១
៤:១១- ១១៣
៤:១៤ ១០៣
៤:១៥-១៦ ៩៤

## ភីលីព

១:២៧ ៣១

## កូឡូស

១:១៨ ៩៤
១:២០ ៨
២:១៣-១៥ ១៨
៣:១០ ៨៤

## ១ថែស្សាឡូនីច

១:៤-១០ ៦១
១:៩-១០ ៥៩, ៦៧

## ២ថែស្សាឡូនីច

២:៣ ១០៥

## ១ធីម៉ូថេ

៤ ២៧
៤:១ ១០៣
៤:១៦ ១២៥

## ២ធីម៉ូថេ

១:១៥ ៣៨
២:៨ ៣៣
២:១៥ ២៩, ១០២
៣:១៣-១៤ ៣៦
៤:២ ៣២, ១១២
៤:៦ ២៧

## ទីតុស

២:១ ១១៣
៣:៩-១១ ១០៧

## ហេព្រើរ

៣ ៥៣
១០:៣៨ ១៨

## យ៉ាកុប

២:១៧ ៦៩
៥:១៩-២០ ១២៩

## ១ពេត្រុស

១:១៦ ១៥
១:២២-២៣ ៥៩
៣:១៨ ៨
៥:២ ៩៩, ៩៩

## ២ពេត្រុស

២:១-៣ ១១១

**១យ៉ូហាន**

១:៨-១០ ៣០
១:៩ ១៦
៤ ៧០
៥:១-៣ ៦៦
៥:១-៥ ៥៩

**វិវរណៈ**

៣:១៥-១៧ ១០៩
២២:១៨-១៩ ១២៧